# នរណាជា ឃាតករភាសាខ្មែរ?

ដោយ

**ហ៊ិន ស៊ីថាន**

អតីតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ
វិទ្យាល័យនេតយ៉ង់ ( បាត់ដំបង )
អតីតសមាជិកសមាគមអ្នកស្រាវជ្រាវឯកសារខេត្តបាត់ដំបង

គ.ស. ១៩៨៦ ព.ស. ២៥២៩

(រក្សាសិទ្ធិគ្រប់យ៉ាង)

# សូមឧទ្ទិសចំពោះ

វិញ្ញាណក្ខ័ន្ធលោកឪពុក ហ៊ិន-និមស៊ា, អ្នកម្តាយ លុត-សាវ៉ាត, ប្អូនប្រុស ហ៊ិន-ស៊ីធន, ហ៊ិន-ស៊ីហ៊ិន, ហ៊ិន-ចាន់ថា, ប្អូនស្រី ហ៊ិន-ចាន់ធី, ក្មួយប្រុស ហ៊ិន-រ៉េាហារ ដែលត្រូវបនខ្មែរក្រហម ប៉ុល-ពត, អៀង-សារី, ខៀវ-សំផន, នួន-ជា បានធ្វើឃាតទាំងខ្លោចផ្សារ ។

វិញ្ញាណក្ខ័ន្ធខ្មែរជាងបីលាននាក់ ដែលស្លាប់ទៅទាំងបីទភ្នែកមិនជិត ។

វិញ្ញាណក្ខ័ន្ធព្រះគ្រូ ប៉ាង-ខាត់, ព្រះវន្តរត្ន ប៉ុណ្ណ-សំភាជ ដែលពួកទមិឡបានធ្វើគត លោកនៅមុខក្រសួងឃោសនាការភ្នំពេញ និងនៅវាលចំណតយន្តហោះបែកចាន-បាត់ដំបង ។

សូមឧទ្ទិសឯលវិញ្ញាណក្ខ័ន្ធអស់លោកអ្នកស្នេហាជាតិទាំងឡាយ មានលោកស៊ឹង -ង៉ុកថាញ់ ដែលបានលះបង់អ្វីៗគ្រប់យ៉ាង រហូតឯល់ជីវិតផ្ទាល់ខ្លួន ដើម្បីសេរីភាព ដើម្បីរាស្ត្រខ្មែរ ដើម្បីស្រោចស្រង់ស្រុកខ្មែរពីក្រញ៉ាំកុម្មុយនិស្តនិងពីគោលដៅសហភាពឥណ្ឌូចិនរបស់យួនហូ-ជីមិញ ។

សូមឧទ្ទិសឯលវិញ្ញាណក្ខ័ន្ធព្រះគ្រូអាចារ្យហែម-ចៀវ ដែលបានបូជាជីវិតនៅកោះត្រឡាចក្រោមអំណាចអាណានិគមបារាំង, លោកអៀវ-កើស ដែលស្លាប់ដោយគ្រាប់បែកពួកសក្តិភូមិ ។

សូមឧទ្ទិសឯលវិញ្ញាណក្ខ័ន្ធលោកឧកញ្ញាក្រឡាហោមគង់, លោកឧកញ្ញាពិស្ណុលោកឈូកដែលបានបាត់បង់ជីវិត ដោយសារស្នាដៃខ្មែរខ្ញុំបារាំង យកលោកទៅឲ្យបារាំងសម្លាប់ ។

សូមឧទ្ទិសឯលវិញ្ញាណក្ខ័ន្ធលោកឧកញ្ញាសឺន-គុយ ដែលបូជាជីវិតដើម្បីសុំឲ្យយួនព្រមទុកទំនៀមទំលាប់ វប្បធម៌ និងពុទ្ធសាសនាឯល់ខ្មែរក្រោមទាំងអស់ ។

និងខ្មែរស្នេហាជាតិទាំងឡាយទៀត ដែលបានបូជាជីវិតដើម្បីប្រទេសជាតិពិតៗ ។

# សេចក្តីថ្លែងអំណរគុណ

*សូមថ្លែងសេចក្តីអំណរគុណដល់បណ្ឌិត ខារ៉ុល ម៉រ័ឡែន* **(Dr. Carol A. Martland)** *និងកញ្ញា ជូឌី ឡេជ័រវុដ* **(Miss Judy Legerwood)** *ដែលបានជួយសំរួលខ្ញុំ បានចូលទៅស្រាវជ្រាវឯកសារក្នុងបណ្ណាល័យក័រណែល និងបានផ្តល់ដល់ខ្ញុំនូវឯកសារមួយចំនួនធំ ជាពិសេសបានផ្តល់ថាសកម្មវិធីអក្សរខ្មែរ សំរាប់ប្រើក្នុងកំព្យូទ័រម៉ាក់ឃិនតូសនេះ ។*

*សូមថ្លែងអំណរគុណដល់លោក ស៊ឹម-គិន ដែលបានជួយជំរុញឲ្យសំនេរនេះមានរូបរាងនិងបានចំណាយប្រាក់កាសផ្ទាល់ទិញកុំព្យូទ័រដើម្បីសរសេរអក្សរខ្មែរនេះ ព្រមទាំងបានផ្តល់ពត៌មានផ្សេងៗ ពីកាលគាត់ធ្វើបដិវត្តន៍ខ្មែរសេរីនៅភ្នំដងរែកជាមួយលោកស៊ឹង-ង៉ុកថាញ់ ។*

*សូមថ្លែងសេចក្តីដឹងគុណដល់អស់លោកអ្នកទាំងអស់ ដែលបានផ្តល់ពត៌មានផ្សេងៗ ដែលមាននាមនៅក្នុងអត្ថបទនេះ ។*

*សូមថ្លែងអំណរគុណដល់លោកបណ្ឌិត កុល-ផេង ដែលបានផ្តល់ថាស់ប្រើកម្មវិធីគណិតូបករណ៍សំរាប់អក្សរខ្មែរដល់ខ្ញុំ ។*

❊ ❊

❊

# កំណត់ស្មេរ

ទោះជានៅសម័យណាក៏ដោយ ឆ្នាំណាក៏ដោយ ក្នុងរបបដឹកនាំស្រុកខ្មែរណាមួយក៏ដោយ បើស្មេររស់នៅក្នុងស្រុកខ្មែរ សំនេរបែបនេះមិនអាចសរសេរបានសោះឡើ-យ សំនេរបានសរសេរឡើងដោយគ្មានឥទ្ធិពលអ្វី ក្រុមបក្សណាមួយ ឬបុគ្គលណាមួ-យមកគ្រប់សង្កត់លើសន្តានចិត្តគំនិតស្មេរឡើយ គឺបានសរសេរក្នុងសេរីភាព១០០% តាមការយល់ឃើញ និងពិចារណាដិតដល់របស់ស្មេរផ្ទាល់ ។

សៀវភៅ « នរណាជាឃាតកររាស្ត្រខ្មែរ » នេះខ្ញុំបានសរសេរយ៉ាងបន្ទាន់ និងស្រូតជាទីបំផុត អស់កំឡុងជាងប្រាំមួយខែ ដើម្បីឲ្យទាន់តាមកាលបរិច្ឆេទដែលត្រូវផ្ញើសំណៅទៅចូលរួមប្រកួតក្នុង « ទិវាមហោស្រពខ្មែរឆ្នាំ១៩៨៧ » នាក្រុងឡុងប៊ីចរដ្ឋកាលីហ្វ័រនិញ៉ា ហេតុនេះហើយបានជាមានតក់ កង្វះសេចក្តី ខ្វះពត៌មាន ឯជំពូកក្រោយៗ ខ្ញុំបានកាត់បន្ថយបំព្រួញសេចក្តីឲ្យខ្លីចុះ ។ សរសេរចប់ក៏ផ្ញើចេញភ្លាមដោយគ្មានពេលផ្ទៀងផ្ទាត់មើលសារឡើងវិញឡើយ ទើបមានកំហុសអក្ខរាវិរុទ្ធិ នាមឈ្មោះខ្លះ ព្រមទាំងខែឆ្នាំនៃព្រឹត្តិការណ៍ខ្លះផង ។

សំណេរនេះ ខ្ញុំបានផ្ញើទៅឲ្យព្រឹត្តិប័ត្រ « ទស្សនខ្មែរ » រដ្ឋមីនីសូតាចុះផ្សាយរហូតឆ្នាំ១៩៨៩ទើបចប់។ មានមិត្តអ្នកអានជាច្រើនបានសុំឲ្យបោះពុម្ពសៀវភៅនេះទុកជាឯកសារ ។ ដោយសារខ្ញុំជាប់រវល់ខ្លាំងក្នុងសំនេរទីបីឈ្មោះ « កាលប្រវត្តិវិទ្យានៃប្រ-ទេសកម្ពុជា » ដែលលាតត្រដាងបកអាក្រាត នូវគោលបំណង ផែនការ និងគោលដៅមេដឹកនាំយួនក្នុងការលេបស្រុកខ្មែរ តើបបង្អង់សិន រហូតដល់ខែធ្នូឆ្នាំ១៩៨៩ ទើបខ្ញុំសើរើអានឡើងវិញ សាកសួរយកពត៌មាន កែសំរួល កែនាមឈ្មោះ អក្ខរាវិរុទ្ធិ ខែឆ្នាំដែលបានសរសេរខុស ជាពិសេសថែមបញ្ចូលពត៌មានជាច្រើនទៀត ដូចជាទំព័រ ២៧ ឡើងជាប្រាំពីរទំព័រ, ទំព័រ១១៥ឡើងជាប្រាំទំព័រជាដើម, ឯជំពូក៥, ៦, ៧ បានសរសេរសារជាថ្មី ដោយខ្ញុំរក្សាទុកចំណងជើងនិងជំពូកដដែល កែដកចេញតែកំហុ-សប៉ុណ្ណោះដូចជាលោកម៉ែនកែនផែនដី ក្រោយពីសាកសួរមក គឺជាមនុស្សដែលលោកស៊ឹង-ង៉ុកថាញ់បានបញ្ជូនមកខាងកំពង់ធំ ពុំមែនជាឥស្សរៈក្លែងក្លាយនោះទេ ហេតុនេះហើយទើបខ្ញុំដកសេចក្តីត្រង់នេះចេញ និងថែមបញ្ចូលនូវផលវិបាកពួកខ្មែរឥស្សរៈ មកលើគ្រួសារស្មេរ ដើម្បីជាបន្ទាល់ក្នុងសម័យដែលស្មេរបានឮ បានឃើញនិងបានរស់នៅផង ។

នៅភាគខាងក្រោយ ខ្ញុំបានបន្ថែមអក្ខរានុក្រម ( Glossary ) និងជំពូកបន្ថែមដែលជាអត្ថបទវិចារណកថាខ្លីៗ យោងតាមព្រឹត្តិការណ៍សកលលោក ចំពោះរឿងសន្តិភាពប្រទេសខ្មែរ ដែលបានចុះផ្សាយក្នុងព្រិត្តិប័ត្រទស្សនខ្មែររដ្ឋមីនីសូតា ។

មួយទៀតឈ្មោះ ឡុង-រ៉ឺត ជាឈ្មោះនួន-ជា ជាជាតិថៃ ( សម័យថៃយកបាត់ដំ-បងឆ្នាំ១៩៤១-៤៦ ) កាលជននេះទៅរៀនស្រុកសៀមនោះ សូមមេត្តាកែជា រុង-លើត វិញ ព្រោះសំនៀងភាសាថៃ ខ្យល់ « រ » មានសំលេងទៅជា « ល » ទើបអ្នកខ្លះហៅឈ្មោះនេះថា « លុង-លើត » ទៅវិញ ។

អរគុណ

ហ៊ិន-ស៊ីថាន

# អារម្ភកថា

ការនិរាសព្រាត់ប្រាស់ដោយការកាប់សម្លាប់រង្គាលនៃបងប្អូនខ្មែរ អនុវត្តដោយក្រុមខ្មែរក្រហមចិននិយម រហូតដល់រលាយអស់ស្រុកទៅទៀតទៅហើយនេះ តើមិនទាន់គ្រប់គ្រាន់ល្មមនឹងឲ្យខ្មែរគ្រប់គ្នាភ្ញាក់ត្រិះរិះពិចារណា រកបុព្វហេតុពិតនៃគ្រោះមហន្តរាយនេះដើម្បីជាមេរៀន និងជាគោលការណ៍រួបរួមឡើងវិញឬ ?

ខ្មែរម្នាក់ៗសុទ្ធតែធ្លាប់បានភ័ក្ស បានប្រទះ និងខ្លះទៀតបានទាំងជួយជំរុញដល់គ្រោះមហន្តរាយនេះផង ខ្លះជួយដោយអចេតនា ខ្លះទៀតដោយចេតនាតែម្តង។

សំនេរនេះគ្រាន់តែជាការសាកល្បងស្រាវជ្រាវ ពិចារណា សិក្សារកការពិតពីបុព្វហេតុ ឫសគល់ ទំនាក់ទំនងផ្សេងៗ ដែលជាបច្ច័យ ជាកត្តាធ្វើឲ្យខ្មែរស្លាប់អស់ជាងបីលាននាក់ និងនៅទីបញ្ចប់ស្រុកខ្មែរក៏ត្រូវយួនត្រួតត្រា និងធ្វើយួនូបនិយកម្មថែមទៀត ដែលជាដំណើរឈានទៅរកការបាត់បង់ទឹកដីនិងជាតិសាសន៍ខ្មែរជាពិតប្រាកដពេកណាស់ ស្របទៅតាមនិក្ខេបបទរបស់លោកនួន-ឃឿន ក្នុងដំណើរឆ្ពោះទៅទិសខាងលិច ឬឥណ្ឌូចិនក្នុងឆ្នាំ២,០០០ ខុសតែត្រង់មហន្តរាយនេះកើតឡើងមុនការទស្សន៍ទាយរបស់លោកប៉ុណ្ណោះ ។ លោកអធិការបឋមសិក្សាអ៊ិត-សារិនក៏បានសរសេរពីការភ័ន្តច្រឡំនយោបាយ ពីគំរោងបំផ្លាញសង្គមនិងស្រុកខ្មែរដោយខ្មែរប្រហម ក្នុងសៀវភៅ « ស្រណោះព្រលឹងខ្មែរ » ក្នុងឆ្នាំ១៩៧៣ ដែលគ្មាននរណាភ្ញាក់ផ្អើលសោះ ។ ក្រៅពីឯកសារសរសេរដោយស្នេហ៍ជាតិខ្មែរ និងបរទេសនានា ខ្ញុំបានធ្វើការទាក់ទងផ្ទាល់ ដោយសម្ភាសន៍ផង និយាយទូរស័ព្ទផង ថតចូលក្នុងខ្សែអាត់ផង សរសេរឆ្លើយឆ្លងផង ដើម្បីយកពត៌មានមកបញ្ជាក់អះអាងនូវព្រឹត្តិការណ៍ផ្សេងៗ ដែលបានសន្និដ្ឋានថាជាបុព្វហេតុនៃមហន្តរាយនៃការព្រាត់ប្រាស់និរាសរបស់ខ្មែរទាំងនគរនេះ ។

តាំងពីបានចូលជំរំខៅ អ៊ីដាងថ្ងៃទី២១ វិច្ឆិកា ១៩៧៩ម៉្លេះ ខ្ញុំបានគ្រោងទុកថានឹងសរសេរពីរឿងរ៉ាវនៃការកាប់សម្លាប់ខ្មែរនេះឲ្យបាន ។ ខ្ញុំក៏ចាប់ស្រាវជ្រាវសន្សំឯកសារទុកបណ្តើរៗមកដោយសុំថតចម្លងសៀវភៅរបស់មិត្តភ័ក្តិខ្លះ របស់បណ្ណាល័យក្នុងជំរំនិងបណ្ណាល័យនៅក្រុងតាខ្មៅខ្លះ តែភាគច្រើនបានសុំថតចម្លងឯកសារពីបណ្ណាល័យនៃមហាវិទ្យាល័យគ័រណែល ( University Library Cornell ) នៅទីក្រុងអ៊ីតាកា ( Ithaca ) រដ្ឋនីវយ៉ក ( New York ) សហរដ្ឋអាមេរិក ។

សំនេរនេះខ្ញុំចែកចេញជាប្រាំពីរជំពូករួមទាំងជំពូកយោបល់ផង ។

ជំពូកទីមួយបរិយាយរៀបរាប់រំលឹកពីផែនការយួនូបនិយកម្មក្នុងរាជ្យក្សត្រីអង្គម៉ី ឬដំណើរឆ្ពោះមកទិសខាងលិចលើកទីមួយ ឬផែនការរបស់ព្រះចៅមិញ-ម៉ាង, ទ្រៀង-មិញយ៉ាង, ព្រះចៅយ៉ា-ឡុង និងយួនូបនិយកម្មដែនដីកម្ពុជាក្រោម ។

ជំពូកទីពីរ គឺរំលឹកពីប្រវត្តិសាស្ត្រសម័យចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ពីការបះបោរ អាចារ្យស្វា ពោរកំបោរ ( ដណ្តើមរាជ្យ ), ការតស៊ូប្រឆាំងបារាំងរបស់លោកឧកញ៉ាពិស្ណុលោកឈ្យូក និងឧកញ៉ាក្រឡាហោមគង់ ដោយការគាំទ្រពីព្រះបាទនរោត្តម រហូតដល់ព្រឹត្តិការណ៍ឆ្នាំ១៩១៦, ព្រឹត្តិការណ៍ឆ្នាំ១៩២៥ ឬព្រឹត្តិការណ៍បាដេ ( Bardez ), ព្រឹត្តិការណ៍ឆ្នាំ១៩៤២ បាតុកម្មព្រះសង្ឃទាមទារឲ្យ

ដោះលែងព្រះគ្រូហែម-ចៀវ, ចលនារំដោះជាតិ « ខ្មែរឥស្សរៈ » ពោលគឺវគ្គបរិ-
យាយពីគំនិតស្នេហាជាតិដំបូង ។

ជំពូកទីបីបរិយាយពីផែនការរបស់ហូ-ជីមិញ ក្នុងការលេបប្រទេសកម្ពុជា និ
ិងលាវ ដើម្បីសំរេចនូវការស្ថាបនាមហាចក្រយួន ហៅថា « សហព័ន្ធឥណ្ឌូចិន »។
ការបង្កើតខ្មែរយៀកមិញ, ផែនការយួនយៀកមិញក្នុងរវាងឆ្នាំ១៩៤៥-៥០ ។ ជំពូក
នេះពិពណ៌នាអំពីផែនការនៃដំណើរឆ្ពោះមកទិសខាងលិចលើកទី២ របស់យួនហូ
ជីមិញ ក្នុងគោលដៅបង្កើត «សហភាពកុម្មុយនិស្តឥណ្ឌូចិន» ។

ជំពូកទីបួនអធិប្បាយពីនយោបាយខុសរបស់សម្តេចសីហនុ ចាប់ពីឆ្នាំ១៩៦២
មក ដោយឃុបឃិតជាមួយចិន ជួយទ័ពយៀកកុង ដោយផ្តល់ស្បៀង អង្ករ ថ្នាំពេ
ទ្យ ដោយមានចិនម្នាក់ឈ្មោះគួច-អាន រកស៊ីផ្តាច់មុខដឹកអង្ករថ្នាំពេទ្យ ដោយមាន
ការអនុញ្ញាតពីសម្តេច និងការចូលហ៊ុនដោយក្រុមរាជវង្សានុវង្សខ្លះ និងអ្នកម្នាងម៉ូ
និចផង ។ ការអនុញ្ញាតឲ្យដឹកអាវុធ គ្រាប់រំសេវ កាំភ្លើងធំ ដោយមាននាយទាហាន
ខ្មែរជួយចាត់ចែងដំលើង និងដឹកនាំយកទៅឲ្យយៀកកុង ក្រោមព្រះរាជបញ្ជារប-
ស់សម្តេចសីហនុ ។ សេដ្ឋកិច្ចស្មុះ ប្រជាពលរដ្ឋខ្វះអង្ករបរិភោគ ការសង្កត់សង្កិន
របស់អាជ្ញាធរខេត្តបាត់ដំបងទៅលើប្រជាជនតំបន់សំឡូត រហូតឲ្យមានការបះបោរ
ឡើង និងកំណើតចលនាខ្មែរក្រហមកុម្មុយនិស្តម៉ៅនិយមហួសហេតុ ។

ជំពូកទីប្រាំបរិយាយជុំវិញបុព្វហេតុ ដែលបណ្តាលឲ្យមានការទម្លាក់សម្តេច
ការប៉ុនប៉ងរបស់សម្តេចដើម្បីកាន់អំណាចវិញ ការពីឃាតដ៏អាថ៌កំបាំងលើរូបលោ
កវរៈសេនិយឯក សេង-ស៊ុនថៃ ។ ការវាយលុករបស់ទ័ពយៀកកុងមកលើសាធា
រណរដ្ឋលោកលន់-នល់ ។ រណសិរ្សរំដោះជាតិគាំទ្រដោយយៀកកុង និងមានស
ម្តេចជាប្រធានតែគ្មានអំណាចចាត់ចែង សីហនុចាញ់បោកចិន, យួន និងខ្មែរក្រ-
ហម ។

ជំពូកទីប្រាំមួយស្តីពីលទ្ធផលរបស់ហូ-ជីមិញ ។ ការកំទេចអន្ទាក់ទី១របស់
យួន តែប៉ុល-ពតបានធ្លាក់ចូលទៅក្នុងអន្ទាក់ទី២របស់យួនទៀតដោយមិនដឹងខ្លួន
។ ការសំរេចនៃគោលបំណងរបស់ហូ-ជីមិញ ឬដំណើឆ្ពោះមកទិសខាងលិចលើ
កទី២ដោយសុវត្ថិភាព និងផែនការយួនូបនិយកម្មលើប្រជារាស្ត្រខ្មែរលើប្រទេស
ខ្មែរ ។

ជំពូកទីប្រាំពីរគឺជំពូកយោបល់ ការសាកល្បងវែកញែករកមុខឃាតកររាស្ត្រ
ខ្មែរជាងបីលាននាក់ និងការប្រមើមើលចំពោះនយោបាយបច្ចុប្បន្ន និងអនាគតរប
ស់មាតុប្រទេសខ្មែរ ។ តើប្រទេសខ្មែរនឹងត្រូវបាត់បង់ពីផែនទីសកលលោកដូចចំ
ប៉ាឬ ?

ស្មេរខ្ញុំសូមអោនកាយអភ័យទោសពីសំណាក់បងៗ និងជនខ្មែរទាំងអស់
ទោះបីបានលាចាកលោកនេះទៅហើយក្តី ឬក៏នៅមានជីវិតរស់នៅសព្វថ្ងៃនៅឡើ-
យក្តី ដែលមាននាមក្នុងអត្ថបទនេះ សូមមេត្តាខន្តីសន្តោសដល់ខ្ញុំបាទ ដែលគ្រាន់
តែចង់លាតត្រដាងនូវការពិតខ្លះៗ និងបុព្វហេតុនៃមហន្តរាយនេះតែប៉ុណ្ណោះ គ្រា
ន់ជាពន្លឺដល់ប្អូនៗជំនាន់ក្រោយ ឬបើហោចណាស់គ្រាន់ទុកជាមេរៀន ដើម្បីកុំឲ្យ
មេដឹកនាំខ្មែរដើរជាន់ដានប្រវត្តិសាស្ត្រគ្រោះថ្នាក់មហន្តរាយដដែលៗបែបនេះទៀ

តទៅអនាគតកាល ។

ទោះជាយ៉ាងណាក៏ដោយ កំហុសក្នុងការសរសេរ ការភ្លាំងភ្លាត់ ការសន្និដ្ឋានមិនសមរម្យ តែងតែមានចៀសមិនរួច ព្រោះថាមនុស្សម្នាក់ៗមិនមែនសុទ្ធតែយល់ត្រូវហូតមិនដែលខុសនោះទេ L'homme n'est pas parfait ។ អាស្រ័យហេតុនេះ សូមបងប្អូនមិត្តអ្នកអានមេត្តាអភ័យទោសដោយអនុគ្រោះដល់ខ្ញុំបាទ ។

ក្រុងស៊ីអាថិល, ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨៦

**ហ៊ិន–ស៊ីថាន**

# សេចក្ដីផ្ដើម

ពេលនេះប្រទេសខ្មែរបានទទួលគ្រោះមហន្តរាយដ៏ធំលើសលប់ ដោយស្លាប់អស់ខ្មែរជាងបីលាន ព្រមទាំងអស់ទាំងស្រុកខ្មែរទៅទៀត ព្រោះតែរបបខ្មែរក្រហមដែលបានរំលាយកំទេចជាតិសាសន៍ និងវប្បធម៌របស់ខ្មែរតាមគោលបំណងរបស់យួន ដែលពួកគេបានអនុវត្តរួចម្ដងមកហើយ កាលនៅរាជ្យក្សត្រីអង្គម៉ីឆ្នាំ១៨៤០ ។ យួនបានបញ្ជាឲ្យព្រះសង្ឃខ្មែរស្លៀកពាក់ដូចព្រះសង្ឃយួន, ឲ្យមន្ត្រីខ្មែរប្រជារាស្ត្រខ្មែរស្លៀកពាក់ដូចយួន, រៀនភាសាយួន, ឲ្យកាប់ដើមពោធិ, រំលាយព្រះ, បំផ្លាញវត្តអារាម ដូចដែលពួកខ្មែរក្រហមបានធ្វើមកក្នុងពេលថ្មីៗកន្លងមកនេះ ។ កាលណោះយួនធ្វើផ្ទាល់ តែដល់មករាជ្យប៉ុល–ពត គឺក្រុមខ្មែរវង្វេងឈ្លក់នឹងទ្រឹស្តីកាល់ម៉ាក–ម៉ៅនិយមហួសហេតុនេះ បានរំលាយគ្រឹះសង្គមខ្មែរ, វប្បធម៌និងប្រទេសខ្មែរខ្លួនឯង គ្មានប្រទេសណាមួយលើសកលលោកធ្វើបានដូចនៅឡើយ ។ ប្រជារាស្ត្រខ្មែរជិត៥០ភាគរយត្រូវគេសម្លាប់ចោល ។ ក្រុមខ្មែរគំនិតយួននេះរហូតមកដល់សព្វថ្ងៃ(១៩៨៧)គេនៅតែថា ពួកគេមិនបានសម្លាប់ខ្មែរទេ គឺពួកក្បត់ទេដែលបានសម្លាប់ខ្មែរ ( សំដីរបស់ជួន–ជឿន ដែលចូលមកក្នុងជំរំខៅអ៊ីដាង នៅថ្ងៃដំបូងទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៩ ) ។

( កកន ៖ នៅថ្ងៃសុំចុះចូលជាមួយរដ្ឋាភិបាលហ៊ុន–សែន កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨... ខៀវ–សំផនបានសារភាពថា ៖ ក្រុមខ្មែរក្រហមរបស់ខ្លួនបានប្រព្រឹត្តអំពើសម្លាប់រង្គាលទៅលើប្រជាពលរដ្ឋខ្មែរពិតប្រាកដមែន ។ គាត់បាននិយាយសុំទោស និងសុំឲ្យប្រជាពលរដ្ឋខ្មែរ « បំភ្លេចអតិតកាលចោលទៅ » ។ ភ្លាមមួយរំពេជ, នាយករដ្ឋមន្ត្រីខ្មែរហ៊ុន–សែនបានថ្លែងបញ្ជាក់ បន្ទាប់ពីបានទទួលយល់ព្រមការចុះចូលថា ៖ ខ្មែរគួរលើកលែងទោស ដើម្បីសន្តិភាពនិងការសំរុះសំរួលជាតិទាំងមូល ! ។ នេះហើយជាភស្តុតាងយ៉ាងច្បាស់ បញ្ជាក់អំពីកល្បល្បិចនិងការស៊ីគ្រលុំគ្នា រវាងពួកខ្មែរក្រហមទាំងពីរក្រុមដែលជាអាយ៉ងរបស់ចិន–យួន ) ។

គ្មានគ្រួសារខ្មែរណាមួយដែលថាមិនមានសាច់ញាតិ, ឪពុកម្ដាយ, បងប្អូនប្រុសស្រីឬអ៊ំមាមីង ស្លាប់ដោយសារស្នាដៃខ្មែរក្រហមប៉ុល–ពតសោះ ។ គ្រួសារខ្លះសល់តែម្នាក់ ខ្លះមួយគ្រួសារត្រូវស្លាប់ទាំងអស់ ។ ជាឧទាហរណ៍ ប្រជាជនខ្មែរជាងដប់ពីរម៉ឺននាក់ដែលខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ហើយយកមកប្រោ

សចោលនៅវាលភ្នំធិបតីនោះ ត្រូវស្លាប់វិនាសសឹងតែទាំងអស់ ។ ពេលដែលយួន ឈ្លានពានចូលមកយកស្រុកខ្មែរកាលពីដើមឆ្នាំ១៩៧៩នោះ ខ្មែរអ្នកភ្នំពេញនៅវា-លភ្នំធិបតីនៅរស់តែប្រមាណជាងបីពាន់នាក់ប៉ុណ្ណោះ ។ ឆ្អឹងខ្មោចខ្មែរនៅចោល រាត់រាយពេញវាលពេញគុម្ពស្បូវ រណ្តៅខ្លះមានខ្មោចពីប្រាំរយនាក់ទៅពីរពាន់នាក់ ទាំងចាស់ ក្មេង ទារកបីទទឹង ។

គេសម្លាប់ដោយគ្រប់វិធី ដែលភាសាក្រហមគេនិយាយថាគ្រប់រូបភាព គឺចាប់ យកត្រង់ៗទៅសម្លាប់ ឬដាក់ឃុំក្នុងមន្ទីរដោយធ្វើទារុណកម្មសព្វបែបយ៉ាងរហូត ដល់ស្លាប់ និងវិធីបង្អត់បាយឲ្យដាច់ពោះស្លាប់យ៉ាងសែនវេទនា ។ល។...

សំនេរនេះជាការសាកល្បងស្រាវជ្រាវ ពិចារណារកធាតុពិតនិងបុព្វហេតុផ្សេងៗ ដែលជាសារវន្តនាំឲ្យប្រជារាស្ត្រខ្មែរត្រូវស្លាប់វិនាស ព្រាត់ប្រាស់និរាសអស់ ខ្ទង់ប្រមាណជាងបីលាននាក់នេះ ។

សំនេរនេះគ្រាន់តែចង់លាតត្រដាងនូវការពិតខ្លះៗដែលមេដឹកនាំខ្មែរខំបំបិទ ខំលាក់ខំសរសេរដើម្បីលាងខ្លួនពីការថ្កោលទោសពីសំណាក់កូនខ្មែរជំនាន់ក្រោ-យ, ពីការដាក់ទោសរបស់ប្រវត្តិសាស្ត្រខ្មែរ និងប្រវត្តិសាស្ត្រសកលលោក ។

អនិច្ចាស្រុកខ្មែរ តើថ្ងៃណាទើបខ្មែរមានមេដឹកនាំដែលចេះគិតដល់ជីវភាពរា-ស្ត្រខ្មែរ ដល់ការគង់វង់នៃប្រទេសខ្មែរ !

យើងខ្វះមេដឹកនាំ ផ្ទុយទៅវិញមេដឹកនាំវៀតណាមបានធ្វើបរិច្ចាគគ្រប់យ៉ាង ដើម្បីស្រុកគេ ឲ្យប្រទេសគេរីកធំទូលាយ !

# សន្ធិសញ្ញាកាត់បន្ថយព្រំដែនខ្មែរ

**សន្ធិសញ្ញាចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ ៖**

ជាសន្ធិសញ្ញាសហប្រតិបត្តិការក្នុងរយៈ២០ឆ្នាំ ហើយនិងបន្ថយជាសម្ងាត់ក្នុង រវាង១០ឆ្នាំម្តង ។ ត្រង់ខទី៤នៃសន្ធិសញ្ញានេះ បញ្ជាក់ពីការកំរិតព្រំដែនមិត្តភាព ដែលគ្រោងថានឹងពិនិត្យពិភាក្សាឡើងវិញ ដោយយកព្រំដែនបច្ចុប្បន្នធ្វើជាគោល

**សន្ធិសញ្ញាចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨២ ៖**

ជាសន្ធិសញ្ញាកាត់បន្ថយដែនសមុទ្រខ្មែរក្នុងតំបន់កោះសេះ ដែលជាតំបន់មា នប្រេងកាត ។ របបហេងសំរិន-ហ៊ុនសែនបានប្រគល់ទៅឲ្យយួន ។

**សន្ធិសញ្ញាចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣ ៖**

ស្តីពីការកាត់បន្ថយព្រមដែនខ្មែរប្រគល់ទៅវៀតណាមជាថ្មីទៀត ។

**ឆ្នាំ១៩៨៤ ៖**

ឡេ-ឌឹកថូ សមាជិកការិយាល័យនយោបាយយួនបានមកធ្វើទស្សនកិច្ចនៅ កម្ពុជា ហើយបានពន្យល់ណែនាំហេងសំរិន-ហ៊ុនសែនថា ៖ គោងមានគ្រួសារយួ នមួយគ្រួក្នុងចំណោមគ្រួសារខ្មែរបួនគ្រួនៅទីជនបទ និងគ្រួសារយួនមួយគ្រួក្នុង ចំណោមគ្រួសារខ្មែរពីរគ្រួនៅតាមទីប្រជុំជននិងតាមទីក្រុងនានា ។

**សន្ធិសញ្ញាខែធ្នូ ឆ្នាំ១៩៨៥ ៖**

សន្ធិសញ្ញាកំណត់ព្រំដែនបន្ថយដីខ្មែរជាថ្មីទៀត និងការយល់ព្រមឲ្យនិគមយួ នចូលមកតាំងទីលំនៅលើដែនដីខ្មែរ ដោយឲ្យខ្មែរជួយផ្គត់ផ្គង់សព្វយ៉ាងដល់និគ-

មយួនថ្មីៗនេះ មានការយកផ្ទះខ្មែរ (ដេញម្ចាស់ចេញ) ដកដីធ្លីឲ្យទៅនិគមយួនទាំងនោះផង ។

**ឆ្នាំ១៩៨៥ ៖**

មេដឹកនាំវៀតណាមបានប្រកាសថា សន្ធិសញ្ញាមួយស្តីពីការលប់ចំបាត់ព្រំដែនរវាងវៀតណាមនិងកម្ពុជា ។ សន្ធិសញ្ញានេះជាមធ្យោបាយរបស់វៀតណាមឲ្យនិគមយួនថ្មីៗចូលមកតាំងទីលំនៅដោយស្របច្បាប់លើទឹកដីខ្មែរ ថែមលើចំនួននិគមយួនចាស់ជិតពីរលាននាក់កាលពីមិនទាន់មានសន្ធិសញ្ញានេះ ។

**សន្ធិសញ្ញាចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៨ ៖**

ហ៊ុន-សែននិងង្វៀង-កូថាច់បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ដែលស្តីពីការរកដំណោះស្រាយវិវាទព្រំប្រទល់ដែន រវាងសាធារណរដ្ឋសង្គមនិយមវៀត-ណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយទៀតស្តីពីលក្ខន្តិកៈព្រំដែនថ្មីនៃប្រទេសទាំងពីរ ។

**ឆ្នាំ១៩៩១ ៖**

និគមយួនក្នុងស្រុកខ្មែរមានចំនួនឡើងដល់បីលាននាក់ហើយ ៗបានទទួលសញ្ជាតិជាជាតិកម្ពុជា ពីរបបអាយ៉ងហេងសំរិន-ហ៊ុនសែនថែមទៀត ។

ចាប់ពីមាត់សមុទ្រឡើងរហូតទៅដល់ព្រំរួមបីមុម (ខ្មែរ-លាវ-យួន) គេបានបង្ខិតបង្គោលសីមាព្រំដែនចម្ងាយពី៣ទៅ៨គីឡូម៉ែត្រ ចូលមកក្នុងដីខ្មែរ ។ កន្លែងខ្លះបង្ខិតចូលដល់ទៅ៣០គីឡូម៉ែត្រផង ។

ពេលថ្មីៗនេះ តាមរយៈរូបភាពផ្កាយរណប (Satellite) ដែលអាមេរិកាំងថតបានៗបញ្ជាក់ថា វៀតណាមបានបង្ខិតព្រំដែនខ្មែរជាថ្មី ដោយបានជីកព្រែកមួយទទឹង២៥ម៉ែត្រ ចម្ងាយ៥៥០គីឡូម៉ែត្រ តាមបណ្តោយព្រំដែនខេត្តកំពត កាត់តាមខេត្តតាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម ។ ប្រជារាស្ត្រខ្មែរក៏ត្រូវជាប់កំណែនជាមួយរាស្ត្រយួន ក្នុងការដ្ឋានជីកព្រែក «វិញតេទី២» នេះដែរ ។ ក្នុងពេលអប់រំនយោបាយពួកអាយ៉ងហេង-សំរិន គ្រូយួនបានពន្យល់ណែនាំឲ្យពួកហេង-សំរិនយោគយល់អធ្យាស្រ័យដល់ព្រំដែនថ្មីរវាងវៀតណាម-កម្ពុជានេះ សុំកុំឲ្យនឹកគិតទៅដល់ព្រំដែនចាស់ធ្វើអ្វី ។

---

# ការបំផ្លាញសម្បត្តិសិល្បៈវត្ថុបុរាណវប្បធម៌ខ្មែរ

ក្នុងរបបប៉ុល-ពតកំឡុងបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ឯកសារអក្សរសាស្ត្រខ្មែរត្រូវបនខ្មែរក្រហមបំផ្លាញចោលខ្ទេចខ្ទី ដោយឲ្យប្រមូលយកតាមគ្រប់វត្តអារាម នូវក្រាំងគម្ពីរ សាស្ត្រាស្លឹករឹត ចំណារពុទ្ធសាសនា កំណាព្យទូន្មាន រឿងសាស្ត្រាល្បែង សាស្ត្រារឿងបុរាណនានា ( សាស្ត្រាស្លឹករឹតពួកអាចមិនឡបញ្ជាឲ្យយកទៅដេរធ្វើមួកពាក់ស្ទូងនិងច្រូតស្រូវ... ឯក្រាំងក្រាស់ៗក្រដាស់ធ្វើអំពីសំបកមន វាប្រមូល

យកទៅដុតចោល... ឯសៀវភៅវិញពួកវាឲ្យមូរបារីជក់ និងយកទៅគរដុតចោល ( តាមផ្លូវបាត់ដំបង-ស៊ីសុផុន-ចំការចេក ) ជាពិសេសសាស្ត្រាចារពីប្រវត្តិសាស្ត្រខ្មែរ ដែលពុំទាន់បានធ្វើការសិក្សាស្រាវជ្រាវនៅឡើយ តាមទីស្ថានសំខាន់ៗខ្លះដូចជា តាមវត្តអារាមតំបន់ថ្មពួក បន្ទាយឆ្មារ... តាមវត្តអារាមខាងតាកែវ អង្គរបូរី, បាភ្នំ, វត្តហារ, កាច់រទេះ (ចំណារពីប្រវត្តិថៅពញាសង្គ្រាមហុក, វត្តត្រៀល រំលង (ចំណារពីរឿងរបស់ឧកញាតេជោមាស ឮតេជោក្រហមក)...ជាដើម ។ សម្បត្តិអក្សរសាស្ត្រនេះ គួរឲ្យសោកស្តាយជាពន់ពេក និងរករកអ្វីមកប្រៀបពុំបាន ។ តាំងពីរាប់រយឆ្នាំមកហើយ ទោះបីមានចំបាំងរាំងជល់ថយ៉ាងណាក៏ដោយ ក៏សម្បត្តិវប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រទាំងអស់នោះ បាននៅគង់វង់តាមវត្តអារាមនានារហូតមក។ របបពួកឆ្វេងនិយមហួសហេតុលីលាពុលក្តួចខុសគេមួយសកលលោក ដឹកនាំស្រុកមិនដល់បួនឆ្នាំផង ក៏បញ្ជាឲ្យបំផ្លិចបំផ្លាញនូវកេរ្តិ៍មរតកជាតិខ្មែរទាំងនោះអស់រលីង ។ កេរ្តិ៍មរតកខាងឯកសារអស់ទាំងនោះ យើងមិនអាចនឹងរកមកវិញបានសោះឡើយ ។

រឿងគួរឲ្យអាណោចអធ៌មមួយទៀត គឺសម្បត្តិសិល្បៈ ចម្លាក់ថ្ម រូបបដិមាករ តាមប្រាសាទបុរេអង្គរនានា ត្រូវបំផ្លិចបំផ្លាញដូចតទៅ ៖

**១- <u>សម័យខ្មែរឥស្សរៈ</u> ៖**

ពួកអតិខ្មែរឥស្សរៈបាននិយាយថា ក្នុងការតស៊ូជាមួយបារាំង ពួកគេបានគាស់យកបុរាណវត្ថុបដិមាតាមបុរាណស្ថានបុរេអង្គរក្នុងតំបន់រនាមដូនសំ បាត់ដំបង ឧត្តរមានជ័យ យកទៅលក់ឲ្យឈ្មួញសៀម យកលុយទៅទិញកាំភ្លើងច្បាំងជាមួយបារាំងខ្លះ និងទុកជាសម្បត្តិផ្ទាល់របស់មេខ្មែរឥស្សរៈធ្វើជាអ្នកមាន ។

**២- <u>សម័យសីហនុ-លន់នល់</u> ៖**

ចៅហ្វាយអនុខេត្តបន្ទាយឆ្មារ ហ៊ុល-ទន, តាមសេចក្តីប្រកាសឲ្យការណ៍របសលោកស្មិក-យេ ( នាយចំណង់នៅថ្មពួកឆ្នាំ១៩៧១-៧២ ), បានឲ្យទាហានគាស់យកបដិមាករស្អាតៗ តាមបុរាណប្រាសាទនានាទៅលក់ឲ្យពួកសៀម ។ ក្នុងរបបរកស៊ីបំផ្លាញជាតិ ក្បត់ជាតិនេះ គេមានធ្វើលានសំងាត់សំរាប់ឧទ្ធម្ភាគចក្រចុះនៅក្នុងព្រៃជិតបន្ទាយឆ្មារ ។ ពេលយប់ទើបឧទ្ធម្ភាគចក្រសៀមចុះមកដឹកយកបដិមាករខ្មែរនោះ ។ ក្នុងរឿងលួចបុរាណវត្ថុខ្មែរនេះមានចៅហ្វាយខេត្តសេក-សំអៀត បានចូលហ៊ុនជាមួយផង ។ ជនណា ទាហានណាដែលដឹងរឿងនេះ ត្រូវហ៊ុល-ទនឲ្យពេជ្ឈឃាតយកទៅក្របែលចោលអស់ ។ តាមសំដីលោកស្មិក-យេ ថាហ៊ុល ទនបានសម្លាប់បំបឹទមាត់កូនទាហាននិងអ្នកស្រុកអស់ច្រើនណាស់ ។ លោកស្មិក យេបានបន្ថែមថា ហ៊ុល-ទនជាជនក្បត់ជាតិ បំផ្លាញជាតិលេខ១ ។ ដោយការកាប់សម្លាប់បំបឹទមាត់ និងអំណាចផ្តាច់ការខ្លាំងពេកនោះនៅចុងឆ្នាំ១៩៧២ ទាហានក៏បះបោររកសម្លាប់ហ៊ុល-ទនចោល តែមេពុករលួយសេក-សំអៀត (១) បានយកឧទ្ធម្ភាគចក្រទៅចុះនៅថ្មពួករំដោះកូនជីងខ្លួននេះ រួចហើយយកទៅដាក់ឲ្យលួចជាតិនៅបរប៉ៃលិនទៀត ។ ជននេះឯងដែលក៏បបំបាត់យកត្បូងទំងន់ជាងបីរយការ៉ាតនោះ ។

ព្រះកេសព្រះពុទ្ធរូបប្រកនាគបីអង្គនៅក្នុងប្រាង្គកំពូលភ្នំបាណន់ និងក្បាលអ

សុរៈទ្វារបាលត្រូវគេលួច ។ នៅជិតភូមិអូរប្រាសាទ នាយទាហានស័ក្តិប្រាំបាននាំទាហានទៅប្លន់យករូបតាព្រហ្មនិងព្រះភគនេស ។ កូនប្រាសាទបុរេអង្គរមួយនៅក្នុងដុបព្រៃ ទល់មុខបន្ទាយសឹករងស៊ីសុផុន ត្រូវពួកទាហានគាស់យកបដិមាការ។

នៅថ្មពួក ចម្ងាយពីរគីឡូម៉ែត្រពីព្រំដែន កូនប្រាសាទបុរេអង្គរជាប្រាង្គថ្មទាំងមូលមួយត្រូវសៀមយកឧទ្ធម្ភាគចក្រមកស្ទូចយកទៅតំរៀបនៅក្នុងដីសៀមទៅ ក្នុងសម័យព្រះអង្គខ្មៅ ឬឧកញ្ញាកថាថនសេក-សំអៀត ។

៣- សម័យខ្មែរក្រហម ៖

ពួកខ្មែរក្រហម តាមទ្រឹស្តីបដិវត្តន៍វប្បធម៌របស់ចិកម៉ៅ (ឪខ្មែរក្រហម) ពួកទមិឡនេះបានបំផ្លាញសម្បត្តិបូរាណនេះយ៉ាងច្រើនឥតគណនា ។ ពួកវាប្រមូលយកតាមវត្តអារាមនូវបដិមាករតូចធំ ដឹកតាមឡានទ្រុងយកទៅដូរអំបិលជាមួយសៀម ឬប្រេងឥន្ធនៈ ។ វត្តបូរាណបាណន់ក្រោមមានបូរាណវត្ថុជាច្រើន មានបដិមាព្រះពុទ្ធរូបប្រកនាគពីរឆ្លាក់ពីថ្មភក់ ( Sandstone ) កំពស់ពីរម៉ែត្រ តាំងពីសតវត្សទី១៤មកម្លេះ និងបដិមាករជាច្រើនទៀតតំកល់ទុកក្នុងវិហារ ។ ក្នុងបរិវេណវត្តមានបូរាណវត្ថុជាច្រើន មានព្រះពុទ្ធរូបសល់តែភ្លែនទំហំប៉ុនព្រះពុទ្ធរូបនៅប្រាសាតបាលិឡៃ ព្រោះទីស្ថានបាណន់ជាកន្លែងដែលព្រះបាទជ័យវរ្ម័នទី៧បានកសាងឧទ្ទិសដល់ពុទ្ធសាសនា ក្រោយពីបង្រ្កាបការបះបោរនៅតំបន់នេះរាបទាបមក ។ ពួកខ្មែរក្រហមបានរើសយកពុទ្ធរូបតូចៗទៅដូរសៀមយកអំបិល យកប្រេងសាំងម៉ាស៊ូត ឯបដិមាករធំៗពួកវាវាយកំទេចចោល ជញ្ជូនយកទៅចាក់ចោលក្នុងស្ទឹងព្រោះពួកជនសាមាន្យអស់នេះវាត្រូវការយកព្រះវិហារទៅធ្វើជាមន្ទីរពិសោធន៍ ពេទ្យវះពោះមនុស្សរស់ ឲ្យសិស្សពេទ្យល្ងិតល្ងង់វា សិក្សាពីវិជ្ជាពេទ្យជាក់ស្តែង ។ សារមន្ទីរវត្តពោធិវាល ត្រូវពួកវារើបំផ្លាញយកបូរាណវត្ថុទៅដូរសៀម យកវិហារធ្វើជាមន្ទីរឃុំឃាំង...។ ប្រាសាទវត្តឯកភ្នំដែលជាស្នាដៃព្រះបាទឧទយាទិត្យវរ្ម័នកសាងក្នុងឆ្នាំ៩១០ បានត្រូវពួកទមិឡអន្តរធានអស់នេះ យកធ្វើជាគុកឃុំឃាំងខ្មែរដែលពួកវាចាត់ទុកថាជាសំណល់ពុករលួយនៃរបបសង្គមចាស់ ឯជញ្ជាំងធ្វើពីថ្មបាយក្រៀមផ្នែកខាងត្បូងប្រាសាទត្រូវពួកវារើគាស់វាយបំបែកយកទៅចាក់ក្រាលថ្នល់ពីវត្តឯកភ្នំមកពាមឯក មកទីប្រជុំជនដូនទាវ ។ ការបំផ្លិចបំផ្លាញវត្ថុបូរាណប្រាសាទបូរាណខ្មែរ វត្តអារាមបានធ្វើឡើងទូទាំងប្រទេសខ្មែរ គឺជាការបំផ្លាញគ្រឹះសង្គមខ្មែរឲ្យសាបសូន្យបង់ សមតាមបំណងរបស់មេដឹកនាំយួនហូ-ជីមិញតែម្តង ។

៤- សម័យយួន-ហេងសំរិន / ហ៊ុនសែន ៖

ពួកយួនបានរើយកសម្បត្តិគរុភ័ណ្ឌតាមវត្តនានា រូវចម្លាក់តាមប្រាសាទទន្លេបាទី, ភ្នំជីសូរ, អង្គរបូរី... សារមន្ទីរសាលារចនាដឹកយកទៅស្រុកវាបឹងបន្តយកទៅលក់នៅហុងកុង ពួកហេង-សំរិនក៏លួចគាស់យកបូរាណវត្ថុយកទៅលក់ឲ្យសៀម-យួនដែរ ។ ពួកយួនបានគាស់យកកោដិមាសនៅចេតិយតំកល់ព្រះសារីរិកធាតុនៅមុខស្ថានិយរថភ្លើងក្រុងភ្នំពេញ ។ ពួកវាលួចយកក្បាលព្រហ្មពីក្នុងសារមន្ទីរវត្តពោធិវាល...។

៥- ពួកចលនាតស៊ូខ្មែរ ៖

មេពួកចលនាតស៊ូរប៉េះរប៉ោះតាំងពីឆ្នាំ១៩៧៨មក សុទ្ធតែរស់ដោយឲ្យពួកទាហានគាស់យកបូរាណវត្ថុតាមប្រាសាទនានាទៅលក់ឲ្យសៀម ប្លន់រាស្ត្រយកមាសពេជ្រ ។ កូនទាហានរបស់ស៊្វី-ធឿន, សព្វថ្ងៃរស់ក្រុងតាកូម៉ា (រដ្ឋវ៉ាស៊ីនតោន)បាននិយាយថា ៖ ស៊្វី-ធឿនបានឲ្យទាហានចុះទៅគាស់មកបដិមា ឬវាយយកព្រះកេស (ក្បាលអ្នកតា) យកមកលក់ឲ្យសៀម ។ សព្វថៃទាហានរ.ជ.រ.ប.ខ.ខ្លះកំពុងតែបំផ្លិចបំផ្លាញគាស់យកបូរាណវត្ថុពីប្រាសាទនានាទៅលក់ឲ្យសៀមដែរ ដូចជាឧត្តមសេនិយទ្បៃ-វិរៈ រួមជាមួយទាហានវរសេនិយទោវិបុល ទៅគាស់បូរាណវត្ថុនៅប្រាសាទយាងដង្គំ (សារពត៌មានអង្គរបូរី ចុះថ្ងៃទី៣១ មករា ១៩៩១), លោកកែមថែង, ស័ក្តិបួនស៊ីថា, ឈ្មោះឆៃ និងលោកផ្កាយមួយឃួន-រឿន បានគាស់យករូបបដិមាលោកកេតេស្វរៈព្រហស្កប្រាំ កំពស់ពីរម៉ែត្រពីរតឹក ទៅលក់តថ្លៃជាមួយថៃជាតម្លៃ៧លានបាត (សារពត៌មានអង្គរបូរីចុះថ្ងៃទី៣១ មករា ១៩៩១) ជាដើម...។

កូនសម្តេចសីហនុ, នរោត្តម-ចក្រពង្ស, ក៏ជាមេខាងបំផ្លាញវត្ថុបុរាណខ្មែរម្នាក់ដែរ ដោយបញ្ជាឲ្យកូនទាហានទៅគាស់យកបុរាណវត្ថុតាមប្រាសាទនានា មកលក់ឲ្យពួកឈ្មួញសៀម ។ ទិញផ្ទះតម្លៃ១លានបាតនៅសុរិនឲ្យប្រពន្ធជាតិថៃ ( ប្រពន្ធទី៦ ) ប្រពន្ធប្រាំទៀតនិងកូននៅប៉ារីស៍ ។

<u>កំណត់</u> ៖ តំបន់ភាគខាងលិចខេត្តបាត់ដំបង ថ្មពួក សំបូរដោយបូរាណប្រាសាទបុរេអង្គរជាច្រើន ខ្ពង់ជិតប្រាំរយកន្លែង ។ ប្រាសាទបុរេអង្គរអស់ទាំងនោះច្រើនកសាងពីឥដ្ឋ ត្រូវបាក់បែករលំគរជាពំនូក ជាទួលអ្នកតា កប់ទាំងរូបបដិមាករនៅក្នុងពំនូកនោះ ។ ទីបូរាណស្ថានអស់ទាំងនោះនៅពុំទាន់បានធ្វើកំណាយស្រាវជ្រាវនៅឡើយក្នុងសម័យកោះសន្តិភាពរបបសម្តេចសីហនុនោះ ។ សៀមតែងតែចូលមកលួចជីកគាស់យកបូរាណវត្ថុតាមប្រាសាទអស់នោះជារឿយៗដូចជា ប្រាសាទកំពែងព្រាវចម្ងាយខ្ពង់ដប់គីឡូម៉ែត្រខាងលិចស្វាយចេក, ប្រាសាទមេបុណ្យ, ប្រាសាទបន្ទាយទាបក្នុងក្រុមប្រាសាទបន្ទាយឆ្មារជាដើម...។

បើខ្មែរគ្រប់គ្នា គ្រប់របប គ្រប់និន្នាការនាំគ្នាបំផ្លាញជាតិឯងយ៉ាងនេះ តើពួកគេនាំគ្នាទៅរំដោះជាតិ ឬក៏នាំគ្នាទៅរំដោះយកអំណាចដើម្បីបំផ្លាញជាតិ ?

(១) ជាជនពុករលួយជាងគេមួយក្នុងរបបសាធារណរដ្ឋលន់-នល់ រកស៊ី (មិនបាច់មានដើមទុន) រត់ពន្ធជាមួយនាយទុនធំៗនៅបាត់ដំបងដឹកទាំងទូរទេះភ្លើង រកស៊ីជាមួយសុង-សាក់ក្នុងការកាប់ព្រៃឈើខ្មែរយកទៅលក់នៅស្រុកសៀម មេលួចបុរាណវត្ថុខ្មែរទៅលក់ឲ្យឈ្មួញសៀម ។ ដោយពុករលួយខ្លាំងពេកក៏ត្រូវផ្លាស់ចេញក្នុងឆ្នាំ១៩៧៤ (ជំនួសដោយឧត្តមសេនិយសរ-ហោរ) តែបាននិយាយប្រាប់ពួកនាយទុននៅបាត់ដំបង រដ្ឋការខេត្តនានា គ្រូបង្រៀនថា ខ្ញុំនឹងវិលត្រឡប់មកវិញជាចៅហ្វាយខេត្តបាត់ដំបងដដែល ។ មែនសេក-សំអៀតបានវិលមកវិញនៅដើមឆ្នាំ១៩៧៥ ពុករលួយលើសដើម ។ ជាចៅហ្វាយខេត្តជួយទ័ពសម្តេចឪ (ពួកខ្មែរក្រហម) ដោយដឹកកាំភ្លើង គ្រាប់រាល់ៗខែ ទៅផ្តល់ឲ្យខ្មែរក្រហម ពី៨ទៅ១០ឡាន GMC ទាហាន ។ ជាពេជ្ឈឃាតសំលាប់បំបឹទមាត់រាស្ត្រខ្មែរ ជនណាដែលដឹងពីអំពើក្បត់ជាតិរបស់សេក-សំអៀត នឹងត្រូវពួកដៃដល់ក្របែលចោល ដូចជាកូនទាហានពីរនាក់នៅបន្ទាយព្រៃជ្រូក (ផ្លូវពីស៊ីសុផុនទៅក្រឡាញ់) ដែលហ៊ានសួរមេបញ្ជាការឈ្មោះម៉ា-អួន ពីរឿងដឹកកាំភ្លើងនិងគ្រាប់ចូលទៅក្នុងតំបន់ខ្មាំង ។ ជាជនល្មោភស្រី, ក្នុងការិយាល័យខេត្ត សេក-សំអៀតមានលេខាធិការផ្ទាល់ខ្លួន សុទ្ធជាស្រីក្មេងៗចំនួន៧នាក់, មានប្រពន្ធចុងថ្វានៅចំការសំរោង, ឲ្យគេរកស្រីៗយកមកឲ្យដូចជាកូនកាត់ចិនយួននៅផ្សារ

ក្រោម ផ្លូវលេខពីរកន្លះ យកមកឲ្យសេក-សំអៀតក្នុងល្ខោចមួយនៅម៉ូតែលខេត្តក្រោយសាលាទក្សិណ ( ល្ខោចនោះស្មេរកំពុងអង្គុយលេងនៅជើងម៉ាថ្មមុខផ្ទះជួល, ផ្ទះលោកម៉ាត់-រឿមអ្នកធ្វើកាតចិនឃួន ) ។ តាមញ៉ៅរសាស្រ្តាចារ្យកូលាប-សាលីវត្តតែមិនបាន  តែបានសាស្រ្តាចារ្យចេញឆ្នាំ១៩៧៣ម្នាក់នៅវិទ្យាល័យអ៊ាប-ឃុតទៅវិញ ។ ទាក់ទងបានអ្នកគ្រូបឋមសិក្សាម្នាក់ឈ្មោះតាន់-យក់ស៊ានទៅទក្សិណសាលា ( Eco le primaire groupe sud ) ទល់មុខវត្តកំផែងហើយទិញផ្ទះនៅកាច់ជ្រុងសាលាទក្សិណ និងផ្លូវទៅបរ-ប៉ៃលិន និងកូនឡានហុងដាមួយឲ្យទៀតផង ។ ដោយសារជននេះប្រើអំណាចជិះជាន់ផ្តាច់ការ ដូចជាស្តេចត្រាញ់ដាប-ឈួន ឬកថាថនឈុំ (ស្តេចត្រាញ់ចុងក្រោយបង្អស់, តំណាទី៥នៃត្រកូលថៅហ្វាបែន ដែនបាត់ដំបង ចង្វាត់បូព៌ានៃរាជាណាចក្រថៃ) នោះទើបសេក-សំអៀត មានរហស្សនាមក្រៅមួយទៀត ដែលអ្នកបាត់ដំបងដាក់ឲ្យថា ព្រះអង្គខ្មៅ ។

# ជំពូកទី១

# រំលឹកប្រវត្តិសាស្ត្រ

ដោយសារតែជម្លោះរវាងរាជវង្សក្សត្រខ្មែរ ដែលចង់សោយរាជ្យ ទើបបណ្តាលឲ្យមានការជ្រៀតជ្រែកពីបរទេសជិតខាង ដែលចូលមកជួយច្បាំងដណ្តើមរាជ្យឲ្យក្សត្រខ្មែរ រួចហើយទារយកសរគុណ ដោយសុំយកខេត្តនេះ-ខេត្តនោះទៅជារបស់សៀមឬរបស់យួន ។ ប្រទេសខ្មែរក្នុងសតវត្សទី១៨-១៩ បានក្លាយទៅជាព្រលានចំបាំងរវាងទ័ពសៀមនិងទ័ពយួន ។ ប្រជារាស្ត្រស្លាប់ហិនហោចព្រាត់បងប្អូន កូនចៅគ្មានពេលល្ហែ ។ ពេលសៀមថយទៅស្រុកវិញ សៀមតែងតែគៀរយកគ្រួខ្មែរ ប្លន់ប្រមូលយកភោគទ្រព្យខ្មែរមិនដែលខាន ។ ក្នុងអតីតកាល រាស្ត្រខ្មែរមិនដែលស្គាល់សន្តិភាពសោះ ។

ដោយសារព្រះរាជាអង្គចន្ទចងស្ពានមេត្រីនឹងយួន ទើបនាំឲ្យព្រះអនុជអង្គអិម និងព្រះអង្គដួងភៀសរត់ទៅប្រទេសសៀម ។ ព្រះចៅអធិរាជយួនមិញ-ម៉ាងបានចាត់មេទ័ពឈ្មោះទ្រឿង-មិញយ៉ាង នាំទ័ពចូលមកតាំងនៅក្នុងស្រុកខ្មែរ តាមសេចក្តីសុំរបស់ស្តេចខ្មែរអង្គចន្ទ ដើម្បីការពារអំណាចស្តេចនេះក្រែងទ័ពថៃចូលមកយាយី ។

ព្រះចៅយួនមានបំណងនឹងយកស្រុកខ្មែរទាំងមូលធ្វើជាដែនដីយួន ទុកជារនាំងដើម្បីទប់ទល់ជាមួយសៀម ដែលកាលណោះក៏ជាអាណាចក្រខ្លាំងពូកែមួយដែរ នៅក្នុងអាស៊ីភាគអគ្នេយ៍ ។ មិនគ្រាន់តែមានកោលបំណងចង់យកស្រុកខ្មែរប៉ុណ្ណោះទេ ស្តេចយួនបានរៀបចំផែនការ ធ្វើយួនូបនិយកម្មលើប្រជារាស្ត្រខ្មែរ បំបាត់វប្បធម៌ អារិយធម៌ ព្រះពុទ្ធសាសនាថេរវាទ អក្សរសាស្ត្រ របៀបស្លៀកពាក់ ពោលគឺយួនត្រូវតែបំបាត់នូវអ្វីៗទាំងអស់ដែលជាខ្មែរចោលចេញ ហើយបង្ខំឲ្យខ្មែរសិក្សាភាសាយួនថែមទៀត ដើម្បីសំរួលដល់ការទាក់ទង ។ ក្នុងឯកសារយួនគេហៅខ្មែរថា អានារ្យជន ( Barbarians ) គឺជនដែលមិនស្គាល់អារ្យធម៌រុងរឿង ឬ ជនព្រៃផ្សៃ ។

ការលើកយកប្រវត្តិសាស្ត្រត្រង់វគ្គនេះមកភ្ជាប់ជាបឋមហេតុក្នុងការសរសេរនេះ គឺខ្ញុំមានគោលបំណងចង់ឲ្យខ្មែរទាំងអស់ យល់និងបានដឹងឲ្យច្បាស់ថា យួនបានរៀបចំនិងបំបាត់ជាតិខ្មែរ លេបស្រុកខ្មែរ រំលាយវប្បធម៌ខ្មែរច្បាស់ណាស់ ។ ហើយថែមពីលើនេះទៀត ខ្ញុំចង់បង្ហាញថា យួនគេបានសិក្សា ធ្វើវិភាគនូវការបរាជ័យរបស់ដូនតាគេ ក្នុងការដែលធ្វើយួនូបនិយកម្មមិនសំរេច មកលើប្រទេសខ្មែរក្នុងឆ្នាំ១៨៤០ ។ ហេតុនេះហើយ ទើបមេដឹកនាំយួនហូ-ជីមិញ បានរៀបចំផែនការធ្វើយួនូបនិយកម្មប្រទេសខ្មែរសារជាថ្មីម្តងទៀត ដែលមានចែងនៅក្នុងបណ្តាំហូ-ជីមិញ ( Ho's testament ) ក្នុងគោលដៅត្រួតត្រាអាស៊ីអគ្នេយ៍ទាំងមូល ។

ហេតុដែលខ្ញុំលើកយកប្រវត្តិសាស្ត្រត្រង់ណោះមករំលឹក ព្រោះចង់បង្ហាញពីគោលបំណងពិតប្រាកដរបស់យួនមកលើស្រុកខ្មែរ ។ កាលនោះព្រះចៅយួនបានចេញរាជបញ្ជាឲ្យមេទ័ពយួនអនុវត្តផែនការយួនូបនិយកម្មលើប្រជារាស្ត្រខ្មែរ និង

ប្រទេសខ្មែរ ដែលឯកសារយួនបានសរសេរពីព្រះរាជបញ្ជាមិញ-ម៉ាងទៅទ័ពព្រះអង្គ (១) ថា ៖

ពួកអនារ្យជន (ក្នុងស្រុកខ្មែរ ) បានក្លាយមកជាកូនចៅរបស់យើងហើយឥឡូវនេះ ហើយលោកត្រូវតែជួយពួកគេ ហើយបង្រៀនគេអំពីទំនៀមទម្លាប់របស់យើង... ជាឧទាហរណ៍, យើងបានឮមកថា ដី(កសិកម្ម)សំបូរហើយមានជីវជាតិណាស់ ហើយសំបូរគោ(សំរាប់ភ្ជួរ)... ប៉ុន្តែប្រជាជនគ្មានការចេះដឹងពីកសិកម្ម(ទាន់សម័យ)សោះ, គេប្រើតែចបត្រសេះ ចបកាប់ ជាជាងប្រើកម្លាំងគោ ។ គេធ្វើស្រែដែលគ្រប់គ្រាន់ឲ្យគេបរិភោគពីរដងក្នុងមួយថ្ងៃ តែគេមិនស្តុកស្រូវទុកទេ ។ វត្ថុដែលត្រូវការចាំបាច់រាល់ថ្ងៃដូចជា សំពត់អាវ, សូត្រ, ទា និងជ្រូកថ្លៃខ្លាំងណាស់...។ វត្ថុកំរអស់នេះ គឺបណ្តាលមកពីខ្មែរខ្ជិល... ហើយបញ្ជារបស់យើងចំពោះលោកគឺ បង្រៀនពួកគេឲ្យចេះប្រើគោ, បង្រៀនពួកគេឲ្យចេះបង្កើនផលស្រូវឲ្យបានច្រើន, បង្រៀនពួកគេឲ្យចេះដាំដើមមន, ចេះចិញ្ចឹមជ្រូកនិងទា...។ ហើយចំពោះភាសាវិញលោកត្រូវតែបង្រៀនពួកគេឲ្យចេះនិយាយភាសាវៀតណាម ។ (របៀប)ស្លៀកពាក់និងប្រើតុតាមទំនៀមយើង ក៏ត្រូវតែពួកគេធ្វើតាមដែរ ។ បើសិនជាមានទំនៀមទំលាប់ណាហួសសម័យ ឬជាទំនៀមទំលាប់ដែលព្រៃផ្សៃ ក៏គួរតែកែសំរួល ឬក៏បង្ក្រាបកុំឲ្យដើររួច (1) ។

---

# យួនូបនិយកម្ម
# ឬដំណើរឆ្ពោះមកទិសខាងលិច

ក្រោយដែលព្រះអង្គចន្ទសុគតដោយរោគចុះមួលក្នុងឆ្នាំ១៨៣៤(២) លើព្រះទីនាំងនាវាកំពង់កោះស្លាកែតមក មេទ័ពយួនអុងលៅឬទ្រឿង-មិញយ៉ាង បានលើកក្សត្រីអង្គមី ជាបុត្រីបន្ទាប់ឲ្យឡើងសោយរាជ្យ ដោយមិនយកក្សត្រីបែនបុត្រីទី១ទេ ព្រោះគេចោទថាក្បត់ ដោយព្រះមាតារត់ទៅសៀមជាមួយព្រះអង្គអិមនិងព្រះអង្គដួង ។

លោក David P. Chandler បានស្រង់ឯកសារយួនដែលស្តីពីការលើកក្សត្រីអង្គមីនេះ ត្រង់ទំព័រ១២៥ថា ៖ « ដើម្បីធ្វើជាអធិបតីក្នុងការតែងតាំងក្សត្រីអង្គមីនេះ ស្តេចយួនមិញម៉ាង បានបញ្ជូនមន្ត្រីយួនមកពីក្រុងព្រៃនគរ ហើយនៅក្នុងរោងពិធីដែលគេសង់ឡើងដើម្បីប្រារព្ធការតែងតាំងនោះ ក្សត្រីអង្គមីព្រមទាំងអានុជទាំងអស់ត្រូវឈរបែរព្រះភក្រ្តឆ្ពោះទៅទិសខាងជើង ប្រឈមនិងព្រះរាជសាររបស់ស្តេចយួនដែលអនុញ្ញាតឲ្យព្រះនាងសោយរាជ្យ ។ ក្នុងពេលនោះតំណាងនិងអស់មន្ត្រីយួនឈរបែរមុខទៅទិសខាងត្បូង ដូចដែលព្រះចៅអធិរាជយួនតែងធ្វើយ៉ាងនេះ នៅក្នុងព្រះរាជវាំងព្រះអង្គឯក្រុងហ្វេនោះ » ។

កាលបានឡើងសោយរាជក្នុងឆ្នាំ១៨៣៥ នោះព្រះនាងគ្មានអំណាចអ្វីសោះ

(១) អ្នកប្រវត្តិសាស្ត្របស្ចឹមប្រទេសស្គាល់ថា ឈ្មោះទ្រឿង-មិញយ៉ាង តែឯកសារខ្មែរស្គាល់ថាឈ្មោះង្វៀង-យ៉ាំងធុយ ( Nguyen Van Thuy ) ហៅក្រៅថា អុងលៅៗ ។

(២) ឯកសារមហាបុរសខ្មែរទំព័រ១០៨៤ ឯសៀវភៅលោកដេវីដ-ឆាន់ល័រថា ឆ្នាំ១៨៣៥ ។

ការចាត់ចែងកិច្ចការផែនដី គឺពួកសេនាបតីដែលស្ថិតនៅក្រោមការត្រួតត្រារបស់ទ្រឿង-មិញយ៉ាងទាំងអស់ ។ ទ្រឿង-មិញយ៉ាងបានតាំងបន្ទាយត្រួតត្រានៅភ្នំពេញ ហើយត្រិះរិះរកតែឱកាសល្អដើម្បីយកប្រទេសកម្ពុជាទៅធ្វើជាស្រុករបស់យួនប៉ុណ្ណោះ (2) ។

អុងលៅក៏ចាប់អនុវត្តផែនការយុទ្ធបនិយកម្មរបស់ព្រះចៅមិញ-ម៉ាង ។ ដើម្បីសំរេចកិច្ចការនេះ ស្តេចយួនបានដាក់ទ័ពយួនចំនួន៥០,០០០(ប្រាំម៉ឺន)នាក់ត្រួតត្រាលើស្រុកខ្មែរ មានបន្ទាយធំនៅភ្នំពេញ និងនៅខេត្តពោធិសាត់ ។

កាលបើដូច្នេះ អំណាចផែនដីទាំងមូលក៏ធ្លាក់មកលើកណ្តាប់ដៃយួនទាំងអស់ (៣)។ យួនបានបញ្ចេញអំណាចយ៉ាងឃោរឃៅមកលើរាស្ត្រខ្មែរ គឺបង្ខំមន្ត្រីខ្មែរឲ្យស្លៀកពាក់ជាយួន ឲ្យរាជការខ្មែររកស្បៀងអាហារចិញ្ចឹមទាហានយួន យួនបានបៀតបៀនយាយីព្រះពុទ្ធសាសនា ដេញព្រះសង្ឃខ្មែរឲ្យចុះចេញពីវត្ត (3) ឲ្យព្រះសង្ឃខ្មែរស្លៀកពាក់ដូចព្រះសង្ឃយួន ឲ្យកាប់ដើមពោធិ រំលាយវត្តអារាមខ្មែរយកទៅសង់វិហារយួន បំផ្លាញព្រះពុទ្ធបដិមាករ ឲ្យរាស្ត្រខ្មែរមន្ត្រីខ្មែររៀនភាសាយួន និងស្លៀកពាក់តាមយួន ( ជាឧទាហរណ៍ គឺសំណល់អាវបំពង់វែង ដែលស្រីខ្មែរមិនវះចំហៀងដូចជាអាវផាយស្រីយួនទេ បែរជាដេរភ្ជិតជាប់គ្នាទៅវិញ ខ្មែរខ្លះយល់ច្រឡំថាជាអាវខ្មែរបូរាណ ) យួនផ្លាស់ឈ្មោះទីក្រុងភ្នំពេញ ឲ្យហៅថា « ណាំយ៉ាង » (4) គឺយួនរៀបចំរំលាយវប្បធម៌ អក្សរសាស្ត្រ ទំនៀមទំលាប់ខ្មែរ និងសាសនាខ្មែរជាមុន ព្រោះវាជាគ្រឹះដែលទ្រទ្រង់នូវការរស់រានរបស់ប្រជាជាតិខ្មែរនិងប្រទេសខ្មែរ ។

ក្នុងការអនុវត្តន៍ផែនការនេះ យួនបានបញ្ជូនស្នងការនយោបាយដប់ប្រាំមួយនាក់ ក្រុមការចិតសិបនាក់ និងគ្រូដប់នាក់មកភ្នំពេញ ដើម្បីរៀបចំស្នូលនៃផ្នែករដ្ឋបាលត្រួតត្រាស្រុកខ្មែរ ។ គេចែកផែនការគេជាបួនវគ្គ ៖

វគ្គទី១- គឺរៀបចំខេត្តខ្មែរជាថ្មី ដោយដកចៅហ្វាយខេត្តខ្មែរចេញ រួចដាក់ចៅហ្វាយខេត្តជាយួន ។ ស្រុកខ្មែរក្លាយទៅជាខេត្តយួនហៅថា ត្រាន់ តាយថាញ់ ។ ខេត្តទាំងអស់ត្រូវដូរឈ្មោះខ្មែរចេញ ហើយដាក់ឈ្មោះជាពាក្យយួនជំនួសវិញ ។ ក្នុងការរៀបចំនេះ យួនត្រូវរកឲ្យមានស្នងការថ្នាក់ទាបខ្ពង់ម្ភៃនាក់ ដែលមានចំណេះខាងធ្វើស្រែ និងខាងវិជ្ជាជានាយទាហាន ដើម្បីដឹកនាំរាស្ត្រខ្មែរ និងដឹកនាំត្រួតត្រាខេត្តខ្មែរទាំងអស់ ។

វគ្គទី២- គឺបើកផែនការវាយសំរុកពង្រីកបង្កបង្កើនផល, បង្ហាត់ពលទាហានខ្មែរឲ្យបានច្រើនសំរាប់ទប់នឹងសៀម និងស្តុកស្រូវទុកឲ្យបានច្រើនដើម្បីចិញ្ចឹមកងទ័ពយួន ។

វគ្គទី៣- ការបង្រៀនខ្មែរឲ្យចេះភាសាយួន ដើម្បីសំរួលដល់ការទាក់ទងគ្នា ។

វគ្គទី៤- គឺជាការជំរុញផែនការធ្វើអាណានិគមស្រុកខ្មែរ ដោយយកនិគមជនចិន និងអ្នកទោសយួន ឲ្យមកតាំងទីលំនៅៗលើទឹកដីខ្មែរ ដើម្បីបង្រៀនទំនៀមទំលាប់យួនដល់ប្រជាជនខ្មែរឲ្យធ្វើតាម ។

(៣) តាមសៀវភៅសង្ខេបពង្សាវតាប្រទេសកម្ពុជារបស់លោករ.គោរិទ ថាមេទ័ពយួនធំៗមានបីនាក់គឺ ទ្រឿង-មិញយ៉ាង, ផាំ-វ៉ាំងយ៉ាង និង វ៉ាំង-ណាង ។

អុងផៀងគុន ( ទ្រឿង-មិញយ៉ាង ) អគ្គមេបញ្ជាការយួន កាលបានជាធំនៅស្រុកខ្មែរហើយ បានរៀបចំគំរោងការយ៉ាងច្បាស់ប្រាកដណាស់ ក្នុងការយកស្រុកខ្មែរធ្វើជាស្រុកយួន ។ វត្តមានព្រះឧបរាជ(អ៊ិម) និងព្រះអង្គដួងនៅខេត្តបាត់ដំបង ជាឧបសគ្គមួយរារាំងដល់គំរោងការណ៍មេទ័ពយួននេះ (5) ។ កាលនោះព្រះចៅសៀមបានចាត់ឲ្យព្រះអង្គអ៊ិមមកគង់នៅខេត្តបាត់ដំបង និងព្រះអង្គដួងមកគង់នៅខេត្តមង្គលបូរី ។ ទ្រៀង-មិញយ៉ាងក៏រកឧបាយកលផ្សេងៗ និងយកយួនចំណោងព្រះហស្តដែលស្តេចយួនបានថ្វាយមកព្រះអង្គចន្ទនោះជាភ្នាក់ងារនាំលិខិតនិងនិយាយបោកព្រះអង្គអ៊ិមជាសម្ងាត់ ថាឲ្យព្រះអង្គអ៊ិមរត់ចូលទៅស្រុកខ្មែរចុះយួននឹងថ្វាយរាជសម្បត្តិ ។ ដោយចង់សោយរាជ្យ ព្រះអង្គអ៊ិមក៏ទូលបង្គាច់ព្រះអង្គដួងថា ប្រុងក្បត់បំរុងរត់ចូលយួន ។ ព្រះចៅសៀម ព្រះពុទ្ធឡិតឡានភាល័យ ក៏ចាប់ព្រះអង្គដួងដាក់ក្តីយកទៅក្រុងទេព (ក្រុងបាងកក) ។ ដើម្បីរត់ទៅស្រុកខ្មែរនោះ ព្រះអង្គអ៊ិមបានចាប់យកក្រមការខេត្តបាត់ដំបង គឺលោកបាឡាត់រស់ទៅជាមួយផង ក្នុងឆ្នាំរកានព្វស័កគ.ស.១៨៣៧ ។ ព្រះអង្គកៀរយកគ្រួខ្មែរតាមផ្លូវវៀងមកដល់ពោធិសាត់ ។ នៅទីនោះយួនក៏ចាប់ឃុំព្រះអង្គអ៊ិមព្រមទាំងរាជវង្សានុវង្សនាំមកភ្នំពេញ ដល់ពេលយប់ស្ងាត់ក៏នាំព្រះអង្គអ៊ិមនិងព្រះញាតិចុះទៅព្រៃនគររួចបន្តយកទៅឃុំទុកនៅក្រុងហ្វេទៅ ។ ស្តេចយួនធៀវ-ទ្រី បានចេញរាជសារមកទ្រឿងមិញយ៉ាងនៅភ្នំពេញបញ្ជូនសម្តេចចៅហ្វាទល្ហៈឡុង១សម្តេចចៅពញាហ៊ូ១ឧកញាក្រឡាហោមមាន់១ ឲ្យចុះទៅគាល់ស្តេចនៅក្រុងហ្វេ រួចឃុំសេនាបតីខ្មែរទុកនៅទីនោះ ។ ក្រោយមកទ្រឿង-មិញយ៉ាងចាត់សេនាទាហានឲ្យឃុំខ្លួនក្សត្រីអង្គម៉ី អង្គបែន អង្គពៅ និងអង្គស្ងួន នាំយកទៅស្រុកយួនជាសម្ងាត់ទៀត ។ ទៅដល់ក្រុងលង់ហោរ អុងដុងដុកចៅហ្វាយខេត្តៗលង់ហោរ ( Vinh Long ) បញ្ជូនតែក្សត្រីបីអង្គទៅក្រុងហ្វេ ឃាត់ទុកព្រះអង្គបែនព្រោះវាចោទថាក្បត់វា ហើយក៏ធ្វើគតព្រះអង្គបែន ដោយជ្រមុជទឹកសម្លាប់នៅស្រុកលង់ហោរនោះទៅ (6) ។

ផែនការដកចៅហ្វាយខេត្តខ្មែរ និងការចាប់ក្សត្រីអង្គម៉ី ព្រមទាំងរាជវង្សខ្មែរយកទៅឃុំទុកនៅទីក្រុងហ្វេ ជាបុព្វហេតុធ្វើឲ្យខ្មែរកាន់តែយល់ច្បាស់ថា យួនប្រុងរំលាយប្រទេសខ្មែរមែនទែនហើយ ។ សេចក្តីក្តៅក្រហាយក៏កើតមានឡើងទូទាំងប្រទេសខ្មែរ ។ រាស្ត្រខ្មែរគ្រប់ខេត្ត និគមជនបទជំនុំគ្នាកជាស្នៃគ្របក្សពួក ពីម្ភៃហាសិប ឬមួយរយនាក់ ដឹកនាំដោយមេដែលគេទុកចិត្ត បះបោរច្រួលច្របល់ក្នុងកំឡុងខែកញ្ញានិងតុលា១៨៤០ ។ ក្នុងការបះបោរនេះ មេស្នៃគ្របក្សពួកតែងប្រជុំទាក់ទងគ្នាទៅវិញទៅមក ។ ការបះបោរជាដំបូង លេចចេញមកពីម្តុំខេត្តភាគខាងកើតក្រុងឧដុង្គ តាមជួរមាត់ទន្លេ មានខេត្តល្វាឯម, ស្រីសឈរ, ខេត្តកណ្តាលស្ទឹងខេត្តគៀនស្វាយ, ខេត្តខ្សាច់កណ្តាល, ខេត្តភ្នំពេញជាដើម ។ នៅពេលដែលបានដំណឹងថា យួនបានចាប់សេនាបតី ក្សត្រីអង្គម៉ី ព្រមទាំងរាជវង្សខ្មែរបាត់ទៅហើយ ។ ដំណឹងនេះបានផ្សព្វផ្សាយយ៉ាងរហ័ស ពីស្រុកមួយទៅស្រុកមួយ ពីខេត្តមួយទៅខេត្តមួយទៀត ។ ក្នុងកំឡុងខែឧសភា១៨៤១ ការបះបោរបានឡើងដល់កំរិតជាអតិមរិមា។ មេស្នៃគ្របក្សពួកក៏សន្មត់គ្នាបះឡើងព្រមៗគ្នាក្នុងកំឡុងវេលា៨ថ្ងៃ លើកគ្នាទៅឡោមព័ទ្ធបន្ទាយយួននានាគ្រប់ស្រុកខេត្តឃុំតំបន់ កាប់សម្លាប់យួនទាំ

ងស៊ីវិលទាំងទាហាន នៅគ្រប់ទីកន្លែងដែលគេជួបប្រទះ ។ គមនាគមន៍រវាងទីក្រុងត្រូវដាច់ ។ ពួកខ្មែរបះបានឡោនព័ទ្ធទ័ពយួន ដែលអាចត្រួតត្រាតែទីក្រុង ឯកងទ័ពយួនតាំងនៅដាច់ស្រយ៉ាល មានសេចក្តីភិតភ័យជាខ្លាំង ។ ក្រុមខ្មែរបះខ្លះមានទាំងព្រះសង្ឃជាមេដឹកនាំផង (7) ចំនួនខ្មែរបះបោរកាលនោះឡើងដល់ជាងបីម៉ឺននាក់ ដែលធ្វើឲ្យនេទ័ពទ្រឿង-មិញយ៉ាង មិនដឹងរកវិធីណាដើម្បីទប់ទល់នឹងខ្មែរបះបោរឲ្យបានស្ងប់ទៅវិញបាន ។ (8) យួនដែលរួចជីវិតពីទ័ពខ្មែរបះបោរ ក៏នាំគ្នារត់មកជ្រកជាមួយទ័ពធំក្នុងបន្ទាយខេត្តពោធិសាត់ និងបន្ទាយធំនៅភ្នំពេញ ។

ដោយសំណូមពរពីមន្ត្រីខ្មែរនិងចៅហ្វាយខេត្តពោធិសាត់ (9) សុំឲ្យព្រះចៅសៀមព្រះណាំងក្លាវបញ្ជូនព្រះអង្គដួង មកស្រោចស្រង់ស្រុកពីកណ្តាប់ដៃយួន នោះព្រះចៅក៏បញ្ជាឲ្យពញ្ញាបៈឌិនតេជោនាំទ័ពសៀម ១៥,០០០នាក់ ដង្ហែរព្រះអង្គដួងចូលមកស្រុកខ្មែរ តាមរយៈបាត់ដំបង និងកេណ្ឌរាស្ត្រខ្មែរបញ្ចូលជាមួយទ័ពសៀម បាន៣៥,០០០នាក់ លើកចូលទៅឡោមបន្ទាយខេត្តពោធិសាត់បានដោយម៉ឺនចាបចេះធ្វើគ្រាប់កាំភ្លើងធំបាញ់ផ្លោងចូលក្នុងឆេះបន្ទាយយួន មេទ័ពយួនក៏សុំចុះចាញ់ មិនហ៊ានទទួលច្បាំង ទ្រង់ក៏លើកទ័ពខ្មែរ-សៀមបន្តមកវាយកំចាត់យួនចេញពីក្រុងឧដុង្គនិងភ្នំពេញទៀត ។

ដោយអស់សង្ឃឹមនឹងធ្វើយួនូបនិយកម្មស្រុកខ្មែរ និងបរាជ័យក្នុងការប៉ុនប៉ងដាក់ព្រះអង្គអ៊ិមឲ្យសោយរាជ្យវិញនោះ ( ព្រោះខ្មែរលែងជឿ ) នៅចុងឆ្នាំ១៨៤១ ទ្រឿង-មិញយ៉ាងក៏ដកថយទ័ពយួន យកព្រះអង្គអ៊ិម ក្សត្រីអង្គម៉ី និងព្រះរាជវង្សានុវង្ស ព្រមទាំងគៀរគ្រួខ្មែរជាងប្រាំមួយពាន់នាក់ ចុះទៅដែនកម្ពុជាក្រោម រួចហើយភេផ្ញើលិខិតទៅក្រុងហ្វេ សុំទទួលទោសដែលធ្វើការមិនបានសំរេច រួចហើយទ្រឿង-មិញយ៉ាងក៏ផឹកថ្នាំបំពុលធ្វើអត្តឃាតខ្លួនស្លាប់ទៅ (10) ។

ស្តេចយួនក៏បញ្ជូនមេទ័ពឈ្មោះ អុង ខាំសាយ ដាយថាន់ នាំទ័ពជាច្រើននាំយកទៅព្រះអង្គអ៊ិម និងក្សត្រីអង្គម៉ី ព្រមទាំងរាជវង្សខ្មែរ ពីខេត្តមាត់ជ្រូក មកទុកនៅបន្ទាយភ្នំពេញ ។ ចំបាំងរវាងខ្មែរនិងយួន កាលនោះមិនចាញ់មិនឈ្នះ ទើបមេទ័ពយួននិងពញ្ញាបៈឌិនសុំចរចាគ្នាឈប់ច្បាំង ហើយទទួលស្គាល់ព្រះអង្គដួងជាក្សត្រខ្មែរទាំងអស់គ្នា ហើយសុំឲ្យយួនប្រគល់ក្សត្រីអង្គម៉ី ព្រមទាំងរាជវង្សានុវង្សខ្មែរមកវិញជាថ្នូរ និងឈ្លើយសឹកយួន-ចាមដែលសៀមឃុំទុកជាឈ្លើយកាលមុននោះ ។ ដើម្បីសេចក្តីសុខដល់បណ្តារាស្ត្រ ព្រះអង្គដួងក៏សុខចិត្តយកសៀមនិងយួនធ្វើជាអាណាព្យាបាលលើស្រុកខ្មែរ ។

ផែនការយួនូបនិយកម្មត្រូវបរាជ័យ ដោយខ្មែរបានដឹងខ្លួនទាន់ តែដើម្បីកុំឲ្យខាតទន់ខ្លាំងពេក យួនក៏ថយទៅ តែទៅតាំងទ័ពសង់បន្ទាយកាន់កាប់រក្សខេត្តខ្មែរដែនកម្ពុជាក្រោម ជាមាំមួន តាំងពីទ្រាំងត្រើយត្បូង មាត់ជ្រូក ក្រមួន-ស ពាម ទឹកខ្មៅ ពលលាវ ព្រះត្រពាំង ព្រៃកប្បស្សី... ជាដើម ។

មុននឹងចូលដល់ផែនការយួនូបនិយកម្ម ខ្ញុំសូមរំលឹកត្រួសៗដែរ អំពីចលនាតស៊ូរបស់ខ្មែរកម្ពុជាក្រោម ដែលប្រឆាំងនឹងនយោបាយបំបាត់ទំនៀមទំលាប់ខ្មែរបំផុតពូជខ្មែរម្ចាស់ស្រុកនៅដែនដីកម្ពុជាក្រោម ។

# វិធានការដែលយួនប្រើសម្លាប់ខ្មែរក្រោម និងការតស៊ូរបស់ខ្មែរក្រោម

ក្នុងឆ្នាំ១៧៧៦ ខ្មែរនៅភាគខាងក្រោមនៃដែនកូសាំងស៊ីនបានបះបោរឡើង វាយកំចាត់យួនដែលប្រើវិធីឃោរឃៅសម្លាប់ខ្មែរ ( ខេត្តព្រះត្រពាំង ) ។ ឆ្លៀតឱកាសនោះ ព្រះអង្គនន់ក៏លើទ័ពខ្មែរចូលទៅវាយដណ្តើមយកខេត្តវិញឡុង ( ឡុង-ហោរ ) និងខេត្តម៉ីថូ ( មេ-ស ) មកវិញ (11) ។

ក្នុងរជ្ជកាលព្រះអង្គចន្ទទី២ (១៨០៦-១៨៣៤ ) ស្របពេលដែលព្រះអង្គម្ចាស់ង្វៀង-អាន ប្រកាសខ្លួនជាស្តេចយួន ហើយច្បាំងជាមួយពួកយួនបះបោរតៃសឺននោះ ចៅហ្វាយខេត្តខ្មែរនៅខេត្តព្រះត្រពាំងឈ្មោះឧកញ្ញាសួស បានក្រោកឡើងកេណ្ឌទ័ពច្បាំងបណ្តេញយួនឈ្លានពាន ឯស្តេចខ្មែរបែរជាបញ្ជូនទ័ពទៅជួយស្តេចយួនទៅវិញ ។

ក្រោយមកក្នុងរជ្ជកាលក្សត្រីអង្គម៉ី (១៨៣៤-១៨៤១ ) ដោយឈឺចិត្តនឹងយួនដែលយាយីបំផ្លាញទំនៀមទម្លាប់ និងព្រះពុទ្ធសាសនា លោកចៅហ្វាយគុយ នៅខេត្តព្រះត្រពាំងបានក្រោកឡើងកេណ្ឌទ័ពច្បាំងបណ្តេញយួនទៀត ដោយមានសេនាជំនិតប្រាំនាក់គឺ ភូឈួយគង់, ហ្មឺនឯក, តាម៉ង់, ទេសាសោម និងមនោរស់ ។ ទ័ពលោកតាំងទីនៅតំបន់ផ្លូវដួង ។ ការតស៊ូរបស់លោកចៅហ្វាយគុយត្រូវបរាជ័យព្រោះភូឈួយគង់ក្បត់ចូលដៃនឹងអុងលូវ មេទ័ពយួនដែលសន្យាថានឹងឲ្យភូឈួយគង់ឡើងទីជាឧកញ្ញាជំនួសចៅហ្វាយគុយ ។ ភូឈួយគង់បានប្រាប់កិច្ចការអាថ៌កំបាំងទ័ពចៅហ្វាយគុយដល់យួនអស់គ្មានសល់ រហូតរកមធ្យោបាយសម្លាប់សហការីរួមតស៊ូជាមួយគ្នា មានហ្មឺនឯក, តាម៉ង់, ទេសាសោម និងមនោរស់អស់ទៀត ។ ចៅហ្វាយគុយត្រូវយួនចាប់ រួចវាតែងតាំងជាភូឈួយវា ។ ពេលដែលព្រះចៅយួនមិញ-ម៉ាងចេញបញ្ញាតិឲ្យខ្មែរក្រោមបោះបង់ទំនៀមទម្លាប់ ព្រះពុទ្ធសាសនាថេរវាទ នោះលោកចៅហ្វាយបានទាមទារប្រឆាំងនឹងការកែប្រែនេះ លោកសុខចិត្តឲ្យយួនសម្លាប់លោកចុះ ឲ្យតែយួនព្រមសន្យារក្សាទុកទំនៀមទំលាប់ព្រះពុទ្ធ-សាសនាឲ្យខ្មែរក្រោម ។ អុងលូវបានប្រហារជីវិតឧកញ្ញាគុយនៅមុខសាលាឃុំបិនឌីក ។ ប្រជារាស្ត្របានយកសពឧកញ្ញាគុយ មកធ្វើបុណ្យបញ្ចុះក្នុងចេតិយមុខវត្តពោធិសាលរាជ ក្នុងខេត្តព្រះត្រពាំង ។ ឯភូឈួយគង់ដែលក្បត់ចៅហ្វាយគុយ ក៏ត្រូវមេទ័ពយួនចាប់ដាក់ទ្រុងសម្លាប់ចោលដែរ ។ (12)

ក្នុងឆ្នាំ១៨៤៧ រជ្ជកាលព្រះអង្គដួង ខ្មែរខេត្តព្រះត្រពាំងក្នុងស្រុកចាប់ភ្លើងម្នាក់ឈ្មោះឡោម-សោមបានក្រោកឡើងដឹកនាំការតស៊ូប្រឆាំងនឹងយួន សងសឹកជួសលោកឧកញ្ញាគុយផង និងដេញយួនចេញពីកម្ពុជាក្រោមផង ។ លោកមានសេនាឯក សេនាប្រញោ និងមឿង-សោមជាជំនួយ ។ ឡោម-សោមបានវាយឈ្នះយួនហើយបានទាំងសម្លាប់ចៅហ្វាយខេត្តយួនអុងបូផង ។ ទ័ពលោកឡោម-សោមវាយចូលដល់ផ្លូវដួង ហើយបានសម្លាប់យួនជាច្រើនផង ។ តែយួនបានបញ្ជូនទ័ពយ៉ាងច្រើនមកពីខេត្តខាងកើត មកទប់ទ័ពឡោម-សោម ។ យួនចាប់ឡោម-

សោមបានដាក់ទ្រូងយកទៅក្រុងហ្វេ ហើយស្តេចយួនផៀវ-ទ្រី ក៏បញ្ជាឲ្យសម្លាប់លោកទៅ ។ (13)

ក្នុងគំរោងការវាតទីចុះមកទិសខាងលិច និងពង្រឹងស្ថានភាពយួនផង ក្នុងឆ្នាំ ១៨៥៦ យួនសង់បន្ទាយយ៉ាងមាំនៅទីរួមខេត្តឃ្លាំងបាសាក់(Soctrang ) ។ លោកចៅហ្វាយស្រុកសុកបានក្រោកឡើងកេណ្ឌទ័ពវាយកំចាត់យួនយ៉ាងក្លាហានគ្រប់ទីកន្លែងក្នុងតំបន់ទំនប់និងកំពង់ត្រប់ ( Thuan Hoa ) ។

ក្នុងឆ្នាំ១៨៥៩ លោកសេនាសួស នៅខេត្តឃ្លាំងបានក្រោកឡើងតស៊ូវាយកំ-ចាត់យួននៅមហាទប់ (Hoa Thuan) និងចុងបាឡាង ( An Ninh ) ។ ក្នុងការតស៊ូជាងបីឆ្នាំ ខ្មែរបានសម្លាប់ឧត្តមមេបញ្ជាការយួនពីរនាក់ផង មួយឈ្មោះអុងឡាន់-សម និងមួយទៀតឈ្មោះអុងឡាន់-ប៊ិនស៊ី ។ តែក្រោយមកលោកសេនាសួសបានត្រូវពួកចាម ដែលជាសម្ពន្ធមិត្តយួនលួចបំពុលលោកស្លាប់ទៅ ។

ក្នុងឆ្នាំ១៨៦០ ក្នុងខេត្តឃ្លាំងបាសាក់ ( Soctrang ) មានបងប្អូនពីរនាក់ឈ្មោះ សេនាទា សេនាមាន់ នៅឡោម ពូយ៉ា ( Nhu Gia ) បានក្រោកឡើងកេណ្ឌទ័ពតស៊ូ តែដោយទ័ពយួនច្រើនសន្ធឹកពេក លោកត្រូវបង្ខំនាំទ័ពថយទៅភូមិឡុង ថាន់ ក្នុងតំបន់ត្រា ខា ខេត្តពលលាវ ( Baclieu ) រួចលោកបាននាំទ័ពវាយច្រានយួនរហូតដល់ពាមបូ លីវ ។ ដោយយួនបានជំនួយទ័ពចាម ជ្វារ ថែមមកជាច្រើនទៀត លោកសេនាទាក៏ត្រូវពួកជ្វារបាញ់លោកដោយកាំភ្លើងស្លាប់ជីវិតទៅ ។ ពលទាហានបានយកសពលោក ទៅបញ្ចុះលើកូនកោះមួយក្បែរវត្តខ្មែរនៅខ្វែង បបិល ក្នុងខេត្តពលលាវ ។

សម័យទ្រឿង-មិញយ៉ាងត្រួតត្រាស្រុកខ្មែរនោះ ខ្មែរនិងយួនត្រូវការជាចាំបាច់នូវ ព្រែកវិញតេ ដោយជីកភ្ជាប់ពីមាត់សមុទ្រ ចូលមកចម្ងាយ៥៣គ.ម. ។ ក្នុងការជីកព្រែវិញតេនេះ មេទ័ពយួនបានទទួលដាវអាជ្ញាសឹកមួយ និងព្រះសង្ការត្រាពីស្តេចខ្មែរព្រះអង្គចន្ទ ដើម្បីត្រួតត្រាការជីកព្រែកនោះ ។ មនុស្សជាប់កំណែនមានខ្មែរ និងយួនលាយគ្នា ។ គេចែកជាក្រុមដើម្បីរែកអាចម៍ដីចេញពីក្នុងបាតព្រែក ។ ក្នុងក្រុមនិមួយៗមានយួនម្នាក់ដើរមុខ យួនម្នាក់ដើរក្រោយ និងយួនម្នាក់ទៀតដើរកណ្តាលជួរ ដើម្បីគក់ឬតប់ឲ្យខ្មែរដើរទៅមុខឲ្យលឿន ។ យួនតែងរករឿងចោទខ្មែរថាចង់រត់គេច ឬមិនធ្វើការជាដើម រួចខ្មែរនោះៗក៏ត្រូវទោស ហើយយកទៅកប់ដីត្រឹមកបីៗនាក់ ធ្វើជាមុមជើងក្រានដាំតែអុង ។ ពេលដែលយួនវាដុតភ្លើងដាំតែនោះ ខ្មែរអ្នកទោសរើបំរះដោយក្តៅនឹងភ្លើង យួនវាស្រែកថា កុំកំរើក « ប្រយ័ត្នកំពប់តែអុង » គឺដាំតែឲ្យលោកធំយួន ។

នេះជារបៀបសម្លាប់ខ្មែរយ៉ាងសាហាវព្រៃផ្សៃ ខ្មែរគ្រប់ៗគ្នាតែងរំលឹករឿងនេះប្រាប់តកូនតចៅ ជាបុព្វហេតុធ្វើឲ្យខ្មែរស្អប់យួនរហូតដល់ឥឡូវ ។ ដល់ពេលជីកព្រែករួចហើយ យួនគេលួចប្រាប់គ្នីគ្នាគេទាំងអស់ឲ្យដឹងជាមុន ឯខ្មែរគេមិនឲ្យដឹងសោះទេ ។ គេយកឃ្នាងវែងមកដាក់គាបកខ្មែរបន្តគ្នាដប់នាក់ ម្ភៃនាក់ ឬរាប់រយនាក់ដោយយកលេសថា កុំឲ្យខ្មែររត់ចោលកំណែនជីកព្រែក ។ រួចហើយមេទ័ពយួនក៏បញ្ជាឲ្យទម្លាយដីមុខទំនប់ ឲ្យទឹកសមុទ្រហូរចូលព្រែកជីកលិចលង់ស្លាប់ខ្មែរវិនាសអន្តរាយអស់គ្មានសល់ ព្រោះកជាប់ឃ្នាងរើមិនរួច ។ ដោយសារការ

សម្លាប់ខ្មែរយ៉ាងឃោរឃៅបែបនោះហើយ ទើបខ្មែរនៅតំបន់ព្រៃកជីកវិញតេ និងនៅតំបន់ជួរភ្នំប្រាំពីរ មានភ្នំពពាល ភ្នំអកយំជាដើមកើតសេចក្តីឈឺចាប់ក្តៅក្រហាយនឹងយួនដែលធ្វើទារុណកម្មកាប់សម្លាប់ខ្មែរយ៉ាងសាហាវព្រៃផ្សៃដូច្នេះនោះ ក៏ក្រោកឡើងប្រមូលគ្នីគ្នាតស៊ូវាយសងសឹកនឹងពួកយួន រហូតសម្លាប់បានមេទ័ពយួន និងសេនាទាហានជាច្រើននាក់ ដែលបាក់ទ័ពរត់ចុះពីស្រុកខ្មែរទៅ ។

ការតស៊ូរបស់ខ្មែរក្រោមមានមកជាហូរហែរហូតមកដល់ពេលថ្មីៗនេះ ជាឧ-ទាហរណ៍នៃការតស៊ូមួយក្នុងចុងឆ្នាំ១៩៤៥ និងដើមឆ្នាំ១៩៤៦ជាដើម ដែលយួនកុម្មុយនិស្តហូ-ជីមិញ បានគ្រោងសម្លាប់ខ្មែរក្រោមទៀត ។ ការតស៊ូនេះបានកើតឡើងនៅក្នុងដែនដីសួ្ត ក្នុងខេត្តឃ្លាំង និងក្នុងភូមិកោះប្រហាតក្នុងខេត្តពលលាវ ។ ក្នុងកំឡុងខែធ្នូ ១៩៤៥ យួនយៀកមិញបានបញ្ឆោតប្រជាជនខ្មែរប្រុសៗក្នុងភូមិកោះប្រហាត យ៉ារ៉ាយ ផ្ទោអណ្តែត ដាំគិន ដាំយ៉ឺយ ព្រៃកហូរផុង ថាយកទៅទទួលលោកធំ ឬថាយកទៅហាត់ហ្វឹកហ្វឺន ហើយបញ្ចូលក្នុងរោងដាក់ស្រូវជប៉ុនដុតសម្លាប់ទាំងរស់អស់រាប់រយនាក់ គ្រាន់តែអ្នកភូមិផ្ទោអណ្តែតតែមួយមានស្លាប់ចំនួនសែសិបនាក់ទៅហើយ (14) ខ្លះទៀតពួកវាបញ្ឆោតឲ្យឡើងលើទូកសមុទ្រ រួចវាចោះពន្លិចទូកសម្លាប់ខ្មែរ ។

យើងឃើញថា គ្រប់វិធានការណ៍ យួនធ្វើការសម្លាប់ខ្មែរជានិច្ចគ្មានឈប់ឈរសោះឡើយ ។ បុព្វហេតុដើមគឺមកតែពីស្តេចខ្មែរកើតវិវាទគ្នាដណ្តើមរាជបល្លង្កដណ្តើមអំណាចគ្នារវាងរាជវង្សឯង ទើបទៅពឹងយួនឲ្យមកជួយ យួនក៏បានលេសនេះឯងចូលមកកាន់កាប់ខេត្តខ្មែរទាំងឡាយនៅកម្ពុជាក្រោម និងធ្វើការកាប់សម្លាប់រង្គាលប្រជាជនខ្មែរ តែអកុសលខ្មែរមិនចេះផ្សាយការដែលយួនសម្លាប់ខ្មែរនេះដល់ពិភពលោកសោះ ។

## វៀតណាមូបនិយកម្មកម្ពុជាក្រោម

ដោយធ្វើយួននូបនិយកម្មកម្ពុជាលើមិនបានសំរេច យួនបានចូលទៅត្រួតត្រាដែនដីកម្ពុជាក្រោមជាមាំមួនមួយរយៈ ពេលដែលខ្មែរកំពុងតែសាងខ្លួន ស្តារប្រទេសដែលទើបនឹងរួចពីមហន្តរាយដោយសង្គ្រាម ។ តាំងពីព្រះចៅមិញ-ម៉ាំងរហូតព្រះចៅយ៉ា-ឡុង ស្តេចយួនបានអនុញ្ញាតឲ្យខ្មែរក្រោមបោះបង់ចោលទំនៀមទំលាប់ អក្សរសាស្រ្ត ការស្លៀកពាក់ជាខ្មែរ ព្រមទាំងព្រះពុទ្ធសាសនាថេរវាទផង ។ ជាដំបូងគេចាប់កែប្រែឈ្មោះខេត្តជាខ្មែរ ដាក់ជាភាសាយួនវិញ ។ ខេត្តខ្មែរនៅកម្ពុជាក្រោមទាំងអស់មាន១៧ខេត្ត តែនៅជំនាន់អាណានិគមបារាំង គេបានកែប្រែទៅជា ២១ខេត្ត ។ ខេត្តទាំងឡាយដែលយួនបានកែប្រែមានដូចតទៅ ៖

| <u>ឈ្មោះជាខ្មែរ</u> | <u>ឈ្មោះកែប្រែជាភាសាយួន</u> |
|---|---|
| ១- ខេត្តកំពប់ស្រកាត្រី ឬចង្វារត្រពាំង | កែជា Bien Hua រួច Phuoc Thanh រួច Phuoc Long |
| ២- ខេត្តរោងដំរី | កែជា Tay Ninh |
| ៣- ខេត្តព្រៃនគរ | កែជា Saigon រួច Gia Dinh Cholo រួច Ho Chi Minh |

| | |
|---|---|
| ៤- ខេត្តផ្សំអំបើស | កែជា Ben Tre រួច Kien Hoa |
| ៥- ខេត្តមេ-ស | កែជា My Tho រួច Dinh Tuong |
| ៦- ខេត្តកោះគង | កែជា Go Cong រួច Long An |
| ៧- ខេត្តព្រែកឫស្សី | កែជា Can Tho រួច Phong Dinh |
| ៨- ខេត្តលង់ហោរ | កែជា Vinh Long |
| ៩- ខេត្តព្រះត្រពាំង | កែជា Tra Vinh រួច Vinh Binh |
| ១០- ខេត្តផ្សារដែក | កែជា Sadec រួច Kien Phong |
| ១១- ខេត្តមាត់ជ្រូក | កែជា Chau Doc |
| ១២- ខេត្តឃ្លាំង (បាសាក់) | កែជា Soctrang រួច Khanh Hung រួច Ba Xuyen |
| ១៣- ខេត្តទឹកខ្មៅ | កែជា Camau រួច Quan Long រួច An Xuyen |
| ១៤- ខេត្តពាម | កែជា Hatien |
| ១៥- ខេត្តក្រមួនស | កែជា Rachgia រួច Kien Giang, Chuong Thien |
| ១៦- ខេត្តពលលាវ | កែជា Baclieu រួច Baclien |
| ១៧- ខេត្តពាមបារ៉ាជ | កែជា Long Xuyen រួចជា An Giang |
| ១៨- ខេត្តតាមោក | កែជា Thudomot រួច Binh Duong, Binh Long |
| ១៩- ព្រះសួគ៌ា | កែជា Baria រួច Phuoc Le, Phuoc Tuy, Binh Tuy |
| ២០- អូកាប់ | កែជា Cap St. Jacques រួច Vung Tau |
| ២១- (ឈ្មោះថ្មី ) | កែជា Tan An |

ស្រុកនិងទីកន្លែងខ្លះទៀត ដែលយួនបានកែប្រែជាឈ្មោះយួនគឺ ៖

| | |
|---|---|
| វាលព្រួស | កែជា Dong Nai |
| ឧកញ៉ាឌិន | កែជា Gia Dinh |
| កោះត្រឡាច | កែជា Con Son |
| កោះត្រល់ | កែជា Phu Quoc |
| ស្រុកអណ្តូងទឹក | កែជា Long Phu |
| សង្កាត់ព្រែកគយ | កែជា Rachgoi |
| សង្កាត់ព្រែកចាក | កែជា Chac Vang |
| សង្កាត់ផ្តៅពេន | កែជា Lo Vieng |
| សង្កាត់ដងក្តោង | កែជា Bai Gi |
| សង្កាត់កូនក្អែក | កែជា Ngang Ho |
| សង្កាត់ដើមពោធិ | កែជា Lam Vo |
| សង្កាត់ខ្វិនតាង | កែជា Dinh My |
| សង្កាត់ដៃនង | កែជា Lieu Tu |

| | |
|---|---|
| សង្កាត់តានាវ | កែជា Bang Lang |
| សង្កាត់បឹងអន្សា | កែជា Bung Sa |
| សង្កាត់ទន្លេឯត្បូង | កែជា My Than |
| សង្កាត់ឯលិច | កែជា Lich Hoi Thuong |
| សង្កាត់ផ្ទោរអណ្តែត | កែជា Giang Noi ។ល។ |



រូបគំនូរផែនទីនេះ គូរដោយលោកថាច់-ស៊ី អតិតចាងហ្វាងអង្គរបូរី និងជាអតិតប្រធាន សមាគមខ្មែរកម្ពុជាក្រោម ប្រចាំរដ្ឋកាលីហ្វ័រនិញ៉ា

នៅឈ្មោះខ្មែរជាច្រើនទៀតដែលយើងមិនអាចដាក់ឲ្យគ្រប់បាន

ផែនទីដែនដីកម្ពុជាក្រោមចំនួន១៧ខេត្ត ដែលក្លាយទៅជាវៀតណាមខាងត្បូង ចំ-ពោះផ្នែកខាងត្បូងព្រៃនគរ សភាអាណានិគមបារាំងបានសំរេចប្រគល់ទៅឲ្យព្រះថៅបៅដាយក្នុងយប់ថ្ងៃទី២១ ឧសភា ឆ្នាំ១៩៤៩ ។ ( ដកស្រង់ចេញពីសារពត៌មានអង្គរបូរី រដ្ឋកាលីហ្វ័រនិញ៉ា អត្ថបទរបស់លោកថាច់-ប៊ុនរឿង ថ្ងៃទី១៥ មិនា ៨៧)

ដោយសារខ្វះឯកសារ ខ្ញុំគ្មានលទ្ធភាពនឹងរៀបរាប់នូវឈ្មោះ ស្រុក ឃុំ សង្កាត់ទាំងអស់នៅដែនដីកម្ពុជាក្រោម ដែលយួនបានកែក្រែជាភាសាយួននោះឡើយ។

## យួនធ្វើអាណានិគមនិយមប្រជារាស្ត្រខ្មែរក្រោម

ក្នុងសម័យទ្រឿង-មិញយ៉ាង ដែលយួនបានអនុវត្តផែនការយកស្រុកខ្មែរធ្វើជាស្រុកយួននោះ ឯកសារសៀមបានហៅខ្មែរថា «ប្រជាជនយួនថ្មី» ។ បន្ថែមលើការបង្ខំឲ្យខ្មែរបោះបង់ទំនៀមទំលាប់ អក្សរសាស្ត្រ ព្រះពុទ្ធសាសនាថេរវាទចោល

និងឲ្យខ្មែររៀនភាសាយួន ស្តេចយួនបានបញ្ញាត្តឲ្យខ្មែរក្រោមទាំងអស់ យកសែត្រកូលទៅតាមពាក្យ ដែលស្តេចយួនដាក់ឲ្យសំរាប់ខេត្តនិមួយៗ ។ នេះជាមធ្យោបាយដើម្បីឲ្យយួនគេស្គាល់ឫសគល់នៃប្រជារាស្ត្រ «យួនកំណើតខ្មែរ»អស់នោះតែប៉ុណ្ណោះព្រោះខ្មែរខេត្តនិមួយៗតែងមានចរិតខុសពីខេត្តមួយទៀត ជាឧទាហរណ៍ ខ្មែរដែលមានត្រកូលថាច់ ច្រើនមានចិត្តប្រែប្រួល យកសុខយករួចខ្លួន ឯខ្មែរដែលមានត្រកូលសឺនច្រើនមានចិត្តក្លាហាន មានៈរឹងត្អឹង មិនអោនក្បាលឲ្យយួនត្រួតត្រា ហ៊ានបះបោរ ។ល។ ព្រះចៅមិញ-ម៉ាងបានបញ្ញាតិឲ្យខ្មែរក្រោមយកសែត្រកូលជាយួនមានជាងម្ភៃសែ តែចាប់ពីរាជ្យព្រះចៅយ៉ាឡុងមក គេបានរាប់យកតែសែប្រាំមួយទៅវិញ ។ គឺថាសែខ្មែរដទៃទៀត បានត្រូវយួនបំភ្លៃឃោសនាបំបាត់ជានថាជាជាតិយួនសុទ្ធ តែខ្មែរទាំងអម្បាលមាណនោះ នៅតែរក្សាទំនៀមទម្លាប់ជាខ្មែរ និងនិយាយភាសាខ្មែរនៅឡើយ ។ សែទាំងប្រាំមួយនោះគឺ ថាច់, សឺន, គីម, គាង, យ៉ាញ និងចៅ ។ ខ្សែគោត្តត្រកូលដែលស្តេចយួនបញ្ញាតិដាក់ឲ្យរាស្ត្រខ្មែរនៅកម្ពុជាក្រោមមានដូចតទៅ ៖

★ ខ្មែរនៅខេត្តពលលាវ ឃ្លាំង និងព្រះត្រពាំង — ត្រូវតែយកសែជា — សឺន, ថាច់, គីម, គាង...ឧទាហរណ៍ ៖ សឺន-ញិល, គាង, វិនជាដើម...

★ ខ្មែរនៅខេត្តមាត់ជ្រូក — ត្រូវតែយកសែជា — ចៅ..ឧទាហរណ៍ : ចៅ-សោម

★ ខ្មែរនៅខេត្តក្រមួនស — ត្រូវតែយកសែជា — យ៉ាញ, ដាញ់... ឧទា. ៖ដាញ់-ក្រួច...

★ ខ្មែរនៅខេត្តរោងដំរី — ត្រូវតែយកសែជា — កាវ...ឧទាហរណ៍ ៖ កាវ-នូ...

★ ខ្មែរនៅខេត្តព្រែកឫស្សី — ត្រូវតែយកសែជា — ដាវ...ឧ. ៖ ដាវ-កាន (15)

ឯសែដទៃទៀតនៅពាសពេញកម្ពុជាក្រោមក៏សុទ្ធជាខ្មែរដែរ តែយួនមិនរាប់ប ញ្ចូលគឺ ៖ យឹប, លី, ឡឹម, ទិន, តាំ, ញ៉ាង, ហុង, វិន, ត្រឹង, ង៉ោ, ដូ, តូ, គី, យឿង, អុង (16) ។

## ឯកសារយោង – REFERENCES


(1) A History of Cambodia - David P. Chanler page 126 - published in 1983.

(2) Georges Maspero- L'Empire Khmer page 70 - Phnom Penh - Imprimerie du protectorat -1904

(3) Roger M. Smith, Cambodia's foreign policy, published 1965, page 13.

(4) សង្ខេបពង្សាវតារប្រទេសកម្ពុជា ដោយរ.គោរិទ ទំព័រ១០៣ ។

(5) J. Moura, Le Royaume du Cambodge Fascicule II, page 131.

(6) ឯកសារមហាបុរសខ្មែរ របស់លោកអេង-សុត បោះពុម្ពឆ្នាំ១៩៦៨ ទំព័រ១០៥៨ ។

(7) Roger M. Smith, Camodia's foreign policy, page 14-15.

(8) A History of Cambodia, David P. Chandler, page 131.

(9) M. Giteau, Histoire du Cambodge, page 155.

(10) David P. Chandler, A History of Cambodia, page 134.

(11) Memorandum of Cambodia on her territories in South Vietnam-Cochinchina 1954 - Imprimerie Gloor- Geneva, page 4.

(12) សូមអានសៀវភៅឧកញាគុយ របស់លោកកែវ-សុវត្ថិ និងថាច់-កាន់ បោះពុម្ពឆ្នាំ១៩៦៦ ។

(13) កូសាំងស៊ីនជាដែនដីរបស់ខ្មែរត្រូវប្រគល់ឲ្យខ្មែរវិញ ទំព័រ៦៣, ៦៤, ៦៥ ដោយសាំង-ម៉ាក់សាង, បោះពុម្ពឆ្នាំ១៩៧៣ ។

(14) សូមអានសៀវភៅ «រស់ព្រោះហ៊ានស្លាប់» របស់លោកម៉ៃ-ផាត់ ឆ្នាំ១៩៧២ ។

(15) តាមសេចក្តីឲ្យការណ៍របស់លោកសឺន-ឡេ និងលោកតិម-ធឹម រដ្ឋវ៉ាស៊ិនតោន អតីតម៉ៃគហ្វក ។

(16) ដែនដីកម្ពុជាក្រោម ទំព័រ១១៨ ឆ្នាំ១៩៧១ ដោយគីម-សាអ៊ុល ។

# ជំពូកទី២

# ស្មារតីភ្ញាក់រឭក

ការដែលខ្ញុំលើកយកវគ្គត្រង់នេះមក ព្រោះជាបឋមហេតុដែលបណ្តាលឲ្យមានជាចលនាស្នេហាជាតិភ្ញាក់រឭក ក្រោកឡើងតស៊ូ និងការជិះជាន់នៃអាណានិគមបារាំង រហូតបង្កើតជាចលនាខ្មែរឥស្សរៈ, ខ្មែរសេរី, ខ្មែរយៀកមិញ, ខ្មែរក្រហមតៗមក ។

ក្នុងគ.ស.១៨៥៧ ព្រះអង្គដួងបានពឹងព្រះសង្ឃកាតូលិកនាម ម៉ុងសែងញ៉័រមីស្ហ ( Monseigneur Miche) នាំព្រះរាជសារទៅសុំជំនួយកងទ័ពបារាំង មកវាយស្រុកព្រៃនគរ បើបានសំរេចរាជការក្រុងកម្ពុជានឹងចេញជាប្រាក់៥០០ណែន ជូនរាជការបារាំង ។ ឯខេត្តទ្រាំងត្រើយត្បូង បាសាក់(ឃ្លាំង) ព្រះត្រពាំង ក្រមួនស មាត់ជ្រូកម្ខាងទល់នឹងមាត់សមុទ្រ ម្ខាងទល់នឹងស្រុកព្រៃនគរនោះ រាជការក្រុងកម្ពុជានឹងចាត់កងទ័ពទៅវាយព័ទ្ធវាំងទៅទល់នឹងដែនព្រៃនគរ ។ ព្រះចៅណាប៉ូឡេអុងទី៣ ក៏ទ្រង់មេត្តាប្រោសតាមព្រះរាជសារគ្រប់ប្រការ ។ ព្រះចៅនរោត្តមបានចាត់ឧកញ្ញាវេ ជាសេដ្ឋីកែប ចៅហ្វាយខេត្តៗពាមជាមេទ័ពនិងសេនាទាហាន ព្រមដោយសាស្ត្រាវុធបំរុងស្រេច ចាត់ឧកញ្ញាយមរាជម៉ុក ជាអ្នកបញ្ជូនស្បៀងអាហារបំរុងចាំកងទ័ពពីក្រុងបារាំងសែសមកដល់ និងវាយផ្ទប់គ្នា (1) ។ ដល់ឆ្នាំមមីសំរិទ្ធិស័កគ.ស.១៨៥៨ ព្រះចៅណាប៉ូឡេអុងបានចាត់ឧត្តមនាវីឯក Admiral Doudart de Lagrée នាំសេនាទាហានចុះកប៉ាល់ទៅវាយក្រុងព្រៃនគរ ។ ឯរាជការក្រុងកម្ពុជាក៏លើកទ័ពទៅវាយខេត្តទ្រាំងត្រើយត្បូង, បាសាក់, ព្រះត្រពាំង, ក្រមួនស, មាត់ជ្រូក (2) តែទ័ពខ្មែរត្រូវទើនៅត្រង់ព្រែកជីកវិញតេ ក៏តាំងបាញ់កាំភ្លើងធំ-តូចទៅវិញទៅមក តែជាអកុសលព្រះអង្គដួងសុគតនៅថ្ងៃទី១៩តុលា១៨៦០ ឯឧកញ្ញាកែបក៏ត្រូវព្រះនរោត្តមតំឡើងងារជាឧកញ្ញាចក្រី (១) ហើយឲ្យលើកទ័ពទៅវាយខេត្តទ្រាំងត្បូងតទៅទៀត ។ ប្រាំបីខែក្រោយព្រះអង្គដួងសុគតទៅនោះ ព្រះស៊ីសុវត្ថាជាអនុជ ព្រះនរោត្តមបានចាត់ឲ្យស្តេងសួរ មនោកែវ ជាញាតិខាងមាតាកេណ្ឌទ័ពពីតំបន់បាភ្នំ សង្កត់ខេត្តត្រើយខាងកើត ដើម្បីច្បាំងដណ្តើមរាជ្យពីនរោត្តមតាមការពន្យុះគាំទ្ររបស់សៀម ។ ក្នុងខែមិនា១៨៦១ មនោកែវត្រូវគេចាប់បាន ឯស្តេងសួរនិងបក្សពួករត់ទៅពឹងបារាំងនៅបន្ទាយខេត្តរោងដំរី ( Tai Ninh ) បារាំងក៏នាំដាក់

(១) ក្នុងផ្នែករដ្ឋបាលខ្មែរ មានព្រះមហាក្សត្រជាធំ រួចបន្ទាប់មកគឺមហាឧបរាជ (ជួនមាន-ជួនគ្មាន) រួចគឺសម្តេចចៅហ្វាទល្ហៈ ឬជួនកាលហៅ អគ្គមហាសេនាបតី ដែលមានមុខងារស្មើនឹងនាយករដ្ឋមន្ត្រី ( Prime Monister ) ។ ក្រោមសម្តេចចៅហ្វា មានសេនាបតី(រដ្ឋមន្ត្រី)បួននាក់គឺ ឧកញ្ញាចក្រី ជាសេនាខាងកងទ័ពជើងគោក នឹងដឹកនាំជើងគោក, ឧកញ្ញាក្រឡាហោម ជាសេនាខាងកងទ័ពជើងទឹកនឹងដឹកនាំផ្លូវទឹក, ឧកញ្ញាយមរាជ ជាសេនាបតីក្រសួងតុលាការ, ឧកញ្ញាវាំង ជាសេនាបតីខាងកិច្ចការព្រះរាជវាំងនិងហិរញ្ញវត្ថុ ( សូមអានសៀវភៅ «កាលប្រវត្តិវិទ្យានៃកម្ពុជា» របស្មេរត្រង់វគ្គទី១ ដែលចែងច្បាស់លាស់ពីរដ្ឋបាលក្រុង ខេត្ត គោរម្យងារ, ឋានន្តរស័ក្តិមន្ត្រី, ចៅហ្វាយខេត្ត, ស្តេចត្រាញ់ទាំងប្រាំ, កំណែនកងទ័ពនៃរបបសក្តិភូមិបូរាណខ្មែរ ) ។

កប៉ាល់យកទៅបំបរបង់ចោលឯកោះត្រឡាចទៅ ។

ក្នុងខែមេសា១៨៦២ សម្ដេចសុទសប៉ាបះបោរកេណ្ឌទ័ពនៅខេត្តសំរោងទង (ខេត្តកំពង់ស្ពឺ) តែត្រូវបរាជ័យចាប់បានសម្លាប់ចោល ។

ក្នុងឆ្នាំកុរបញ្ចស័ក១៨៦៤ បាវលោកឧកញ្ញាតេជោសុក, ខេត្តកំពង់ស្វាយ, ឈ្មោះស្វា រត់ទៅខេត្តទ្រាំងត្រើយត្បូង តាំងខ្លួនជាអង្គភឹម (២) បញ្ចុះបញ្ចូលរាស្ត្រឲ្យបានទ័ពច្រើន លើកមកតាំងនៅស្រុកជើងកញ្ចុំសង្កត់យកខេត្តពាម បន្ទាយមាស ទ្រាំង ព្រៃកប្បាស ។ វេលាយប់ស្ងាត់ មេបះនេះនាំសេនាលុកឧកញ្ញាចក្រីកែប អនិច្ចកម្មនៅខេត្តទ្រាំងទៅ ។

ចៅហ្វាយខេត្តយួននៅខេត្តមាត់ជ្រូក ( Chaudoc ) បានគាំទ្រចលនាបះបោរនេះ (3) ។ ដោយបារាំងធ្វើការគំរាមខ្លាំង ទើបឧបរាជយួនព្រមប្រគល់ខ្លួនអាចារ្យស្វានៅខែសីហា១៨៦៦ ។ តែនៅខែមករា មុនប្រគល់ខ្លួនអាចារ្យស្វា យួនបង្កើតចលនាបះបោរមួយទៀត ដោយបញ្ចេះឲ្យគ្រូអាគមឈ្មោះដើមន្ទូ តាំងខ្លួនជាពោរកំបោរ កេណ្ឌទ័ពតំបន់រោងដំរីច្បាំងដណ្ដើមរាជ្យ ។ ឯពោរកំបោរពិតនោះ ជាបុត្រាព្រះអង្គច័ន្ទទី២ បានសុគតនៅក្រុងឧត្តុង្គតាំងពីព្រះជន្ម៨ខែម្ល៉េះ (4) ។ ឧបរាជយួនខេត្តលង់ហោរបានគាំទ្រចលនាបះបោរនេះ (5) ។ ចំបាំងនេះស៊ីពេលអស់ជិត២ឆ្នាំ ទំរាំសម្លាប់ពោរកំបោរបាននៅខែធ្នូ១៨៦៧ នៅទួលបង់បត់ ភូមិស្វាយភ្លើង តាំងគោក ដោយឧបាយរបស់លោកឧកញ្ញាតេជោអ៊ីខេត្តកំពង់ស្វាយ ឯមន្ត្រីរាជការប្រជារាស្ត្រស្លាប់វិនាសអស់ជាច្រើននាក់ ។

យើងបានឃើញថា ព្រះអង្គឌួងបានឲ្យឧកញ្ញារាជាសេដ្ឋីកែបវាយយកខេត្តកម្ពុជាក្រោមវិញ តែដោយទ្រង់សុគតក្នុងឆ្នាំ១៨៦០ទៅ ឧកញ្ញាកែបក៏ផ្អាកសង្គ្រាមនោះសិន ក្រោយមកហ្លួងនរោត្តមបានតម្លើងងារឧកញ្ញាកែប ជាសេនាបតីទាហានជើងគោកជាទីចក្រីពេញយស រួចឲ្យលើកទ័ពទៅវាយខេត្តទ្រាំងត្រើយត្បូងទៀត។ ហេតុនេះហើយ ដើម្បីកុំឲ្យខ្មែរទៅវាយយកខេត្តកម្ពុជាក្រោមបាន មហាឧបរាជយួនដែលតាំងនៅខេត្តលង់ហោរ ( Vinh Long ) នោះក៏រកមធ្យោបាយគាំទ្រមេបះបោរអាចារ្យស្វា ឲ្យទៅលុកសម្លាប់ឧកញ្ញាចក្រីកែបទាល់តែបាន ។ ក្រោយមកទៀតយួនគាំទ្រចលនាបះបោរពោរកំបោរទៀត គឺក្នុងគោលបំណងធ្វើឲ្យខ្មែរមានចលាចលក្នុងស្រុក ហើយគ្មានឱកាសនឹងវាយយកខេត្តកូសាំងស៊ីនមកវិញ ។ ខ្មែរក៏ធ្លាក់ក្នុងឧបាយកលយួន ដែលប្រើកល្បយកធ្យូងលាបមុខមាន់ឲ្យជល់គ្នា ខ្មែរក៏ច្បាំងកាប់សម្លាប់តែគ្នាឯង ហើយគ្មានឱកាសនឹងវាយយកខេត្ត ដែលយួនប្លន់យកនោះមកវិញឡើយ ។ ចំបាំងក្នុងស្រុកខ្មែរសព្វថ្ងៃ ( ១៩៧៩-១៩៩០ ) ក៏ជានយោបាយដដែលដែលយួនយកមកប្រើឲ្យខ្មែរសម្លាប់តែគ្នាឯង ។

(២) អង្គភឹមជាបុត្រារបស់ឧបរាជអង្គអ៊ីម ដែលលួចភៀសចេញពីបាត់ដំបង (សៀម) ដោយចាញ់ឧបាយកលយួន ត្រូវទ្រឿង-មិញយ៉ាងឃុំទុកនៅខេត្តលង់ហោរ ឯអង្គភឹមពិតប្រាកដនោះបានសុគតរួចទៅហើយនៅទីនោះ ។

# អាណាព្យាបាលបារាំង

ដើម្បីឲ្យរួចចាកពីជំរៀតជំរែកបរទេសជិតខាង ព្រះនរោត្តមក៏ដាក់ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង ដោយសន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ។ ដោយសារការបះបោរទាំងពីរលើកនោះ បារាំងបានថ្កោលទោសថា មកពីផ្នែករដ្ឋបាលខ្មែរខ្សោយ ។ បារាំងយល់ឃើញថា របៀបរដ្ឋបាលរបស់ព្រះនរោត្តមមិនល្អ ក៏មានបំណងសើរើកែប្រែរដ្ឋបាលបែបថ្មី ។ នៅឆ្នាំ១៨៨៣ លោក Charles Thomsonបានមកជាអភិបាលឥណ្ឌូចិនផ្នែករដ្ឋបាលស៊ីវិល ។ លោកសំរេចថាត្រូវតែបង្ខំឲ្យព្រះនរោត្តមឡាយព្រះហត្ថលេខាក្នុងការប្រគល់កិច្ចការផែនដីខ្មែរទៅបារាំងកាន់កាប់ទាំងអស់ ។ គេបានគ្រោងទុកថា បើព្រះនរោត្តមមិនព្រមទេនោះ គេនឹងបង្ខំឲ្យព្រះអង្គដាក់រាជ្យ រួចហើយលើកព្រះស៊ីសុវត្ថិដែលគាំទ្របារាំងនោះឲ្យឡើងសោយរាជ្យវិញ ។ តាំងពីយប់ភ្លឺនៃថ្ងៃទី១៧មិថុនាឆ្នាំ១៨៨៤ ដើម្បីអនុវត្តការនោះ លោកថុមសុនបានបើកកាប៉ាល់ឈ្មោះស៊ីល្វូអែតមកចតនៅចំមុខវាំងភ្នំពេញ (6) ។ ដល់ម៉ោងប្រហែល១០យប់ លោកកាន់សំណុំលិខិតចូលទៅជួបព្រះនរោត្តម ដោយមានទាហានប្រដាប់អាវុធសំឡូត ( ទ្វារបាលនិងឧកញ្ញាវាំងមិនឲ្យចូលព្រោះស្តេចកំពុងផ្ទំ លោកថុមសុនយកជើងឈ្វសទ្វារក្រឡាបន្ទំឡើងគ្រាំង ) ។ បើព្រះនរោត្តមមិនព្រមចុះព្រះហត្ថលេខាទេនោះ ទ្រង់ត្រូវតែដាក់រាជ្យ ព្រះនរោត្តមក៏ព្រមចុះហត្ថលេខាទាំងទើសទាល់និងពិរោធ (7) ដោយសុខចិត្តប្រគល់អមណាចកិច្ចការផែនដីទៅរាជការបារាំងចាត់ចែងរៀបចំ ។ ប្រាំមួយខែក្រោយមកទ្រង់ក៏តម្លើងងារភក្តីឈូក ជាមហាតលឹកឲ្យគ្រងងារជាឧកញ្ញាពិស្ណុលោកឈូក ជា



កប៉ាល់ឈ្មោះ សាល្វូអែត ដែលបារាំងបានជិះមកបង្ខំព្រះករុណាព្រះបាទនរោត្តម ឲ្យឡាយព្រះហត្ថលេខាលើអនុសញ្ញាឆ្នាំ១៨៨៤ ។



ចេតិយតំកល់ធាតុព្រះចៅពញា-យ៉ាតលើភ្នំដូនពេញ ( រូបថតឆ្នាំ ១៨៨៥ ) ខាងលិចព្រះវិហារ បា-រាំងបានឲ្យធ្វើជាធ្នើនៅកចេតិយ ដើម្បីឲ្យទាហានស្រួលមើលចលនាពួកបះបោរសម័យពិស្ណុលោកឈូក និងក្រឡាហោមគង់ ដោ-យឡើងតាមជណ្តើរឫស្សីផ្អែកនិងចេតិយ ។ កំពូលចេតិយត្រូវរន្ទះបាញ់បាក់ក្នុងសម័យសាធារណរដ្ឋលន់-នល់ឆ្នាំ១៩៧០ ។

ស្ដេចត្រាញ់ដែនដីទ្រាំងត្រួតខេត្តប្រាំពីរគឺ ៖ បន្ទាយមាស បាទី ព្រៃកប្បាស ពាម កំពត កំពង់សោម និងកោះកុង ហើយឲ្យលោកចាត់ចែងប្រមូលកេណ្ឌទ័ពធ្វើស-ង្គ្រាមតស៊ូវាយបារាំង ដើម្បីយកអំណាចមកឲ្យព្រះអង្គវិញ ។ ក្នុងពេលជាមួយគ្នានោះដែរ អ្នកដែលជួយឧកញ្ញាពិស្ណុលោកឈូកក្នុងចំបាំងរវាងទ័ពបារាំង គឺមានបាឡាត់ង៉ែត ឧកញ្ញាហ៊ីង បាឡាត់ឈុប វង្សាអគ្គរាជកែវ ហើយសុទ្ធតែមានកងទ័ពរៀងៗខ្លួន ឯចិនឈ្មោះលីខ្វាងឃឹម ក៏មានទ័ពចិននៅតំបន់កំពតបះបោរវាយបារាំ-ងដែរ (8) ។ ដោយឈឺចិត្តនឹងបារាំងដកយកបឹងឡនេសាទ ដែលប្រជារាស្ត្រខ្មែរធ្លាប់រកត្រីផ្គត់ផ្គង់គ្រួសារ ហើយលក់ទៅឲ្យដង្វៅយួន លោកឧកញ្ញានរាធិបតីប្រាក់ព្រមទាំងក្រមការក្រោមបង្គាប់ក្នុងខេត្តព្រៃវែងបានរត់ចោលរាជការ ហើយទៅកទ័ពវាយបារាំងដែរ (9) ។ ក្នុងពេលនោះមានខ្មែរជាច្រើនទៀតដែលកទ័ពវាយបារាំ

ងដូចជាបណ្ឌិតនូនៅបាភ្នំ ឧកញ៉ាសួគ៌ាលោកនៅខេត្តពោធិសាត់ អាចារ្យសេងនៅល្វាឯមជាដើម (10) ។

ថ្ងៃមួយពេលដេញពួកបណ្ឌិតប្រាក់ដែលរត់គេចបាត់ត្រង់មុំវត្តកោះក្របី លោកសក្តិពីរបារាំងម្នាក់ បានចូលទៅសាកសួររកចោរនោះ ពីលោកគ្រូចៅអធិការគង់ដែលកំពុងតែឆាន់អាហារថ្ងៃត្រង់ លោកបានប្រាប់ថាពុំបានឃើញទេ ទាហានបារាំងនោះសំឡុត ហើយយកម្រាមដៃទៅចង្អុលថ្ងាសលោក ។

ថ្ងៃមួយពេលដេញពួកបណ្ឌិតប្រាក់ដែលរត់គេចបាត់ត្រង់មុំវត្តកោះក្របី លោកសក្តិពីរបារាំងម្នាក់ បានចូលទៅសាកសួររកចោរនោះ ពីលោកគ្រូចៅអធិការគង់ដែលកំពុងតែឆាន់អាហារថ្ងៃត្រង់ លោកបានប្រាប់ថាពុំបានឃើញទេ ទាហានបារាំងនោះសំឡុត ហើយយកម្រាមដៃទៅចង្អុលថ្ងាសលោក ។ ដោយសេចក្តីប្រមាថនេះ ក្នុងយប់នោះ លោកគ្រូចៅអធិការគង់ ដែលសុទ្ធជាសិស្សជំនិតរបស់លោកផ្ទាល់ ។ ទីកន្លែងកទ័ពដំបូងគឺ នៅក្រោមដើមអំពិលរៀច ភូមិអំពិលរៀច ក្នុងស្រុកកណ្តាលស្ទឹង (៤) ។ ក្រោយមកលោកប្រមូលបានឧបាសកជាច្រើនជាកងទ័ពព្រមទាំងរទេះក្របី សេះ ដំរី ជាច្រើនសំរាប់ដឹកស្បៀងផង ។ ងារជាឧកញ៉ាក្រឡាហោម គឺជាងារដែលរាស្ត្របានដាក់ឲ្យលោកជាបណ្តោះអាសន្នទេ ដើម្បីកុំឲ្យអន់ជាឧកញ៉ាពិស្ណុលោកឈ្យូកតែប៉ុណ្ណោះ ។ មេទ័ពរងឈ្មោះបេងរបស់លោក ក៏ទទួលងារជាវិបុលបេងដែរ ។ ទ័ពរបស់លោកធ្វើសកម្មភាពនៅតំបន់ស្អាង តំបន់រាយដប ខេត្តកណ្តាលស្ទឹង ។ ក្រោយមក ដោយបារាំងវាយបំបែកបន្ទាយដែលលោកកំពុងសង់នៅតំបន់ក្រាំងតាផូ ឧកញ៉ាក្រឡាហោមគង់ក៏បញ្ជូនទ័ពដកថយចូលទៅក្នុងខេត្តបាទី ។ យប់ឡើងលោកនាំទ័ពវាយឆ្មក់សម្លាប់ទាហានបារាំង-យួន ដែលសំរាកនៅក្នុងវត្តទន្លេបាទី ។ ក្រោយមកលោករួបរួមទ័ពជាមួយឧកញ៉ាពិស្ណុលោកឈ្យូក វាយអន្ទាក់ចាំស្ទាក់វាយទ័ពបារាំង រហូតបានជ័យជំនះនៅស្ទឹងស្លាគូ សម្លាប់ទាហានបារាំងជាច្រើននាក់ កាត់ក្បាលដោតនៅមាត់ស្ទឹងស្លាគូនោះផង ។

ខាងខេត្តត្បូងឃ្មុំក៏មានចៅហ្វាយស្រុកនិងក្រមការ កេណ្ឌទ័ពបះបោរវាយបារាំងដែរ ដូចជាបាឡាត់នៅ ( ឆ្លូង-ក្រចេះ ), អាចារ្យពៅ ( ក្រូចឆ្មារ ), បាឡាត់ម៉ា ( កំពង់ចាម ), បាឡាត់ស្រី ( ខាងជើងព្រៃវែង ) (៥) ។ លោកឧកញ៉ាមហាវិជ័យស្រុកព្រៃឈរ និងមេទ័ពទន់ក៏កេណ្ឌទ័ពវាយបារាំងដែរ (10) ។ ទ័ពតស៊ូមានប្រមាណជាប្រាំមួយទៅប្រាំបីពាន់នាក់ គេមានតែកាំភ្លើងបូរាណតិចតួច លំពែង ដាវខែលជាអាវុធ ។

(៤) លោកតា នូ ជីតារបស់អ្នកគ្រូជា-ស៊ីនី ធ្លាប់បាននិទានឲ្យខ្ញុំស្តាប់ក្នុងឆ្នាំ១៩៦៤-៦៥ ។ ផ្ទះគាត់និងផ្ទះខ្ញុំនៅជិតគ្នា នៅទន្ទឹមនឹងផ្ទះលោកសឹង-ភឿកថ (អតិតចាងហ្វាងសារព័ត៌មានមាតុភូមិ) ផ្លូវលេខ២៩០ ខាងកើតសាលាបឋមសិក្សាអង្គអេង។ លោកតានេះចាំរឿងក្រឡាហោមគង់ពីដើមដល់ចប់ តែគួរឲ្យស្តាយដោយលោកតាបានបាត់បង់ជីវិតក្នុងសម័យខ្មែរក្រហម ជាមួយនិងកូនចៅ នៅសល់តែប្អូនស្រីអ្នកគ្រូពីរនាក់ដែលរស់នៅក្នុងរបបហេង-សំរិន ។ តានូបានឧទានពីឧបាយដែលទ័ពចិនខ្វាងឃីម ធ្វើជាដួលស្លាប់អស់ពេលបារាំងបាញ់ ដល់ទាហានយួនបារាំងដើរចូលទៅមើលខ្មោចដោយមិនប្រយ័ត្ន ទ័ពចិនក៏ងើបឡើងកាប់ សម្លាប់បារាំងនិងភាពល្ងង់នៃខ្មែរកាលនោះ ឃើញទ័ពបារាំងដេកដាក់កាំភ្លើងចោល គេមិនលបទៅយកកាំភ្លើងទេ បែជាពោទីស្គរយកជ័យមុនបារាំងភ្ញាក់ឡើងទាញកាំភ្លើងបាញ់ស្លាប់ជាច្រើន ។

(៥) Etude Cambodgienne. No.11, Juillet - Septembre, 1968, page 39



តំបន់ដែលចលនាតស៊ូរបស់ឧកញ្ញាក្រឡាហោមគង់ និងឧកញ្ញាពិស្ណុលោកឈូក
ធ្វើសកម្មភាពប្រឆាំងនឹងអាណានិគមបារាំង ដើម្បីយកអំណាចមកឲ្យហ្លួងនរោត្តមវិញ

ខាងខេត្តកំពង់ស្វាយ ព្រះអង្គម្ចាស់ស៊ីវត្ថា ដែលច្បាំងដណ្ដើមរាជ្យពីព្រះនរោត្តម ជាព្រះរាមនោះ នៅតែកាន់កាប់ទ័ពនៅតាមដងស្ទឹងសែននៅឡើយ តែឯកសារមិនបានបញ្ជាក់ថា ម្ចាស់ស៊ីវត្ថាបានចូលរួមក្នុងចលនាតស៊ូឆ្នាំ១៨៨៤-១៨៨៦ ឬទេ ។

ខេត្តពោធិសាត់មានឧកញ្ញាសួគ៌ាលោកជ័យកេណ្ឌទ័ពវាយឆ្មក់សង្កាត់និងប៉ុស្តិ៍បារាំងជាញឹកញាប់ ។ បារាំងមិនអាចដើរ ឬចេញឆ្ងាយពីខេត្តពោធិសាត់បានឡើយ

ឯខេត្តកំពង់ឆ្នាំងវិញ មានទ័ពលោកបាឡាត់ដុន ងារជាផ្លូវសង្គ្រាម តាំងបន្ទាយនៅតំបន់ក្រួស ប្រមូលទ័ពពីរលៀប្មៀរ ប្រុងលើកទៅវាយក្រុងកំពង់ឆ្នាំង ។

នៅពាក់កណ្ដាលឆ្នាំ១៨៨៦ ទ័ពសេនាប្រាក់និងសេនាសុខ យកបានស្រុក

ក្រុង, ទ័ពបាឡាត់កែ-ទល់, វង្សាស្រី-កុយ, សេនារុំទ្ធ នៅភ្នំក្រវាញ ។ ទ័ពលោកឧកញ្ញាប៉ុល ជាចៅហ្វាយស្រុក តាំងនៅស្រុកទទឹងថ្ងៃ (៦) ។

ដោយខ្វះសហប្រតិបត្តិការរួមរវាងចលនាបះបោរទាំងអស់ និងភាពខ្សត់ខ្សោយខាងសព្វាវុធនោះ ចលនាតស៊ូមិនអាចវាយតទល់ជាមួយទ័ពបារាំងបានឡើយ គេប្រើមធ្យោបាយតាមការយល់ឃើញរបស់មេទ័ព ឬមេបះបោរម្នាក់ៗ និងប្រើវិធីកងទ័ពឆ្មក់តែប៉ុណ្ណោះ ដែលធ្វើឲ្យទ័ពបារាំងមានការលំបាកជាខ្លាំង ក្នុងការបង្ក្រាបចលនាតស៊ូខ្មែរពេលនោះណាស់ ។ កាលនោះបារាំងបានចំណាយជីវិតទាហានបារាំង-យួនអស់ខ្ទង់បួនពាន់នាក់ (11) ហើយ នៅតែបង្ក្រាបខ្មែរមិនបានទៀត ទើបបារាំងកែប្រែនយោបាយ ។ លោក Piqet ជារ៉េស៊ីដង់ស៊ុប៉េរីយើរ បានផ្ញើលិខិតទៅរាជការបារាំងរាយការណ៍ពីរឿងខ្មែរប្រឆាំងនឹងកំណែទំរង់ ។ ក្នុងថ្ងៃសៅរ៍ ១០ កើត ខែកត្តិក ឆ្នាំចអដ្ឋស័ក គ.ស.១៨៨៦ បារាំងធ្វើជាប្រគល់អំណាចកិច្ចការផែនដីមកព្រះនរោត្តមវិញ ។ ព្រះនរោត្តមបានទៅសង់ព្រះពន្លានៅព្រៃទទឹង (កំពង់ស្ពឺ) ហើយកោះហៅឲ្យមេចលនាតស៊ូទាំងអស់ចូលគាល់ និងបញ្ឈប់ការតស៊ូតទៅទៀត ។ មេដឹកនាំការតស៊ូខ្មែរទាំងអស់ បានចូលមកគាល់ព្រះនរោត្តម លើកលែងតែឧកញ្ញាពិស្ណុលោកឈ្យូក និងឧកញ្ញាក្រឡាហោមគង់ ដែលសន្យាថានឹងចូលគាល់នៅឯក្រុងភ្នំពេញថ្ងៃក្រោយវិញ ។ ហ្លួងបានសន្យាថា នឹងរៀបពិធីផ្តល់ឋានន្តរស័ក្តិក្រឡាហោមគង់និងឧកញ្ញាពិស្ណុលោកឈ្យូក ឲ្យពេញយសជាសេនាបតី នៅ ហ្លួងបានសន្យាថា នឹងរៀបពិធីផ្តល់ឋានន្តរ ស័ក្តិក្រឡាហោមគង់និងឧកញ្ញាពិស្ណុលោកឈ្យូកឲ្យពេញយសជាសេនាបតី នៅរាជវាំងក្រុងភ្នំពេញ ។ ការតស៊ូនេះបានស៊ីពេលវេលាអស់ពីរឆ្នាំ ។ រាជាណាចក្រស្ថិតនៅក្នុងសភាពតោកយ៉ាក ហើយបណ្តាលឲ្យរាស្ត្រនៅខេត្តក្រៅមានសេចក្តីលំបាកជាខ្លាំង ។ ពេលប្រតិបត្តិការសឹកទាហានបារាំងបានធ្វើបាបគំរាមកំហែងនិងដុតផ្ទះសំបែង ។ អ្នកស្រុករត់គេចបួនក្នុងព្រៃ ។ គ្រួសារត្រូវបាក់បែកព្រាត់ប្រាស់គ្នា និងបាត់បង់ជីវិតអស់ជាច្រើន ។ អ្នកដែលបានបាត់បង់អ្វីៗអស់រលីងនោះ ក៏ចូលរួបរួមជាមួយក្រុមអ្នកតស៊ូដែលមានធនចាស់ៗ ស្ត្រីនិងកូនក្មេងជួយផ្គត់ផ្គង់ខាងស្បៀងអាហារ (12) ។

ដោយសេចក្តីច្រណែនខ្លាចក្រឡាហោមគង់បានធំជាង នាម៉ឺនវាំងម្នាក់ក៏នាំលោកថាទៅដើរលេងតាមមាត់ទន្លេ ពេលទៅដល់កបាល់ចំបាំងបារាំង នាម៉ឺនក្បត់ខ្មែរនោះក៏ឲ្យទាហានបារាំងចាប់លោកដាក់ខ្នោះ ចងអោបបំពង់ផ្សែង រួចសណ្តូនថ្មទម្លាក់ចោលក្នុងទឹកទន្លេទៅ។ ឯឧកញ្ញាពិស្ណុលោកឈ្យូកបានទៅសំណាក់នឹងផ្ទះលោកប្រសើរសុរិយវង្សម៉ៅ ដែលត្រូវជាឪពុកមាលោកនៅផ្សារកាប់គោ ក្រោយមកនៅផ្ទះលោកដែលមាលោកបានសង់ឲ្យនៅជិតវត្តបទុមវត្តី ។ ថ្ងៃមួយដោយអស់កម្លាំងពេក (ព្រោះពេលយប់លោកមិនសូវបានសំរាន្តប្រយ័ត្នខ្លួន) ពេលលោកទំរេតខ្លួនលើក្តារង្លឿ មានឃាតករម្នាក់បានឡើងលបតាមផ្ទះបាយ ទៅបាញ់សម្លាប់លោកស្លាប់ទៅ (៧) ។

ដោយសារបារាំងមើលឃើញថា របបរដ្ឋបាលរបស់ខ្មែរសម័យហ្លួងនរោត្តម

(៦) Etude Cambodgienne. No.12, Octobre - décembre, 1967, pasge 27

(៧) សូមអានសៀវភៅឧកញ្ញាពិស្ណុលោកឈ្យូក, ឧ-គាម និង Etude cambodgienne No.18, 1969




នោះជារបបចាស់ មិនមែនជាការិយាល័យនិយម ហើយជារបបពុករលួយថែមទៀត ទើបបារាំងសំរេចធ្វើការកែប្រែផ្នែករដ្ឋបាល តុលាការ ពាណិជ្ជកម្ម ឯពន្ធដារឈប់ឲ្យចៅហ្វាយស្រុកទារយកពីរាស្ត្រផ្ទាល់ បន្ថយចំនួនចៅហ្វាយខេត្ត ( កាលដើម ហៅថាចៅហ្វាយស្រុក ឧទាហរណ៍ចៅហ្វាយស្រុកសំរោងទង ។ល។ ) ដោយយក ខេត្តតូចៗខ្លះមករួមបញ្ចូលជាខេត្តមួយដូចជា ខេត្តស្ទឹងត្រែង ខេត្តកំ-ពង់សៀម ខេត្តជើងព្រៃ រួមជាខេត្តកំពង់ចាមជាដើម ។

កំណែទំរង់រដ្ឋបាលបែបនេះ ធ្វើឲ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ពួកមន្ត្រីនាហ្មឺនខេត្ត ក្រុង និងព្រះរាជា ព្រមទាំងព្រះរាជវង្សានុវង្ស ដែលស្មួយសារអា-ករបានមកពីការទារពន្ធពីរាស្ត្រដោយពួកចៅហ្វាយខេត្ត រួចខេត្តឡើងស្មួយទៅមន្ត្រីក្នុងក្រុង តាមដែលព្រះរាជាបានកំណត់ ឲ្យខេត្តណាឡើងមកមន្ត្រីណាមួយឬឡើង ទៅព្រះរាជាដូចជាដែនដីទ្រាំងត្រូវឡើងស្មួយទៅឧកញ្ញាយមរាជជាដើម ។ល។ (13)

ការដែលលោកថុមសុនបានឡោមវាំង ហើយគំរាមព្រះនរោត្តមឲ្យឡាយព្រះហត្ថលេខាលើសន្ធិសញ្ញានៃកំណែទំរង់នោះ បានធ្វើឲ្យព្រះនរោត្តមប្រឆាំងតបវិញព្រោះធ្វើឲ្យព្រះអង្គអស់អំណាចរលីង ព្រះអង្គក៏ចាត់ឲ្យបំបះរាស្ត្រខ្មែរឡើងវាយបារាំងដើម្បីយកអំណាចមកវិញ ។

ដើម្បីឈានចូលក្នុងការពិចារណារកបុព្វហេតុជាសារវន្តនានា ដែលបណ្ដាលឲ្យមានការកាប់សម្លាប់រង្គាលប្រជារាស្ត្រខ្មែរជាងបីលាននាក់នោះ គប្បីលើកយកគំនិតប្រឆាំងតបសកម្មភាពបះបោរតស៊ូដែលរាស្ត្រខ្មែរបានឆ្លើយតបទៅនឹងរបបជិះជាន់អាណានិគមបារាំងនៅដើមសតវត្សទី២០នេះ ព្រោះព្រឹត្តិការណ៍ទាំងអស់នោះហើយដែលជាកត្តាបង្កើតឲ្យមានចលនាស្នេហាជាតិ រំដោះជាតិ មានចលនាខ្មែរឥ-ស្សរៈ ខ្មែរវៀតមិញ ខ្មែរសេរី ខ្មែរក្រហមជាលំដាប់ហូរហែមក ។

ថ្វីបើសង្គ្រាមលោកលើកទី១មិនបានប៉ះពាល់ដល់ដែនដីឥណ្ឌូចិនក៏ដោយ តែ




ចលនាតស៊ូនៅខេត្តត្បូងឃ្មុំនិងខេត្តកំពង់ស្វាយ ក្នុងឆ្នាំ១៨៨៥

ដើម្បីជួយដល់ស្ថានភាពសេដ្ឋកិច្ចនៅស្រុកបារាំងអាណានិគមបារាំងបានតម្លើងពន្ធ អាករយ៉ាងធ្ងន់នៅឥណ្ឌូចិន ។ ប្រជាកសិករខ្មែរសម័យនោះក្រីក្រណាស់ ក្នុងមួយឆ្នាំៗ គ្រួសារអាចលក់ស្រូវបានប្រហែល៨០រៀល ឯពន្ធឡើងដល់ទៅ១២រៀលទៅហើយក្នុងមួយឆ្នាំ ។ កសិករក៏កើតមានការមិនសប្បាយចិត្ត ហើយបានលើកគ្នាប់ពាន់នាក់ មកពីតំបន់ខេត្តកំពង់ឆ្នាំ ខេត្តខាងកើតទីក្រុងភ្នំពេញ ចូលមកទូលសុំហ្លួងស៊ីសុវត្ថិបន្ថយពន្ធដារ ។ ព្រឹត្តិការណ៍ជាដំបូងកើតឡើង នៅដើមខែវិច្ឆិកា ១៩១៥ ដោយមានប្រជារាស្ត្រប្រមាណបីរយនាក់ ចូលទៅទាមទារសុំឲ្យហ្លួងបញ្ចុះពន្ធ ។ ក្រោយមកទៀតនៅដើមឆ្នាំ១៩១៦ ការទាមទារបានរាលដាលដល់ខេត្តភាគខាងកើតទីក្រុងភ្នំពេញ ដោយមានប្រជារាស្ត្ររាប់ម៉ឺននាក់ ចូលរួមក្នុងក្បួនបាតុកម្មដើរចូលមកក្នុងទីក្រុងភ្នំពេញ ។ គេពុំបានស្គាល់មេបាតុកម្មនោះទេ ហើយការទាមទារនោះក៏មិនទាន់ច្បាស់ថា ធ្វើឡើងដើម្បីប្រឆាំងនឹងបារាំងនៅឡើយដែរ តែគេសំគាល់ដឹងថា ពួកបាតុករបានពោលថា បារាំងបានធ្វើឲ្យយើងមិនសប្បាយចិត្តជាខ្លាំងអស់ពេលជាច្រើនឆ្នាំមកហើយ ដោយយកតែមនុស្សអាក្រក់មកធ្វើជាស្តេចសោយរាជ្យ និងមន្ត្រីរាជការ ហើយគំរាមកំហែងសង្កត់សង្កិនធ្វើបាបតែមនុស្សល្អ (14) ។

នៅថ្ងៃទី១៨មេសាឆ្នាំ១៩២៥ ដោយហេតុអ្នកស្រុកក្រាំងលាវមិនព្រមបង់ពន្ធ លោកប៉េស៊ីដង់ ខេត្តកំពង់ឆ្នាំងក៏អញ្ជើញទៅផ្ទាល់ដោយមានអ្នកបកប្រែភាសាម្នាក់ និងប៉ូទីសង់ម្នាក់ទៅផង ។ លោកបានចាប់អ្នកស្រុកខ្លះដែលមិនព្រមបង់ពន្ធដាក់ខ្នោះនៅលើសាលា ហើយកំហែងថានឹងយកទៅដាក់គុកទៀតផង ។ គាត់មិនអនុ-

ញ្ញាតឲ្យអ្នកទោសទទួលទានបាយឡើយ តែផ្ទុយទៅវិញគាត់អាស្រ័យបាយថ្ងៃត្រ-
ង់ធ្វើអឹងអើយ ។ កំហឹងដល់ក ប្រជារាស្ត្រក្រើក្រទាំងនោះប្រមាណសាមសិបនាក់
ក៏ឡោមវាយលោករ៉េស៊ីដង់Bardez ព្រមទាំងសហការីស្លាប់ទៅហើយកាប់ចិញ្ច្រាំ
សាកសពខ្ទេចខ្ទីថែមទៀត ។ ហ្លួងស៊ីសុវត្ថិបានបញ្ជូនព្រះអង្គម្ចាស់ស៊ីសុវត្ថិ-មុនីវ
ង្សជារាជបុត្រឲ្យទៅពិនិត្យហេតុការណ៍ ។ ក្រោយមកហ្លួងក៏ចេញរាជក្រិត្យដាក់
ទណ្ឌកម្មអ្នកស្រុកក្រាំងលាវទាំងអស់ បញ្ចូលជាអ្នកងារជាប់កំណែន ដើម្បីធ្វើបុ-
ណ្យរំលឹកថ្ងៃដែលលោក Bardez ត្រូវសម្លាប់ ហើយប្រែឈ្មោះភូមិក្រាំលាវឲ្យ
ហៅថា « ភូមិតិរច្ឆាន » វិញតាំងពីថ្ងៃនោះមក (15) ។ បន្ទាប់ពីសន្តិសិទហ្សឺណែវ
ភូមិក្រាំងលាវក៏ក្លាយមកជាមូលដ្ឋានបដិវត្តន៍ពួកខ្មែរក្រហម ហើយកូនស្រីម្នាក់
នៃអ្នកភូមិនេះបានក្លាយមកជាប្រពន្ធរុង-លើត (នួន-ជា) ។


ព្រះបាទស៊ីសុវត្ថិ

ព្រឹត្តិការណ៍ឆ្នាំ១៩១៦និងឆ្នាំ១៩២៥ ជាលំអានឲ្យខ្មែរចេះភ្ញាក់រលឹក ចេះតវ៉ាប្រឆាំងនឹងការសង្កត់សង្កិនពីរបបត្រួតត្រា ។ ព្រឹត្តិការណ៍ទាំងពីរនេះជាដើមអាទិនៃគំនិតគំនិតស្នេហាជាតិ ដែលបានចាប់បដិសន្ធិឡើងជាដំបូងបង្អស់ក្នុងចំណោមរៀមច្បងបញ្ញវ័ន្តខ្មែរនៅចុងឆ្នាំ១៩៣០ ហើយចាប់រីកដុះដាលយ៉ាងខ្លាំង បន្ទាប់ពីការបង្កើតពត៌មានខ្មែរជាដំបូងក្នុងឆ្នាំ១៩៣៦ឈ្មោះ « នគរវត្ត » ដោយក្រុមប្រជាធិបតេយ្យមាននិន ការសេរីនិយមប្រឆាំងស្តេច ដឹកនាំដោយលោកប៉ាច-ឈឺននិងលោកស៊ឹម-វ៉ា់រ ដែលពេលខាងក្រោយបន្ថិចមក មានលោកសឺង-ង៉ុកថាញ់ ( អតិតសុភាចារបុរសខេត្តពោធិសាត់ និងអតិតនិស្សិតស្រុកបារាំង ) បានចូលរួមផងដែរ (16) និងព្រះសង្ឃចេះដឹងជាន់ខ្ពស់ខាងពុទ្ធចក្រមួយចំនួនមាន លោកគ្រូប៉ាង-ខាត់, អាចារ្យខៀវ-ជុំ, អាចារ្យអ៊ុក-ជា, លោកគ្រូអាចារ្យហែម-ចៀវជាដើម...។

ក្រោយមកអ្នកស្រីស៊ុយសាន-កាពើលេស ( Suzanne Karpeles ) បានសុំយកលោកសឺង-ង៉ុកថាញ់ឲ្យមកធ្វើជាបណ្ណាគារ័ក្សនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិ ត ដែលជាឱកាសឲ្យលោកធ្វើការទាក់ទងស្គាល់លោកគ្រូអាចារ្យហែម-ចៀវ ដែលមានឈ្មោះល្បីល្បាញពូកែទេសនាណាស់នៅសម័យនោះ ហើយមានពុទ្ធសាសនិកជនជាច្រើនចូលចិត្តស្តាប់ធម្មទេសនារបស់លោកគ្រូនេះណាស់ (17) ។

លោកសឹង-ង៉ុកថាញ់បានយកគំនិតស្នេហាជាតិ ទៅផ្សព្វផ្សាយនឹងព្រះសង្ឃជាសមណសិស្សនៅពុទ្ធិកវិទ្យាល័យពុទ្ធសាសនបណ្ឌិត ដោយធ្វើការទាក់ទងជាមួយលោកគ្រូអាចារ្យហែម-ចៀវ ដើម្បីជួយទេសនាពន្យល់ឲ្យខ្មែរភ្ញាក់រលឹកឡើង ។ ដោយហេតុនេះហើយ ទើបខ្មែរនិងគិញបារាំងបានទៅទូលពិតបារាំង ឲ្យមកចាប់អាចារ្យហែម-ចៀវផ្សឹកនៅថ្ងៃទី១៧ កក្កដា ១៩៤៣ (៥) រួចភ្លាមមួយរំពេចនោះ គេក៏នាំលោកដាក់ឡានបញ្ជូនទៅព្រៃនគរ ហើយបញ្ជូនទៅគុកកោះត្រឡាចក្នុងខែមិថុនា ១៩៤៣ ។ ប្រាំមួយខែក្រោយមក លោកមានជម្ងឺរាគមួលរហូតបាត់បង់ជីវិតទៅ ។ សៀវភៅលោកគង់-សម្ភារបានសរសេរថា សម្តេចសីហនុជាអ្នកខ្សឹបឲ្យបារាំងចាប់អាចារ្យហែម-ចៀវ (៦) ។

បីថ្ងៃក្រោយមក ព្រះសង្ឃសមណសិស្សជាងប្រាំរយអង្គ រួមជាមួយគ្រហស្ថជាង៥០០នាក់ បានដើរហែរក្បួនសំដៅទៅអាគាររ៉េស៊ីដង់បារាំងនៅវត្តភ្នំ ទាមទារឲ្យបារាំងដោះលែងអាចារ្យហែម-ចៀវមកវិញ ។ ដោយខ្វះរបៀបរៀបរយ ការទាមទារក៏មិនបានផលលោកប៉ាច-ឈឺន, លោកប៊ុណ្ណចន្ទម៉ុល, លោកអាចារ្យនួន-ឌួងក៏ត្រូវបារាំងចាប់យកទៅដាក់គុកទៀត ។ លោកសឹង-ង៉ុកថាញ់រត់ចូលពួននៅក្នុងបន្ទាយអាវុធហត្ថជប៉ុន នាយទាហានជប៉ុនជួយលាក់ហើយបណ្តោះលោកសឹង-ង៉ុកថាញ់ឲ្យទៅជ្រកកោននយោបាយនៅក្រុងតូក្យូប្រទេសជប៉ុន ។ ឯលោកប៊ុណ្ណ-ចន្ទម៉ុល, លោកប៉ាច-ឈឺន, អាចារ្យនួន-ឌួង ត្រូវបញ្ជូនទៅឃុំនៅគុកកោះត្រឡាចមុនលោកអាចារ្យហែម-ចៀវបន្តិច ។

(៥) អាចារ្យហែម-ចៀវ និពន្ធដោយគង់-សម្ភារ ទំព័រ៤៣ ។
(៦) អាចារ្យហែម-ចៀវ និពន្ធដោយគង់-សម្ភារ ទំព័រ៤២ ។

# ចលនាតស៊ូខ្មែរឥស្សរៈ

ព្រឹត្តិការណ៍ថ្ងៃ៩ មិនា ១៩៤៥ ជប៉ុនចងបារាំងនៅឥណ្ឌូចិនទាំងមូល ។ នៅថ្ងៃនេះ ស្តេចក្មេងសីហនុមានការភ័យភិត ហើយភៀសខ្លួនចេញពីវាំងចតុមុខទៅពួនលាក់ខ្លួននៅកុដិសម្តេចវត្តបទុមវត្តិ មេទ័ពជប៉ុនតាមទៅរកឃើញហើយក៏យកមកឲ្យអង្គុយលើបល្ល័ង្ករាជ្យវិញ នេះបើតាមសេចក្តីឲ្យការណ៍របស់លោកតូច-ឈ្លួង អ្នកនិពន្ធសៀវភៅ «បាត់ដំបងសម័យលោកម្ចាស់ » ។ ជប៉ុនបានជួយលោកសឺង-ង៉ុកថាញ់ឲ្យវិលត្រឡប់ពីជប៉ុនចូលមកក្នុងស្រុកខ្មែរក្នុងខែឧសភា១៩៤៥ (៧) ក្រោយពីលោកស្នាក់នៅតូក្យូកាលពីសម័យបារាំងចាប់អាចារ្យហែម-ចៀវមក ។ នៅថ្ងៃទី១៣ មិនា ១៩៤៥ ជប៉ុនបានឲ្យព្រះចៅលាវ, សម្តេចសីហនុ និងស្តេចយួនបៅ-ដាយ ប្រកាសប្រទេសឯករាជ្យ តែកាលនោះពួកវៀតមិញមិនព្រម ហើយហូ-ជីមិ-ញក៏វាយដណ្តើមយកទីក្រុងហាណូយបាន (18) ។

ថ្ងៃទី២០ កក្កដា ១៩៤៥ លោកប៉ាច-ឈឺន, ប៊ុណ្ណ-ចន្ទម៉ុល, នួន-ឌួង បានត្រូវគេដោះលែងមកវិញ ។ ស្តេចសីហនុបានធ្វើជាប្រធានក្នុងការជួបប្រជុំរំលឹកដល់បាតុ-កម្មព្រះសង្ឃកាលឆ្នាំ១៩៤២ ដោយមានលោកប៉ាច-ឈឺនជាអ្នកថ្លែងសុន្ទរកថារំលឹកពីការបះបោរប្រឆាំងស្តេចក្នុងឆ្នាំ១៨៦០, ការតស៊ូវាយបារាំងឆ្នាំ១៨៨៤-១៨៨៦, ព្រឹត្តិការណ៍ឆ្នាំ១៩១៦, ព្រឹត្តិការណ៍ Bardez, បាតុកម្មព្រះសង្ឃឆ្នាំ១៩៤២ ។

នៅថ្ងៃទី៨-៩សីហា រដ្ឋាភិបាលអ៊ុំង-អ៊ីដែលរណបបារាំងត្រូវរលំ ។ ស្តេចសីហនុបានតែងតាំងលោកសឺង-ង៉ុកថាញ់ជារដ្ឋមន្ត្រីការបរទេស រួចជានាយករដ្ឋមន្ត្រី (19) តាមការស្នើររបស់ជប៉ុន ។ នៅពាក់កណ្តាលខែតុលា១៩៤៥ ទ័ពសម្ពន្ធមិត្តដែលមានទាហានអង់គ្លេស-ឥណ្ឌាចូលមកដល់ព្រៃនគរ ។ លោកឃឹម-ទិតដែលទទួលបេសកកម្មទៅចរចាជាមួយបារាំងបានក្បត់ ( សីហនុចូលរួមផង ) ។ គ្រាប់បែកមរមាណូពីរគ្រាប់ទម្លាក់នៅអ៊ីរ៉ូហ្ស៊ីម៉ា-ណាហ្កាសាគី ធ្វើឲ្យជប៉ុនចុះចាញ់ ។ ថ្ងៃទី១៦ តុលា១៩៤៥ លោកសឺង-ង៉ុកថាញ់ដែលទើបឡើងជានាយករដ្ឋមន្ត្រីត្រូវបារាំងចាប់ (20), អាចារ្យអ៊ុក-ជា, អាចារ្យខៀវ-ជុំភៀសព្រះអង្គទៅសៀម, លោកប៊ុណ្ណ-ចន្ទម៉ុល, នួន-ឌួងគេចខ្លួនទៅបាត់ដំបង ដែលកាលណោះស្ថិតនៅក្រោមការត្រួតត្រារបស់ថៃ ។ លោកសឺង-ង៉ុកថាញ់ត្រូវតុលាការបារាំងនៅព្រៃនគរចោទថាជាអ្នកចូលដៃជាមួយជប៉ុន ហើយសកម្មភាពលោកជាការគំរាមកំហែងដល់សន្តិសុខនៃកងទ័ពសម្ពន្ធមិត្ត តែស្តេចសីហនុបានសុំបារាំងឲ្យនិរទេសលោកសឺង-ង៉ុកថាញ់ទៅស្រុកបា-រាំងនៅតំបន់ Poitiers (21) អស់រយៈ៦ឆ្នាំ គឺរហូតដល់ឆ្នាំ១៩៥១ (22) ។ អ្នកដែល

(៧) នាមដើមគឺ គង់-ឈ្លួន ជាអតីតទាហានបារាំងក្នុងសង្គ្រាមថៃ-បារាំងឆ្នាំ១៩៤២ រត់ទៅចូលថៃដោយចង់បានបុណ្យស័ក្តិខ្ពស់ពាក់ត្រឹមនាយដាប (ដោយ) ហេតុនេះគង់-ឈ្លួនក៏យកស័ក្តិនាយដាបធ្វើជានាមត្រកូលវិញ ។ ដាប-ឈ្លួនក៏រត់ចូលខ្មែរឥស្សរៈ រួចចុះចូលជាមួយសីហនុក្នុងឆ្នាំ១៩៤៩ ហើយបានទទួលបុណ្យជាស្តេចត្រាញ់ មេទ័ពខេត្តសៀមរាបនិងកំពង់ធំ ។ នៅចុងឆ្នាំ១៩៥៨ សីហនុបានចាញ់កងទ័ពខេមរភូមិន្ទទៅព័ទ្ធផ្ទះដាប-ឈ្លួន ព្រោះបានក្បត់ប្រុងធ្វើរដ្ឋប្រហារ ដោយមានការគាំទ្រពីក្រុមសេអ៊ីអាអាមេរិ-កាំង និងសង្ស័យថាលោកសឺង-ង៉ុកថាញ់បានចូលរួមផង ។ ចំរើន-ស៊ិនបានចាត់ឲ្យស័ក្តិពីរហេង ជាជំ-និតដាប-ឈ្លួនតាមទៅសម្លាប់បាន រួចទាក់កអូសតាមឡានមក ។

ចូលរួមតស៊ូជាមួយលោក ក៏គេចបែកគ្នាជាពីរក្រុម ។ ក្រុមទី១ ភៀសខ្លួនទៅបាសាក់កម្ពុជាក្រោម មានលោកប៉ាច-ឈឺន, ចៅសែន-កុសលឈុំ, អ្នកស្រីសឺង-ង៉ុកថាញ់នាមដើមឡាំ-ធីអ៊ុក និងបក្សពួកជាច្រើននាក់ទៀត ។ ក្រុមទី២គេចទៅបាត់ដំបងមានលោកប៊ុណ្ណ-ចន្ទម៉ុល, នួន-ឌួងជាដើម (23) ។ កាលនោះបាត់ដំបងស្ថិតនៅក្រោមការត្រួតត្រាថៃតាំងពីឆ្នាំ១៩៤១ដល់១៩៤៦ ។

ដើម្បីធ្វើការតស៊ូនឹងបារាំងទៀត ដោយមានការគាំទ្រពីលោកប៉ុក-ឃុនជាមាផងនិងការគាំទ្រពីរាជរដ្ឋាភិបាលថៃផង លោកប៊ុណ្ណ-ចន្ទម៉ុលក៏បង្កើតចលនាតស៊ូរំដោះជាតិហៅថា « ខ្មែរឥស្សរៈ » ឡើង នាចុងឆ្នាំ១៩៤៥ ។ តាមលោកម៉ុលថា ខ្មែរឥស្សរៈមានន័យថាធំ, មិនកញ្ជះគេ, ជាអ្នកជា (24) មានគោលដៅរំដោះស្រុកពីនឹមអាណានិគមបារាំង ។ ក្នុងសៀវភៅ « ចរិតខ្មែរ » លោកចន្ទម៉ុលបានរៀបរាប់ឈ្មោះមេខ្មែរឥស្សរៈដំបូងគឺមាន ៖ ហែម-សាវាង, ហែម-សាវ៉ាត, សារូ, ទ្រង់ចន្ទរង្សី, ឈៀង, ចន្ទ-តោត្រេស, ផាន-សាឃុ, រស់-យិន, ហ៊ូ, អ៊ុក-សាន, ពុំ, ភោគ-នី។ល។ ក្រោយមកទាក់ទងបាន កៅ-តក់, ស៊ីវ-ហេង, ដាប-ឈួន ថែមទៀត (៧) ។ លោកប៊ុណ្ណ-ចន្ទម៉ុល និងប៉ុក-ឃុន ជាអ្នករត់ការទាក់ទងចុះឡើងបាងកក សុំកាំភ្លើងខ្លះពីអាជ្ញាធរថៃ និងទិញកាំភ្លើងថែមពីបាងកកមកទៀត ។ លោកចន្ទម៉ុលបានសរសេរពីកំហកចិត្តយ៉ាងខ្លាំងរបស់លោក លើសកម្មភាពព្រៃផ្សៃរបស់ពួកខ្មែរឥស្សរៈ ខុសចាកគំនិតដើមក្នុងការតស៊ូជាមួយបារាំង ។ ក្រោយមកទៀតដោយការច្រណែនគ្នារវាងពួកឥស្សរៈ ការប្រទូស្តរាយកាប់សម្លាប់គ្នាឯងក៏កើតមានឡើង ព្រមគ្នាជាមួយការលូកដៃយ៉ាងជ្រៅនៃក្រុមយួនវៀតមិញមកក្នុងចលនាខ្មែរឥស្សរៈ ។ ក្នុងចំណោមមេឥស្សរៈដែលលោកប៊ុណ្ណ-ចន្ទម៉ុលនិងប៉ុក-ឃុនជាអ្នកបង្កើត មានតែកៅ-តក់និងដាប-ឈួនទេ ដែលមានឈ្មោះល្បីល្បាញជាងគេ ។ ដាប-ឈួនមានឈ្មោះល្បីខាងសាហាវកាប់សម្លាប់គ្នាឯង ដើម្បីកុំឲ្យអ្នកណាលើសជាងខ្លួន មានការបញ្ឆោតយកហែម-សាវាង, ហែម-សាវ៉ាត ទៅសម្លាប់ចោលជាដើម ។ ក្រោយមកពួកឥស្សរៈក៏បាក់បែកគ្នាមានទ័ពរៀងៗខ្លួន ទៅតាំងនៅទីដទៃពីគ្នា ៖ លោកចន្ទរង្សីនៅច្បារមនកំពង់ស្ពឺ, ដាប-ឈួននៅសៀមរាប, កៅ-តក់នៅឧត្តរមានជ័យ...។ ដើម្បីរកសោហ៊ុយទប់ទល់ការចំណាយចិញ្ចឹមទ័ព ខ្មែរឥស្សរៈក៏ធ្វើការរៃអង្គាសឬជួនកាលទៅប្លន់តែម្តង ។ ដល់ក្រោយមកមានកើតឥស្សរៈក្លែងក្លាយ ដែលរាស្ត្រសាមញ្ញខ្សឹបគ្នាថា « ឥស្សរ៉ោចាក់ » គ្រលាស់មកថា « ឥស្សរៈចោរ » ។ ឯសៀវភៅ « ចរិតខ្មែរ » របស់លោកប៊ុណ្ណ-ចន្ទម៉ុលក៏បានសរសេរពីត្រង់នេះដែរ, ដូចជាពួកចោរឃីនៅកំពង់ចាម-ព្រៃវែង, និងកំណើតពួកឥស្សរៈដែលឆ្លៀតឱកាសកសាងនិងតាំងខ្លួនដើម្បីរកលាភសក្ការៈ ដូចជាពួក ពុត-ឆាយ ( អតីតជនបោឡែ ល្បែងស៊ីសង ), ស័ក្តិមួយធិញ (អតីតទាហានបារាំង), ស័ក្តិបីស៊ាប (អតីតទាហានបារាំង) ជាដើម ដើរប្លន់អ្នកស្រុកចិនផ្សារ អ្នកមានបង្គួរនៅតាមជនបទ មានចាប់ឲ្យយកលុយទៅលោះជាដើម ។ល។ ប្រជាជនមានសេចក្តីរងទុក្ខវេទនាណាស់ ពេលយប់ឡើងគឺនាំគ្នាភិតភ័យមិនដឹងថាតើគ្រោះអន្តរាយនឹងធ្លាក់មកលើគ្រួសារខ្លួនឬមួយក៏ទេ។ មេខ្មែរឥស្សរៈទាំងអស់ក្នុងសម័យនោះ, ដូចគ្នានឹងសម័យបះបោរឆ្នាំ១៨៨៤-៨៦ដែរ គឺពួកគេមិនចុះសំរុងរួបរួមគ្នាជាកម្លាំងកំចាត់សត្រូវរួមទេ, នេះហើយជាចរិតមួយរបស់ខ្មែរ, ម្នាក់ៗ

ខិតខំកសាងកម្លាំងនិងកិត្តិយសខ្លួនឲ្យបានខ្ពង់ខ្ពស់ល្បីខ្ទរខ្ទារពូកែ ដោយជឿស៊ប់ទៅលើមន្តអាគមគាថា បាញ់មិនមុតដុតមិនឆេះ បំបាំងខ្លួន...ដូចជាពុត-ឆាយដែលល្បួងសុំកូនប្រពន្ធខ្លួនឯងមានផ្ទៃពោះ រួចហើយរៀបចំធ្វើហោមពិធីរានទេវតាបាយសី១២ថ្នាក់ និងគ្រឿងសក្ការៈបូជាយ៉ាងច្រើនទៀត រួចក៏សម្លាប់ប្រពន្ធខ្លួននោះវះយកកូនរុំអំបោះឆៅ ឆ្អើរទុកជាប់នឹងខ្លួនជាកូនក្រក ដែលគាត់មានជំនឿថាអាចជួយគាត់ដឹងជាមុននូវគ្រោះអាសន្នដល់ខ្លួន និងជួយឲ្យរួចពីការពួនស្ទាក់ដោះចំណោមជាដើម... និងជំនឿច្រើនទៀត មានកន្សែង យ័ន្ត ខ្លកតេជៈ (៨), ខ្សែរកថា, នាងពួនចែកាច់(៩), កណ្តាញ់សក់លើ, កណ្តាញ់សក់ក្រោមរបស់ស្រី(១០), កាសក្របីកាសមនុស្ស(១១), ខ្នាយតាន់(12), ព្រះសិរិទ្ធិ(១៣ ), កូនសង្កត់(១៤), នខ្វាក់(១៥), ប៉ែតដានសារដាន(១៦)ទាំងអស់នេះសុទ្ធតែជាវត្ថុដែលពួកបះបោរឥស្សរៈខំស្វះស្វែងរកដើម្បីធ្វើឲ្យខ្លួនគេខ្លាំងពូកែ ។ ក្រៅពីនេះទៀត ពួកឥស្សរៈតែងធ្វើការកាប់សម្លាប់គ្នាទៅវិញទៅមក ដូចជាស័ក្តិមួយធិញត្រូវពុត-ឆាយបញ្ឆោតយកទៅសម្លាប់ចោលជាដើម ។ ថែមលើការប្រទូស្តរាយបំបាក់គ្នាកុំឲ្យមានគេខ្លាំងលើសជាងខ្លួនម្នាក់ៗនោះ ពួកយួនវៀតមិញបានលូកចូលមកយ៉ាងជ្រៅក្នុងចលនាខ្មែរឥស្សរៈ លាបមុខពួកនេះឲ្យសម្លាប់គ្នាទៅវិញទៅមក ។ ពុត-ឆាយមានឈ្មោះល្បីខាងកាប់សម្លាប់ពួកអាណិកជនជាតិយួនយ៉ាងចាស់ដៃ ( សូមអានកំពប់តែអុង) (១៧) ពួកវៀតមិញក៏រកស្រីក្រមុំយួនយ៉ាងស្អាតទៅជូនឲ្យធ្វើជាប្រពន្ធចុង ទើបពុត-ឆាយឈប់សម្លាប់យួនតាំងពីនោះមក ។

កាលពីខ្ញុំអាយុ៧ឆ្នាំ ក្នុងចុងឆ្នាំ១៩៥១ ខ្ញុំនៅចាំថា គឺពួកចោរអាចារ្យឃីនេះឯងដែលមានគ្នាប្រហែលម្ភៃនាក់ លើកគ្នាទៅប្លន់ផ្ទះចិកណាំ ដែលស្ថិតនៅទល់មុខផ្ទះកំណើតខ្ញុំ ក្នុងឃុំល្វា ស្រុកព្រៃឈរ ( ខេត្តកំពង់ចាម ) ។ កាប់បំបែកទ្វារផ្ទះ ចូលទៅចាប់ចិកណាំនិងប្រពន្ធកូនចងកាប់បំបែកទូយកមាសប្រាក់ ហើយបាញ់មួយគ្រាប់សំដៅមកផ្ទះខ្ញុំបែកក្បឿង ដោយខ្លាចគ្រួសារខ្ញុំចុះទៅជួយ ព្រោះជីតាខាងម្តាយខ្ញុំជាឃោក្សាត់សាលាស្រុកព្រៃឈរ និងមានកាំភ្លើងប្រមាញ់នៅលើផ្ទះផង ។ ខ្ញុំនៅចាំបានទៀតថា កាលនោះដោយផ្ទះកំណើតខ្ញុំធំពេក ( ជីតាខ្ញុំបានទៅនៅឯព្រៃទទឹង ដោយសាលាស្រុកបានរើផ្លាស់ចេញពីទួលចាក់អង្ករទៅព្រៃទទឹង ក្រោយមកទួលចាក់អង្ករក្លាយជាសាលារៀនបឋមសិក្សាឃុំល្វា )(១៨) ឪពុកខ្ញុំបានកាត់ផ្តាច់រានហាលដែលភ្ជាប់ទៅផ្ទះបាយខាងក្រោយ ហើយដាក់ឈើស្នួទៅផ្ទះបាយពេលថ្ងៃ ពេលយប់ហូតឈើស្នួនោះចូលមកផ្ទះធំវិញ ដាក់រនុកទ្វារយ៉ាងមាំ រួចនាំគ្នាឡើងទៅសំរាកនៅលើឡៅដែលចាក់ស៊ីម៉ង់ ។ នៅទីនោះឪពុកខ្ញុំបានទាំងប្រមូលយកដុំថ្មជាច្រើនទៅគរទុក ធ្វើស្នួដងយ៉ាងវែងសំរាប់ចាក់ពីលើផ្ទះ បើពួកចោរចូលប្លន់សំរាប់ទុកតទល់ ឯឃុំវិញផ្ទះមានរបងបន្លាយ៉ាងក្រាស់ របងមានទ្វារនិងរនុកយ៉ាងមាំ ហើយឪពុកខ្ញុំថែមទាំងបានចិញ្ចឹមឆ្កែជាងដប់សំរាប់ការពារផ្ទះផង ។

ក្នុងសម័យឥស្សរៈនោះ អ្នកមានបង្គួរ ចិនផ្សារ នាំគ្នារត់ចាកចេញពីផ្សារថ្កល់បែក ឃុំល្វា បោះបង់ចោលផ្ទះតៀម នាំគ្នាទៅនៅកំពង់ចាមខ្លះ ព្រៃទទឹងខ្លះ ភ្នំពេញខ្លះនៅសល់តែគ្រួសារចិនបី-បួនគ្រួប៉ុណ្ណោះដែលត្រដររស់នៅទីនោះ ដូចជាគ្រួសារចិកមុយ ( អតីតមេឃុំល្វា ), គ្រួសារចិកណាំ និង២-៣គ្រួសារទៀតដែលខ្ញុំមិនចាំ ។

ប្រជាជននៅភូមិក្នុងៗបាននាំគ្នាសែងផ្ទះឈើអើមកតាំងនៅតាមដងផ្លូវជាតិដែលមា-នសន្តិសុខជាង ។

រឿងឥស្សរៈនេះក៏ជាបុព្វហេតុធំដែលធ្វើឲ្យគ្រួសារខ្ញុំបោះបង់ស្រុកកំណើតមករស់នៅភ្នំពេញ កាលពីពាក់កណ្ដាលឆ្នាំ១៩៥២ដែរ ដោយពុំអាចទ្រាំទ្ររស់នៅទីនោះកើត ។ សូមជំរាបថា ក្រោយជប៉ុនចងបារាំង កំឡុងឆ្នាំ១៩៤៥ ( តាមសំដីឪពុកខ្ញុំដំណាលប្រាប់ ) ឪពុកខ្ញុំដែលជាបុគ្គលិកកសិកម្មនៅកោះព្រែង ក្រចេះ ក៏មានការភិតភ័យខ្លាចកងទ័ពជប៉ុនចាប់ ក៏លាក់ខ្លួនហែកអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួនចោ-ល រួចគេចមកសម្ងំនៅផ្ទះឃុំល្វា ។ ក្រោយជប៉ុនចាញ់ មិនចូលធ្វើការវិញទេ ហើយយកប្រាក់សន្សំខ្ទង់ប្រាំម៉ឺនរៀលរួមនឹងប្រាក់មិត្តភក្តិជំនួយខ្លះ មករកស៊ីធ្វើជាដង្វៅស្រូវ ប្រមូលទិញស្រូវកិននិងត្បាល់កិនសាមញ្ញ នាំចុះទៅលក់ឯព្រៃនគរ ។ មនុស្សម្នាក់ឈ្មោះថីសន ជាទំនុកចិត្តដែលឪពុកខ្ញុំជួលឲ្យដើរប្រមូលស្រូវ បានបោកយកប្រាក់ជាងបីម៉ឺនរួចរត់ចូលឥស្សរៈអាចារ្យឃី ហើយផ្ដាំឲ្យឪពុកខ្ញុំតាមទៅយកលុយនោះពីពួកចោរថែមទៀតផង ។ របរទិញស្រូវនៅសម័យឥស្សរៈក៏ត្រូវខាតបង់ទាំងដើមទាំងចុង និងជំពាក់មិត្តភក្តិថែមទៀត ដែលជាបុព្វហេតុធ្វើឲ្យគ្រួសារខ្ញុំសុខចិត្តចាកចោលស្រុកកំណើត ដោយឪពុកខ្ញុំបានចូលធ្វើជាបុគ្គលិកគណនេយ្យនៅបេសកកម្មទាហានបារាំង ( Mission Militaire Française : MMF ) នៅខាងលិចជាប់អាគារ រ៉េស៊ីដង់ បារាំងនៅវត្តភ្នំ ។

ដោយសារចង់បានបុណ្យស័ក្តិ ពួកខ្មែរឥស្សរៈក៏បាត់បង់គំនិតស្នេហាជាតិអស់រលីង ដូចជាករណីដាប-ឈួន ដែលមកសុំចុះចូលជាមួយសីហនុក្នុងឆ្នាំ១៩៤៩ ហើយបានសីហនុលើកជាស្ដេចត្រាញ់ត្រួតខេត្តកំពង់ធំនិងសៀមរាប ។ ពួកពុត-ឆាយ, ច័ន្ទ-រង្សី ក៏ចុះចូលជាមួយសីហនុនៅក្នុងឆ្នាំ១៩៥២ ។ ក្រោយមកនៅឆ្នាំ១៩៥៥ ដាប-ឈួនបានសម្លាប់កៅ-តក់(១៩) នៅជិតផ្សារពួក សៀមរាប ពេលកំពុងរៀបចំឈរជាបេក្ខជនតំណាងរាស្ត្រមណ្ឌលក្រឡាញ់-ពួក ។ កាលពី២ខែមុនឃាតកម្មនេះ ពេលកៅ-តក់កំពុងបើកឡានហ្ស៊ីបមកបាត់ដំបង មានឡាន GMC ទាហានមួយមកពីសៀមរាបកៀរឡានកៅ-តក់ទម្លាក់ទៅក្នុងស្នាមភ្លោះ ។ ឈ្មោះអុនដែលត្រូវជាក្មួយប្រសារកៅ-តក់ បានធ្លាក់ពីលើឡានបោកក្បាលនឹងថ្មស្លាប់ទៅ ។ មួយអាទិត្យក្រោយមក ពេលកៅ-តក់ឡើងជិះឡានឈ្នួល ធ្វើដំណើរទៅសាលាខេត្តសៀមរាបដើម្បីធ្វើលិខិតផ្សេងៗ ក្នុងការឈរបេក្ខជនតំណាងរាស្ត្រនោះ ពួកដាប-ឈួនដែលតាមកៅ-តក់ពីរខែមកហើយនោះ បានដកកាំភ្លើងខ្លីភ្ជង់កៅ-តក់ នាំចុះពីឡានឈ្នួលចូលដុប ( បីគីឡូម៉ែត្រទៀតដល់ផ្សារពួក ) ។ ដឹងថាគេប្រុងសម្លាប់ខ្លួនហើយ កៅ-តក់ក៏ប្រយុទ្ធដៃទទេដោះខ្លួន ។ ហេតុតែមិនដឹងខ្លួន ថាគេតាមប្រុងព្យាបាទសម្លាប់ខ្លួននោះ ទើបកៅ-តក់មិនមានដាក់អាវុធការពារខ្លួន ។

(៨) ជាបន្ទះសំណមាសឬទង់ដែងចារមន្តអាគមយន្ត មូរបង្កកក្នុងខ្សែវេញជាមួយបញ្ញើក្អែក ដុះលើឈើកំរដូចឬស្សី, ពោធិ, ខ្លឹមស្នោរ... ជ្រលក់ជ័រម្រាក់ ពាក់នៅក្បាលក្នុងការប្រយុទ្ធរបស់ខ្មែរសម័យអង្គរ ។
(៩) ដំរីស្រុកខ្មែរដែលគ្មានភ្លុក មានតែចៃដែលមិនអាចដុះវែងបាន ព្រោះវាធ្វើឲ្យដំរីនៅមិនសុខនឹងចៃនេះ ក៏បុកកប់ទៅក្នុងដើមឈើ កាច់បំបាក់ចោល ហៅថាចៃកាច់ ។ បើសំបកឈើដុះកប់បាត់ គេហៅនាងពួន ។ គេមានជំនឿថា អាចជួយបញ្ចៀសគ្រាប់កាំភ្លើងធ្នូស្នាបាន ។
(១០) គេជឿថាមានប្រសិទ្ធិភាពអាចបញ្ចៀសគ្រាប់កាំភ្លើង ( ក្ដុំស័ក្តិប្រពន្ធដាប-ឈួន មានកណ្ដាញ់នេះ ) ។

(១១) ឆ្អឹងក្រអូមមាត់រាងសំប៉ែតប៉ុនកាក់ ( គោក្របីឬមនុស្សតែកំរមានណាស់ ) អាចការពារគ្រាប់រំសេវ ។
(១២) ខ្លាឃ្មុំជ្រូកភាគច្រើនៗប្រហោង កំរមានតាន់ គេជឿថាអាចការពារភ្លើងឆេះនិងគ្រាប់រំសេវបាន ។
(១៣) ជាវត្ថុកសាងឡើងតាំងពីជំនាន់សម័យអង្គរ សំរាប់ពួកទាហានកាន់ការពារខ្លួនពេលសង្គ្រាម ។ គេសាងពីសិរិទ្ធិ ដោយមានបញ្ចុះអាគមនិងលោហធាតុជាច្រើនមុខ និងរៀបហោមពិធីតាមសាសនាព្រាហ្មណ៍ ស្លទំហំប៉ុនម្រាមដៃជារូបព្រះពុទ្ធ ព្រះសិអារ្យ និងអាទិទេពសាសនាហិណ្ឌូជាច្រើន ដូចជាព្រះឥសូរ ព្រះនរាយណ៍ ព្រះភគនេស ព្រះខ្ទម(បីទមុខ) ព្រះកច្ចាយ ព្រះក្រុង... ជាវត្ថុកំរដែលជនជាតិសៀមនិងខ្មែរស្វះស្វែងរកទុកការពារខ្លួននឹងគ្រោះថ្នាក់សព្វយ៉ាង និងការពារកាំភ្លើងគ្រាប់រំសេវ ។
(១៤) ជាដុំសំណាមូល ដែលគេចារយ័ន្តនិងអាគម រួចដំលុញឲ្យមូល រៀបហោមពិធីប្រសិទ្ធីឲ្យខ្លាំងពូកែ ។
(១៥) ជាតួព្យញ្ជនៈ ន តែខុសគ្នាទាំងរាងទាំងអក្សរអម មានចំនួន១០៨តួ កំរមានអ្នកចេះនខ្វាក់និមួយៗមានការប្រើផ្សេងពីគ្នា តាំងពីការពារអំពើ ស្នេហ៍ សត្រូវ សត្វសាហាវ ការពារគ្រាប់កាំភ្លើង ។
(១៦) មិនដឹងពីជំនាន់ណាមក គេយកធម៌ព្រះពុទ្ធ នមោពុទ្ធាយ មអឧ ឥតិបិសោ... ភគវាតិ តាំងជា៨ៗ ត្រូវជា៦៨តួ រួចគេទាញចុះឡើងចំនួន១០៨យ៉ាងផ្សេងគ្នា ដូចជា ប៉ែតដាន សារដាន ទាក់ដាន វង់ដាន ថយល័ងមហាឥស្សរោ សំណាញ់ពេជ្រ ឥតិបិសោលោតជើងសេះ មហាពុទ្ធា រនាំងពេជ្រ ឥតិបិសោមូរឆ្វេង មូរស្តាំម្កុដព្រះ និងយ័ន្តឥតិបិសោមួយចំនួន គេជឿថាស័ក្តិសិទ្ធិពូកែអាចការពារគ្រាប់រំសេវ ។
(១៧) សូមអានសៀវភៅ កាលប្បវត្តិវិទ្យានៃប្រទេសកម្ពុជា របស់ស្មេរត្រង់ទំព័រ១២៧ ។
(១៨) ហេតុបានជាបារាំងយកទីតាំងទួលចាក់អង្ករជាសាលាស្រុកព្រៃឈរ ព្រោះឃុំល្វាជាលំនៅស្ថានឧញ្ញាមហាវិជ័យ អតីតចៅហ្វាយស្រុកព្រៃឈរពីជំនាន់ហ្លួងនរោត្តមមក ។ ពេលបារាំងធ្វើកំណែទំរង់ រដ្ឋបាលខ្មែរគេក៏បង្កើតសាលាស្រុកនៅទីនោះ ។ ទីទួលស្ថិតនៅខ្ពង់៤០០ម៉ែត្រចុះពីផ្លូវជាតិ ទីជុំវិញជាវាលស្រែ ជាចំណុចគ្រោះថ្នាក់ បើកាលណាពួកបះបោរធ្វើការហ៊ុំព័ទ្ធ ទើបបារាំងលើកសាលាស្រុកទៅនៅព្រៃទទឹងវិញក្នុងរវាងឆ្នាំ១៩៤៨ ចម្ងាយ២៣គីឡូម៉ែត្រពីក្រុងកំពង់ចាម ១៨គីឡូម៉ែត្រពីប្រជុំជនផ្សារស្គន់ ។
(១៩) ពត៌មាននេះផ្ទួយពីសំណេរប៉ិណ្ណ-ចន្ទម៉ុលក្នុងសៀវភៅចរិតខ្មែរ ដែលថាកៅ-តក់ បានទៅសុំខ្ចីប្រាក់ដាប-ឈ្មួនមករកស៊ី ហើយដាប-ឈ្មួនក៏សម្លាប់កៅ-តក់ចោលទៅ ព្រោះខ្លាចធំជាងខ្លួន ។ លោកស៊ិម-គិនត្រូវជាក្មួយកៅ-តក់ និងជាអតិតខ្មែរសេរីបានឲ្យការថា លោកស័ក្តិប្រាំម៉ម-សារ៉ាត ដែលសព្វថ្ងៃរស់នៅរដ្ឋ Origan សហរដ្ឋអាមេរិក ជាទាហានជំនិតដាប-ឈ្មួនបាននិយាយប្រាប់ថា ការសម្លាប់កៅ-តក់គឺសម្តេចសីហនុបានបញ្ជាពីភ្នំពេញ មកឲ្យដាប-ឈ្មួនសម្លាប់កៅ-តក់ឲ្យបាន ព្រោះជាមេទ័ពខ្លាំងរបស់សឹងង៉ុកថាញ់ ដែលសម្តេចសីហនុចាត់ទុកជាសត្រូវទី១របស់ទ្រង់ ។

# ប្រវត្តិសង្ខេបរបស់កៅ-តក់

អ្នករស់នៅជាយដែនខ្មែរថៃ តោងតែជាអ្នកក្លាហាន ( អ្នកលេងឬដង្ហៅ ) ។ ក្នុងសម័យអាណានិគមបារាំង អ្នកលេងជាយដែនកៅ-តក់ ជាអ្នករកស៊ីនាំប្រហុក ត្រីងៀត ត្រីឆ្អើរ ពីបាត់ដំបង សៀមរាប ដឹកយកទៅលក់នៅខេត្តសុរិនស្រុកសៀម រួចទិញក្រណាត់នាំត្រឡប់មកវិញ ។ នៅពេលជប៉ុនវាយយកឥណ្ឌូចិននោះ ថៃដែលជាសម្ពន្ធមិត្តជប៉ុន ក៏វាយកងទ័ពអាណានិគមបារាំងដែរ ។ ក្នុងសង្គ្រាមឈ្លានពាននេះ ថៃបានរកកៅ-តក់ធ្វើជាអ្នកនាំផ្លូវកងទ័ពថៃចូលវាយទ័ពបារាំងនៅស្រុកខ្មែរ ។ ឆ្នាំ១៩៤១ បារាំងសុខចិត្តប្រគល់បាត់ដំបង សៀមរាបទៅថៃ ។ ពេលនោះថៃបានសុំឲ្យកៅ-តក់ធ្វើជាទាហានថៃ តែកៅ-តក់មិនព្រម គ្រាន់តែសុំសិទ្ធិអាជ្ញាធរថៃឲ្យលោកអាចចុះឡើងពីបាត់ដំបង សៀមរាប នាំប្រហុក ត្រីងៀត ត្រីឆ្អើរ ទៅលក់នៅស្រុកថៃដូចកាលពីមុន ថៃក៏យល់ព្រមហើយបានជូនមេដាយកិត្តិយសមួយដល់កៅ-តក់ផង ។ ព្រឹត្តិការណ៍ឆ្នាំ១៩៤៥ ទ័ពសម្ពន្ធមិត្តបារាំង-អង់គ្លេសចូលមកឥណ្ឌូចិនវិញ លោកសឺង-ង៉ុកថាញ់ដែលទើបឡើងជានាយករដ្ឋមន្ត្រី ត្រូវបារាំងចាប់និរទេសទៅស្រុកបារាំង ។ ប៊ុណ្ណ-ចន្ទម៉ុល, អាចារ្យនួន-ឌួងបានភៀសខ្លួនចូលមកខេត្តបាត់ដំបង ហើយបានផ្តួចផ្តើមបង្កើតចលនាខ្មែរឥស្សរៈជាមួយមាប៉ុក-ឃុន ។ អ្នកទាំងពីរក៏រកអ្នកដែលមានសិទ្ធិអាចចុះឡើងពីបាត់ដំបង សៀមរាបទៅស្រុកថៃ ព្រោះត្រូវការទិញកាំភ្លើង ។ កៅ-តក់ក៏បានជួបជាមួយនិងអាចារ្យនួន-ឌួង នៅបាត់ដំបង ។ ក្រោយមកតែងទៅជួបពិភាក្សាគ្នានៅបណ្ណាគារលក់សៀវភៅមួយឈ្មោះ « បណ្ណាគារខ្មែរអូរជ្រៅ» នៅផ្សារក្រោម-បាត់ដំបង ។ ប៊ុណ្ណ-ចន្ទម៉ុលនិងនួន-ឌួង ក៏បញ្ចុះបញ្ចូលយកកៅ-តក់ឲ្យធ្វើជាមេឥស្សរៈម្នាក់ទៅជាមួយនឹងស៊ីវ-ហេង ដែលស្គាល់គ្នានៅបាត់ដំបង ហើយគ្រួសារទាំងពីរបានរស់នៅជាមួយគ្នាក្នុងជីវិតឥស្សរៈ ។ ឆ្នាំ១៩៥០-៥១ ក្រោយពីមានពួកវៀតមិញចូលមកជ្រៀតជ្រែកក្នុងចលនាខ្មែរឥស្សរៈនោះ លាវកែវ-មុនី, ម៉ា-មូន, ម៉ី-ផូ បានចូលជាមួយវៀតមិញ ដោយមានភ្នាក់ងាររបស់យួនជាទីប្រឹក្សានិងកងទ័ពយួននៅជាមួយផង ។ កៅតក់ និងលាវកែវ-មុនី ក៏បែកបាក់គ្នាជាពីរក្រុម Ben Kiernan បានសរសេរក្នុងសៀវភៅ **HOW POL POT CAME TO POWER** ថា បុព្វហេតុនៃការបែកបាក់គ្នា គឺបណ្តាលមកពីរឿងប្រាក់៦០០,០០០រៀល និងកៅ-តក់ធ្វើបាបអ្នកស្រុក ។ ឯការប្រយុទ្ធគ្នាក៏សៀវភៅនេះសរសេរខុសដែរថា ពួកកៅ-តក់ប្រយុទ្ធគ្នាជាមួយពួកលាវកែវ-មុនី នៅត្រង់ស្រុកបី តាមពិតពួកលាវកែវ-មុនីចូលមកខាងដែនដីកៅ-តក់ ហើយដេញបាញ់ពួកកៅ-តក់ដែលមានគ្នាតិច ត្រង់ភូមិក្រូចឆ្មារ ចម្ងាយ១៥គីឡូម៉ែត្រពីភូមិស្រុកបី (តាមសំដីកូនទាហានពីរនាក់ដែលនៅជាមួយកៅ-តក់ក្នុងការប្រយុទ្ធនោះ សព្វថ្ងៃរស់នៅ **Everett** រដ្ឋវ៉ាស៊ិនតោន ។ ដែនដីលាវកែវ-មុនី និងដែនដីត្រួតដោយកៅ-តក់ ចែកគ្នាត្រង់ស្ទឹង ។ ពួកលាវកែវ-មុនីឆ្លងស្ទឹងចូលមកមានគ្នាច្រើន ក៏ដេញបាញ់ពួកកៅ-តក់ ៗត្រូវរបួសភ្លៅកំប៉េះគូថក៏ដួលចុះ ។ នឹកស្មានតែស្លាប់ហើយ ពួកលាវកែវ-មុនីក៏ចូលមកយកកាំភ្លើង កៅ-តក់ដេកនៅដីក៏ទាញកាំភ្លើងកាប៊ីនបាញ់ស្លា



លោកកៅ-តក់

*ប់អស់ប្រាំបួននាក់វិញ ។ ពួកលាវកែ-មុនីជាងដប់នាក់ទៀតក៏ប្រាស់រត់យករួចខ្លួនតែរៀងៗខ្លួនទៅ ។ ពួកកូនចៅ
ក៏នាំគ្នាគ្រាសែងកៅ-តក់សំដៅទៅជាយដែន ទាហានខ្មែរ-បារាំងម្នាក់ដែលធ្លាប់ជួយឥស្សរៈ បានឲ្យថ្នាំនិងជួយរុំ
របួស ។ គេនាំកៅ-តក់ឆ្លងដែនចូលទៅស្រុកថៃ ទៅបាងកកដេកព្យាបាលនៅក្នុងពេទ្យមួយនៅត្រើយខាងលិច
ទន្លេចៅប្រះយ៉ា ឈ្មោះស៊ីរីរ៉ាត់ ( តាមសំនៀងភាសាថៃ បើខ្មែរថា សិរីរដ្ឋ ) អ្នកដែលនាំកៅ-តក់ទៅព្យាបាល និ
ងនៅបំរើក្នុងពេទ្យថៃនោះ គឺមួយឈ្មោះ សំ-ផុត ( ជីដូនមួយនិងលោកប៉ាន់-សុធី ) ដោយផ្លាស់ប្ដូរគ្នាជាមួយ
ឈ្មោះផល-ប៊ុនតូ ( សព្វថ្ងៃរស់នៅ* **Puyallup** *រដ្ឋវ៉ាស៊ិនតោន ) ។ ឯសៀវភៅ* **HoOW POL POT CAME TO
POWER** *និង* **Channa** *ថា កៅ-តក់មកដេកពេទ្យស្រុកខ្មែរទៅវិញ ។ បើកៅ-តក់ដេកពេទ្យស្រុកខ្មែរ ក៏នឹងត្រូវ
ទាហានខ្មែរ-បារាំងចាប់សម្លាប់ចោលជាមិនខាន ក្នុងដើម ( ថ្ងៃ១៣ កុម្ភៈ តាមឯកសារក្រសួងសម្ងាត់បារាំង ) ឆ្នាំ
១៩៥១នោះ ។*

*មួយទៀតយួនវៀតមិញបានទាំងយកក្មួយលាវកែវ-មុនីពីរនាក់ទៅបញ្ជូកទ្រឹស្ដីយួនួបនិយកម្មនៅហាណូ
យទៀតផង មួយឈ្មោះ បូ និងមួយទៀតឈ្មោះឈឿង ដោយធ្វើដំណើរចូលទៅស្រុកថៃ វាងទៅចូលខាងពោ
ធិសាត់ កំពត ទៅតាកែវ រួចទៅស្រុកយួន ។ ឯឈ្មោះ ផល-ប៊ុនតូ ( សព្វថ្ងៃរស់នៅរដ្ឋវ៉ាស៊ិនតោន ) ក៏ប្រុងប្រៀ
បរៀបចំខ្លួនចេញពីឧត្តរមានជ័យទៅស្រុកសៀម រួចបន្តទៅហាណូយទៀត តែក្រោយដឹងថា ពួកលាវកែវ-
មុនីចូលដៃជាមួយយួន និងមានភ្នាក់ងារយួនវៀតមិញនៅធ្វើការជាមួយក្នុងក្រុមស្នូលដឹកនាំផងនោះ ក៏ក្រាញមិ
នព្រមទៅ ។ សៀវភៅ* **HOW POL POT CAME TO POWER** *សរសេរត្រង់ទំព័រ៩៥ ថាកៅ-តក់និងលាវកែវ
មុនីឈ្មោះគ្នាដោយសារប៉ុក-ឃុនយកប្រាក់៦០០ពាន់រៀល សំរាប់ទិញកាំភ្លើង និងដោយសារកៅ-តក់ធ្វើបាប
ប្រជាជន ។ អ្នកនិពន្ធចៀសវាងមិនសរសេរពីជំរៀតជំរែកយួនមកក្នុងចលនាខ្មែរឥស្សរៈទេ ពេលនោះស៊ីវ-ហេ
ងបានចេញទៅរៀននៅហាណូយផុត ។*

*ក្នុងការទាក់ទាញយកពួកខ្មែរឥស្សរៈតំបន់សៀមរាប-បាត់ដំបង ហូ-ជីមិញបានចាត់ភ្នាក់ងារចំនួនប្រាំនាក់។
មេដឹកនាំនេះមានឈ្មោះថា អុងស៊ីង (* **Nguyen Thanh Son** *) ។ ដើម្បីសំរេចកិច្ចការនេះ ពួកភ្នាក់ងារយួនបាន
រកស្រីពីរនាក់ ដែលមានអ្នកស្រុកចូលចិត្តស្រឡាញ់ស្ដាប់ច្រើន គឺម្នាក់ឈ្មោះ ម៉ា-មួន ត្រូវជាម្ដាយមីងកៅ-តក់
ទៅនិយាយទាក់ទាញកៅ-តក់ឲ្យបានដោយឲ្យប្រាក់មួយចំនួនយ៉ាងធំទៅម៉ា-មួន ដើម្បីចៀសវាងដើម្បីចៀសវា
ងក្រែងគេដឹង លុយនោះយួនខ្ចប់នឹងស្លឹកចេក តែផល-ប៊ុនតូសព្វថ្ងៃនៅរដ្ឋវ៉ាស៊ិនតោនជាក្មួយម៉ា-
មួនបានលប
មើលឃើញ ។ កៅ-តក់បានប្រកែកដាច់អហង្កានឹងការបញ្ចុះបញ្ចូលដែលម៉ា-មួនខំនិយាយល្បួងលោមបញ្ចុះ
បញ្ចូល តាមបំណងរបស់ភ្នាក់ងារយួនវៀតមិញនោះ រហូតទាញកាំភ្លើងរកបាញ់ម៉ា-មួនចោលទៀតផង ។ ដោ-
យគំរោងការបរាជ័យ មេភ្នាក់ងារហូ-ជីមិញឈ្មោះអុងស៊ីង ក៏ឲ្យគ្នាវាម្នាក់ឈ្មោះ ង្វៀង មកទាក់ទងជាមួយយា
យទុំ-ឃុន ( នៅភូមិត្រុំ ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ) ទៀត ដែលមានអ្នកស្រុកចូលចិត្តរាប់អានស្ដាប់ច្រើន
និងជិតដិតជាមួយកៅ-តក់ផង ។ យួនង្វៀងនោះបានស្កាត់រកជួបកៅ-តក់នៅជំរំទ័ពឥស្សរៈនៅព្រៃឈ្មោះត្រពាំ
ងក្លែងពណ៌ជាច្រើនដង តែកៅ-តក់បានឲ្យពួកទ័ពឥស្សរៈដេញភ្នាក់ងារយួនវៀតមិញនោះចេញពីតំបន់នោះផង
។ កូនប្រុសទុំ-ឃុនពីរនាក់ ( ទុំ-សង និង ទុំ-ស៊ីន ) សព្វថ្ងៃរស់នៅ* **Everett** *រដ្ឋវ៉ាស៊ិនតោន ជាសាក្សីដែលបា
ននៅជាប់ជាមួយនឹងកៅ-តក់ ពេលបាញ់គ្នាជាមួយពួកលាវកែវ-មុនីនៅត្រង់ភូមិក្រូចចារ ឧត្តរមានជ័យនោះ ។*

*ឆ្នាំ១៩៤៦ បារាំងយកបាត់ដំបង សៀមរាបវិញ ពួកអ្នកមានខ្លួនប្រឆាំងបារាំងដូចជាម៉ា-មួន, ទុំ-ឃុន,
កៅ-តក់... ក៏ដឹកនាំបញ្ជូនប្រពន្ធកូនចៅទៅរស់ខេត្តសុរិន ស្រុកសៀម ឯប្រុសៗនៅតែធ្វើសកម្មភាពចលនាខ្មែរ
ឥស្សរៈតំបន់ឧត្តរមានជ័យ សំរោងចុងកាល់ដដែល រហូតមកដល់ឆ្នាំ៥១ ទើបបានជួបត្រូវរ៉ូវគ្នានឹងក្រុមសឹង-ង៉ុ
កថាញ់ ។ ក្រោយសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ក៏វិលត្រឡប់មករស់នៅក្នុងស្រុកខ្មែរវិញខ្លះនៅសំរោងចុងកាល់
ឧត្តរមានជ័យ ខ្លះមករស់នៅក្រឡាញ់កំពង់ថ្កូវវិញ ដូចជាកៅ-តក់ជាដើម លើកលែងតែយាយម៉ា-មួន ដែលក្លា
យជាអ្នកមានបង្គួរ ( ដោយសារលុយយួនវៀតមិញឲ្យ ) ក៏រស់នៅសុរិនរហូត ហើយជរាស្លាប់ក្នុងឆ្នាំ១៩៧៧ ។
កាលសាធារណរដ្ឋរលំឆ្នាំ១៩៧៥ នាយទាហាន ចៅហ្វាយខេត្ត រត់ចូលទៅស្រុកសៀម ម៉ា-មួនបានទៅជួបហើ
យនិយាយថា ៖ « ពួកអស់លោកធ្វើរដ្ឋប្រហារទម្លាក់សីហនុ ពេលសីហនុនៅក្នុងស្រុកលោកមិនធ្វើទេ លោកទុ
កឲ្យសីហនុចេញពីស្រុក ទើបលោកនាំគ្នាទម្លាក់ រហូតសីហនុចូលជាមួយយួន ជាមួយខ្មែរក្រហម លោកច្បាំង
ម៉េចនឹងឈ្នះ » ។*

*រហូតដល់ឆ្នាំ១៩៥៥ កៅ-តក់ដែលប្រុងឈរជាបេក្ខជនតំនាងរាស្ត្រជាមួយប៉ុក-ឃុន, លាវកែវ-មុនី ក៏ត្រូ
វសម្ដេចបញ្ជាមកដាប-ឈួន ឲ្យសម្លាប់កៅ-តក់ចោលក្នុងខែមករា ត្រូវនឹងខែបុស្ស ឆ្នាំមមីរ បើតាមសំដីឲ្យការ
របស់អ្នកស្រីហង្ស-ធុនហាក់ ជាកូនស្រីកៅ-តក់ សព្វថ្ងៃរស់នៅរដ្ឋ* **Oregon** *និងអ្នកស្រីអ៊ីវ-យ៉ាង នាដើមកៅ-
សាវ៉ៃ ជាក្មួយកៅ-តក់, សព្វថ្ងៃរស់នៅក្រុងប៉ារីស៍ ស្រុកបារាំង បានចូលរួមទាំងចលនាខ្មែរឥស្សរៈ ទាំងជួយបំរើ*

*ចលនាសឹង-ង៉ុកថាញ់ ( បំរើបាយទឹកលោកសឹង-ង៉ុកថាញ់ ) កាលពីវ័យជំទង់ និងបានស្គាល់គ្រួសារលោកស៊ីវ ហេង, ភរិយាឈ្មោះផុស-អ៊ីង និងកូនប្រុសបងឈ្មោះលាង-ម៉ានិត យ៉ាងជិតដិតទៀតផង ។*

សៀវភៅចរិតខ្មែររបស់លោកប៊ុណ្ណ-ចន្ទម៉ុលសរសេរថា ប្រសិនកៅ-តក់មានកាំបិតឬដំបងជាប់នឹងដៃនោះ គ្មាននរណាអាចចូលជិតគាត់បានឡើយ ។ មនុស្សដាប-ឈួនឈ្មោះដោយរ៉ែម ( ធ្មេញមាសពេញមាត់ ) ខ្លាចប្រយុទ្ធមិនឈ្នះក៏បាញ់សម្លាប់កៅ-តក់ទៅ ។ ខ្មោចចោលនៅទីនោះជាងបីថ្ងៃគ្មាននរណាហ៊ានទៅជិតឡើយ។ បីថ្ងៃក្រោយមក ទើបក្រុមគ្រួសារទៅលបលួចយកសពមកបញ្ចុះស្ងាត់ៗនៅវត្តទ្រង់បាត្រ ជិតផ្លូវក្ដុយអុន ដែលធ្លាក់ពីលើឡានហ្ស៊ីបស្លាប់ជាង១០ថ្ងៃមុននោះ ។ បីឆ្នាំក្រោយ ទើបក្រុមគ្រួសារហ៊ានទៅគាស់សពទាំងពីរមកបូជាធ្វើបុណ្យឧទ្ទិសកុសលនៅក្នុងវត្តទ្រង់បាត្រ ។

ឯក្រុមស៊ីវ-ហេង, ប្រាក់-ខាន់ ( សម័យលន់-នល់គាត់ពាក់ស័ក្តិបួន ធ្វើចៅហ្វាយស្រុកបាណន់ ), ឡាច-សារេន ( អាចារ្យសារេន ), ឡាច-សាវ៉ន, មូល-សម្បត្តិ, អាចារ្យប្រេស, ប៊ុង-គឿក, លាវកែវ-មុនី, ម៉ា-មូន (ម្ដាយមីងកៅ-តក់ ), ម៉ី-ផូ, រុង-លើតជាដើម... បានទាក់ទងជាមួយយួនវៀតមិញ ដោយសារចាញ់ឧបាយឃោសនារបស់ពួកហូ-ជីមិញ និងដោយចង់បានកាំភ្លើងពីយួនមកវាយអាណានិគមបារាំងផង (២០) និងម្យ៉ាងទៀត ដោយសារយួនឃើញខ្មែរកំពុងបាត់មេដឹកនាំ ( បារាំងចាប់សឹង-ង៉ុកថាញ់និរទេសទៅស្រុកបារាំងនៅPoitier ) យួនក៏ឆ្លៀតឱកាសដ៏កំរនេះជ្រៀតជ្រែកចូលក្នុងស្នូលដឹកនាំខ្មែរឥស្សរៈ ដោយប្រើលុយផង និយាយបញ្ចុះបញ្ចូលផងចាក់ពួកខ្មែរឥស្សរៈឲ្យឈ្លោះគ្នា និងរកកល្បល្បិចសម្លាប់ខ្មែរ ដែលមិនព្រមចុះចូលជាមួយយួនវៀតមិញចោលឲ្យអស់ ។

ក្នុងឆ្នាំ១៩៤៧ លោកស៊ីវ-ហេងបានទៅអន្ទងបញ្ចុះបញ្ចូលក្មួយបង្កើតរបស់ភរិយាលោកម្នាក់ឈ្មោះរុង-លើត ដែលជានិស្សិតនៅមហាវិទ្យាល័យធម្មសាត ( សំនៀងថៃ បើខ្មែរគឺមហាវិទ្យាល័យធម្មសាស្ត្រ ឬមហាវិទ្យាល័យច្បាប់ ) នាក្រុងបាងកក (១០) ។

ពួកក្រុមលោកស៊ីវ-ហេងនេះក៏បានក្លាយទៅជា « ខ្មែរវៀតមិញ » តែនៅក្នុងការឃុំគ្រងដឹកនាំដោយយួនវៀតមិញ ។ ទីតាំងរបស់ពួកនេះនៅតំបន់សំឡូត ក្រញូង ខេត្តបាត់ដំបងជិតទល់ដែនសៀម ។ សេចក្ដីបញ្ជាក់របស់លោកប៊ុណ្ណ-ចន្ទម៉ុលក្នុងសៀវភៅ « ចរិតខ្មែរ » ក៏បានសារភាពថា ខ្មែរឥស្សរៈមានការទាក់ទងជាមួយយួនវៀតមិញដែរ (១១) ។

ដោយសារមានទំនាស់ចង់ធ្វើធំតែរៀងខ្លួននោះ ខ្មែរឥស្សរៈក៏បាក់បែកគ្នាអស់។ ដាប-ឈួនទៅតាំងទីនៅភ្នំគូលែន, កៅ-តក់នៅភ្នំដងរែក ឧត្តរមានជ័យ ក្រឡាញ់

(២០) តាមសំដីឲ្យការរបស់លោកលាង-ម៉ានិត ត្រូវជាកូនប្រុសច្បងសពលោកស៊ីវ-ហេង សព្វថ្ងៃរស់នៅរដ្ឋនីវ-យ៉ក សហរដ្ឋអាមេរិក ។

(១០) រុង-លើត ( ជាឈ្មោះថៃ ) នេះឯងដែលក្រោយមកគេស្គាល់ថា នួន-ជា ឯឈ្មោះដើមគឺឡៅ-បេងគន ផ្ទះនៅខាងលើវត្តគរបន្ទិច ចម្ងាយប្រហែលជា២គីឡូម៉ែត្រពីផ្សារលើបាត់ដំបង ។

(១១) សូមអានសៀវភៅ « ចរិតខ្មែរ » របស់ប៊ុណ្ណ-ចន្ទម៉ុល ត្រង់ទំព័រ៨១ ។

សៀមរាប ។ នៅបាត់ដំបងមានលាវកែវ-មុនី, ស៊ីវ-ហេង, មូល-សម្បត្តិ, ប៊ុង-គឿ

ដោយសារមានទំនាស់ចង់ធ្វើធំតែរៀងខ្លួននោះ ខ្មែរឥស្សរៈក៏បាក់បែកគ្នាអស់។ ដាប-ឈួនទៅតាំងទីនៅភ្នំគូលែន, កៅ-តក់នៅភ្នំដងរែក ឧត្តរមានជ័យ ក្រឡាញ់ សៀមរាប ។ នៅបាត់ដំបងមានលាវកែវ-មុនី, ស៊ីវ-ហេង, មូល-សម្បត្តិ, ប៊ុង-គឿកជាដើម ។ ខេត្តកំពង់ធំមាន ងួន-ហុង, សាឡុត-ឆាយ (១២), ស័ក្តិបីស៊ាប ក្រោយមកមានចូលពីភ្នំដងរែកថែមម្នាក់ទៀតឈ្មោះម៉ែន ដែលយករហស្សនាមថា ម៉ែនកែនផែនដីឥសីអគ្គីនេត្រ ។ ឯស័ក្តិបីស៊ាបក្រោយមកមិនចូលរួមជាមួយសឹង-ង៉ុកថាញ់ទេ នៅឯកាជាមួយកូនទ័ពឥស្សរៈ ដោយយកលេសថា វិន័យចលនាលោកសឹង-ង៉ុកថាញ់តឹងតែងពេក ។ ពួកខ្មែរវៀតមិញនៅតំបន់បូព៌ា នៅខាងស្វាយរៀង ព្រៃវែង ដូចជា សោម-ភឹម, ក្រុមហេង-សរិន... ក៏មិនចូលរួមជាមួយសឹង-ង៉ុកថាញ់ដែរ ដោយយួនបានអប់រំប ញួលទ្រឹស្តីឲ្យបំរើវាទៅហើយ ។ ខេត្តកំពង់ស្ពឺ មានច័ន្ទរង្សីនៅបន្ទាយច្បារមន, សាវ៉ាង-វង្ស ( ឥស្សរៈគាំទ្របារាំង ), ពុត-ឆាយ នៅចន្លោះភ្នំត្នោតពងមកតំបន់បាត់ដឹង ភ្នំប្រសិទ្ធិ ។ ខេត្តកំពង់ចាមមានសោម-ភឹម, អាចារ្យឃីមេចោរ ។ ខេត្តកំពតមានណុប-បូផាន, អាចារ្យមៀន (សឹង-ង៉ុកមិញ) ក្រោយមកមាននិស្សិតពីស្រុកបារាំងមកចូ លរួមទៀតគឺ វិស្វករជី-គិមអាន និងសាឡុត-សរ (ប៉ុល-ពត) ។

យើងឃើញថា ក្នុងពេលដែលខ្មែរបាត់មេ យួនវៀតមិញបានលូកដៃចូលមកជ្រៀតជ្រែកបញ្ចុះបញ្ចូលយកខ្មែរឥស្សរៈ ខ្មែរវៀតមិញបាន ហេតុនេះហើយទើបលោកថាញ់មិនអាចធ្វើការបង្រួបបង្រួមចលនាខ្មែរឥស្សរៈទាំងអស់ក្នុងប្រទេសខ្មែរបាន ។

*　　　　*

*

(១២) សាឡុត-ឆាយ ត្រូវជាបងបង្កើតរបស់សាឡុត-សរ ( ប៉ុល-ពត ) ។

# ចលនាតស៊ូលោកសឺង-ង៉ុកថាញ់

ដោយអន្តរាគមន៍ពីក្រុមបក្សប្រជាធិបតេយ្យ និងគំហើញពួកវៀតមិញចូលមកជ្រៀតជ្រែកខ្លាំងក្លាផងនោះ សម្តេចសីហនុបានសុំបារាំងអនុញ្ញាតឲ្យលោកសឺង-ង៉ុកថាញ់បានវិលត្រឡប់មកមាតុភូមិវិញ ដោយសន្យាថាមិនចូលឡូកឡំរឿងនយោបាយទៀតឡើយ ។

លោកសឺង-ង៉ុកថាញ់បានចូលមកស្រុកខ្មែរវិញនៅថ្ងៃទី២៩តុលា ១៩៥១ ។ ថ្ងៃនោះឯង មេដឹកនាំយួនបានឲ្យភ្នាក់ងារគេដែលជាកូនចិញ្ចឹមនិងជាបំរើផ្ទាល់លោករ៉ាយម៉ុង វាយសម្លាប់លោក Jean de Raymond ពេលលោកកំពុងសំរាន្ត ។ ឯសៀវភៅ How Pol Pot came to power បានសរសេរត្រង់ទំព័រ៩៥ ថាគឺជាបក្សពួកលោកសឺង-ង៉ុកថាញ់ ជាអ្នកសម្លាប់ទេវិញ ។

ក្រោយពីជួបជុំគ្នាជាមួយលោកប៉ាច-ឈឺន, ស៊ឹម-វ៉ា និងពួកប្រជាធិបតេយ្យមក ក៏ស្រុះមតិគ្នាថា ត្រូវតែចេញទៅព្រៃប្រមូលបង្រួបបង្រួមខ្មែរឥស្សរៈវាយបារាំងដើម្បីឯករាជផង និងកុំឲ្យយួនចូលមកលូកដៃក្នុងរឿងខ្មែរបានផង ។



លោកសឺង-ង៉ុកថាញ់

សូមជ្រាបថាកាលលោកថាញ់នៅជាជននិរទេសឯស្រុកបារាំងនោះ លោកបានទាក់ទងប្រឹក្សាជាមួយបញ្ញវ័ន្តខ្មែរក្មេងៗ ដែលបានទៅសិក្សានៅស្រុកបារាំងមានលោកហង្ស-ធុនហាក់, លោកអ៊ីវ-យ៉ាងជាដើម... ហើយបានស្គាល់ចិត្តថ្លើមគ្នាជាមុន ។ ពេលមកស្រុកខ្មែរវិញ លោកថាញ់បានចាត់ឲ្យលោកអ៊ីវ-យ៉ាងទៅរកមើលកន្លែងដែលអាចធ្វើមូលដ្ឋានតស៊ូបាន ។ លោកអ៊ីវ-យ៉ាងបានទៅរកមើលឃើញទីកន្លែងពីរ ៖

១- តំបន់កំពង់ស្ពឺ ភ្នំឱរ៉ាល់ តែជាកន្លែងពិបាកតម្លើងប៉ុស្តិ៍វិទ្យុផ្សាយសម្លេងផង ជាតំបន់ដែលប្រជាជនមិនសូវជ្រួតជ្រាបនឹងចលនាតស៊ូរំដោះជាតិ ពីអាណានិគមផង និងជាតំបន់ដែលពិបាកក្នុងការទាក់ទងជាមួយពិភពបរទេសដើម្បីរកជំនួយផង

២- តំបន់សៀមរាប អូរស្មាច់ ភ្នំដងរែក : ជាទីកន្លែងល្អអាចតាំងជាមូលដ្ឋានបាន ព្រោះប្រជាជនក៏ភ្ញាក់រលឹកច្រើន ដោយមានចលនាខ្មែរឥស្សរៈតាំងពីឆ្នាំ១៩៤៥ ផង ជាទីអាចតម្លើងប៉ុស្តិ៍វិទ្យុផ្សាយសម្លេងបានស្រួល ហើយនិងជាផ្លូវមួយអាចទាក់ទងជាមួយពិភពបរទេសតាមរយៈស្រុកសៀមផង ។ ហេតុនេះហើយទើបលោកថាញ់សំរេចយកអូរស្មាច់ ធ្វើជាមូលដ្ឋានតស៊ូជាមួយបារាំងដើម្បីឯករាជ្យ ។ លោកអ៊ីវ-យ៉ាងបាននិយាយត្រូវរ៉ូវគ្នាជាមួយមេខ្មែរឥស្សរៈកៅ-តក់ និងទីប្រឹក្សាសាមុត-ប៊ុនថាន់ (១២) រួចជាស្រេច ស្របពេលនឹងការតថ្លៃរបស់លោកលន់-ធល់ជាចៅហ្វាយខេត្តបាត់ដំបង ។

នៅថ្ងៃទី៩ មិនា ១៩៥២ វេលាម៉ោង១ភ្លឺ លោកថាញ់បានចាកចេញពីក្រុងភ្នំពេញ ដោយមានសហការីរួមដំណើរគឺ លោកអៀរ-ស៊ីចូវ, ហង្ស-ធុនហាក់, គាំ-រ៉េត និងសាំង-សាវ៉ាត (១៣) តាមរថយន្តស៊ីត្រូអែនបីរបស់លោកថាញ់, លោកអៀរ-ស៊ីចូវ និងគាំ-រ៉េតផ្ទាល់ ។ ថ្ងៃទី១០ ទាំងអស់គ្នាបានទៅដល់គោកត្រុំ នៅចន្លោះក្រឡាញ់និងព្រៃជ្រូក ។ ពេលនោះកៅ-តក់និងសាមុត-ប៊ុនថាន់ បានជិះសេះមកចាំទទួល

(១២) លោកសាមុត-ប៊ុនថាន់សព្វថ្ងៃរស់នៅក្រុងឡុងប៊ីចរដ្ឋកាលីហ្វ័រនិញ៉ា ។

(១៣) លោកសាំង-សាវ៉ាតបាននិពន្ធរឿងប្រលោមលោកពីរដ៏ពិរោះចាប់ចិត្ត ស្នេហាខ្ពង់ខ្ពស់ឧត្តមគតិស្នេហាជាតិមោះមុត គឺរឿង « តេជោក្រហម » និង « មហាចោរនៅទល់ដែន » ។ រឿងមហាចោរនៅទល់ដែននេះ កាលពីដំបូងបោះជាពីរវ៉ៃ្ស តែនៅឆ្នាំ១៩៧២ ក្រុមសារពត៌មាន « នគរធំ » បានប្រមូលបោះរួមគ្នាតែមួយសៀវភៅទៅវិញ ។ ក្នុងរឿងមហាចោរនៅទល់ដែន វិសេសក្លាហាន ឪពុកនាងទេវី (សង្សារមានន្ទ) ជាតំណាងលោកសឺង-ង៉ុកថាញ់តែម្តង ព្រោះត្រង់វគ្គដែលលោកឲ្យពរកូន ត្រង់ទំព័រ៨៦ គឺជាសំដីលោកថាញ់ដែលតែងតែនិយាយឲ្យពរគូស្វាមីក្នុងជួរតស៊ូរបស់លោក ។ លោកសាំង-សាវ៉ាត បានត្រូវលោកសេក-សំអៀត ( បច្ចុប្បន្នជាសមាជិកព្រឹទ្ធសភារបបហ៊ុន-សែន) ចាប់យកទៅសម្លាប់ចោលក្នុងថ្ងៃ២០-២១ មករា ១៩៥៩ រួមគ្នានឹងការចាប់ចងក្នុងថ្ងៃជាមួយគ្នា នៃពួកអតិតខ្មែរឥស្សរៈជាម្ភៃនាក់ផ្សេងទៀត ។ ឯអ្នកខ្លះទៀតបានគេចរត់ទៅស្រុកយួនខាងត្បូង រួមធ្វើជា «ខ្មែរសេរី» ជាមួយលោកសឺងង៉ុកថាញ់ ។ ខ្លះទៀតត្រូវជាប់គុកដូចជា លោកអ៊ីវ-យ៉ាង, គាំ-រ៉េត, ដួង-ច័ន្ទសារាតជាដើម...។ អ្នកដែលត្រូវគេសម្លាប់ជាមួយលោកសាំង-សាវ៉ាតគឺ ៖ ទាវ-ទឹងសាន, គ្រូមួន, សារី, អាចារ្យប្រុក តាមសំដីអ្នកស្រីអ៊ីវ-យ៉ាងថា លន់-ណុនជាអ្នកទៅចាប់អ៊ីវ-យ៉ាង ក្នុងវេលាយប់ម៉ោងប្រាំបីថ្ងៃទី២០ មករា១៩៥៩ ។

ហើយនាំចុះតាមផ្លូវរទេះទៅក្នុងព្រៃ ។ ថ្ងៃនោះឡានមួយត្រូវខូចដោយដាច់ចង្កូត ក៏នាំគ្នារុញលាក់ទុកក្នុងព្រៃកុំឲ្យបារាំងដឹងដាន ។ ថ្ងៃបន្ទាប់ បានមកសំណាក់នៅក្នុងវត្តជ្រោយនាងងួនខួង់បីម៉ោងក៏ឮសូរកាំភ្លើងបាញ់ចំរុះនៅក្រឡាញ់ ទាំងអស់គ្នាក៏បន្តដំណើរទៅមុខទៀត ។

ពីរថ្ងៃក្រោយមក លោកអ៊ីវ-យ៉ាងបានយករថយន្តឡង់រ៉ូវែរមួយដឹកប៉ុស្តិ៍វិទ្យុផ្សាយសម្លេងមួយពីក្រសួងឃោសនាការ ( លោកប៉ាច-ឈឿនជារដ្ឋមន្ត្រីក្រសួងឃោសនាការ ) មកឈប់នៅភូមិទ្រង់បាត្រ (ក្រឡាញ់) ។ អ្នកទាំងអស់គ្នាក៏ទៅជួបជុំគ្នានៅខាងកើតស្រុកចុងកាល់ត្រង់ស្ទឹងដាច់ តាមដងស្ទឹងស្រែង រួចយកប៉ុស្តិ៍វិទ្យុទៅតម្លើងនៅត្រង់កូនភ្នំរូងស្លដែកពីបូរាណជាបណ្តោះអាសន្នសិន ដោយលោកប៉េង-គិតជាអ្នកតំលើង ។

លោកសឺង-ង៉ុកថាញ់បានដាក់ឈ្មោះចលនារបស់លោកថា ៖ « ចលនាឥស្សរៈរួមខ្មែរបំរើជាតិ » ដែលមានបាវចនា : ឯករាជ្យ-ប្រជាធិបតេយ្យ-សង្គមខ្មែរថ្មី-វិន័យថ្លៃថ្នូរ-ក្លាហាន ។ ឯការចាត់តាំងក្នុងចលនាតស៊ូមានដូចតទៅ ៖

១- លោកសឺង-ង៉ុកថាញ់ ជាប្រមុខចលនា ។

២- លោកអៀវ-ស៊ីចូវ ជាប្រមុខរង ជាអ្នកចងក្រងទ្រឹស្តីក្បួនចលនាតស៊ូវិន័យ និងការទទួលខុសត្រូវ ខាងផែនការនយោបាយបង្រួបបង្រួមពួកអ្នកតស៊ូខ្មែរឥស្សរៈ ។

៣- លោកអាចារ្យខៀវ-ជុំ (១៤) ជាអគ្គលេខាធិការ មានលោកយន់-ហ៊ាងជាភូឈ្មួយ ។

៤- លោកហង្ស-ធុនហាក់ ទទួលខុសត្រូវខាងផ្នែកអប់រំ វប្បធម៌ សិល្បៈ និងរៀបចំក្រុមល្ខោនអប់រំដាស់សតិអ្នកតស៊ូ និងប្រជារាស្ត្រនៅតំបន់នោះ ។

៥- លោកអ៊ីវ-យ៉ាង ជាមេបញ្ជាការគ្រប់គ្រងទទួលបន្ទុកខាងផ្នែកសន្តិសុខទូទៅ (១៥) និងមេបញ្ជាការភូមិភាគបស្ចិមទិស (ខេត្តបាត់ដំបង ពោធិសាត់)

៦- លោកប៉េង-គិត ជាអ្នកបច្ចេកទេសខាងតំលើងនិងជួសជុលប៉ុស្តិ៍វិទ្យុផ្សាយសម្លេង ។
លោកឃី-តាំងលឹម ទទួលខុសត្រូវរៀបចំខាងកម្មវិធីផ្សាយសម្លេងចំរៀងចលនាតស៊ូ ភ្លេង អត្ថាធិប្បាយនយោបាយ និងជំហរចលនាតស៊ូដើម្បីឯករាជ្យ ប្រឆាំងអាណានិគមបារាំង ( បច្ចុប្បន្នធ្វើជារដ្ឋមន្ត្រីក្រសួងសាធារណការនៃរដ្ឋាភិបាលហ៊ុន-សែន ) ។

(១៤) លោកអាចារ្យខៀវ-ជុំ កាលឆ្នាំ១៩៤២ បានភៀសជាមួយអាចារ្យអ៊ុក-ជា ទៅគង់នៅស្រុកសៀម (ក្រុងបាងកក) ក្នុងសម័យដែលបារាំងចាប់អាចារ្យហែម-ចៀវ ។ ពេលលោកសឺង-ង៉ុកថាញ់វិលមកពីស្រុកបារាំង (អន្តរាគមន៍ពួកប្រជាធិបតេយ្យ) ហើយចូលព្រៃ (ឆ្នាំ១៩៥២) លោកអាចារ្យខៀវ-ជុំបានចូលមករួបរួមជាមួយ តែលោកពុំបានលាចាកសិក្ខាបទទេពេលនោះ
(១៥) នាទីមេបញ្ជាការគ្រប់គ្រង គឺទទួលខុសត្រូវខាងរដ្ឋបាលស៊ីវិល សង្គមកិច្ច និងខាងនយោបាយ ។

៧- លោកដួង-ច័ន្ទសារ៉ាត (១៦) ជានាយអគ្គសេនាធិការកងទ័ព មានភូឈ្មួយ ឬអគ្គសេនាធិការរងគឺលោក លាវ-ផានសី (១៧) ។

៨-លោកកៅ-តក់ ជាមេទ័ពនិងជាមេបញ្ជាការសឹកឃោធភូមិភាគបស្ចឹមទិស។

៩- លោកសាំង-សាវ៉ាត ( ក្រោយឆ្នាំ១៩៥៨ ជាចាងហ្វាងសារពត៌មានខ្មែរ ជាអ្នកនិពន្ធរឿង «តេជោក្រហម» និង «មហាចោរនៅទល់ដែន» ។ ដើមឆ្នាំ ១៩៥៩ ត្រូវអតិតស័ក្តិបីសេក-សំអៀតសម្លាប់ចោល ។ លោកជាមេបញ្ជា-ការភូមិភាគឧត្តរទិស (សៀមរាប) មានលោកឡឹក-សំអឿន ( រហស្សនាមផ្កាយព្រឹក, សព្វថ្ងៃរស់នៅរដ្ឋម៉ាស្សាឈូសែត ) ជាភូឈ្មួយ ។

១០- លោកគាំ-វ៉េត មេបញ្ជាការគ្រប់គ្រង និងជាមេបញ្ជាការភូមិភាគព្យសានទិស ( កំពង់ធំ, កំពង់ឆ្នាំង, កំពង់ចាម ) ដែលមានមេបញ្ជាការប្រចាំខេត្តនិ-មួយៗ គឺលោកម៉ែន (១៨) (រហស្សនាមម៉ែនកែនផែនដីឥសីអគ្គីនេត្រត្រូវពួកប៉ូលីសអាណានិគមបារាំងព័ទ្ធចាប់សម្លាប់ក្នុងឆ្នាំ៥៣), លោកអ៊ុម-ស៊ុម (១៩) ( ត្រូវជាបងលោកអ៊ុម-ហាក់, សព្វថ្ងៃធ្វើការនៅខាងក្រុមអវកាស NA

(១៦) លោកដួងច័ន្ទ-សារ៉ាត ( អនុសេនិយទោ ) និងលោកលាវ-ផានសី កាលនោះកាន់ទា-ហានមួយកងវរៈសេនាតូចនៅស៊ីសុផុន បាននាំទាហានព្រមទាំងអាវុធ ឡានសេអ៊ិមសេ១០ និងឡានហ្ស៊ីប២គ្រឿង រត់ទៅចូលរួមជាមួយលោកសឺង-ង៉ុកថាញ់ ។ ការប្រគល់អាវុធធ្វើនៅភូមិផ្អុង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ។ ឯទាហានដែលមិនព្រមតាមលោកៗបានអនុញ្ញាតឲ្យត្រឡប់មកជួបប្រពន្ធកូនវិញ សល់តែទាហាន៣០នាក់ដែលសុខចិត្តតាមលោក ។ ក្រោយមក ដោយមិនអាចទ្រាំបាននឹងការលំបាកស៊ីអត់ស៊ីឃ្លាន ដេកព្រៃ ព្រាត់ប្រពន្ធកូន ទាហានខ្លះក៏រត់ចេញថែមទៀត នៅសល់តែ៧នាក់ប៉ុណ្ណោះ ។

(១៧) ជាអនុសេនិយត្រី ជាកូនលោកលាវ-ផានស៊ូ មេឃុំកំពង់ថ្ម ស្រុកបារាយ ខេត្តកំពង់ធំ ។ ម្តាយឈ្មោះគៀល ។ លោកមានបងប្អូនប្រុសស្រីប្រាំបីនាក់គឺ ៖ លាវ-ផានអេង, លាវ-ផានស៊ី លាវ-ផានអៀម និងប្អូនស្រីពីរនាក់គឺ ៖ លាវ-គីមឈុន និងលាវ-គីមឈី ។ លាវ-ផានអ៊ឹម និស្សិតវេជ្ជបណ្ឌិតឆ្នាំ១៩៥៥-៥៦ បានទាក់ទងស្នេហាអ្នកគ្រូខៀវ-ប៉ុណ្ណារី ( ក្រោយមកជាប្រពន្ធទី១របស់ប៉ុល-ពត ដោយខ្វះមនោសញ្ចេតនាប្តីប្រពន្ធ ទើបក្នុងឆ្នាំ១៩៧៨ក្លាយជាឆ្កួតវក់ ប៉ុល-ពតក៏មានប្រពន្ធថ្មីទៀត ) តែអ៊ុំគៀលជាម្តាយមិនយល់ព្រម ព្រោះមានរូបសម្បត្តិមិនស្អាតសមធ្វើជាកូនប្រសារគាត់ ។ ត្រង់នេះហើយដែលធ្វើឲ្យខៀវ-ប៉ុណ្ណារីតូចចិត្តនឹងខ្លួនឯង មានគំនិតសាំញ៉ាំ(complex)ស្អប់ពួកវណ្ណៈអ្នកមាន ជាហេតុឲ្យអ្នកគ្រូអភ័ព្វស្នេហ៍នេះស្រូបឃោប-ល់គ្នាជាមួយសាឡុត-សរ ដែលមានបំណងលាងជំរះសង្គមពុករលួយ និងកសាងសង្គមកុម្មុយនិស្តទៅតាមទ្រឹស្តីចំកួតលីលារបស់Karl Max និងទ្រឹស្តីម៉ៅនិយមរើរវាយឆ្វេងហួសហេតុ

(១៨) លោកម៉ែន ជាឥស្សរៈដែលលោកសឺង-ង៉ុកថាញ់បញ្ជូនមកពីភ្នំដងរែក មិនមែនជាខ្មែរឥស្សរៈពីមុនមកទេ ។

(១៩) លោកអ៊ុម-ស៊ុម ជាមិត្តលោកលាវ-ផានស៊ី បានចូលបន្លំធ្វើជាកូនទាហានលោកលាវ-ផានស៊ី ដើម្បីជារនុកក្នុងនាំរត់មកភ្នំដងរែក ។ កាលនោះ លោកសេង-ស៊ុនថៃ ( ត្រូវលន់-ណុនធ្វើឃាតនៅថ្ងៃទី២៤ មិនា ឆ្នាំ១៩៧០ ដោយខ្លាចលោកធ្វើរដ្ឋប្រហារយកអំណាចទៅឲ្យលោកសឺង-ង៉ុកថាញ់វិញ ក្រោយការប្រកាសទម្លាក់សម្តេចសីហនុរួច ) ក៏បាននាំកូនទាហានរត់មកភ្នំដងរែកដែរ តែដោយគ្មានអ្នកនាំផ្លូវ ក៏ត្រូវបារាំងតាមមកទាន់ចាប់យកទៅវិញនៅត្រង់ភ្នំត្បែង-មានជ័យ ហើយបញ្ឈប់លែងឲ្យកាន់កូនទាហានទៀត ឲ្យទៅកាន់ខាងផ្នែកសម្ភារៈនិងនាំសារវិញ ។

SA, រដ្ឋ FLORIDA ) និងលោកម៉ៅ-ថេន ។

ដោយសារសេចក្ដីអំពាវនាវនូវការបង្រួបបង្រួម, ខែសីហា១៩៥២ លោកងួន-ហុង មានកូនឈ្មួយឈ្មោះសារិន និងសាឡុត-ឆាយ (២០) ខាងកំពង់ធំ បាននាំទា-ហានឥស្សរៈ១៥០នាក់ព្រមទាំងអាវុធផង មកចូលរួមជាមួយ ។ ឯនរោត្តម-ច័ន្ទរង្សី ខាងកំពង់ស្ពឺ ក៏ចង់ទ័ពឥស្សរៈមកចូលរួមជាមួយដែរ តែលោកថាញ់បានសុំឲ្យច័ន្ទ-រង្សីតាំងនៅបន្ទាយច្បារមន (ខាងលិខក្រុងកំពង់ស្ពឺ)ដដែល ហើយលោកបានបញ្ជូនលោកអៀរ-ស៊ីចូវខាងនយោបាយ (២១) និងជំនួយខាងផ្នែកយោធាម្នាក់ឈ្មោះ ចែមទៅជួយ ។

ការលើកយកចលនាឥស្សរៈលោកសឺង-ង៉ុកថាញ់មកអធិប្បាយត្រួសៗនេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា លោកថាញ់មានចិត្តស្នេហាជាតិមោះមុត ជាមេដឹកនាំគំរូម្នាក់ (រហូតសព្វថ្ងៃខ្មែរគ្មានមេដឹកនាំគំរូទេ) មាននិន្នាការខាងរបបសាធារណរដ្ឋសេរីនិយម ដែលជាគ្រោះថ្នាក់ចំពោះរបបរាជានិយមផ្ដាច់ការ ។ ការរៀបចំដ៏ខ្លាំងក្លានិងចំណុះចុះចូលនៃពួកបញ្ញវ័ន្តខ្មែរជាមួយលោកថាញ់ បានធ្វើឲ្យសីហនុបារម្ភខ្លាចបាត់បង់អំណាចក៏ចាត់ទុកលោកថាញ់ជាសត្រូវទី១របស់ទ្រង់ ។ ហេតុនេះហើយ បានជានៅក្រោយសន្ធិសិទហ្ស៊ឺណែវឆ្នាំ១៩៥៤ ពួកអន្តរជាតិបាននាំលោកថាញ់ចូលមកជិតដល់ក្រុងភ្នំពេញ តែសីហនុមិនព្រមទទួល ។ ចុងឆ្នាំ១៩៥៥ លោកថាញ់បានសរសេរលិខិតជនមកសីហនុសុំចូលមករួបរួមជាមួយ តែសីហនុមិនព្រមជាដាច់ខាត ហើយចាត់ទុកលោកថាញ់ជាជនក្បត់ជាតិ ព្រោះបានប្រឆាំងនឹងព្រះមហាក្សត្រ ។ មកតែពីលោកថាញ់មានចិត្តទោរទន់ មិនហ៊ានធ្វើឲ្យដូចរដ្ឋប្រហារថៃ ( ១៩៣២ ព្រះចៅទី៧រត់ទៅអឺរ៉ុប- ឆ្នាំ១៩៤១ ព្រះចៅទី៨ដែលប្រាថ្នាដណ្ដើមយកអំណាចមកវិញនោះត្រូវគេធ្វើគត) ដើម្បីចៀសវាងការសម្លាប់រង្គាលគ្នាឯង ទើបនយោបាយលោកត្រូវបរាជ័យ

(២០) សាឡុត-ឆាយ ត្រូវជាបងបង្កើតរបស់សាឡុត-សរ (ប៉ុល-ពត) ។

(២១) នៅឆ្នាំ១៩៥៣ ដោយចង់បានបុណ្យស័ក្តិ ច័ន្ទរង្សីបាននាំទាហាននិងអាវុធមកចុះចូលជាមួយសម្ដេច ដោយយកទាំងលោកអៀរ-ស៊ីចូវមកផង តែសម្ដេចមិនព្រមទទួល ព្រោះលោកអៀរ-ស៊ីចូវជាបក្សពួករបស់លោកសឺង-ង៉ុកថាញ់ ហើយសីហនុបានឲ្យប៉ូលីសនាំលោកមកប្រគល់ឲ្យក្រុមភ្នំដងរែកវិញ ។ ឯពុត-ឆាយ តំបន់ខេត្តកណ្ដាល ភ្នំប្រសិទ្ធិក៏បានមកចុះចូលជាមួយសីហនុក្នុងរវាងឆ្នាំ១៩៥២-៥៣នោះដែរ ។ ឯដាប-ឈួន (ដាបជាពាក្យសៀមជាឋានន្តរស័ក្តិទាហានដោយ)បានចុះចូលជាមួយសីហនុតាំងពីឆ្នាំ១៩៤៩ ហើយសម្ដេចបានតែងតាំងឲ្យធ្វើជាស្ដេចត្រាញ់ ជាមេទ័ពត្រួតត្រាខេត្តសៀមរាបនិងកំពង់ធំ ។

(២២) ។ លោកថាញ់បានហាមដាច់ខាតមិនឲ្យសម្លាប់ខ្មែរគ្នាឯងទេ លោកតែងពោលបញ្ជាក់ថា ជាអន្ទាក់របស់ខ្មាំងយួនកុម្មុយនិស្តដែលចង់ឲ្យខ្មែរឈ្លោះគ្នា និងទាញខ្មែរបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិន ព្រោះហូ-ជីមិញកាលនៅជាកម្មករឯស្រុកបារាំង បានបបួលលោកម្ដង ឲ្យបង្កើតចលនាតស៊ូរួមគ្នាយួន-ខ្មែរ-លាវ វាយអាណានិគមបារាំង តែលោកមិនព្រម ។ ក្រោយមក ពេលលោកបង្កើតចលនាឥស្សរៈរួមខ្មែរបំរើជាតិ ហូ-ជីមិញបានបញ្ជូនតំណាងបួននាក់ (ខ្មែរពីរនាក់យួនពីរនាក់) មកទាក់ទងលោកម្ដងទៀត តែលោកនៅតែមិនព្រមចូលរួមជាមួយពួកយួនវៀតមិញជាដាច់ខាត ព្រោះខ្មែរមានតែខាតគ្មានចំណេញសោះ និងម៉្យាងទៀត លោកជាខ្មែរក្រោមដែលបានរស់នៅ និងស្គាល់ពុតត្បុតមេដឹកនាំយួនច្បាស់ណាស់ ។

ក្រោយមកទៀត ក្នុងឆ្នាំ១៩៥៧ លោកសឺង-ង៉ុកថាញ់បានសរសេរលិខិតចំនួនបី បរិយាយព្រមានពីដំណើរនយោបាយខុសរបស់សីហនុ ដែលកំពុងជឿតាមការលួងលោមរបស់ជូ-អេងឡាយនិងម៉ៅ-សេទុង ឲ្យសីហនុជួយហូ-ជីមិញក្នុងសង្គ្រាមរំដោះវៀតណាមខាងត្បូង ។ លិខិតទាំងបីនោះ បានបញ្ជាក់ប្រាប់សីហនុពីគ្រោះថ្នាក់យួនហូ-ជីមិញ វត្តមានកងទ័ពយួនកុម្មុយនិស្តនៅលើទឹកដីខ្មែរ ស្រុកខ្មែរនឹងក្លាយជាលានចំបាំងរវាងប្លុកសេរីនិងប្លុកកុម្មុយនិស្ត និងបមណងរបស់ហូ-ជីមិញក្នុងការលេបស្រុកខ្មែរ រួមធ្វើសហព័ន្ធឥណ្ឌូចិនទៀតផង ។ លិខិតទាំងបីនោះ សីហនុគ្មានបានយកចិត្តទុកដាក់សូម្បីបន្តិចសោះឡើយ ព្រោះជឿតាមការធានាអះអាងរបស់មេដឹកនាំចិន និងហូ-ជីមិញ ដែលសន្យាថានឹងគោរពបូរណភាពទឹកដីខ្មែរ និងគាំទ្រឲ្យសីហនុនៅលើអំណាចរហូត ។ ហេតុនេះដោយជឿសំដីបោកប្រាស់របស់មេដឹកនាំយួន១០០ភាគរយនោះ សីហនុនៅតែបន្តជួយយួនកុម្មុយនិស្តកាន់តែខ្លាំងឡើងៗថែមទៀត ។

(២២) ក្នុងរជ្ជកាលព្រះចៅ Pracha Thipok, Rama VII មានរដ្ឋប្រហារដកហូតអំណាចពីព្រះមហាក្សត្រដឹកនាំដោយ Pya Bahol និង Song Varadeth ។ ព្រះចៅប្រជាធីប៉ុកបានភៀសព្រះអង្គទៅអឺរ៉ុប (ស្វីស, អង់គ្លេស) ។ ជាសម័យលើកដម្លើងអំបូរថៃ ។ គេធ្វើការកែទម្រង់អក្សរសាស្ត្រថៃ កែតួព្យញ្ជនៈខ្លះដូចជា ខ, ឆ, ផ, ថ...។ ក្រុមអ្នកធ្វើរដ្ឋប្រហារបានបង្កើតក្រុមរាជានុសិទ្ធិឲ្យជំនួសរហូតដល់ឆ្នាំ១៩៤០ ទើបគេលើកព្រះចៅ Ananda Mahidol ឲ្យឡើងសោយរាជ្យជាព្រះចៅរជ្ជកាលទី៨ ( Rama VIII ) ។ មួយឆ្នាំក្រោយមក, ប្រហែលដោយសារព្រះចៅនេះមានបំណងដណ្ដើមយកអំណាចរាជសិទ្ធិមកវិញនោះ ទើបត្រូវគេធ្វើគត ។ រួចហើយគេក៏អភិសេកព្រះចៅភូមិបុល អដុលតេជ រជ្ជកាលទី៩ (Rama IX) រហូតដល់សព្វថ្ងៃនេះ ។ ប្រទេសថៃ, ថ្វីបើកើតក្រោយខ្មែរ ( ឆ្នាំ១២៣៨នៃគ្រិស្តសករាជ ) តែមេដឹកនាំថៃមានការវាងវៃកែប្រែប្រទេសទៅតាមទំនោរនៃនយោបាយសកលលោក ( Flexibility)ទើបប្រទេសនេះនៅគង់វង់បាន ទាំងរបបរាជានិយមក៏គង់វង់ជានិមិត្តរូបរបស់ប្រទេសថៃរហូតសព្វថ្ងៃ ដោយព្រះរាជាមិនកាន់អំណាចដូចជាព្រះរាជនីអេលីហ្សាបែតដែរ ។

# ឯកសារយោង - References

(1) អេង-សុត, ឯកសារមហាបុរសខ្មែរ ទំព័រ ១០៨៧-១០៨៨

(2) អេង-សុត, ឯកសារមហាបុរសខ្មែរ ទំព័រ ១០៩២-១០៩៣

(3) Georges Maspero, L'Empire Khmère - publié en 1904 - page 90

(4) អ៊ឹម-ធុំ, ពោរកំបោរ បោះពុម្ពឆ្នាំ១៩៦៦ ទំព័រ៣៨

(5) Georges Maspero, L'Empire Khmère - publié en 1904 - page 90

(6) Milton E. Osborne, the French presence in Indichina 1859 - published 1905 - page 90

(7) ឌ. គាម, ឧកញ៉ាវិណ្ណុឈ្មូក បោះពុម្ពឆ្នាំ១៩៧១ ទំព័រ៤៦-៥៩

(8) Etude Cambodgienne - 1967 Avril-Juin No 10, page 27-28

(9) ឌ. គាម, ឧកញ៉ាវិណ្ណុឈ្មូក បោះពុម្ពឆ្នាំ១៩៧១ ទំព័រ៧៨

(10) ឌ. គាម, ឧកញ៉ាវិណ្ណុឈ្មូក បោះពុម្ពឆ្នាំ១៩៧១ ទំព័រ១៨២

(10') មេទ័ពទន់ជាជីតាទួតខាងឪពុកខ្ញុំ តាមសេចក្តីដំណាលពីជីតាខាងឪពុកនិងឪពុកខ្ញុំផ្ទាល់ ថា តាទន់ជាមួយឧកញ៉ាមហាវិជ័យ ជាចៅហ្វាយស្រុកបានទ័ពវាយបារាំង បានលើកទ័ពទៅឡោមទ័ពបារាំងនៅលើភ្នំសន្ទុក ។ គ្រឿងខ្មុកតេជ: អាវតេជ: ដាវកំណាន់ខ្លួនខ្ញុំបានឃើញ ហើយដាវនោះ ខ្ញុំបានយកមករក្សាទុកផ្ទាល់ខ្លួន ដាវនោះត្រូវពួកប៉ុល-ពតពាយ័-យ្យទិសដកហូតយកនៅចុងឆ្នាំ១៩៧៨ ព្រោះខ្លាចប្រជាជនបះសម្លាប់ពួកវាវិញ សូម្បីតែពូថៅ កាំបិតផ្គាក់ ខ្វែវ ក៏ពួកវាដកហូតទុកដែរ នៅមុនពេលទ័ពយួនចូលឈ្លានពានស្រុកខ្មែរបន្តិច ។

(11) Etude Cambodgienne - 1969 Avril-Juin No 18, page 34
David P. Chandler, A History of Cambodia, Published 1983, page 144

(12) Etude Cambodgienne - 1969 Avril-Juin No 18, page 31

(13) Milton Osborne, the French presence in Indichina and Cambodia 1859-1905

(14) David P. Chandler, A History of Cambodia, Published 1983, page 154

(15) David P. Chandler, A History of Cambodia, Published 1983, page 159

(16) គង់-សម្ភារ, ព្រះគ្រូអាចារ្យហែម-ចៀវ, ទំព័រ ៣៣

(17) គង់-សម្ភារ, ព្រះគ្រូអាចារ្យហែម-ចៀវ, ទំព័រ ២៨

(18) William Shawcross, Side-Show, Published 1979, page 47

(19) William Shawcross, Side-Show, Published 1979, page 47

(20) ប៉ុណ្ណ-ច័ន្ទម៉ុល, ចរិតខ្មែរ, ទំព័រ២០

(21) William Shawcross, Side-Show, Published 1979, page 47

(22) David P. Chandler, A History of Cambodia, Published 1983, page 47

(23) ប៉ុណ្ណ-ច័ន្ទម៉ុល, ចរិតខ្មែរ, ទំព័រ២១

(24) ប៉ុណ្ណ-ច័ន្ទម៉ុល, ចរិតខ្មែរ, ទំព័រ៣៥

(20) ប៉ុណ្ណ-ច័ន្ទម៉ុល, ចរិតខ្មែរ, ទំព័រ៣៦

# ជំពូកទី៣

# គោលបំណង របស់ហូ-ជីមិញ

នៅក្នុងវគ្គមុនៗយើងបានឃើញហើយថា ជនជាតិយួន មេដឹកនាំយួននៅតែបន្តសង្គ្រាមរហូត គ្មានសញ្ញាណាមួយបញ្ជាក់ថា ជនជាតិនេះឈប់ធ្វើសង្គ្រាមសោះឡើយ ។ សង្គ្រាមដែលជនជាតិនេះបានធ្វើមកអស់ប្រាំសតវត្សហើយនោះ គឺជាសង្គ្រាមពង្រីកទឹកដី សង្គ្រាមបង្រួបបង្រួមវៀតណាមខាងជើងនិងវៀតណាមខាងត្បូង ។ នគរចំប៉ា (១) បានត្រូវលាយបាតពីផែនទីសកលលោកក្នុងឆ្នាំ១៦៩៦ យួនទុកតែខេត្តសាមលចាមពីរ, ជាសរគុណដល់មេទ័ពក្បត់ចាម ដែលជួយយួនឲ្យលេបស្រុកចាម, គឺខេត្តផានរី និងផាន់រ៉ាង ។ ខេត្តសាមលទាំងពីរនេះ ត្រូវយួនរំលាយទៀតក្នុងឆ្នាំ១៧២៥ (1) ។

តាំងតែពីមិនទាន់លេបស្រុកចាមរួចរាល់ស្រួលបួលផង ជនជាតិយួនបានចុះមកជានិគមជន ហើយមកតាំងទីលំនៅយ៉ាងស្ងៀមស្ងាត់ក្នុងខេត្តស្រកាត្រី ចង្វាត្រពាំង (២) នៅដើមសតវត្សទី១៧ ដោយសារតែការធ្វេសប្រហែសរបស់ចៅហ្វាយខេត្តខ្មែរនៅទីនោះ ហើយនិងដោយសារសង្គ្រាមរវាងរាជវង្សខ្មែរ ដែលឈ្លោះគ្នាដណ្តើមរាជបល្លង្កនៅក្នុងឆ្នាំ១៦៥១ ។ ក្សត្រខ្មែរបានទៅសុំជំនួយទ័ពស្តេចយួនឲ្យមកជួយច្បាំងយកអំណាចឲ្យខ្លួន ស្តេចង្វៀង-វៀងក៏បញ្ជូនកងទ័ពយួនមួយកងពលធំមកជួយច្បាំងឲ្យស្តេចខ្មែរ ហើយឆ្លៀតពេលនោះក៏ដណ្តើមយកខេត្តស្រកាត្រីនិងចង្វាត្រពាំង ទៅទុកជាសរគុណដែលគេបានជួយស្តេចខ្មែរឲ្យបានអង្គុយលើរាជបល្លង្ក ។ ( កកន ៖ ស្តេចសីហនុក៏បានធ្វើដូចគ្នាដែរកាលពីឆ្នាំ១៩៧០ ដោយរត់ទៅពឹងកងទ័ពវៀតកុង-វៀតណាមខាងជើង ឲ្យចូលមកវាយប្រហាររបបសាធារណរដ្ឋខ្មែរ ដើម្បីយកអំណាចត្រឡប់មកវិញ ។ អំពើនេះបានបណ្តាលឲ្យបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិខ្មែរយ៉ាងសំបើម រហូតដល់ធ្វើឲ្យស្រុកខ្មែរក្លាយទៅជា<ទីលានពិឃាត>នៃសតវត្សទី២០ ។ នេះហើយគំនិតស្តេចលោភលន់ និងស៊ីជោរចាញ់កលខ្មាំង ) ។

អាណាខេត្តខ្មែរប៉ែកខាងកើតបានរបូតមួយម្តងៗទៅក្នុងកណ្តាប់ដៃយួន ៖ កំពង់ក្របីព្រៃនគរ (១៦៩៦), ខេត្តពាម, រាជា, មេ-ស, លង់ហោរ (១៧៣១), ផ្សារដែក, មាត់ជ្រូក (១៦៩៦), ទ្រាំងត្រើយត្បូង, ខេត្តទឹកខ្មៅ (១៨៤០) ។ ដំណើរឆ្ពោះមកទិសខាងត្បូងនៃជនជាតិយួនបានចប់សព្វគ្រប់ជាស្ថាពរ នៅពេលដែលយួនកាន់កាប់បានតំបន់ជ្រោយទឹកខ្មៅ ដែលជាដែនចុងខាងត្បូងបំផុតនៃដែនដីឥណ្ឌូចិន ។ មេដឹកនាំយួនក៏ចាប់រៀបចំដំណើរចុះមកទិសខាងលិចជាបន្តទៀត ព្រោះវាចាំបាច់ឲ្យជនជាតិយួនរស់ ។

(១) ប្រទេសចាមឬចំប៉ា កាន់សាសនាឥស្លាមនៅត្រង់វៀតណាមកណ្តាល មានប្រាសាទចាមជាតឹកតាង ។

(២) គឺខេត្តបៀនហ្វ៉ា ដូនណាយ បារៀ សព្វថ្ងៃ ។

ក្រោយស្តេចអង្គចន្ទទី២សុគតឆ្នាំ១៨៣៤ ក្នុងរាជក្សត្រីអង្គម៉ី យួនត្រួតត្រាស្រុកខ្មែរទាំងមូលដូចជាអាណាខេត្តយួនហៅថាត្រាន់-តាយថាន់ ហើយក្រុងភ្នំពេញបានប្រែឈ្មោះទៅជាណាំយ៉ាង ។ នេះជាដំណើរឆ្ពោះមកទិសខាងលិចលើកទី១របស់យួន ។ ក្នុងជំពូកទី១ យើងឃើញថា ការធ្វើវៀតណាមូបនិយកម្មប្រទេសខ្មែរ ការធ្វើឲ្យខ្មែរក្លាយទៅជាយួន ដោយមធ្យោបាយក្តៅរបស់ស្តេចមិញ-ម៉ាង, យ៉ា-ឡុង និង ទៀង-មិញយ៉ាងបានត្រូវបរាជ័យ ដោយសារប្រជារាស្ត្រខ្មែរបះបោរពាសពេញផ្ទៃប្រទេស កាប់សម្លាប់យួនទាំងស៊ីវិលទាំងទាហាន និងដោយសារវត្តមានព្រះអង្គឌួង ជាមួយកងទ័ពខ្មែរ-ថៃ ដែលមានព្យ៉ាបៈឱនតេជោជាមេទ័ពចូលមកស្រុកខ្មែរឆ្នាំ១៨៤១ ។

វត្តមានបារាំងដែលវាយយកស្រុកយួនដាក់ជាអាណានិគមបានក្នុងឆ្នាំ១៨៥៩ បានបង្អាក់ សំណើរឆ្ពោះមកទិសខាងលិច នៃពួកយួនមួយរយៈ ។

ក្នុងសម័យអាណានិគម យួនក៏បានធ្វើការតស៊ូវាយបារាំងមិនឈប់ឈរដែរ តែមានច្រើនក្រុមច្រើនបក្ស , មានតែបក្សកុម្មុយនិស្តវៀតណាមដឹកនាំដោយហូ-ជីមិញទេ ដែលមានឈ្មោះល្បីជាងគេ និងមានសមាជិកច្រើនជាងគេផង ។ មេដឹកនាំយួននេះមានបំណងដ៏ធំធេងណាស់ គឺប៉ងបង្កើតមហាចក្រវៀតណាម ( Viet Empire ) ដោយដាក់ឈ្មោះបំភ័ន្តថា សហព័ន្ធកុម្មុយនិស្តឥណ្ឌូចិន ឬសហព័ន្ធឥណ្ឌូចិន (Federation of Indochina) ដោយមធ្យោបាយលេបប្រទេសខ្មែរនិងលាវបញ្ចូលគ្នា ។ ក្នុងសម័យបារាំង យួនបានជំរុញបញ្ជូននិគមយួន ឲ្យមកតាំងនៅលើដែនដីកូសាំងស៊ីនកាន់តែច្រើនឡើងៗ និងបណ្តាក់គ្នាគេចូលទៅជិតជួយធ្វើការបារាំង យកចិត្តបារាំងក្នុងផែនការពង្រីកទឹកដីនេះ ។ ក្នុងវគ្គនេះខ្ញុំនឹងរាវរកនូវទំនាក់ទំនងសកម្មភាពដែលហូ-ជីមិញ ប៉ងយកចលនាតស៊ូខ្មែរ-លាវឲ្យរួបរួមជាមួយយួន ធ្វើជាទ័ពរួមចលនាតស៊ូឥណ្ឌូចិន វាយបារាំងឲ្យចេញពីឥណ្ឌូចិនទាំងមូល តែក្នុងពេលនោះយួនជាមេដឹកនាំគ្រប់វិស័យ ។

ច្បាស់ណាស់ ហូ-ជីមិញបានសិក្សាពិចារណាប្រវត្តិសាស្ត្រដូនតាគេ បរាជ័យភាពដូនតាគេ ក្នុងផែនការសំរេចនៃយួនូបនិយកម្មស្រុកខ្មែរ កាលពីពាក់កណ្តាលសតវត្សទី១៩នោះ ។ ដើម្បីសំរេចនូវផែនការយួនូបនិយកម្មក្នុងដំណើរឆ្ពោះមកទិសខាងលិចលើកទី២ក្នុងអនាគតនោះ ហូ-ជីមិញបានត្រិះរិះនិងរៀបចំគំរោងការយ៉ាងហ្មត់ចត់ណាស់ ដោយសិក្សាដល់ជំរៅសង្គមខ្មែរ ចំណុចខ្សោយ, ការគិតតែប្រយោជន៍ផ្ទាល់ខ្លួននៃមេដឹកនាំខ្មែរ រួចសរសេរបណ្តាំទុកឲ្យសាវ័កគាត់បន្តវេននយោបាយនេះទៀត ។

*　　*
*

# សកម្មភាពហូ-ជីមិញមកលើខ្មែរ និងការបដិសេធរបស់លោកសឺង-ង៉ុកថាន់

តាំងពីនៅជាកម្មករកប៉ាល់ឯស្រុកបារាំងម្ល៉េះ ហូ-ជីមិញមានគោលបំណងដ៏ធំធេងក្នុងការប្រឆាំងនឹងបារាំង និងបង្រួបបង្រួមប្រទេសទាំងបី (យួន-នាវ-ខ្មែរ) ធ្វើជាសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនដែលមានយួនជាអ្នកដឹកនាំ ។ ហូ-ជីមិញបានទាំងសរសេរនិចារណ៍កថាក្នុងសារព័ត៌មានផ្សាយនៅស្រុកបារាំងថា ឥណ្ឌូចិនបារាំងនឹងត្រូវធ្វើវៀតណាមូបនិយកម្មទៀតផង ។ តាមសំដីលោកទិត-អួន ដែលជាលេខាធិការផ្ទាល់របស់លោកសឺង-ង៉ុកថាន់ថា កាលនៅស្រុកបារាំងជាកម្មករដើរកប៉ាល់នៅឡើយរវាងឆ្នាំ១៩៣៥ ហូ-ជីមិញបានទៅបបួលទ្រង់សុផាណុវង្ស (លាវ) និងលោកថាន់ដើម្បីរួបរួមគ្នាបង្កើតចលនាតស៊ូរំដោះឥណ្ឌូចិនទាំងមូលពីអាណានិគមបារាំង តែដោយដឹងកលល្បិចរបស់យួន លោកសឺង-ង៉ុកថាន់បានបដិសេធសំណើររបស់ហូជីមិញដោយនិយាយថា សុំឲ្យយួនធ្វើការរំដោះឯស្រុកយួនចុះ ឯខ្មែរវិញយើងនឹងធ្វើការតស៊ូរំដោះនៅស្រុកខ្មែរដែរ យើងនឹងវាយបារាំងទាំងអស់គ្នា ដោយមិនឈ្លានពានគ្នា គឺយួនមិនត្រូវយកកងទ័ពមកនៅលើទឹកដីខ្មែរ ឯខ្មែរវិញក៏មិនយកកងទ័ពទៅតាំងនៅលើទឹកដីយួនដែរ ។ ព្រោះលោកសឺង-ង៉ុកថាន់មើលឃើញថា បើខ្មែរនិងលាវទៅរួបរួមចលនាតស៊ូជាមួយយួននោះ ខ្មែរនិងលាវក៏នឹងត្រូវយួនលេបអស់ទាំងកងកម្លាំងតស៊ូ អស់ទាំងទឹកដីទៅទៀត ដោយសារយួនមានប្រជាជនច្រើនជាងខ្មែរនិងលាវ ហើយមួយទៀតវាជាគោលបំណងមេដឹកនាំយួនក្នុងផែនការពង្រីកទឹកដីសំរាប់ប្រជាជនយួនស្រួលរស់នៅតទៅអនាគតផង ។ លោកសឺង-ង៉ុកថាន់មានកំណើតនៅដែនដីកម្ពុជាក្រោម ដែលយួនធ្លាប់ប្លន់យកនោះ, បានស្គាល់និងយល់ច្បាស់ណាស់នូវចិត្តគំនិតមេដឹកនាំយួន និងគោលបំណងរបស់ហូ-ជីមិញនេះ តែហូ-ជីមិញនេះមិនបោះបង់បំណងដ៏ធំធេងនោះឡើយ មេដឹកនាំយួននេះថែមទាំងបានសរសេរបន្ទាត់នយោបាយ និងបណ្តាំទុកឲ្យសាវ័កគាត់អនុវត្តតទៅអនាគត គឺដំណើរឆ្ពោះមកទិសខាងលិច តាមលំអានដូនតាយួន ( ព្រះចៅមិញ-ម៉ាង, យ៉ា-ឡុង, ទ្រឿង-មិញយ៉ាង ) នោះរហូតទាល់តែបានសំរេច ។

ក្រោយមកទៀត ពេលលោកសឺង-ង៉ុកថាញ់បានវិលត្រឡប់មកពីជីវភាពនិរទេសឯស្រុកបារាំងក្នុងឆ្នាំ១៩៥១ ហើយចូលព្រៃភ្នំដងរែកបង្កើតចលនាឥស្សរៈរួមខ្មែរបំរើជាតិនោះ (១) ប្រមាណជា៦ខែក្រោយមកលោកចូលព្រៃ ហូ-ជីមិញបានបញ្ជូន

(១) លោកសឺង-ង៉ុកថាញ់បានវិលត្រឡប់ពីជីវភាពនិរទេសឯស្រុកបារាំងនៅថ្ងៃទី២០តុលា១៩៥១ ហើយបានចូលព្រៃតស៊ូនៅថ្ងៃទី៩មិនា១៩៥២ ។ ពួកគណបក្សប្រជាធិបតេយ្យបានរៀបចំទទួលលោកនៅភោជនិយដ្ឋានកុក-ម៉េង ក្នុងពេលនោះលោកមិនបានធ្វើសុន្ទរកថាវែងឡើយ គ្រាន់តែពោលពាក្យអរគុណដល់គណកម្មការទាំងអស់ រួចលោកផ្តាំថា ៖ បើប្រសិនជាលោកម្នាក់ដួល សូមអ្នកទាំងអស់គ្នាកុំឈប់ ត្រូវនាំគ្នាបន្តរស់ទៅមុខទៀត ។ នេះជាសេចក្តីឲ្យការណ៍របស់លោកស៊ាម-ហួត គណកម្មការបក្សប្រជាធិបតេយ្យប្រចាំទីក្រុងភ្នំពេញ សព្វថ្ងៃរស់នៅក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។

តំណាងបួននាក់ (យួនពីរខ្មែរពីរ) មកសុំជួបជាមួយ ។ លោកសឹង-ង៉ុកថាន់បានឲ្យតំណាងវៀតមិញទាំងបួននាក់នៅក្នុងជំរំអូរស្មាច់សិន ។ លុះព្រឹកឡើងលោកថាន់ចាត់ផែនការជំនុំជាលើកទី២ ។ ក្នុងសម័យប្រជុំពេញអង្គលើកទី១ លោកបានឲ្យតំណាងយួន២នាក់នៅក្រៅសិន ចាំចូលរួមនៅថ្ងៃទី៣វិញ ព្រោះថ្ងៃទី១ជាការប្រជុំនៃមេដឹកនាំខ្មែរសុទ្ធ ។ តែដល់ថ្ងៃទី២ យួនពីរនាក់នោះមិនព្រមចូលប្រជុំ ដោយសំអាងថាគេមិនបានចូលរួមប្រជុំនៅលើកទី១ ។ ក្នុងថ្ងៃទី១ ខ្មែរពីរនាក់នោះបានស្នើតាមសំណើរយួនយៀកមិញថា ៖

១- សុំបញ្ជូនកងទ័ពវៀតមិញមកជួយច្បាំងបណ្តេញបារាំងចេញពីស្រុកខ្មែរ

២- សុំឲ្យខ្មែរជួយផ្តល់ស្បៀងអាហារសំរាប់កងទ័ពយួននៅឯស្រុកយួន

៣- សុំឲ្យទ័ពវៀតមិញចុះឡើងធ្វើសកម្មភាពតាមព្រំដែនខ្មែរដើម្បីវាយបារាំង

លោកសឹង-ង៉ុកថាញ់បានបដិសេធនូវសំណើររបស់យួនវៀតមិញនេះ ហើយបានពន្យល់ខ្មែរវៀតមិញទាំងពីរ ពីគំរោងការមិនស្មោះត្រង់របស់មេដឹកនាំយួនមកលើប្រទេសខ្មែរ ។ លោកបញ្ជាក់ថា ខ្មែរមិនចាំបាច់ទៅធ្វើកុម្មុយនិស្តទេ, ប្រជារាស្ត្រខ្មែរច្បាស់ជាមិនពេញចិត្តជាដាច់ខាត បើពួកគេយល់ថា កុម្មុយនិស្តជាអ្វីនោះ ? ។ បើចង់នាំខ្មែរឲ្យចូលកុម្មុយនិស្ត មានតែប្រើធម៌ក្តៅប៉ុណ្ណោះ (២) ព្រោះប្រជារាស្ត្រខ្មែរស្រឡាញ់សេរីភាព រាស្រ្តខ្មែរមិនទាន់ខ្វះម្ហូបអាហារដូចជារាស្ត្រយួននៅឡើយ គេធ្វើស្រែម្តងក្នុងមួយឆ្នាំ រួចសំរាក៥-៦ខែ ឯដីធ្លីបង្កបង្កើតផលក៏នៅធំទូលាយណាស់ រដ្ឋាភិបាលគ្រាន់តែជួយឲ្យកសិករខ្មែរចេះធ្វើស្រែតាមបច្ចេកទេសទំនើប បំបាត់ឈ្មួញកណ្តាល សំណូកសូកប៉ាន់ពុករលួយ នោះក៏នឹងអាចដោះស្រាយបញ្ហាជីវភាពកសិករខ្មែរបានហើយ ។

ពេលត្រឡប់ទៅវិញ ខ្មែរទាំងពីរនាក់នោះក៏ត្រូវយួនយកទៅសម្លាប់ចោល ដោយវាមិនទុកចិត្តនិងចោទថា បានចូលរួមប្រជុំសម្ងាត់ជាមួយលោកសឹង-ង៉ុកថាន់ ។

*　　*
*

(២) ចំណុចត្រង់នេះ ប៉ុល-ពតឬសាឡុត-សរបានមើលឃើញដែរ ហៅប្រើមធ្យោបាយក្តៅបង្ខំខ្មែរទូទាំងប្រទេសឲ្យទទួលយករបបកុម្មុយនិស្តម៉ៅនិយម ដោយជាដំបូងជននេះមិនបញ្ចេញគោលដៅនយោបាយគេឲ្យខ្មែរទាំងអស់ដឹងដូចជាសឹង-ង៉ុកថាញ់ទេ គេចែកផែនការគេជាដំណាក់ៗ រហូតរលាយស្រុក ។

# ផែនការហូ-ជីមិញ និងកលល្បិចបោកប្រាស់ខ្មែរ

លោកគីម-ផែន មានដើមកំណើតនៅកម្ពុជាក្រោម ធ្លាប់បានបួសរៀន ហើយបានទាក់ទងស្គាល់ពួកយួននិងខ្មែរក្រោមខ្លះ ដែលបានបំរើចលនាតស៊ូវៀតមិញ រហូតលោកបានទទួលឯកសារជាភាសាយួនស្តីពីចលនា និងសកម្មភាពយួនវៀតមិញ ក្នុងគោលបំណងលេបទឹកដីខ្មែរនិងលាវ ។ ដោយមើលឃើញគ្រោះមហន្តរាយដែលយួនកំពុងតែធ្វើមកលើខ្មែរដូច្នេះនោះ លោកក៏បានងាកមកចូលរួមជាមួយចលនាខ្មែរសេរីរបស់លោកសឺង-ង៉ុកថាញ់វិញ ។ លោកបានសរសេរចុះជាអត្ថបទប្រចាំថ្ងៃក្នុងទំព័រសារពត៌មាន « កោះសន្តិភាព » ស្តីអំពីគ្រោះថ្នាក់ដែលយួនកំពុងរៀបផែនការយកស្រុកខ្មែរ ។ ស្មេរខ្ញុំក៏ធ្លាប់បានអានអត្ថបទនោះដែរ ហើយក្នុងអត្ថបទនោះ មានភស្តុតាងថតចម្លងជាប់ទាំងឈ្មោះសារពត៌មាន និងអត្ថបទរបស់ហូ-ជីមិញ ដែលបានសរសេរចុះផ្សាយនៅស្រុកបារាំង តាំងតែពីកាលហូ-ជីមិញនៅធ្វើជាកម្មករឯស្រុកបារាំងម៉្លេះ ។ ចំណងជើងនោះសរសេរជាភាសាបារាំងថា ៖ L'Indochine française sera vietnamisee ។

ក្នុងសម័យសាធារណរដ្ឋ លោកគីម-ផែនមានឋានន្តរស័ក្តិជាអនុសេនិយឯក ( ស័ក្តិបី ) ធ្វើការក្នុងការិយាល័យទី២ (៣) ខាងផ្នែកយកពត៌មាន ក្រោយមកលោកជាប់ឆ្នោតជាតំណាងរាស្ត្រមណ្ឌលវិហារសួគ៌ ។ ដោយសេចក្តីស្នើរសុំពីអ្នកអានជាច្រើន លោកបានរៀបចំប្រមូលសំនេររបស់លោក ដែលចុះក្នុងសារពត៌មានកោះសន្តិភាព នោះចងក្រងជាសៀវភៅមួយឡើង ។ សំណៅអត្ថបទបានចូលទៅក្នុងរោងពុម្ពដើម្បីបោះជាសៀវភៅទៅហើយ តែអកុសលប្រទេសខ្មែរត្រូវអន្តរកប្ប ខ្មែរក្រហមឈ្នះរបបសាធារណរដ្ឋត្រូវរលំ លោកក៏បានបាត់បង់ជីវិតក្នុងរបបប៉ុល-ពតថែមទៀត ។

លោកគីម-ផែនបានបកប្រែឯកសារសរសេរជាភាសាយួននោះ ស្តីពីដំណើររបស់គណកម្មការយួន ដែលបានចុះមកធ្វើសកម្មភាពជាដំបូងក្នុងស្រុកខ្មែរ រវាងឆ្នាំ ១៩៤៧ ។ អត្ថបទនោះសរសេរថា គណកម្មការយួនវៀតមិញនោះមានពីរក្រុម មួយក្រុមមានគ្នាជាង១០នាក់ ។ ក្រុមទី១បានចុះមក ហើយតាំងទីទាក់ទងបង្កើតគណកម្មការស្ងួល ក្នុងតំបន់ខេត្តស្វាយរៀង, ព្រៃវែង, កំពង់ចាម, ជប់, មេមត់ ព្រោះនៅទីនោះមានយួនជាច្រើន ជាកម្មករចំការកៅស៊ូបារាំងនៅជប់-មេមត់ ។ ក្រុមទី២បានបន្តដំណើរទៅខេត្តកំពត ដោយឆ្លងកាត់តាមខេត្តតាកែវ ។ នៅតាកែវពួកគេបានទាំងចូលរួមសប្បាយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរក្នុងភូមិជនបទមួយ រួចទើបពួកវៀតមិញបន្តដំណើរទៅខេត្តកំពតទៀត ។ នៅទីនោះគេបានទាក់ទងបង្កើតគណកម្មការស្ងួល

(៣) នាយការិយាល័យទី២ គឺលោកគីម-អេងគួរនដេត ជាភ្នាក់ងារសម្ងាត់ផ្ទៃក្នុងរបស់ខ្មែរក្រហម ហេតុនេះហើយទើបគ្រប់ប្រតិបត្តិការយោធាចេនឡា១ ចេនឡា២ ត្រូវបរាជ័យរហូត ។

វៀតមិញ ដោយរើសពួកអនិកជនយួនកើតក្នុងស្រុកខ្មែរ ក្នុងចំណោមនិគមយួនជាច្រើន ដែលបានចាកចេញពីខេត្តពាម ( Hatien ) ។ ក្នុងនោះមានយួនកើតស្រុកខ្មែរម្នាក់ ធ្លាប់បួសសិក្សាធម៌វិន័យនៅពុទ្ធិកវិទ្យាល័យ ចេះនិយាយខ្មែរស្ទាត់ច្បាស់លាស់ ដែលខ្មែរយើងខ្លះស្គាល់ឈ្មោះថា « អាចារ្យមៀន » ។




*អាចារ្យអន-មៀន ឬ សឺង-ង៉ុកមិញ ជាកូនរបស់និគមយួនមកពីខេត្តពាម ( **Hatein** ) កើតនៅខេត្តកំពត ។ ហូ-ជីមិញបានឲ្យជននេះក្លែងឈ្មោះបន្លំ ថាជាប្អូនរបស់លោកសឺង-ង៉ុកថាញ់ ដើម្បីដឹកនាំចលនាខ្មែរវៀតមិញ ( បំរើយួន ) ។ ទៅរស់នៅហាណូយក្រោយសន្ធិសិទហ្សឺណែវ (២០កក្កដា១៩៥៤) ។ មេដឹកនាំយួនបានបញ្ជូនមក (ជាមួយអតិតខ្មែរវៀតមិញពីរពាន់នាក់) ឲ្យដឹកនាំចលនាខ្មែរក្រហមក្នុងឆ្នាំ១៩៧០ ។ ស្លាប់ក្នុងឆ្នាំ១៩៧២ ដោយប៉ុល-ពតបំពុល ។*

ដោយលោកសឺង-ង៉ុកថាញ់ជាមេដឹកនាំខ្មែរប្រឆាំងនឹងអាណានិគម ហើយត្រូវបារាំងចាប់ទៅ ខ្មែរកំពុងបាត់មេនោះ ហូ-ជីមិញក៏ឲ្យអាចារ្យមៀននេះមកក្លែងឈ្មោះជាសឺង-ង៉ុកមិញ ហើយឃោសនាថាជាបង្អូនបង្កើតរបស់លោកសឺង-ង៉ុកថាន់ ដើម្បីទាក់ទាញយកខ្មែរទៅបំរើចលនាយួនវៀតមិញ ។ ក្នុងឆ្នាំ១៩៥២ ខ្មែរពីរនាក់ដែលទៅជួបលោកសឺង-ង៉ុកថាន់ ( ជាមួយយួនពីរនាក់ ) បានសួរលោកថា ៖ តើសឺង-ង៉ុកមិញដែលមួនបន្តុបឲ្យធ្វើជាមេដឹកនាំនៅកំពតនោះ ត្រូវជាប្អូនលោកមែនទេ ? ។ លោកសឺង-ង៉ុកថាន់ឆ្លើយតបវិញថា ៖ បើសឺង-ង៉ុកមិញធ្វើការដើម្បីខ្មែរ បំរើផលប្រយោជន៍ខ្មែរ បំរើឧត្តមគតិខ្មែរ មិនធ្វើការឲ្យយួន នោះទើបសឺង-ង៉ុកមិញជាប្អូនខ្ញុំ តែសឺង-ង៉ុកមិញធ្វើការបំរើហូ-ជីមិញ ហេតុនេះហើយសឺង-ង៉ុកមិញមិនមែនជាប្អូនខ្ញុំទេ ។ ហូ-ជីមិញបានឲ្យអាចារ្យមៀនកែឈ្មោះជាសឺង-ង៉ុកមិញ ក្នុងបំ-ណងបោកយកខ្មែរដែលកំពុងបាត់មេ ដឹកនាំឲ្យចូលក្នុងអន្ទាក់យួន បំរើចលនានិងផលប្រយោជន៍យួន ព្រោះងាយនឹងសំរេចមហិច្ឆិតាដ៏ធំធេងរបស់ហូ-ជីមិញ ក្នុងគំនិតពង្រីកទឹកដី បង្កើតជា «សហាពន្ធឥណ្ឌូចិន» ដោយមេដឹកនាំយួននេះមើលឃើ-ញថា តទៅអនាគតរាស្ត្រយួនមិនអាចរស់នៅលើដែនដីដ៏តូចចង្អៀតផ្តល់ផលិតផលកសិកម្មចិញ្ចឹមមាត់មិនគ្រប់គ្រាន់នោះទេ គឺមានតែយកស្រុកខ្មែរនិងលាវទេទើបយួនរស់ ។ តាមពិតលោកសឺង-ង៉ុកថាន់ គ្មានប្អូនបង្កើតឈ្មោះសឺង-ង៉ុកមិញទាល់តែសោះ គឺយួនហូ-ជីមិញធ្វើបំភ័ន្តខ្មែរឲ្យយល់ច្រឡំ ហើយនាំគ្នីគ្នាចូលទៅរួមបំរើចលនាតស៊ូយួន ក្នុងគោលដៅយកស្រុកខ្មែរបញ្ចូលទៅក្នុងសហាពន្ធឥណ្ឌូចិនតែប៉ុ-ណ្ណោះនាអនាគត នៅ ពេលយួនមានជ័យជំនះលើអាណានិគមបារាំងនិងចក្រពត្តិអា

មេរិកាំងរួចរាល់ហើយ ។ ដូច្នេះគ្មានសញ្ញាណាមួយបញ្ជាក់ថា មេដឹកនាំយួននឹងប-
ញ្ឈប់សង្គ្រាមពង្រីកទឹកដីសោះឡើយ ។

ក្រោយបន្តិចមកទៀត ពួកវៀតមិញបានមកបណ្តុះគណកម្មការស្តួលនៅសំឡូ
ត អាគ្នេយ៍ខេត្តបាត់ដំបង ដោយបញ្ជូនយួនប្រាំនាក់មកទាក់ទងបានខ្មែរឥស្សរៈ ៖
ស៊ីវ-ហេង, មូល-សម្បត្តិ, លាវ-កែវមុនី, អាចារ្យប្រេស, ប៊ុង-គឿក, រុង-លើត (
នួន-ជា ) ។ ខ្មែរឥស្សរៈទាំងនោះ ក៏មានឈ្មោះថ្មីថា « ខ្មែរវៀតមិញ » ។ ពួកក្រោយ
នេះធ្វើសកម្មភាពកាប់សម្លាប់រាស្ត្រខ្មែរដាក់មីនធ្វើឲ្យរទេះភ្លើងផ្ទុះក្រឡាប់ស្លាប់ខ្មែរ
ស្លូតត្រង់ជាច្រើន តាមខ្សែបញ្ជាក់របស់វៀតមិញ ។ នេះជាការចាប់ផ្តើមរបស់យួនក្នុង
នយោបាយខ្ចីដៃខ្មែរលាបមុខខ្មែរ ( ដូចគេលាបមុខមាន់ប្រជល់គ្នា ) ឲ្យសម្លាប់ខ្មែរ
ហើយ ។

យួនបានទុកចលនាខ្មែរកុម្មុយនិស្តនិងលាវក្រហមដូចកូនរបស់គេ ។ យួនបាន
រៀបចំគ្រោងការណ៍ល្អិតល្អន់ណាស់ ក្នុងការបណ្តុះស្តួលខ្មែរវៀតមិញនេះ ។ ក្រោ
យពីការទាក់យកបានខ្មែរឥស្សរៈមួយចំនួនហើយ យួនក៏ចាប់អប់រំផ្នែកសតិអារម្ម-
ណ៍ពួកនេះឲ្យស្រឡាញ់យួនវៀតមិញ ដើរតាមមាគ៌ាយួន ។ ពួកខ្មែរវៀតមិញរាប់រយ
នាក់ បានទៅសិក្សាទ្រឹស្តីវៀតមិញក្នុងសាលានយោបាយក្រុងហាណូយក្នុងឆ្នាំ១៩-
៤៧ (2) ឯស៊ីវ-ហេងបានទៅហាណូយក្នុងឆ្នាំ១៩៥១ ខ្លះបានទៅសិក្សានៅស្រុកចិន
ប៉េកាំងទៀតផង ដូចជាអាចារ្យសារេន ( ឡាច-សារេន ) បានចេញទៅហាណូយរួច
បន្តទៅប៉េកាំងក្នុងឆ្នាំ១៩៥៥ ឯប្រពន្ធឈ្មោះលឿត កូនប្រុសពីរ ( ឡាចវីរៈ, ឡាច-
វរវីរៈ ) កូនស្រីពីរ ( ឡាច-តារា, ឡាច-វិរតារា ) បានចាកចោលផ្ទះនៅវត្តគរ ស្រុក
សង្កែ បាត់ដំបង ( ជិតផ្ទះម្តាយនួន-ជា ) ទៅតាមប្តីក្នុងឆ្នាំ១៩៦០ តាមរយៈខ្សែចារ
កិច្ចយួននៅបាត់ដំបង រួចទៅសំណាក់ផ្ទះញាតិនៅភ្នំពេញ និងឡើងយន្តហោះទៅ
ហាណូយ ។ អាចារ្យសារេនមានកំណើតនៅភូមិចំការសំរោង ជាប់ឌីប្លូមសាលាបា
លីក្រុងភ្នំពេញ ( Diplome de l'Ecole Suprême de Pali à Phnom Penh ) (៩)
កាលនៅក្នុងព្រៃមានមុខងារជាគណនយោបាយរបស់វៀតមិញ នៅស្រុកសំឡូតខេ
ត្តបាត់ដំបង ។

ថែមពីលើការនេះទៀតនោះ មេដឹកនាំយួនហូ-ជីមិញប្រហែលជាគេមិនទុកចិត្ត
ពួកខ្មែរវៀតមិញក៏មិនដឹង ទើបគេរៀបចំគំរោងការណ៍សំរាប់រយៈពេលវែងមួយទៀ
ត ។ ពួកយួនបានដើរចាប់កុមារខ្មែរ ឬបញ្ចុះបញ្ចូលក្មេងជំទង់ខ្មែរ យកទៅហាណូ-
យអប់រំខួរក្បាលសំរាប់បំរើនយោបាយយួន ។ បងៗខ្លះប្រហែលនៅចាំបានថា រវាង
ឆ្នាំ១៩៥១-៥៥ ម្តាយខ្មែរតែងព្រមានកូនមិនឲ្យដើរលេង ខ្លាចប្រមាត់ប្រមង់ឬអារ៉ាប់
ចាប់កូនក្មេង ។ វៀតមិញបានជួលឲ្យចាប់ក្មេងខ្មែរយកទៅអប់រំដើម្បីសំរេចផែនការ
វៀតណាមូបនិយកម្មរាស្ត្រនិងស្រុកខ្មែរ ធ្វើជាសហាពន្ធឥណ្ឌូចិននាអនាគត ដោយ
យកក្មេងខ្មែរ ដែលវាអប់រំទុកនោះឲ្យដឹកនាំស្រុក តែក្រោមការត្រួតពិនិត្យរបស់យួន
។ ពួកក្មេងខ្មែរអស់ទាំងនោះ រហូតមកដល់សព្វថ្ងៃ ខ្លះមានវ័យ៣០ឬ៤០ឆ្នាំ ហើយ

(៩) តាមសេចក្តីឲ្យការណ៍របស់លោកតូច-ឈ្លួង អ្នកនិពន្ធសៀវភៅ « បាត់ដំបងសម័យលោ
កម្ចាស់ » សព្វថ្ងៃនៅវត្តគរ ។

ធ្វើការក្នុងរបបហេង-សំរិន ខ្លះមិនទាំងស្គាល់ម៉ែឪ បងប្អូនបង្កើត ឬស្រុកភូមិកំណើតខ្លួនឡើយ លើកលែងតែមានវ័យជំទង់ ក្នុងចំណោមនោះមានប៉ែន-សុវណ្ណ, ជា-ស៊ីម, រស់-សម័យ ដែលយួនដឹកនាំយកពីស្រុកលាវ ពោធិសាត់ទៅ ( តាមសំដីឲ្យការណ៍របស់លោកឡៅ-ឈិន ) ។

នៅដើមឆ្នាំ១៩៧៩ ដែលទ័ពយួនវាយឈ្លានពានប្រទេសខ្មែរនោះ ប៉ុល-ពតបានដឹកជញ្ជូនក្មេងកំព្រាធំៗកៀរមកតាម កាត់ព្រៃអត់អាហារស្លាប់អស់ជាច្រើន ឯក្មេងកំព្រាតូចៗ ដែលវាប្រមូលមិនទាន់ ក៏ចាក់សោរឃុំទុកក្នុងមន្ទីរ ។ ដល់កងទ័ពយួនចូលមក វាក៏ប្រមូលយកក្មេងកំព្រាខ្ទង់១,០០០នាក់ទៅហាណូយ (៥) ដើម្បីអប់រំបញ្ចូកទ្រឹស្តី ទុកធ្វើជាស្នូលបំពើផែនការយួនតទៅអនាគតទៀត ។ យួនធ្វើដូចគ្នានៅឯស្រុកលាវ ចំពោះកូនកំព្រាលាវ ។ ពួកខ្មែរវៀតមិញមានឈ្មោះសឺង-ង៉ុកមិញជាមេដឹកនាំ ដូច្នេះយួនជាអ្នកបង្កើតខ្មែរនិងលាវកុម្មុយនិស្ត ។ បក្សកុម្មុយនិស្តទាំងបីប្រទេស ( យួន-លាវ-ខ្មែរ ) ត្រូវរួមបញ្ចូលគ្នាហៅថា « បក្សកុម្មុយនិស្តឥណ្ឌូចិន Indochinese Communist Party ឬ ICP ) ។ បក្សកុម្មុយនិស្តឥណ្ឌូចិនបានបង្កើតឡើងនៅឆ្នាំ១៩៣០ នៅក្រុងហុងកុង ។ កាលណោះនៅមិនទាន់មានសមាជិកជាជាតិខ្មែរនៅឡើយទេ ។ លុះក្រោយមក ក្នុងរវាងឆ្នាំ១៩៤០ប្លាយ ទើបយួនបោកបានខ្មែរមួយចំនួន តែភាគច្រើនជាខ្មែរក្រហមដោយបញ្ឆោតថាយួននឹងប្រគល់ដីកម្ពុជាក្រោមមកខ្មែរវិញ កាលណាច្បាំងឈ្នះបារាំង ។

នៅឆ្នាំ១៩៤៥-៤៧ យួនវៀតមិញបានគាំទ្រចលនាតស៊ូដើម្បីសេរីភាពនៅប្រទេសខ្មែរ (និងលាវ) ដោយសារខ្មែរកំពុងបាត់មេដឹកនាំ ព្រោះលោកសឺង-ង៉ុកថាញ់ត្រូវបារាំងចាប់ យួនក៏បានឱកាសលូកដៃមកកកូរផ្ទៃក្នុងចលនាខ្មែរឥស្សរៈ ទាក់ទាញបានពួកលាវ-កែវមុនី, ម៉ី-ផូ, ម៉ា-មូន, ស៊ីវ-ហេង, មូល-សម្បត្តិ, សោ-ភឹម... ។ល។

នៅក្នុងឆ្នាំ១៩៥០ ពួកខ្មែរឆ្វេងនិយមបានរីកដុះដាលយ៉ាងខ្លាំង ដោយមានទំនាក់ទំនងជិតស្និទ្ធជាមួយពួកប៉ាថេតឡាវ និងបក្សលានវៀត ( Lien Viet Front of Vietnam ) ។

នៅថ្ងៃទី១៧មេសា១៩៥០ ខ្មែរឥស្សរៈ ដែលភាគច្រើនជាអតិតសមាជិកកុម្មុយ

(៥) ជាពិសេសពួកកូនកំព្រាដែលឪពុកម្តាយវិលត្រឡប់មកពីបរទេស ( ភាគច្រើនមកពីប្រទេសបារាំង ក្នុងចំណោមនោះមានក្មួយបង្កើតខ្ញុំមួយដែរ ដែលឪពុកវា ( ហ៊ុន-ស៊ីហ៊ាន ) បាននាំត្រឡប់មកពីក្រុងប៉ារីសក្នុងឆ្នាំ១៩៧៦ ក្នុងរវាងខែមេសា តាមការបោកបញ្ឆោតរបស់អៀង-សារី ថាត្រូវការបញ្ញវ័ន្តខ្មែរនៅបរទេសមកជួយ កសាងស្តារស្រុកទេសដែលខ្ទេចខ្ទាំដោយសង្គ្រាម ។ ប្រាំមួយខែក្រោយមក ពួកខ្មែរក្រហមបានយកប្អូនខ្ញុំនេះទៅសម្លាប់ចោលបាត់ទៅ ហើយយកក្មួយហ៊ិន-រ៉ោហារអាយុពីរឆ្នាំ ទៅដាក់ក្នុងមន្ទីរភូមិមួយជិតរោងចក្រធ្វើកែវចំការដូង ។ ប្រាំមួយ-ប្រាំពីរខែក្រោយដែលយួនវាយឈ្លានពានកាន់កាប់ស្រុកខ្មែរ អ្នកស្រីអេលីសាបែត-បេចក័រ ( Elizabeth Becker ) បានឃើញក្មេងកំព្រាខ្មែរជាង៧០០នាក់នៅហាណូយ ដូចអ្នកស្រីបានសរសេរក្នុងអត្ថបទ ( How Vietnamese create a regional communist Empire - The Hanoi Pact ) ចុះក្នុង The New Republic ថ្ងៃទី២០ តុលា ១៩៨៦ ស្រាប់ ។

និស្តឥណ្ឌូចិន បានបើកសមាជទី១នៅសំឡូតបាត់ដំបង ជាប់ព្រំដែនថៃ ដើម្បីបង្កើតរណសិរ្សរួបរួមខ្មែរឥស្សរៈ ( United Khmer Issarak Front ) ។ សមាជលើកទី១នេះដឹកនាំដោយសឺង-ង៉ុកមិញ ។ ត្រង់នេះហើយដែលធ្វើឲ្យខ្មែរឥស្សរៈកៅ-តក់បានបាក់បែកគ្នាពីពួកលាវ-កែវមុនី រហូតមានការបាញ់គ្នានៅភូមិក្រូចចារ មិនមែននៅភូមិប្រី និងមិនមែនដោយសារប្រាក់៦០០,០០០ ដែល Ben Kiernan បានសរសេរក្នុងសៀវភៅ How Pol Pot came to power នោះទេ ។ តាមឯកសារប្រវត្តិបក្សកុម្មុយ និស្តខ្មែរបោះផ្សាយក្នុងឆ្នាំ១៩៧៣ថា កាលណោះមានបក្ខជនខ្មែរកុម្មុយនិស្តតែចំនួន៤០នាក់ប៉ុណ្ណោះ ( គ្មានការចេះដឹងជ្រៅជ្រះ និងមិនដឹងពីគោលបំណងយួនរៀបផែនការលេបស្រុកខ្មែរផង) ។ ដោយខ្មែរមិនព្រមនៅក្រោមការដឹកនាំយួនៗក៏រៀបចំផែនការថ្មី គឺឲ្យបក្សកុម្មុយនិស្តឥណ្ឌូចិនរំលាយខ្លួននៅដើមឆ្នាំ១៩៥១ ហើយបង្កើតជាបក្សកុម្មុយនិស្តខ្មែរ លាវ និងវៀតណាមរៀងៗខ្លួន តែបក្សកុម្មុយនិស្តយួននៅតែត្រួតត្រាដដែល ដូចដែលឯកសារវៀតណាមបានបញ្ជាក់ក្នុងខែវិច្ឆិកា ១៩៥១ ថា ៖ បក្សកុម្មុយនិស្តវៀតណាមនៅរក្សាសិទ្ធិ មើលការខុសត្រូវលើសកម្មភាពបក្សបងប្អូនកម្ពុជានិងលាវ ។ ក្រោយមក, ទោះបីយ៉ាងណាក៏ដោយ បើលក្ខ័ណអនុញ្ញាតឲ្យនោះ បក្សបដិវត្តន៍ទាំងបីនឹងរួបរួមគ្នាធ្វើបក្សតែមួយ គឺបក្សសហព័ន្ធវៀតណាម ខ្មែរ និងលាវ (The Vietnam-Khmer-Laotian Federation's Party ) (3)

បក្សបដិវត្តន៍ប្រជាជនខ្មែរ ( Khmer's People Revolution Party - KPRP ) បានកើតឡើងនៅខែកញ្ញាឆ្នាំ១៩៥១ ឯលក្ខន្តិកៈគឺចម្លងចេញមកបីបក្សកុម្មុយនិស្តវៀតណាម (5) ។ តាមប្រវត្តិរបស់បក្សកុម្មុយនិស្តខ្មែរនៅឆ្នាំ១៩៥២ ពួកគេមានសមាជិកខ្ទង់មួយពាន់នាក់ជាស្រេច ។

នៅថ្ងៃទី៣ ខែមិនា ១៩៥១ រណសិរ្សរួបរួមជាតិខ្មែរ វៀតណាម និងលាវ បានជួបប្រឹក្សាគ្នា ហើយបង្កើតជាបក្សសម្ពន្ធវៀតណាម-ខ្មែរ-លាវឡើង រួចក៏ប្រកាសហៅប្រជាជនប្រទេសទាំងបីឲ្យធ្វើសហប្រតិបត្តិការវាយរំលំអាណានិគម ។ យោលលើការសំរេចចិត្តនេះ ដែលគេបានបោះផ្សាយនៅថ្ងៃទី១១ ខែមិនា ១៩៥១នោះ កងទ័ពយួនវៀតមិញក៏បានលេសសំអាងចូលមកក្នុងស្រុកខ្មែរនិងលាវ ដើម្បីជួយច្បាំងពួកខ្មែរក្រហមដែលក្រោយមកក្លាយជាកងទ័ពរំដោះជាតិកម្ពុជា ( The Khmer National Liberation Army ) និងជួយច្បាំងពួកលាវក្រហមប៉ាថេតឡាវផងដែរ (6) ។

នៅឆ្នាំ១៩៥៤ ពួកយួនវៀតមិញបានទៅឃោសនាបោកពួកខ្មែរកម្ពុជាក្រោមថាពួកគេធ្វើការឲ្យសម្តេចសីហនុ ហើយបានបង្ហាញប័ណ្ណគណកម្មការពិសេសដែលមានរូបថតសម្តេចនៅលើនោះផង ។ ខ្មែរក្រោមមួយចំនួនធំបានចូលរួបរួមក្នុងចលនាយួនវៀតមិញ ។ (៦) គេឃោសនាឲ្យខ្មែរនៅកម្ពុជាក្រោមមកវិញ ។ នេះជាល្បិចព្រួញមួយបាញ់បានសត្វពីររបស់យួនវៀតមិញ ។ មួយគឺពួកវៀតមិញចំផុសឲ្យខ្មែរបះបោរឡើង ដើម្បីឲ្យមានការរីករាលក្នុងផ្នែករដ្ឋបាល-សង្គមយួនខាងត្បូង ។ ពីរគឺ

(៦) សេចក្តីឲ្យការណ៍របស់លោកសឺន-ឡៃ វរសេនិយទោម៉ែកហ្វក សព្វថ្ងៃរស់នៅតាខូម៉ា រដ្ឋវ៉ាស៊ិនតោន ។

រដ្ឋការយួនព្រៃនគរក៏នឹងចាត់វិធានការបង្ក្រាបកាប់សម្លាប់ខ្មែរក្រោម យ៉ាងចាស់ដៃទៀត។ អ្នកចំណោញគឺវៀតកុង-វៀតណាមខាងជើងឯណោះសោះ ព្រោះខ្មែរដែលបះបោរនោះក៏នឹងត្រូវស្លាប់វិនាសផង ហើយអ្នកដែលរត់រួចខ្លួន នឹងរត់មកចូលបំរើពួកវៀតកុងវិញ ។ នេះជាល្បិចយ៉ាងងាយបំផុតរបស់យួនកុម្មុយនិស្តក្នុងការសម្លាប់ខ្មែរ ។ កាលនោះ លោកសឹង-ង៉ុកថាន់ទើបនឹងវិលចូលមក ពីជីវភាពលាក់ខ្លួននៅឯខេត្តឡុងនិញ ។ ពេលនោះលោកបានដឹងថា ខ្មែរក្រោមចាញ់ឃោសនាបោកបញ្ឆោតរបស់ពួកវៀតកុងហើយៗប្រុងនឹងបះបោរថែមទៀត ដោយមានមេដឹកនាំម្នាក់ឈ្មោះថាច់-ណៃង (៧) ។ ពួកគិញសម្ងាត់យួនខាងត្បូងបានរកចាប់លោកថាច់-ណៃង ព្រមទាំងបក្សពួកដែលរត់គេចលាក់ខ្លួនតាំងភ័យភិត ។ លោកសឹង-ង៉ុកថាន់បានឲ្យគេហៅលោកថាច់-ណៃងទៅជួបលោកនៅឯព្រៃនគរ ។ លោកក៏បាននិយាយសំរួលដោះស្រាយជាមួយរដ្ឋការព្រៃនគរឲ្យបានស្រួលបួលទៅវិញ ។ លោកបានពន្យល់ពីគ្រោះថ្នាក់ ដែលជាល្បិចរបស់យួនកុម្មុយនិស្តប្រុងនឹងសម្លាប់ខ្មែរនេះដល់ខ្មែរក្រោមគ្រប់ៗគ្នាឲ្យប្រុងប្រយ័ត្នគ្រប់ៗជំហាន (៨) ។

* *
*

(៧) ប៉ូលីសតាំងពីសម័យបារាំង ខ្មែរខេត្តព្រះត្រពាំងស្លាប់ជឿតាមណាស់- គាត់ព្រមចូលរួមនឹងលោកសឹង-ង៉ុកថាញ់ ។
(៨) សេចក្ដីឲ្យការណ៍របស់លោកសិម-គិន នៅទីក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។

# ខ្មែរវៀតមិញ

គឺយួនវៀតមិញដែលជាអ្នកបង្កើតពួកខ្មែរវៀតមិញនេះក្នុងរវាងឆ្នាំ១៩៤៦-១៩៤៧ តែកាលនោះមានខ្មែរ តែខ្ទង់សែសិបនាក់ ដែលជាសមាជិកក្នុងចលនាឥណ្ឌូចិនកុម្មុយនិស្ត ( Indochinese Communist Party - ICP ) ។ ពួកយួនវៀតមិញបានចូលមកបង្កើតមូលដ្ឋានបីនៅក្នុងស្រុកខ្មែរ ៖

១- មូលដ្ឋានព្រែក មេមត់-ជប់ មានជនជាតិយួនជាច្រើនជាកម្មកររបស់ចំការកៅស៊ូបារាំង ។ មូលដ្ឋាននេះធ្វើសកម្មភាពនៅក្នុងតំបន់ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី កំពង់ចាម ព្រៃវែង ស្វាយរៀង ។ មូលដ្ឋាននេះកាន់កាប់ដោយពួកយួនវៀតមិញផ្ទាល់តែម្តង ។

២- មូលដ្ឋានទី២នៅកំពត ដែលដឹកនាំដោយយួនកើតនៅស្រុកខ្មែរឈ្មោះអាចារ្យអន-មៀន ដែលយួនឲ្យក្លែងឈ្មោះថា សឺង-ង៉ុកមិញ ជាមេដឹកនាំរបស់ពួកខ្មែរវៀតមិញ ។ មូលដ្ឋាននេះធ្វើសកម្មភាពក្នុងមណ្ឌលខេត្តតាកែវ, កំពត, កោះកុង, កំពង់ស្ពឺ ។ ក្រោយមកទៀតមានលោកវិស្វករជី-គិមអាន និងសាឡុត-សរ មកពីស្រុកបារាំង មកចូលរួមក្នុងមូលដ្ឋាននេះដែរនៅឆ្នាំ១៩៥៣ (2) ។

៣- មូលដ្ឋានទី៣គឺនៅប៉ែកខាងលិចឆៀងខាងត្បូងខេត្តបាត់ដំបង ត្រង់តំបន់សំឡូត ក្រញូង ។ យួនបានជ្រើសរើសគណកម្មាធិការដែលជាអតីតខ្មែរឥស្សរៈ ដែលមានលោកស៊ីវ-ហេង(៩) ជាមេបញ្ជាការសឹកភូមិភាគពាយព្យទិស, មូល-សម្បត្តិជាមេទ័ព, រុង-លើត (ឡុន-ជា ) ជានាយផ្នែកសេដ្ឋកិច្ច, អាចារ្យឡាច-សាវេន និងឡាច-សារ៉ែន ជាគណៈនយោបាយ ។ មូលដ្ឋាននេះធ្វើសកម្មភាពក្នុងខេត្តពោធិសាត់ បាត់ដំបង សៀមរាប ។

សាឡុត-សរ ឬប៉ុល-ពត បានវិលមកចូលរួមក្នុងចលនាខ្មែរវៀតមិញ ដែលមានមេដឹកនាំយួនឈ្មោះសឺង-ង៉ុកមិញ ក្នុងខែមករា ឆ្នាំ១៩៥៣ នៅមូលដ្ឋានកំពង់ត្រាច ។

ក្នុងសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ពួកខ្មែរវៀតមិញគ្មានកៅអីទេ ដោយពួកនេះគ្មានដែនដីរំដោះកាន់កាប់ដូចយួនហូ-ជីមិញ ។ ឯប៉ាថេតឡាវមានកៅអី ដោយគេមានមូលដ្ឋានរំដោះនៅប៉ែកខាងជើងជាប់នឹងទល់ដែនយួន ។ ចំពោះប្រទេសខ្មែរ មានតែរដ្ឋាភិបាលសម្តេចសីហនុទេដែលតំណាងកៅអីខ្មែរ ដោយយកខ្មែរឥស្សរៈចុះចូលមានដាប-ឈួន, ច័ន្ទរង្សី, ពុត-ឆាយ ជាបន្ទាល់មិនឲ្យបែងចែកប្រទេសខ្មែរជាពីរ ដូចជាប្រទេសលាវនិងយួនទេ ។ នេះជាមេរៀនមួយរបស់ពួកខ្មែរវៀតមិញដែលក្រោយមក ក្លាយមកជាខ្មែរក្រហម ។ មេរៀននេះហើយដែលជំរុញឲ្យក្រុមប៉ុល-ពតអនុវត្តនូវផែនការវាយរំដោះយកតំបន់ជនបទឡោមព័ទ្ធទីក្រុងពុករលួយ រហូតដល់បានសំរេចជោគជ័យជាស្ថាពរក្នុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ( តាមឱវាទម៉ៅ-សេទុង ) ។

*(៩) ស៊ីវ-ហេងចូលរួមជាមួយលន់-នល់ក្នុងឆ្នាំ១៩៧០ ធ្វើជាវរសេនិយទោនៅបន្ទាយសឹករងស៊ីសុផុន ។*

ក្រោយសន្ធិសិទហ្សឺណែវ យួនបានយកខ្មែរវៀតមិញរាប់ពាន់នាក់ ឲ្យទៅជ្រក កោននៅហាណូយ រង់ចាំឱកាសល្អលើកក្រោយទៀត ។ ក្នុងនោះមានមេដឹកនាំខ្មែរវៀតមិញឈ្មោះសឺង-ង៉ុកមិញ ( អាចារ្យអន-មៀន ) ក៏ទៅរស់នៅក្រុងហាណូយដែរ ។

ក្រុមទី២ខ្មែរវៀតមិញមាន សាឡុត-សរ, រ៉ុង-លើត (នួន-ជា), ស៊ីវ-ហេង, មូល-សម្បត្តិ ( រស់-ញឹម ឬតាកៅ ), អាចារ្យឡាច-សារ៉ែន, ឡាច-សារេនជាដើមមិនទៅហាណូយតាមពួកយួនវៀតមិញឡើយ ។ គឺក្រុមទី២នេះឯង ដែលក្រោយមកក្លាយជាខ្មែរក្រហម ។ ពួកក្រោយនេះចែកចេញជាពីរក្រុមទៅទៀត ៖

១- ក្រុមទី១មាន លោកស៊ីវ-ហេង, មូល-សម្បត្តិ,អាចារ្យឡាច-សារេន, ឡាចសារ៉ែន បានរស់នៅរកស៊ីជាជនសាមញ្ញធ្វើស្រែចំការក្រួចនៅភូមិវត្តគរខ្លះ នៅរូងកន្ទឹកង់ហាតខ្លះ ( តាមដងស្ទឹងសង្កែទៅលើ ), នៅភូមិថ្វាកខ្លះ ក្នុងខេត្តបាត់ដំបង ។

២- ក្រុមទី២មាន សាឡុត-សរ (ប៉ុល-ពត), រ៉ុង-លើត (នួន-ជា) និងគ្នាគេមួយចំនួនទៀត បន្លំបង្កប់ខ្លួនក្នុងទីក្រុងភ្នំពេញដើម្បីរៀបចំគ្រឹះបដិវត្តន៍ ។ ពួកគេជួលផ្ទះនៅជិតៗគ្នាត្រង់ម្តុំមេភ្លើងខាងក្រោមពេទ្យចិន ។ ពួកគេបង្កប់ខ្លួន ធ្វើសកម្មភាពពន្យល់ទាក់ទាញពួកយុវសិស្សក្រីក្រ ដែលភាគច្រើនមិនស្គាល់ថាកុម្មុយនិស្តជាស្អីផង ។

*　　　*

*

# ខ្មែរក្រហម

នៅក្នុងក្រុងភ្នំពេញ សាឡុត-សរ និងឡេា-បេងគន (១០) បានបង្កើតវិទ្យាល័យឯកជនពីរនៅជិតមេភ្លើងក្រោមពេទ្យចិនគឺ : វិទ្យាល័យកម្ពុជាបុត្រ និងវិទ្យាល័យចំរើនវិជ្ជា ។ ឡេា-បេងគន នៅបង្រៀនប្រវត្តិសាស្ត្រក្នុងវិទ្យាល័យទាំងពីរ, គឺជននេះហើយដែលបញ្ចុះបញ្ចូលសិស្សក្រីក្រគ្មានប្រាក់បង់ថ្លៃសាលា ធ្វើជា « ចលនាយុវជនកុម្មុយនិស្តកម្ពុជា - អក្សរកាត់ហៅថា : យុវកក » (១១) ឡើង ។ ពួកសមាជិកចលនា « យុវកក » គឺជាចលនាស្នូលបដិវត្តន៍របស់សាឡុត-សរ ។ ក្រោយដែលពួកខ្មែរក្រហមមានជ័យជំនះរំលំរបបសាធារណរដ្ឋលន់នល់ នៅថ្ងៃទី១៧ មេសា ១៩៧៥មក អង្គការខ្មែរក្រហមបានយកពួក យុវកក នេះមកធ្វើជាគណៈស្រុកនានា ឬជួនកាលតែងតាំងជាគណសហករណ៍ផង ។

(១០) ជាឈ្មោះពិតរបស់នួន-ជា ព្រោះឪពុកឈ្មោះ ឡេា-លីវ នៅភូមិវត្តគរ ខេត្តបាត់ដំបង ។

(១១) សំដីឆ្លើយឆ្លងគណៈស្រុកឆេងជាមួយម្តាយនួន-ជា នៅពាក់កណ្តាលឆ្នាំ១៩៧៩ ។ កាលណោះប៉ុល-ពតបានយកយោធាមជ្ឈឹមបក្សទៅព័ទ្ធចាប់មូល-សម្បត្តិ ភាគពាយ័ព្យនិងគណៈតំបន់, គណៈសហករណ៍, គណៈស្រុក, គណៈឃុំ, កងឈ្លបនិងកងយោធា ដកហូតអាវុធអស់រួចយកទៅសម្លាប់ចោល លើកលែងតែគណៈស្រុកយាន ដែលជិតដិតនឹងម្តាយនួន-ជា គេមិនបានចាប់ចងឬធ្វើទោសអ្វីឡើយ ។ កាលនោះស្មេរខ្ញុំនៅធ្វើជាកម្មករក្នុងរោងជាងឃុំវត្តគរ តាំងនៅពីរគីឡូខាងលើឃុំវត្តគរ ។ ថ្ងៃ១៨មិថុនា១៩៧៨ គណៈឃុំដាក់ទិសឲ្យទៅចូលរើដែក កាត់សំបករថយន្តតូចៗយកមកធ្វើជាប៉ែលចាក់ដីចែកចាយឲ្យពួកកងចល័តនិងសេនាជនឃុំវត្តគរ ។ ស្រាប់តែមានរថក្រោះ ំ-១១៣ ជាងម្ភៃគ្រឿងនិងពួកយោធាខ្ទង់៥,០០០នាក់ ចូលមកក្នុងអតីតក្រុងបាត់ដំបងដោយគ្មានឲ្យដំណឹងជាមុន ចាប់ចងពួកគណៈពាណិជ្ជ, គណៈស្រុកនានា ហើយទៅចាប់មូល-សម្បត្តិនៅផ្ទះគាត់ក្បែរចំការជប៉ុន ជិតភ្នំតូចភ្នំធំ ។ កាលនោះពួកយោធាបានដេញពួកជាងខ្ញុំឲ្យវិលមកឃុំវិញ ។ ហេតុការណ៍នេះបានធ្វើឲ្យខ្ញុំមានសេចក្តីងឿងឆ្ងល់ណាស់ ដោយវាចាប់សម្លាប់តែគ្នាវា គឺម្តាក់ៗយល់ថា ជាពៀរវេរារបស់ពួកវា ឈាមស្រែកស្បែកហៅ ព្រោះពួកពាយ័ព្យទិសនេះក៏សម្លាប់ប្រជាជនខ្មែរអស់ច្រើនសំបើមណាស់ដែរ ។ ដោយការពិចារណាតាមហេតុការណ៍ ក្រោយមកទើបខ្ញុំដឹងថា មកពីដន្លងរបស់មូល-សម្បត្តិ ឈ្មោះសោ-ភឹមបានក្បត់ប្រុងធ្វើរដ្ឋប្រហារក្នុងរវាងខែវិច្ឆិកាឆ្នាំ១៩៧៧ តែប៉ុល-ពតវាដឹងខ្លួនមុន ឯសោ-ភិមគណៈភូមិភាគបូព៌ាទិស ក៏ត្រូវយោធាស្មោះនឹងប៉ុល-ពតសម្លាប់បានទៅ ។ ឯកូនប្រុសមូល-សម្បត្តិមួយឈ្មោះមិត្តឆ្នាំង (ឈ្មោះបដិវត្តន៍)បានរៀបការជាមួយកូនស្រីសោ-ភិម ។ មូល-សម្បត្តិនិងសោ-ភិមជាក្លើនឹងគ្នាផង តាំងពីសម័យខ្មែរវៀតមិញមក ។ ពេលនោះគេយកពួកយុវកកពីភូមិភាគនិរតីតាកែវ-កំពត មកជំនួសគណៈផ្សេងៗនៅពាយ័ព្យទិស ។ គណៈស្រុកឆេង ដែលទើបបានមកកាន់ក្តាប់ស្រុកបាត់ដំបង ជំនួសគណៈស្រុកហឿន ( ត្រូវចាប់សម្លាប់ចោលជាមួយមូល-សម្បត្តិ ) នោះ បានចូលទៅគួរសមយាយពាញ ( ម្តាយនួន-ជា ) ។ យាយពាញបានសួរគណៈស្រុកឆេងថា ៖ កូនអើយ, យ៉ាងណាបានជាកូនឯងបានមកជួបពាក់ព័ន្ធជាមួយនឹងអង្គការ ? ។ គណៈស្រុកឆេងបានឆ្លើយតបវិញថា ៖ អូ! ម៉ាអើយ ខ្ញុំក៏ក៏ជាអតិតកូនចៅក្នុងចលនាយុវកករបស់អ៊ុំជាដែរតើ ។ កាលនោះខ្ញុំនៅរៀនសាលាចំរើនវិជ្ជា ។ ម៉ាអើយ ពួកគិញប៉ូលីសរបស់សីហនុនិងអាឆ្កែលន់-នល់ គ្មានដឹងខ្យល់អីសោះតែម្តង ពួកខ្ញុំធ្វើវិច្ឆេទកម្ម វិទ្ធង្សនាក្រឡុកបង្កចលនា ពួកនេះគ្មានដឹងអីសោះ ហើយបើចាប់បានពួកខ្ញុំខ្លះ យកលុយទៅសូក វាលែងឲ្យរួចខ្លួនមកវិញអស់ ពួកវាមើលឃើញលុយជាធំលើសអ្វីៗទាំងអស់ ។

ក្នុងឆ្នាំ១៩៦០ មានពួកបញ្ញវ័ន្តក្រហមខ្លះវិលត្រឡប់មកពីស្រុកបារាំង ដូចជា ៖ ចៅ-សេង, ខៀវ-សំផន, ហ៊ូ-យន់, ភោគ-ឆាយ, គាត-ឆុន, ហ៊ូ-នឹម ។ ឆ្នាំនោះពួកកុម្មុយនិស្តខ្មែរបានបង្កើតបក្សម៉ាសសីស្ត-ឡេនីននៅក្នុងក្រុងភ្នំពេញ ។

ក្នុងឆ្នាំ១៩៦០ មានពួកបញ្ញវ័ន្តក្រហមខ្លះវិលត្រឡប់មកពីស្រុកបារាំង ដូចជា ៖ ចៅ-សេង, ខៀវ-សំផន, ហ៊ូ-យន់, ភោគ-ឆាយ, គាត-ឆុន, ហ៊ូ-នឹម ។ ឆ្នាំនោះពួកកុម្មុយនិស្តខ្មែរបានបង្កើតបក្សម៉ាសសីស្ត-ឡេនីននៅក្នុងក្រុងភ្នំពេញ ។ តាំងពីឆ្នាំនោះមក ចលនាយុវកកបានលូតលាស់ជាខ្លាំង ។ ពួកនេះជាមេក្រមីជ្រៀតចូលមកទិសអង្គការ ចូលទៅបន្លំខ្លួននៅក្នុងគ្រប់សកម្មភាពនានា ដែលមានប្រយោជន៍ដល់បក្សគេ ដូចជាបាតុកម្មវាយស្ថានទូតអាមេរិកាំងក្នុងឆ្នាំ១៩៦៣ (១២), បាតុកម្មសិស្សក្នុងឆ្នាំ១៩៧២-៧៣ រហូតធ្វើឃាតលោកថាច់-ជា និងវេជ្ជបណ្ឌិតកែវ-សាំងគីម ក្នុងបរិវេណវិទ្យាល័យ១៨មិនា ( អតិតវិទ្យាល័យព្រះយុគន្ធរ ), បាតុកម្មបុគ្គលិកសិក្សាក្នុងឆ្នាំ១៩៧៣-៧៤ ដើម្បីបំបែរទិសបាតុកម្ម ឲ្យក្លាយជាឈ្នាន់បំរើផលប្រយោជន៍របស់បក្សកុម្មុយនិស្តខ្មែរទៅវិញ ។

ពួកយុវកកចេះតែទាក់ទងបន្តតាមខ្សែរយៈគេ ដើម្បីប្រមូលសមាជិកឲ្យបានកាន់តែច្រើនថែមទៀត ។ គេជ្រៀតចូលទៅក្នុងចំណោមពួកនិស្សិត ដូចជាករណីជុំ-រំភើយ (១៣) ក្នុងគណកម្មការសមាគមនិស្សិតនៅមហាវិទ្យាល័យអក្សរសាស្ត្រភ្នំពេញជាដើម ។

ពពួកយុវកកខ្លះទៀតដែលបានក្លាយទៅជាគ្រូបង្រៀន សាស្ត្រាចារ្យ ក៏បានសាបព្រួសមនោគមវិជ្ជាកុម្មុយនិស្តក្នុងចំណោមមិត្តភក្តិគ្រូបឋមសិក្សាឬសាស្ត្រាចារ្យ ។ ក្នុងចំណោមសាស្ត្រាចារ្យ មានលោកគ្រូធុច-រិន ( សាស្ត្រាចារ្យម.ស.ប.ភ. ), លោកឃី-យ៉ុន (១៤) ( បរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ )...។ ក្រោយមកថ្ងៃទី១៧មិនា១៩៧៣ ក្រោយដែលពួកកូនចៅលោកលន់-ណុន បានគប់គ្រាប់បែកបំបែកហ្វូងបាតុកម្មគ្រូ ដែលកំពុងតែធ្វើមីទីង មានគ្នាជាង៤០០នាក់ ក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យខាងត្បូង មានស្លាប់គ្រូពីរនាក់និងរបួសជាច្រើននាក់មក ពួកសាស្ត្រាចារ្យគ្រូបង្រៀនមួយចំនួនទៀតយល់ឃើញថា បើទ្រាំនៅតទៅទៀត នឹងត្រូវពួកលន់-ណុនសម្លាប់ចោល ហើយថែមពីលើនេះទៅទៀត របបសាធារណរដ្ឋលោកលន់-នល់ពុករលួយអយុត្តិធម៌ណាស់ មិនទាំងគោរពលក្ខ័ណ ដែលចារលើស្តូបសាធារណរដ្ឋ នៅមុខអតិតបរមរាជវាំងសោះ ហើយតទៅមុខគ្មានសង្ឃឹមឈ្នះពួករណៈសិរ្សរំដោះជាតិឡើយ ទើបពួកនោះក៏រត់ចូលខ្មែរក្រហមបណ្តោយដូចជាធួន-ឃឿន

*(១២) កាលនោះសម្តេចបញ្ជាទាហានប្លងស្លៀកពាក់ស៊ីវិល ចូលទៅក្នុងវិទ្យាល័យនានា នាំសិស្សចេញទៅវាយស្ថានទូតអាមេរិកាំង មានលោកឃឹម-ទិតជាអ្នកដឹកនាំធ្វើ តាមសំដីលោកប៉ោ-ថន និងលោកស៊ិម-គិន ។*

*(១៣) ជុំ-រំភើយ ជាអតិតសិស្សខ្ញុំក្នុងឆ្នាំ១៩៦៨-៦៩ កាលជាប់មធ្យមសិក្សាប័ត្រភាគទី២ក្នុងឆ្នាំ១៩៧២ បានទៅបន្តវិជ្ជានៅមហាវិទ្យាល័យអក្សរសាស្ត្រ ផ្នែកប្រវត្តិវិទ្យា-ភូមិវិទ្យា មាជុំ-រំភើយម្នាក់ឈ្មោះមិត្តហឿន ជាអតីតខ្មែរក្រហមនៅសំឡូត ។ សម័យប៉ុល-ពតមិត្តហឿនធ្វើជាគណៈស្រុកភ្នំសំពៅ ខេត្តបាត់ដំបង ។*

*(១៤) លោកឃី-យ៉ុន ត្រូវជាបងថ្លៃលោកឯក-សំអុល អគ្គលេខាធិការមហាវិទ្យាល័យអក្សរសាស្ត្រ ។*



លោកថាច់-ជា



លោកកែវ-សង់គីម

(អ្នកនិពន្ធ «ដំណើរឆ្ពោះមកទិសខាងលិច ឬឥណ្ឌូចិនក្នុងឆ្នាំ២,០០០»), លោកកុល-យឿត (បរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ), លោកសោម-សំអ៊ុន (បរិញ្ញាប័ត្រប្រវត្តិវិទ្យា) បីនាក់ក្រោយនេះចេញពីបាត់ដំបងនៅដើមខែមិនា១៩៧៥ ។

ក្នុងចំណោមពួកបច្ចេកទេសវិស្វករ ក៏មាននិន្នាការក្រហមដែរដូចជា លោកគាត-ឆុន, លោកជី-គីមអាន (១៥), លោកវេជ្ជបណ្ឌិតធ្មេញឌី-ផុន (១៦), លោកងួន-អេង (វិស្វករ), លោកម៉ែន-នីថូ (វិស្វករអគ្គីសនី), លោកសៀង-ប៉ោសែ (វិស្វករនិងនាយកក្រសួងសុរិយោដី), លោកចន្ទ-បុប្ផ (ចៅក្រម) ។ល។...

មេដឹកនាំចលនាយុវកកគឺ ឡៅ-បេងគន (នួន-ជា) ។ ជននេះរស់នៅបង្កប់ខ្លួនក្នុងក្រុងភ្នំពេញរហូតមកដល់ឆ្នាំ១៩៧២-៧៣ ទើបចេញទៅព្រៃ តែនៅតែលបចូលមកម្តងៗទៀត ដើម្បីទាក់ទងពួកខ្មែរយុវៈក្នុងក្រុង ។ នៅក្នុងក្រុងភ្នំពេញ ក្រៅពីធ្វើជាគ្រូឯកជននៅវិទ្យាល័យចំរើនវិជ្ជានិងកម្ពុជបុត្រ ជននេះបន្លំខ្លួនធ្វើជាអ្នកចិញ្ចឹមមាន់-ទា លក់ឫស្សី ផ្តៅ ស្លឹកប្រក់ផ្ទះនៅម្តុំជិតវត្តស្ទឹងមានជ័យ ។

*(១៥) អ្នកស្រីជី-គីមអាន ជាសាស្ត្រាចារ្យ មសបភ ក្នុងឆ្នាំ១៩៧២ ។ អ្នកស្រីបានផ្លាស់ពីភ្នំពេញមកបង្រៀននៅវិទ្យាល័យនេត-យ៉ង់ បាត់ដំបងដែរ ។ ប្រហែលដោយខុសគោលបំណងដែលប៉ុងប្រាថ្នាពីមុនមក ទើបឮថាលោកជី-គីមអាន បានចងកធ្វើអត្តឃាតខ្លួនឯងក្នុងរវាងឆ្នាំ១៩៧៣ នៅតំបន់អូរអណ្តូងទៅ ? ។*

*(១៦) លោកវេជ្ជបណ្ឌិតឌី-ផុន បានរត់ចូលព្រៃក្នុងឆ្នាំ១៩៧២ ហើយក្រោយមកត្រូវបាត់ខ្លួនដោយអាថ៌កំបាំង ក្នុងរវាងឆ្នាំ១៩៧៣-៧៤ ។ អ្នកស្រីឌី-ផុន ជាសាស្ត្រាចារ្យរុក្ខជីវវិទ្យា ( Biologie végétale ) របស់ខ្ញុំកាលខ្ញុំនៅជានិស្សិតផ្នែក រ.វ.គ.ធ. ( SPCN ) នៅមហាវិទ្យាល័យវិទ្យាសាស្ត្រ ក្នុងឆ្នាំ១៩៦៦-៦៧ ។ ពេលចូលជំរំខៅ-អ៊ីដាង ក្នុងឆ្នាំ១៩៧៩ ថ្ងៃទី២១ ខែវិច្ឆិកា ខ្ញុំបានជួបអ្នកស្រីឌី-ផុន ហើយបានសាកសួរពត៌មានខ្លះៗពីស្វាមី អ្នកស្រីគ្រាន់តែប្រាប់ថា ស្វាមីគាត់ត្រូវស្លាប់ប៉ុណ្ណោះ ហើយមិនព្រមផ្តល់ពត៌មានរឿងនយោបាយសោះ (ខ្លាចក្រហមសម្លាប់) ។*

ឯប្រពន្ធធ្វើជាអ្នកលក់បង្អែមចំណីសៀម ។ យ៉ាងហោចក្នុងមួយខែ ជននេះតែងមកលេងផ្ទះប្អូនស្រីឈ្មោះភូ-ពូន ( ស្វាមីពាក់ស័ក្តិប្រាំឈ្មោះគីម-សាន ខាងផ្តល់សម្ភារៈសាំង ) នៅផ្សារអូឡាំពិក ហើយចាក់ស្រាហេណេស៊ីឬសំប៉ាញប្អូនថ្លៃផឹក ។ ជននេះលាក់កន្លែងរស់នៅយ៉ាងជិត (១៧) ។ បើដឹងថាបងប្អូនលួចតាមទៅមើលផ្ទះ ជននេះក៏ប្តូរទីលំនៅភ្លាម ។

បក្សកុម្មុយនិស្តខ្មែរបានរៀបផែនការគេយ៉ាងល្អិតល្អន់ណាស់ ក្នុងការដណ្តើមអំណាចបីស្តេចសីហនុ ។ គេបណ្តាក់គ្នាជ្រៀតចូលទៅនៅកៀកនឹងសីហនុ ក្នុងប្រព័ន្ធរដ្ឋាភិបាល (ខៀវ-សំផន, ហ៊ូ-យន់... ) តាមខ្សែរយៈសម្តេចវាំងប៉ែន-នុត ដែលជាអ្នកនាំឲ្យទៅជួបសីហនុ ។ ពួកខ្មែរក្រហមបានរៀបចំកំណត់គោលដៅគេដូចតទៅនេះ ៖

១- រៀបចំបង្កើតយុវជនស្ទួលបដិវត្តន៍នៅទីក្រុងភ្នំពេញ (បង្កើតវិទ្យាល័យឯកជនចំរើនវិជ្ជា និងកម្ពុជបុត្រ) និងនៅទីរួមខេត្តខ្លះ ដូចជាកំពង់ចាម (ស្រុកកំណើតហ៊ូយន់), តាកែវ, កំពត (មូលដ្ឋានយួនវៀតមិញ), បាត់ដំបង (ខ្មែរវៀតមិញនៅសំឡូត) គេជ្រើសយកតែសិស្សគ្រីក្រមកពង្វក់បំប៉នស្មារតី (ចលនាយុវកក = យុវជនកុម្មុយនិស្តកម្ពុជា) ។ ពួកនេះហើយដែលជាអ្នកបង្កអនាធិបតេយ្យ បាចខិតប័ណ្ណធ្វើឲ្យច-លាចលក្នុងទីក្រុង ដើម្បីបំបែរទិសបាតុកម្មឬកូដកម្មនានា ជាប្រយោជន៍បក្សកុម្មុយនិស្តខ្មែរទៅវិញ ។

២-បណ្តាក់គ្នាចូលទៅក្នុងរដ្ឋាភិបាល ដោយប្រើល្បិចចូលជិតខ្នាំងដើម្បីកំចាត់

*(១៧) តាមសំដីរបស់អ្នកស្រីគីម-សាន ជាប្អូនស្រីបង្កើតឡៅ-បេងគន ដែលខ្ញុំបានជួបក្នុងពេលដែលកងទ័ពយួន ចូលមកយកស្រុកខ្មែរនៅដើមឆ្នាំ១៩៧៩នោះថា គាត់មានសេចក្តីក្តៅក្រហាយ និងជេរប្រទេចបណ្តាសារបងប្រុសនេះសព្វបែបយ៉ាង ព្រោះយកស្វាមីគាត់ទៅសម្លាប់ កាលដែលខ្មែរក្រហមចូលដល់ភ្នំពេញភ្លាម ។ សូមជំរាបថា អ្នកស្រីភូ-ពូនបានជាយកត្រកូលខុសពីឡៅ-បេងគននោះ ព្រោះអ៊ុំភូ-យឿង (អ៊ុំក្មេករបស់ស្មេរ) បានសុំពីយាយពាញមកធ្វើជាកូន ឯភរិយារបស់អ៊ុំភូ-យឿង ត្រូវជាប្អូនស្រីបង្កើតរបស់យាយពាញ ។ ពេលយោធាខ្មែរក្រហមដេញប្រជាជនឲ្យចេញពីទីក្រុងនោះ គ្រួសារគាត់នៅក្រោយគេបង្អស់ ព្រោះសំអាងថា បងប្រុសគាត់មកដល់ហើយ។ ប្អូនស្រីនួន-ជាម្នាក់ទៀតឈ្មោះឡៅ-គីមនី ជាភរិយាលោកកោះ-ពាញ (ប្អូនប្រុសលោកកោះ-ឈួន) ក៏បានមកជួបជុំគ្នានៅផ្ទះអ្នកស្រីភូ-ពូនដែរ ។ នួន-ជាបានប្រើយោធាឲ្យមកនាំយកលោកគីម-សានទៅជួប ។ ដោយមិនស្គាល់ណាមួយជាលោកគីម-សាននោះ យោធាក៏នាំប្រុសៗទាំងអស់ប្រាំនាក់ទៅឲ្យនួន-ជា ដែលនៅចំណោមនោះមាន លោកកោះ-ពាញ, គីម-សាន, ប៊ុនរិត-ខាំឡុន (បងថ្លៃប្រុសរបស់ស្មេរនៅលីវ) និងក្មួយពីរនាក់ទៀត ។ នួន-ជាកាត់ទុកតែលោកគិម-សាន រួចដោះលែងអ្នកប្អូននាក់ឲ្យវិលត្រឡប់មកវិញ ។ នួន-ជាក៏សម្លាប់ប្អូនថ្លៃស័ក្តិប្រាំខាងដឹកជញ្ជូនសម្ភារៈនេះទៅ ដើម្បីសំដែងសេចក្តីស្មោះត្រង់ជាមួយប៉ុល-ពត ។ អ្នកស្រីគីម-សានចាំប្តីមិនឃើញវិលត្រឡប់មកវិញសោះ ។ លុះព្រឹកឡើងឃើញតែយោធាមកបណ្តេញទាំងអស់គ្នាឲ្យចេញពីផ្ទះ ។ លោកកោះ-ពាញមកស្លាប់នៅខេត្តពោធិសាត់ដោយគ្មានថ្នាំព្យាបាល ។ សព្វថ្ងៃអ្នកស្រីភូ-ពូនរស់នៅផ្សារលើ ជិតភូមិវត្តគរ បាត់ដំបង ។ កូនប្រុសម្នាក់ជាចល័ត ដោយពួកវាប្រើគ្មានពេលសំរាក ក៏ឈឺរត់មករកម្តាយដួលដាច់ខ្យល់ស្លាប់នៅនឹងកាំជណ្តើរខ្ទម ។ ឯកូនម្នាក់ទៀត ពួកវាចោទថាខ្ជិល ហើយចាប់យកទៅវាយធ្វើទារុណកម្ម រួចដុតសម្លាប់ចោលទាំងរស់ ។ ឯអ្នកស្រីកោះ-ពាញ (សល់តែកូនស្រីម្នាក់) សព្វថ្ងៃបានមករស់នៅរដ្ឋកាលីហ្វ័រនិញ៉ា សហរដ្ឋអាមេរិក ។*

ពួកស្តាំនិយមមុន រួចរំលំសម្តេចជាក្រោយ ។ គេចូលកៀកសម្តេច បញ្ចុះបញ្ចូលបញ្ឆោតសម្តេចឲ្យងាកទៅរកពិភពកុម្មុយនិស្ត រហូតទ្រង់បានទាក់ទងជាមួយចិនជាដំបូងក្នុងឆ្នាំ១៩៥៦ ។ ពន្យល់សម្តេចឲ្យធ្វើជាតួបនិយកម្មសហគ្រាសនានា, រោងចក្រ, បង្កើតសហករណ៍តាមបែបកុម្មុយនិស្ត... ដោយបញ្ចូលខៀវ-សំផនជារដ្ឋមន្ត្រីពាណិជ្ជកម្ម, គាត-ឈុនជារដ្ឋមន្ត្រីឧស្សាហកម្ម, ចៅ-សេងជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ។

ដំណាក់ការមួយទៀត ពួកគេជ្រៀតចូលទៅដណ្តើមកៅអីក្នុងមន្ទីររដ្ឋសភាធ្វើជាតំណាងរាស្ត្រ ដើម្បីបានជិតដិតនិងទាក់ទងជាមួយប្រជាជន ក្នុងផែនការរៀបចំនិងពង្រីកមូលដ្ឋានបដិវត្តន៍នៅតាមជនបទស្រែចំការ ដែលរបបដឹកនាំមិនសូវអើពើនោះ ។

៣- ប៉ែងកំចាត់ពួកស្តាំនិយម មានក្រុមលោកស៊ឹម-វ៉ារ, យ៉ែម-សំបូរ, សឺន-សាន, លន់-នល់, យី-តាំងលីម ឲ្យខ្វាតឆ្ងាយពីសម្តេចសីហនុ ពីរដ្ឋាភិបាល ពីរដ្ឋសភា ហើយនិងធ្វើយ៉ាងណាឲ្យសីហនុស្អប់ពួកទាំងនេះទៀតផង ។

ផែនការរបស់គេមានដំណាក់ការច្បាស់លាស់ណាស់ ក្នុងការប្រឆាំងនឹងសីហនុ ។ លុះដល់ប្រព័ន្ធបដិវត្តន៍ផ្ទៃក្នុងគេរឹងមាំគួរជាទីទុកចិត្តបានហើយ មេដឹកនាំខ្មែរក្រហមក៏បណ្តោះគ្នាភៀសខ្លួនចេញទៅព្រៃ នៅទីជនបទរួមរស់ជាមួយប្រជាជនដើម្បីរាវរកចំណុចខ្សោយប្រជាជន ងាយស្រួលនឹងទាក់ទាញដឹកនាំ ។ កាលបើប្រជាជនចូលចិត្តពួកគេហើយ គេក៏ចាប់ផ្តើមឆាកបណ្តុះកំហឹងបដិវត្តន៍វណ្ណៈអធនឲ្យស្អប់វណ្ណៈអ្នកដឹកនាំ វណ្ណៈស័ក្តិភូមិ អ្នកមាន អ្នកក្រុង អ្នកចេះដឹង...។ គេលើកយកឧទាហរណ៍ជាក់ស្តែងមកលាតត្រដាង ពន្យល់ប្រជាជន ចង្អុលបង្ហាញពីរបៀបកេងប្រវ័ញ្ច ជិះជាន់ បំបិទសិទ្ធិ និងអយុត្តិធម៌ពុករលួយរបស់ពួកវណ្ណៈសក្តិភូមិកាន់អំណាច ។ គេពន្យល់ប្រជាជន ពីពួកប៉ូលីស គិញ គយ ប៉េអ៊ឹម ដែលគ្មានធ្វើការបំពើរក្សាសន្តិសុខឲ្យប្រជារាស្ត្រទាល់តែសោះ គឺច្រាក់គ្នាចាំតែច្របាច់ក ជិះជាន់ ចាប់ចងរាស្ត្រខ្មែរ ជំរិតយកលុយកាក់ជាដើម ។ ដោយឃើញឧទាហរណ៍ជាក់ស្តែង ប្រជាជនជាពិសេសពួកយុវជនក៏ជឿទុកចិត្ត ចូលបំពើជាយោធាតាមការភូតភររបស់អង្គការថា ទៅរំដោះខ្មែរឲ្យរួចពីចក្រពត្តិអាមេរិកាំង ពីវណ្ណៈសក្តិភូមិជិះជាន់ជញ្ជក់ឈាមរាស្ត្រនោះ ។

កាលបើកំហឹងវណ្ណៈពុះកញ្ជ្រោលក្នុងស្រទាប់ប្រជាជនហើយ ពួកគេចាប់ពន្យល់ពីមធ្យោបាយយ៉ាងណា ដើម្បីរំដោះរំបំរះខ្លួនចេញពីការជិះជាន់នោះៗដោយលើកយកការតស៊ូវណ្ណៈឲ្យឈ្មោះថា ៖ កងទ័ពប្រដាប់អាវុធប្រជាជនវណ្ណៈអធន ជាមធ្យោបាយ ពោលគឺគេត្រូវតែប្រយុទ្ធសម្លាប់ខ្មាំងជាដាច់ខាត ទើបរំដោះខ្លួនបាន ។ ត្រង់នេះហើយដែលពួកក្រហមឲ្យឈ្មោះថា (កម្ពុជាប្រជាធិបតេយ្យ) នោះ ។ ក្នុងការពន្យល់បំផុសកំហឹងវណ្ណៈនោះ ពួកគេបានបំភ្លៃប្រវត្តិសាស្ត្រឲ្យស្របទៅនឹងទិសដៅស្មារតីតស៊ូបដិវត្តន៍បក្សកុម្មុយនិស្តខ្មែរ ដូចជាការបំភ្លៃប្រវត្តិតស៊ូបះបោរក្នុងរាជ្យនរោត្តម មានអាចារ្យស្វា ពោរកំបោរ ( យួនគាំទ្រឲ្យបង្កចលនាក្នុងស្រុក កុំឲ្យខ្មែរមានឱកាសទៅវាយដណ្តើមយកកម្ពុជាក្រោមមកវិញ ), ការសម្លាប់លោកបាដេ នៅភូមិក្រាំងលាវ (បារាំងជិះជាន់ទារពន្ធធ្ងន់ពេក), អាចារ្យហែម-ចៀវ (ពន្យល់ខ្មែរឲ្យភ្ញា

ក់រព្យករហ្វូតបារាំងចាប់ផ្សឹកដាក់គុក សុគតនៅកោះត្រឡាច)... ថាបានត្រួសត្រាយបដិវត្តន៍មុនគេ ។

ដល់ពេលនេះ ប្រជាជនក្លាយមកជាឧបករណ៍របស់បដិវត្តន៍គេហើយ ស្រេចតែនឹងគេលៃឆ្នៃប្រើតាមសេចក្ដីត្រូវការ ដោយយកវិន័យរឹងដូចដែក ធរណាក្បត់ទិសដៅអង្គការត្រូវកាត់ទោសខ្លួនឯង... បេះដូងថ្ម គ្មានមនោសញ្ចេតនា គ្មានមេត្តាអនុគ្រោះសោះឡើយ ។ ឯកងឈ្លបនិងយោធា គេបង្រៀនតែពីវិធីសម្លាប់ខ្មាំងប៉ុណ្ណោះ ។

ក្នុងឆ្នាំ១៩៦២ សាឡុត-សរបានភៀសខ្លួនពីក្រុងភ្នំពេញចូលព្រៃ រៀបចំត្រៀមលក្ខណៈប្រឆាំងនឹងសម្ដេចសីហនុ ។ គ្នាគាត់ជាច្រើនទៀតបានរត់ចេញជាបន្តបន្ទាប់ដែរដូចជាខៀវ-ប៉ែន (សាស្ត្រាចារ្យ មសបក) (១៨) រត់ចូលព្រៃក្នុងឆ្នាំ១៩៦៣ ។ ក្រោយមកទៀតមានទីវ-អុល (សាស្ត្រាចារ្យទុតិយភូមិផ្នែកអក្សរសាស្ត្រខ្មែរ), ធុច-រិន (សាស្ត្រាចារ្យ មសបក)... ក៏នាំគ្នាភៀសខ្លួនចេញបន្តបន្ទាប់គ្នាដើម្បីរៀបចំកម្លាំងបដិវត្តន៍វាយយកអំណាចពីសម្ដេចសីហនុនៅឯទីជនបទ ។

ក្នុងឆ្នាំ១៩៦៧ ខៀវ-សំផន, ហ៊ូ-យន់ក៏ភៀសខ្លួនចេញពីក្រុងភ្នំពេញ ចូលទៅពួនសម្ងំក្នុងស្ថានទូតចិនខ្ទង់បីខែ ទើបចិនបណ្ដោះចេញទៅព្រៃទៀត ដោយខ្លាចពួកគិញសម្ដេចសម្លាប់ចោល ព្រោះជាប់ចោទថា បានចំបះរាស្ត្រនៅសំឡូត ក្រញូងបាត់ដំបង ។

*　　　　*

*

*(១៨) ឈ្មោះបដិវត្តន៍ហៅថា មិត្តស៊ូ បាននាំកងទ័ពចូលក្រុងបាត់ដំបងមុនគេនៅល្ងាចថ្ងៃទី១៧មេសា ១៩៧៥ បានធ្វើជាគណៈតំបន់៤ (គឺផ្នែកខាងក្រោមក្រុងបាត់ដំបង ទៅដូនទាវ ចែកគ្នាជាមួយតំបន់៣ ដោយយកផ្លូវរទេះភ្លើងជាគោល) មួយរយៈ ។ ប្រាំមួយខែក្រោយមក មូល-សម្បត្តិចាត់ឲ្យយោធាទៅចាប់ស្វាតៗ យកទៅសម្លាប់ចោល ហើយកុហកប្រជាជនថា អង្គការបានបញ្ជូនឲ្យទៅធ្វើទូតនៅស្រុកថៃ ។*

# ការបះបោរនៅតំបន់សំឡូត

ការបះបោរនៅតំបន់សំឡូត ក្រញូងនេះហើយ ដែលជាដើមភ្លើងនៃសង្គ្រាមស៊ីវិលក្នុងស្រុកខ្មែរ ឬសង្គ្រាមបដិវត្តន៍ពួកខ្មែរក្រហម ។ អំពើពុករលួយនិងអំពើអយុត្តិធម៌ជិះជាន់របស់ពួកអាជ្ញាធរខេត្តបាត់ដំបងសម័យលោកយ៉ែម-មុនីវ័ត្តបានធ្វើឲ្យប្រជារាស្ត្រស្រុកសំឡូត មានសេចក្តីក្តៅក្រហាយយ៉ាងខ្លាំង ។ មូលហេតុនេះក្លាយជាឱកាសយ៉ាងល្អកំររកបានមួយ ដែលពួកខ្មែរក្រហមរង់ចាំអស់ពេលជាយូរមកហើយ ។

ពួកស្តូលខ្មែរក្រហមនៅក្រុងភ្នំពេញ បានបញ្ជូនគ្នាគេមកបំបះរាស្ត្រឲ្យក្រោកឡើងតស៊ូប្រឆាំងនឹងអាជ្ញាធរខេត្តបាត់ដំបង ។ ហើយការបះបោរនៅតំបន់សំឡូតនេះបានរាលដាលចូលទៅក្នុងខេត្តនានាទៀត ដូចជាខេត្តកោះកុង, កំពត(ឈូក) កំពង់ស្ពឺ, តាកែវ, កំពង់ឆ្នាំង(កំពង់ត្រឡាច), កំពង់ចាម, កំពង់ធំ... ដែលមានមូលដ្ឋានខ្មែរក្រហម ឬមានជំណាងរាស្ត្រនិន្នាការក្រហម ។

ក្នុងឆ្នាំ១៩៦៧ ប្រជាជនស្រុកសំឡូតបាននាំគ្នាទាំងភូមិៗរត់ចូលព្រៃ ហើយត្រូវពួកអាជ្ញាធរខេត្តបាត់ដំបងលាបពណ៌គ្នាថា «ខ្មែរក្រហម» ។ ក្នុងសៀវភៅ «កសិករនិងនយោបាយនៅកម្ពុជា, ១៩៤២-៨០» ( **Peasants and Politics in Kampuchea, 1942-80** ), លោកបែន-គៀកណាន់ ( **Ben Kiernan** ) បានសរសេរពីការបះបោរនោះថា បានកើតឡើងចំពេលដែលកងទ័ពយួនយៀកកុងនៅវៀតណាមកំពុងតែជាប់ដៃតទល់ជាមួយនឹងកងទ័ពអាមេរិកាំងកន្លះលាននាក់ ។ នៅក្នុងខែមិថុនា១៩៦៧ ប្រជារាស្ត្រជាងបួនពាន់នាក់ បានរត់ចូលព្រៃអស់ជាងមួយខែ ។ ក្រោយមកបានព្រះគ្រូព្រះវន្តរតន៍ អ៊ីវ-ទួត មេគណខេត្តបាត់ដំបងនិមន្តទៅសំរុះសំរួលបញ្ចុះបញ្ចូលខ្មែរបះបោរទាំងនោះ ដែលមានទាំងព្រះសង្ឃផង ឲ្យចូលមករស់នៅក្នុងភូមិម្តងវិញ

ដោយចង់ទូលការពិត អ្នកស្រុកសំឡូតបានជ្រើសរើសតំណាងពីរនាក់ ហើយចាត់ឲ្យធ្វើដំណើរនាំដំណឹងទៅទូលសម្តេចនៅឯក្រុងភ្នំពេញ តែត្រូវបក្សពួកលោកលន់-នល់ចាប់សម្លាប់ចោលបាត់ទៅ ។ តាមពិតលោកលន់-នល់មិនបានដឹងសោះទេ គឺជាបក្សពួកលោកអភិបាលខេត្តបាត់ដំបងយ៉ែម-មុនីវ័ត្ត និងនាយទុនទេ ដែលឃុបឃិតគ្នាធ្វើការបំបិទមាត់តំណាងអ្នកស្រុកសំឡូតទាំងពីរនាក់នោះ ព្រោះខ្លាចសម្តេចជ្រាបពីរឿងដែលពួកគេប្លន់កម្មសិទ្ធិ ប្លន់ប្រវ័ញ្ចយកដីចំការប្រជារាស្ត្រស្រុកសំឡូត ។

ក្នុងឆ្នាំ១៩៦៨ ស្មេរខ្ញុំចេញពីមហាវិទ្យាល័យគរុកោសល្យ ជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ មកបង្រៀននៅវិទ្យាល័យអ៊ាបឃុត-នេតយ៉ង់ បាត់ដំបងក្រុង មានលោកឃិន-ផូ ជាចាងហ្វាង ។ កាលនោះអាជ្ញាធរខេត្តបានកេណ្ឌកងប៉ូលីសខេត្តកងស្វ័យត្រាណតាមភូមិនានា គ្រូបង្រៀនបឋមសិក្សា ឲ្យទៅធ្វើការបង្ក្រាបអ្នកស្រុកសំឡូត និងធ្វើការឃោសនាបញ្ចុះបញ្ចូលឲ្យអ្នកស្រុកមករស់នៅក្នុងភូមិដូចធម្មតាវិញ ។ គេឲ្យឈ្មោះសកម្មភាពនោះថា ប្រតិបត្តិការសន្តិភាព ។ តាមលោកបែន-គៀកណាន់ ដែលបានសម្ភាសន៍ជាមួយអធិការធុយ-ប៊ុនសួរ នៅទីក្រុងប៉ារីសឆ្នាំ

១៩៨០ ថាពួកលោកគ្រូបឋមសិក្សាបានចូលរួមដោយស្ម័គ្រចិត្ត តែបើតាមខ្ញុំដឹងវិញនោះ គឺស្ម័គ្រចិត្តដោយបង្ខំ ( volontaire obligatoire ) ទេវិញទេ ព្រោះអស់លោកគ្រូបឋមសិក្សាខ្លាចអំណាចលោកអធិការបឋមសិក្សាណាស់ ។ ឯលោកអធិការស្តាប់បង្គាប់និងផ្តាប់ចៅហ្វាយខេត្ត ។ ឯលោកគ្រូមធ្យមសិក្សាមិនបានចូលរួមក្នុងប្រតិបត្តិការសន្តិភាពយកល្អមើលនោះទេ ។

លោកមាស-ម៉ុន ដែលសព្វថ្ងៃរស់នៅក្រុងតាខូម៉ា រដ្ឋវ៉ាស៊ិនតោន ជាអតិតកងស្វ័យត្រាណឃុំបាយដំរាំ ស្រុកបាណន់ បានជាប់កំណែនទៅបង្ក្រាបរាស្ត្រនៅតំបន់សំឡូតដែរក្នុងឆ្នាំ១៩៦៨ ។ លោកមាស-ម៉ុនបានសារភាពថា កងស្វ័យត្រាណ ប៉ូលីស បានចាប់មាន់ទាជ្រូក គាស់យកចានឆ្នាំង ទ្រព្យសម្បត្តិដែលអ្នកស្រុកជីកដីកប់លាក់ទុក ក្នុងវេលាដែលរត់លួន តាមការបញ្ចេះរបស់ពួកខ្មែរក្រហមនោះ ។

តើបុព្វហេតុពិតនោះយ៉ាងណា ទើបបណ្តាលឲ្យមានការបះបោរនៅសំឡូត ?

សូមមេត្តាជ្រាបថា ចាប់តាំងពីឆ្នាំ១៩៦០មក អ្នកស្រុកនៅខេត្តបាត់ដំបងបាននាំគ្នាពង្រីកដីចំការសំរាប់ដំណាំ ក្រូច ស្វាយ ម្នាស់... ច្រើនឡើងៗ ហើយនាំគ្នាចាប់ដីថ្មីៗមានជីវជាតិនៅអណ្តើកហែប, ថ្ងៃ(ម្នាស់ កៅស៊ូ), កំពង់គល់ រហូតដល់សំឡូត ។ ការនេះក៏វាលដាលដល់ពួកអស់លោកផ្នែករដ្ឋបាលខែត្រ នាយកក្រសួងសុរិយោដីនាយទុនខ្មែរ ចិន មានលោកហូ-តុងហាន់, ហូ-តុងហាប់ជាដើម ។ តាំងពីយូរយារមកហើយ អ្នកស្រុកនៅសំឡូតមានដីចំការកេរ្តិ៍ពីដូនតាម៉ែឪគេមក ដើមស្វាយគល់ប៉ិនកង់រទេះ ដើមធូរេនធំខ្ពស់លលៃ, ចំការចេក ម្នាស់ សាវម៉ាវ... តែដីចំការទាំងនោះមិនដែលមានប្លង់កម្មសិទ្ធិសំគាល់ទេ ព្រោះប្រជារាស្ត្ររស់នៅតំបន់ដាច់ស្រយាល គ្មានផ្លូវថ្នល់ (ខ្លះមិនដែលស្គាល់ផ្សារផង) នៅល្ងង់ខ្លៅពេកក្នុងរឿងកម្មសិទ្ធិប្លង់ដីនេះ ។

ដោយចង់បានដីតំបន់សំឡូត (ដីក្រហម) ដ៏មានជីវជាតិនោះ បុគ្គលិកសាលាខេត្ត សាលាស្រុកបាត់ដំបង ចៅក្រសួងនានា នាយទុនខ្មែរ ចិន ជាពិសេសនាយកក្រសួងសុរិយោដី ( ក្រសួងផែនទី ) បានឃុបឃិតគ្នាធ្វើប្លង់កម្មសិទ្ធិវាតប្លន់យកដីចំការអ្នកស្រុកសំឡូតទាំងបំពាននិងអយុត្តិធម៌ ។ ដោយសំអាងលើប្លង់កម្មសិទ្ធិត្រឹមត្រូវស្របច្បាប់ ពួកគេបានឲ្យត្រាក់ទ័រទៅឈូសរុញព្រលំដំណាំចាស់វាតធ្វើរបងធ្វើព្រំដីរបស់គេ ។ អ្នកស្រុកសំឡូតដល់ឃើញគេមកឈូសយកដីចំការខ្លួនទាំងបំពាន ក៏នាំគ្នាមកឃាត់ តែម្ចាស់កម្មសិទ្ធិថ្មីសំអាងលើប្លង់ដីត្រឹមត្រូវមិនព្រមស្តាប់ហើយរឹតតែបន្តការឈូសដីតទៅទៀត ។ ដោយឃាត់មិនស្តាប់ អ្នកស្រុកក៏នាំគ្នាបះកាប់សម្លាប់អ្នកបើកបរត្រាក់ទ័រស្លាប់ទៅ ។ អាជ្ញាធរខេត្តក៏បញ្ជូនកងប៉ូលីសទៅបង្ក្រាប មានបាញ់សម្លាប់និងចាប់មកដាក់គុកផង ។ ប្រុសៗក៏នាំគ្នារត់ចូលពួនព្រៃអស់ នៅសល់តែស្រីៗ ក្មេង និងចាស់នៅចាំផ្ទះសំបែងទ្រព្យសម្បត្តិ ។ ដោយការសំរុះសំរួល ប្រុសៗបាននាំគ្នាចូលមកនៅក្នុងភូមិស្រុកវិញ ។ បន្តិចមក ក្នុងពិធីបុណ្យចូលឆ្នាំរាំវង់មួយ (តាមសេចក្តីរាយការណ៍របស់លោកម៉ៃ-សៅរី គ្រូបឋមសិក្សាទក្ខិណាសាលា) ថាប៉ូលីសបានចាប់រំលោភកូនក្រមុំអ្នកស្រុកសំឡូត ។ ការបំពាននេះបានបង្កើតជាអធិករមួយថែមទៀត ។ កំណាន់នារីនោះបានកាប់ប៉ូលីសនឹងពូថៅស្លា

ប់ទៅ ។ ពួកកងប៉ូលីសក៏លើកគ្នាមកបាញ់សម្លាប់អ្នកស្រុកអស់ជាច្រើន ។ អ្នកស្រុកក៏បះបោរម្តងទៀត នាំគ្នាទាំងប្រុស ស្រី ក្មេង ចាស់ ទាំងភូមិៗនាំគ្នារត់ចូលព្រៃ ។ ឃើញឱកាសល្អហើយ ពួកខ្មែរក្រហមក៏ចូលមកបន្លំទាក់ទងពន្យល់អ្នកស្រុកសំឡូត ញុះញង់បន្ថែម បំផុសកំហឹងសងសឹកប្រឆាំងនឹងពួកអាជ្ញាធរខេត្តបាត់ដំបងប-ណ្តោយ ។ នេះហើយជារឿងពិតដែលគេខំនាំគ្នាលាក់រហូតដល់សព្វថ្ងៃ ។

នៅថ្ងៃទី៣០ មេសា ១៩៦៧ សម្តេចមានបន្ទូលថា ៖ មិនមែនមានតែពួកខ្មែរក្រហមទេដែលខឹងនោះ គឺប្រជាជនសាមញ្ញនៅខេត្តបាត់ដំបង ក៏មានចិត្តខេរខឹងនឹងអាជ្ញាធរខេត្តដែរ ។ លោកបែន-ឃៀកណាន់បានដកស្រង់ព្រះបន្ទូលរបស់សម្តេចតាមសម្លេងវិទ្យុប៊ីប៊ីស៊ី ត្រង់ទំព័រ១៧៧ថា ៖ ពួកអាជ្ញាធរខេត្តទាំងនោះ បានជួយគាំទ្រដល់ពួកមូលធនដែរ ដោយអនុញ្ញាតឲ្យពួកគេសង្កត់សង្កិនប្រជារាស្ត្រ ជាឧទាហរណ៍គេយល់ព្រមឲ្យពួកមូលធនទទួលផ្តាច់មុខ ឬមានសិទ្ធិពិសេសក្នុងការដឹកនាំត្រីនិងឥវ៉ាន់ផ្សេងៗទៀត )ទៅលក់)ក្នុងតំបន់អណ្តើកហែប និងប៉ៃលិន ។ ហើយមានអំពើអយុត្តិធម៌ធំៗដែរក្នុងការចែកដីធ្លី ។ ពួកអ្នកមានទាំងនោះបានក្រឡៃដីធ្លីគេទៅជាកម្មសិទ្ធិស្របច្បាប់ ដែលធ្វើឲ្យខូចប្រយោជន៍ដល់ជីវភាពនៃជនក្រីក្រ ដែលរស់នៅៗក្នុងតំបន់នោះៗ ។

នៅមោងឫស្សីក៏មានបញ្ហារវាងចៅតំបន់និងប្រជារាស្ត្រសាមញ្ញដែរ ធ្វើឲ្យប្រជាជនមានការឈឺចាប់នឹងអំពើអយុត្តិធម៌...។ តាមការពិត អានាធិបតេយ្យពេញទីនិងការរំជើបរំជួលបានកើតមានឡើងនៅក្នុងខេត្តបាត់ដំបង ។ ខ្ញុំសុំប្រាប់ថា ខ្ញុំនឹងផ្លាស់អាជ្ញាធរទទួលខុសត្រូវខេត្តបាត់ដំបងមួយរំពេជ ។

លោកយ៉ែម-មុនីរ័ត្ន ក៏ត្រូវផ្លាស់ចេញ ហើយលោកទឹម-ង្ងួនបានមកជំនួសប្រហែលប្រាំមួយខែ សម្តេចក៏ចាត់លោកអ៊ិន-តាំ មកធ្វើជាអភិបាលខេត្តបាត់ដំបងដើម្បីជួយដោះស្រាយរំងាប់អធិករនិងការបះបោរនៅសំឡូត ។

លោកភុន-គង់ អតីតស្មៀនសាលាស្រុកអូរជ្រៅ សព្វថ្ងៃរស់នៅក្រុងតាខូម៉ាបានឲ្យការណ៍ថា កាលនោះមានអ្នកបះបោរនៅសំឡូត បាននាំកាំភ្លើងមួយដើមមកចុះចូល ហើយបាននិយាយថា ពួកគេមិនមែនជាខ្មែរក្រហមទេ គេរត់ចូលព្រៃក៏ព្រោះតែក្តៅក្រហាយនឹងពួកអាជ្ញាធរខេត្តបាត់ដំបងឃុបឃិតជាមួយនាយទុន ទៅប្លន់យកដីកេរ្តិ៍របស់គេ និងការបង្ក្រាបយ៉ាងព្រៃផ្សៃបាញ់សម្លាប់ប្រជារាស្ត្រនៅសំ-ឡូត ។ ការបះបោរនេះហាក់ដូចជារង់ចាំតែឱកាសនឹងផ្ទុះកាលណាបើមានមេដឹកនាំណាមួយមកពន្យល់បន្ថែម ។

នេះហើយជាបុព្វហេតុពិតនៃការបះបោរនៅសំឡូត ហើយដែលពួកខ្មែរក្រហមមួយក្តាប់តូចឆ្លៀតឆក់យកឱកាសដ៏ល្អនេះ មកធ្វើជាឈ្នាន់បដិវត្តន៍បណ្តោយ ។ ពួកអតិតខ្មែរវៀតមិញមាន មូល-សម្បត្តិ, អាចារ្យប្រេស, ធុច-រិន... ព្រមទាំងសមាជិកចលនាយុវកក បានចូលជ្រៀតជ្រែកក្នុងរឿងនេះ ។ ពួកគេលូកដៃកកូរបំបះរាស្ត្រឲ្យក្រោកឡើងតស៊ូ ហើយពួកគេក៏បង្កើតកងទ័ពខ្មែរក្រហមជាដំបូងក្នុងឆ្នាំ១៩៦៨នៅបាយដំរាំ ស្រុកបាណន់ ដោយកោះហៅគ្នីគ្នាគេជាអតិតខ្មែរឥស្សរៈ, ខ្មែរវៀតមិញមិនបានបុណ្យស័ក្តិអ្វីបន្តិចសោះពីសម្តេច ក្រោយសន្និសិទហ្សឺណែវបញ្ចប់សង្គ្រាម

នៅឥណ្ឌូចិនក្នុងឆ្នាំ១៩៥៤មក ។ មូល-សម្បត្តិ (រស់-ញឹម ឬតាកៅ), អាចារ្យប្រេស, ប៊ុង-ភឿក, អាចារ្យឡាច-សារេន (១៩) បានចូលទៅព្រៃវិញ លើកលែងតែលោកស៊ីវ-ហេង, អាចារ្យឡាច-សាវ៉ន (២០), ប្រាក់-ខាន់មិនព្រមចូលទៅព្រៃវិញឡើយ ទោះបីមានសំបុត្រមកបង្ខំនិងគំរាមថា បើមិនទៅនឹងត្រូវស្លាប់ក៏ដោយ ។

សំឡូតក៏បានក្លាយទៅជាមូលដ្ឋានចំបងនៃចលនាបដិវត្តន៍តស៊ូពួកខ្មែរក្រហម មានទីតាំងនៅលើភ្នំវាយចាប មានរូងគុហារ ( Grottes ) អាចលាក់មនុស្សបានរាប់រយ និងសម្ភារៈសឹកជាច្រើនផង ( ភ្នំវាយចាបជាភ្នំថ្មកំបោរ Roches calcaires ) ។

សូមសួរថា តើនរណាជាអ្នកទទួលខុសត្រូវក្នុងរឿងបះបោរ និងការកកើតនៃខ្មែរក្រហមនៅសំឡូតនេះ ? តើហេតុអ្វីបានជាយ៉ែម-មុនីរតន៍ហ៊ានធ្វើអំពើពុករលួយនេះ ក្រែងគាត់ស្រង់ដើមព្រោះបានទិញប៉ុស្តិ៍ខ្លាញ់នេះពីអ្នកម្នាងជាច្រើនលានរៀលទេដឹង ? ។

*　　　　*

*

*(១៩) ឡាច-សារេន និងឡាច-សាវ៉នជាបងប្អូនបង្កើត ។ ឡាច-សារេនបានចេញទៅហាណូយនៅចុងឆ្នាំ១៩៥៥ ឯប្រពន្ធនិងកូនប្អូននាក់បានទៅតាមជាក្រោយក្នុងឆ្នាំ១៩៦០ ។ កូនប្រុសរៀនជាប់វេជ្ជបណ្ឌិតពីស្រុកចិន ។ ក្នុងឆ្នាំ១៩៧៦-៧៧ ប៉ុល-ពតបានចាប់ពួកខ្មែរក្រហមអតីតវៀតមិញ ឯកូនប្រុសស្រីឡាច-សារេនក៏ត្រូវគេសម្លាប់អស់ ។ គេជន្លៀសប្រពន្ធឡាច-សារេនឈ្មោះលឿត ឲ្យមកនៅបាត់ដំបងជាមុន នៅលើផ្ទះលោកលិម-ករ (បុគ្គលិកកសិកម្ម) ។ ដល់ដឹងថាប្តី កូនៗ ត្រូវគេសម្លាប់លោលអស់ហើយ ក្នុងពេលដែលប៉ុល-ពតឲ្យទ័ពមជ្ឈិមប័ក្សមកចាប់មូល-សម្បត្តិ នាថ្ងៃទី១៨ មិថុនា ១៩៧៨ នោះយាយលឿតនេះក៏ចងកសម្លាប់ខ្លួននៅនឹងភ្នាក់ដៃជណ្តើរផ្ទះលោកលិម-ករស្លាប់ទៅ ។*

*(២០) ឡាច-សាវ៉ននិងស៊ីវ-ហេង បានចុះចូលនឹងសាធារណរដ្ឋលោកលន់-នល់ ។ លោកស៊ីវ-ហេងបានប្រគល់ឯកសារនិងរូបថតជាច្រើននៃពួកខ្មែរក្រហម ខ្មែរវៀតមិញ ហើយបានពាក់ស័ក្តិជាវរសេនិយទោនៅបន្ទាយសឹករងស៊ីសុផុន ឯកូនអាចារ្យឡាច-សាវ៉នឈ្មោះឡាច-សុវត្ថិ បានពាក់ជាអនុសេនិយទោ ។ ល្ងាចថ្ងៃខ្មែរក្រ-ហមចូលក្រុងបាត់ដំបង ពួកគេចាប់ឡាច-សុវត្ថិបាញ់សំលាប់ចោលនៅនឹងជើងជណ្តើរផ្ទះនៅភូមិគរ ហើយហាមមិនឲ្យយកសពទៅដុតឬកប់ឡើយ ។ តាំងពីឆ្នាំ១៩៧៣មក លោកស៊ីវ-ហេងឈឺខ្វិនស្លាប់មួយចំហៀងខ្លួននៅនឹងផ្ទះភូមិគរ ( សូមអានផ្នែកសេចក្តីបន្ថែមនៅផ្នែកបញ្ចប់សៀវភៅ ) មួយខែក្រោយពីខ្មែរក្រហមឈ្មោះមិត្តភៀង ( គណឃុំជ្រៃ និងមេនគរបាលខេត្តបាត់ដំបង ) បានទៅយកលោកស៊ីវ-ហេង ទៅសម្លាប់នៅភ្នំក្រពើ រួចកាត់ក្បាលផ្ញើទៅឲ្យនួន-ជានៅឯភ្នំពេញ ។*

ពួកសមា ជិកចលនា « យុវកក » គឺជាចលនាស្នូលបដិវត្តន៍របស់សាឡុត-សរ ។ ក្រោយដែ លពួកខ្មែរក្រហមមានជ័យជំនះរំលំរបបសាធារណរដ្ឋលន់នល់ នៅថ្ងៃទី១៧ មេសា ១៩៧៥មក អង្គការខ្មែរក្រហមបានយកពួក យុវកក

នេះមកធ្វើជាគណៈស្រុកនានា ឬជួនកាលតែងតាំងជាគណសហករណ៍ផង ។

ក្នុងឆ្នាំ១៩៦០ មានពួកបញ្ញវ័ន្តក្រហមខ្លះវិលត្រឡប់មកពីស្រុកបារាំង ដូចជា ៖ ចៅ-សេង, ខៀវ-សំផន, ហ៊ូ-យន់, ភោគ-ឆាយ, គាត-ឆុន, ហ៊ូ-នឹម ។ ឆ្នាំនោះពួកកុម្មុយនិស្តខ្មែរបានបង្កើតបក្សម៉ាសសីស្ត-ឡេនីននៅក្នុងក្រុងភ្នំពេញ ។

# ប្រព័ន្ធចារកិច្ចយួនកុម្មុយនិស្ត

តាំងពីឆ្នាំ១៩៤៧ មកម៉្លេះ ដែលពួកវៀតណាមខាងជើងបាននាំអាវុធចូលមកក្នុងស្រុកខ្មែរ (11) ហើយបង្កើតមូលដ្ឋានបីក្នុងស្រុកខ្មែរគឺ ជប់-មេមត់មួយ, នៅតំបន់កំពង់ត្រាច-កំពតមួយ និងនៅសំឡូត-បាត់ដំបងមួយ ។ បន្ទាប់មកយួនវៀតមិញបានបង្កើតខ្មែរវៀតមិញ និងរាយបណ្ដាញចារកិច្ចយួននៅស្ទើរគ្រប់ទីរួមខេត្តខ្មែរ ជាពិសេសនៅក្នុងក្រុងភ្នំពេញតែម្ដង ។ គេយកពួកយួនដែលមានកំណើតនៅស្រុកខ្មែរ ឲ្យមកធ្វើកិច្ចការទាំងអស់នេះ ។ ជាដំបូងគេឲ្យយួនម្នាក់កើតនៅខេត្តកំពត ចូលមកបួសធ្វើជាព្រះសង្ឃខ្មែរគណាថេរវាទ រួចចូលមករៀនជាប់សញ្ញាប័ត្រសាលាបាលីនៅក្រុងភ្នំពេញ ។ យួនធ្វើយ៉ាងនេះព្រោះកាលនោះ ពួកអ្នកនយោបាយខ្មែរដែលប្រឆាំងនឹងបារាំង ច្រើនចេញមកពីប្រភពព្រះសង្ឃ ដូចជាករណីបាតុកម្មព្រះសង្ឃក្នុងឆ្នាំ១៩៤២, ករណីអាចារ្យហែម-ចៀវ, អាចារ្យខៀវ-ជុំ, ព្រះគ្រូប៉ាង-ខាត់, អាចារ្យអ៊ុក-ជា, ព្រះគ្រូសូរ-ហាយជាដើម ។ គេឲ្យយួនដែលមានមានឈ្មោះក្រៅហៅថា អាចារ្យអន-មៀន យកឈ្មោះជាសឺង-ង៉ុកមិញ ហើយបន្លំថាជាប្អូនរបស់លោកសឺង-ង៉ុកថាញ់ទៀត ព្រោះកាលនោះលោកថាញ់ មានកេរ្តិ៍ឈ្មោះល្បីសំបើមណាស់ក្នុងការប្រឆាំងបារាំង ហើយពេលនោះខ្មែរកំពុងបាត់មេដោយសឺង-ង៉ុកថាញ់ត្រូវបារាំងចាប់ ។

លោកសង្ឃមួយអង្គឈ្មោះចូវជាតិយួនបួសធ្វើព្រះសង្ឃខ្មែរ នៅលើភ្នំសំពៅបាត់ដំបង ( ល្អាងលោកតាចូវ ) ក៏ជាខ្សែរយៈបណ្ដាញចារកិច្ចយួនវៀតមិញដែរ ។

សន្និសិទហ្សឺណែវឆ្នាំ១៩៥៤ បានសំរេចឲ្យកងទ័ពបរទេសទាំងអស់ចេញពីកម្ពុជា តែកងទ័ពយួនខាងជើងមិនបានគោរពសេចក្ដីសំរេចនេះឡើយ ។ ពេលទ័ពធំយួនដកថយទៅ យួនវៀតមិញបានទុកបណ្ដាញចារកិច្ចធ្វើសកម្មភាពស្ងាត់ៗនៅតាមខេត្តនានា ជាពិសេសក្នុងក្រុងភ្នំពេញតែម្ដង ។ ដើម្បីជាសញ្ញាសំគាល់គ្នា នៅមុខផ្ទះគេៗតែងដាំដើមឬស្សីកែវមួយឬពីរគុម្ពជានិច្ច ។ ពួកយួនទាំងនោះនៅបន្លំខ្លួនធ្វើជាប្រកបរបរកំប៉ិកកំប៉ុក បើកហាងកាត់ដេរសំលៀកបំពាក់បុរសម៉ូដអឺរ៉ុប, នៅផ្សារចាស់, ជិតវិមានឯករាជ្យ, នៅតាមខេត្តដូចជាហាងកាត់ដេរតៃល័រនៅសៀមរាប, ហាងធ្វើឡាំងរ៉ែកទឹកនៅផ្លូវលេខពីរកន្លះខេត្តបាត់ដំបង (២០), និងបនស្រីពេស្យាដែលភាគច្រើនមានមេជាស្រីយួនមើលការខុសត្រូវ ហើយនារីពេស្យាយួនគឺជាចារនារីតែម្ដង ។

វៀតមិញបានអប់រំស្រីយួនមួយចំនួន ហើយលែងឲ្យមកធ្វើការទាក់ទងយ៉ាងណាឲ្យបានជាស្រីកំណាន់ ជាប្រពន្ធចុងអស់លោកធំ នាម៉ឺនមន្ត្រី ចៅក្រសួងប៉ូលីសគិញ្ញ គយ ជាពិសេសប្រពន្ធចុងនាយទាហានខ្មែរ ។ មេរៀននេះមិនមែនថ្មីឡើយ ខ្មែរធ្លាប់ស្គាល់ម្ដងរួចមកហើយ សម័យស្ដេចជ័យជេដ្ឋាទី២ដែលបាននាងកូ-ជិនស៊ិន បុត្រីស្ដេចយួនជាមហេសី រហូតដល់អស់ដីកំពង់ក្របីព្រៃនគរ ចង្វាត្រពាំង ព្រះសួគ៌ា ឧកញ្ញាឱន... ទៅហើយ ។ នៅសម័យបារាំង ក៏ខ្មែរដឹងម្ដងទៀតដែរ ។ នាយ

*(២០) ប្រពន្ធនិងកូនអាចារ្យសារេនបានទៅតាមប្ដីនិងឪពុកម្ដាយតាមរយៈនេះ ក្នុងឆ្នាំ១៩៦០ ។*

ទាហានធំៗបារាំង ដែលចូលចិត្តបោយឃ្លួន កំណាន់ស្រីយួន ប្រពន្ធយួន ត្រូវស្លាប់អស់មិនតិចដែរ ដូចជាករណីលោក Jean De Raymond ត្រូវបោយដែលលោកស្រឡាញ់ធ្វើជាកូនចិញ្ចឹមនោះ វាយលោកសម្លាប់ពេលកំពុងសំរាន្តលក់ (១៩៥២) ពុំ-មែនក្រុមលោកសឺង-ង៉ុកថាញ់សម្លាប់ដូចសៀវភៅ How Pol Pot came to power សរសេរនោះទេ ។

ម្ចាស់បណ្ណាគារហុង-យូ ផ្សារចាស់ ជាស័ក្តិប្រាំវៀតកុង ។ កូនហុង-យូអាចចេញចូលចំការមនដូចជាផ្ទះរបស់គេ ព្រោះគេជាគ្រូបង្រៀនបុត្រអ្នកម្នាងម៉ូនិច ។ ហុងយូនេះទៀតឮថាបានបើកក្រុមហ៊ុនរកស៊ីជាមួយអ្នកម្នាងនិងអ៊ុំ-ម៉ាណូរិន រត់ពន្ធរប-ស់ពីបរទេសតាមកប៉ាល់ ដែលចូលមកចតក្នុងកំពង់ផែហ្វ្រង់ស៊ី (ផែរួចពន្ធ) នៅមុខវាំងភ្នំពេញ ។ កាលសម័យនោះ មានលោកជួន-យ៉ែម ជាមេគយធំនៅភ្នំពេញ ។

ឈ្មោះថង-ឃីន នៅខេត្តសៀមរាបជាខ្មែរវៀតមិញ ។ ក្នុងបីបួនខែម្តងតែងតែឡើងចុះទៅហាណូយ ឯពួកអាជ្ញាធរខ្មែរដូចជាគ្មានដឹងខ្យល់អ្វីបន្តិចសោះ(២១)។

ជនជាតិយួនច្រើនរស់នៅជាសហគម មិនរស់លាយឡំជាមួយខ្មែរទេ ។ នៅក្រុងភ្នំពេញមានសង្កាត់យួនធំៗ ម្តុំពេទ្យចិន វិហារកៅដាយ អូរឫស្សី ផ្សារតូច គេមានបង្កើតជាសមាគមសាសនា សមាគមឯកជននានា ដែលធ្វើសកម្មភាពនយោបាយភាគច្រើនជាងសកម្មភាពសង្គមកិច្ច ។ វិហារកៅដាយជិតបន្ទាយស្លឹក ផ្សារដើមគរបានទាំងនាំកាំភ្លើងតូចធំ គ្រាប់រំសេវមកលាក់ទុកយ៉ាងច្រើន ដោយលាក់ក្នុងក្តារម-ឈូស ធ្វើជាហែរខ្មោចនាំចូលទៅលាក់ទុកក្នុងវិហារ ដល់ក្រោយមកទើបបែកការ ( ឆ្នាំ១៩៥៩ ) ។

នៅកំពង់ឆ្នាំង នៅខ្សាច់ពោយបាត់ដំបង ជុំវិញបឹងទន្លេសាបសុទ្ធតែយួន ។

ក្នុងឆ្នាំ១៩៦៣ ពេលសម្តេចយាងទៅសម្ពោធទីលានកីឡាបាល់បោះនៅខេត្តកំពង់ធំនោះ ចៅហ្វាយខេត្តកំពង់ធំបានថ្វាយយួនម្នាក់ឈ្មោះឡេ-ឌឹក ជាមេចុងភៅយ៉ាងល្បី ។ សម្តេចបាននាំយកយួននេះមកថ្វាយមាតាលោក សំរាប់ធ្វើក្រយាថ្វាយរាល់ថ្ងៃក្នុងវាំងនៅភ្នំពេញ ។ ឡេ-ឌឹក នេះជាស័ក្តិបីចារបុរសយួនវៀតកុងម្នាក់ដែរ។ វាបានទាំងនាំក្រុមគ្រួសារវា តាំងពីម្តាយក្មេក ប្រពន្ធមកនៅក្នុងវាំង បំរើក្សត្រីបុប្ផាទេវីនៅក្រោមមហាប្រាសាទ ។ ដំបូងពួកប៉ូលីសខេត្តបានចាប់យួនឈ្មោះឡេ-ឌឹកមកដាក់គុក ដោយវាលួចចូលមកនៅកំពង់ធំ ដោយគ្មានអត្តសញ្ញាណសំគាល់ខ្លួន។ នៅក្នុងគុក យួននេះបាននិយាយថា វាចេះធ្វើម្ហូបឆ្ងាញ់ ។ មេភូឃុំក៏យកវាឲ្យធ្វើម្ហូបឲ្យ ។ ក្រោយមកល្បីដល់ចៅហ្វាយខេត្តៗក៏នាំយកទៅធ្វើជាចុងភៅផ្ទាល់ ។ ដល់ពេលសម្តេចទ្រង់យាងទៅខេត្តកំពង់ធំ ក៏សរសើរជាប់មាត់នឹងម្ហូប ដែលលោកចៅ-ហ្វាយខេត្តរៀបថ្វាយ ហើយសួររកមុខអ្នកធ្វើ ។ ចៅហ្វាយខេត្តកំពង់ធំ ពូ-តុងហាវក៏ថ្វាយឡេ-ឌឹកនេះបណ្តោយ ។ យួនចារបុរសឡេ-ឌឹកនេះមិនចេះនិយាយខ្មែរទេ ។ ពេលលន់-នល់ធ្វើរដ្ឋប្រហារទំលាក់សីហនុក្នុងឆ្នាំ១៩៧០ ទាហានបានចាប់ឡេ-

*(២១) តាមសេចក្តីឲ្យការណ៍របស់លោកសាមុត-ប៊ុនថាន់ សព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រនិញ៉ាថា ៖ ថង-ឃីនជាបក្សពួកលាវ-កែវមុនី ។ ថង-ឃីនកើតនៅភូមិជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ។ បំរើយួនវៀតមិញម្តងទៀតក្នុងឆ្នាំ១៩៧២ ។ ពេលប៉ុល-ពតឈ្នះ គេក៏សម្លាប់ថង-ឃីនទៅ ។*

ឱកដាក់ឡាន ដោយអាងខ្លួនភ្ញាក់ងារយួននេះមិនខ្លាចអ្នកចាប់ទេ ស្រែកជេរកញ្ច្រោលធ្លាក់ពីលើរថយន្តបែកក្បាលស្លាប់ទៅ ។

រឿងមួយទៀត គឺមានឈ្មោះស្រីផ្លយ ជាគណកម្មការវៀតមិញដែរ ធ្លាប់បំរើចលនានេះនៅជប់ មេមត់ ក្រែក បាមទទួលការអប់រំពីពួកវៀតមិញថា ៖ យើងជាអ្នកតស៊ូវាយបារាំងដូចគ្នា ចូរកុំប្រកាន់យើងជាប្រជាជនវៀតណាម ខ្មែរ លាវ ត្រូវស្រឡាញ់គ្នាដូចជាបងប្អូនបង្កើត ដីយួនក៏ដូចជាដីខ្មែរ ដីលាវដែរ ប្រជាជនយួនក៏ដូចជាប្រជាជនខ្មែរដែរ យើងបើកចំហាឲ្យប្រជាជនទាំងបីរស់នៅសុខស្រួលជាមួយគ្នាបើយើងប្រកាន់ហួសហេតុ នឹងនាំឲ្យប្រជាជនយើងទាំងបីឈ្លោះគ្នាគ្មានពេលចប់ឡើយ ។

តាមសេចក្តីឲ្យការណ៍របស់លោកស៊ឹម-គិន (ស៊ីអាថិល) ថា ស្រីផ្លយនេះមានកំណើតនៅឧត្តរមានជ័យ ។ សម័យយួនបានធ្វើជាគណខេត្តឧត្តរមានជ័យមួយរយៈ ។ គឺស្រីផ្លយនេះហើយដែលធ្វើជាខ្សែរយៈជាមួយហាងកាត់ដេរថៃល័រនៅសៀមរាបក្រុង ។

យើងឃើញថាយួនខាងជើងបានដាក់ចារជនគេឲ្យចូលទៅនៅកៀកនឹងមេដឹកនាំខ្មែរ ដើម្បីស្គាល់ចំណុចខ្សោយ អត្តចរិតមេដឹកនាំខ្មែរ និងយកការសម្ងាត់ពីខ្មែរទើបមេដឹកនាំយួនស្គាល់ក្រយៅក្បាលមេដឹកនាំខ្មែរយ៉ាងច្បាស់ដូចក្រយៅបាតដៃវាអីចឹង ។ កាលបាតុកម្មវាយទូតវៀតកុង-យួនខាងជើង គេយកបានឯកសារដែលយួនសិក្សាពីមេខ្មែរថា មេខ្មែរចូលចិត្តលុយ, ស្រី, ស្រា, អំណាច តែក្រុមសម្ងាត់ខ្មែរបំបិទចោលទៅ ។

គំរោងការណ៍នេះគេរៀបចំជាយូរយារណាស់មកហើយ តាំងពីសម័យចំបាំងជាមួយអាណានិគមបារាំងម្ល៉េះ គឺយួនខាងជើងគ្រោងយកស្រុកខ្មែរឲ្យបានក្នុងអនាគត ។ ពេលយួនមើលឃើញថា គេជិតបានសំរេចជោគជ័យរំដោះបង្រួបបង្រួមវៀតណាមខាងត្បូង មេដឹកនាំយួនក៏សំរេចដំណាក់ការទី២តាមបណ្តាំហូ-ជីមិញ ដែលមុននឹងស្លាប់បានផ្តាំហើយផ្តាំទៀត ឲ្យសាវ័កគាត់បន្តការរំដោះយកឥណ្ឌូចិនទាំងមូល (ខ្មែរ លាវ) រួមធ្វើជាសហព័ន្ធឥណ្ឌូចិននោះ ទើបប្រជាជនយួនទាំងខាងជើងនិងខាងត្បូងចំនួនជាង៦០លាននាក់អាចរស់នៅបានស្រួល ព្រោះដីខ្មែរជាដីខ្លាញ់ខាងផ្តល់ស្រូវ-ត្រី ដែលមាត់រាស្ត្រយួនត្រូវការជាចាំបាច់ ហើយមួយទៀតទាំងមេដឹកនាំទាំងរាស្ត្រខ្មែរមិនបានគិតគូរពីវាសនាប្រទេសរបស់គេទេ ព្រោះមនុស្សនៅតិចលើទឹកដីធំទូលាយ បានធ្វើឲ្យខ្មែរមានគំនិតខ្ជិល រស់នៅសប្បាយភ្លេចខ្លួន ទាំងមេដឹកនាំ (អោបអំណាច) ទាំងរាស្ត្រ ។

*          *
*

# ជំពូកទី៤
## អាណាព្យាបាលតាំងពីឆ្នាំណា

កាលដែលលោកសឺង-ង៉ុកថាញ់វិលត្រឡប់មកពីស្រុកបារាំង ពីជីវភាពជាជននិរទេសនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៥១ នោះសម្តេចសីហនុបានហាមប្រាមមិនឲ្យគេទៅទទួលលោកសឺង-ង៉ុកថាញ់ឡើយ តែសិស្សានុសិស្ស ប្រជារាស្ត្ររាប់ពាន់ម៉ឺននាក់បានទៅទទួលលោក ។ តាំងពីវាលចំណតយន្តហោះពោធិចិនតុងមកដល់រាជធានីភ្នំពេញ មានមនុស្សឈរអមផ្លូវជាពីរជួររហូត (១) ។ សីហនុមានសេចក្តីច្រណែនណាស់នឹងប្រជាប្រិយភាពរបស់លោកសឺង-ង៉ុកថាញ់ក្នុងប្រទេសខ្មែរ ជាគ្រោះមិនល្អដល់ព្រះអង្គនិងរបបរាជានិយម ។ តទៅថ្ងៃមុខព្រះអង្គនឹងបាត់មុខមាត់បាត់រាជបល្លង្គ បាត់អំណាចជាមិនខាន ព្រោះលោកសឺង-ង៉ុកថាញ់ហាក់មានកម្លាំងស្រូបទាក់ទាញពពួកបញ្ញវ័ន្តខ្មែរឲ្យមករួបរួមជាមួយបាន ។ ហេតុនេះហើយទើបសីហនុចាត់ទុកលោកសឺង-ង៉ុកថាញ់ជាសត្រូវទី១របស់ទ្រង់ និងរបបរាជាសក្តិភូមិដែលមានទ្រង់ជាតំណាង ។

លោកសឺង-ង៉ុកថាញ់បានចេញទៅព្រៃថ្ងៃទី៩ មិនា ១៩៥២ ដើម្បីវាយបារាំងទាមទារឯករាជ្យ ។ បារាំងចាញ់សង្គ្រាមឌៀនបៀនភូ នៅថ្ងៃទី៧ ឧសភា ១៩៥៤ ធ្វើឲ្យអំណាចអាណានិគមរង្គោះរង្គើអស់ពិស ។ ការទាមទារឯករាជ្យសន្តិវិធីរបស់សម្តេចក្លាយជាមានជោគជ័យ ។ ដោយបារាំងចាញ់សង្គ្រាមជាមួយហូ-ជីមិញយ៉ាងធ្ងន់ក៏សុខចិត្តប្រគល់ឯករាជ្យមកប្រទេសកម្ពុជា ស៊ីយ៉ឹងពួកលោកសឺង-ង៉ុកថាញ់ ដែលកទ័ពនៅអូរស្មាច់ភ្នំដងរែកទៅវិញ ។ សីហនុបានក្លាយជាមហាវីរបុរសរង្គ ជាបិតាឯករាជ្យជាតិ មានប្រជាប្រិយភាពដ៏អស្ចារ្យ ដែលរាស្ត្រខ្មែរល្ងង់ខ្លៅនាំគ្នាជឿថាទ្រង់ជាធម្មិករាជ បារាំងសុំចុះញ៉មក្រោមអនុភាពកាំភ្លើងឈើពួកជីវពល-នារីក្លាហាន ។

រដ្ឋធម្មនុញ្ញដែលរៀបចំឡើងដោយទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស (២) និងបក្សប្រជាធិបតេយ្យ ហើយប្រកាសប្រើក្នុងឆ្នាំ១៩៤៧ បានដក់អំណាចជាច្រើនពីព្រះមហាក្សត្រ ប្រគល់ទៅឲ្យប្រជារាស្ត្រ ដែលមានសភាជាតំណាង ។ រដ្ឋធម្មនុញ្ញដែលប្រកាសប្រើមកនោះ មិនជាទីសព្វព្រះហឫទ័យសម្តេចឡើយ ។ សីហនុបានកែប្រែត្រឡប់ត្រឡិនចុះឡើងជាច្រើនសារដើម្បីការពារតែផលប្រយោជន៍និងឋានៈពួកក្សត្រ ។ សភាជាតិនីតិកាលទី១ ចាប់បើកពីថ្ងៃទី២១ ខែមករា ១៩៤៨ ហើយមានសមាជិកភាគច្រើនជាបក្សប្រជាធិបតេយ្យ ។ ដោយច្រណែននឹងបក្សប្រជាធិបតេយ្យមានប្រជាប្រិយភាពជាង ហើយដោយសមាជិកភាគច្រើនមិនព្រមធ្វើតាមបំណងទ្រង់ សីហនុក៏ប្រកាសរំលាយរដ្ឋសភានីតិកាលទី១នោះទៅនៅថ្ងៃទី១៧ កញ្ញា ឆ្នាំ១៩៤៩ (1) ។

*(១) តាមសេចក្តីឲ្យការរបស់លោកស៊ាម-ហួត អតីតគណកម្មការបក្សប្រជាធិបតេយ្យប្រចាំក្រុងភ្នំពេញ សព្វថ្ងៃលោករស់នៅក្នុងក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។*

*(២) សូមអានទំព័រ៧៦*

ក្រោយមកទៀតនៅថ្ងៃទី១៩ មករា ១៩៥០ ជនម្នាក់បានយកគ្រាប់បែកទៅគប់ចូលទីចាត់ការគណបក្សប្រជាធិបតេយ្យសម្លាប់លោកអៀវ-កើស, អតិតប្រធានរដ្ឋសភា និងជាអគ្គលេខាធិការគណបក្សប្រជាធិបតេយ្យ, នេះក៏ជាស្នាដៃរបស់សម្តេចដែរ(2) តែទម្លាក់ទោសទៅលើទ្រង់នរិន្ទដេតទៅវិញ ។ ក្នុងការដណ្តើមអំណាចពីរាស្ត្រនេះ សីហនុបានអនុវត្តអំពើកាចសាហាវណាស់ ធ្វើទុក្ខបុកម្នេញពួកប្រជាធិបតេយ្យ ចាប់ដាក់គុក (កេង-វ៉ាន់សាក់...), សម្លាប់ចោលអស់ជាច្រើន មានលោកអៀវ-កើស, អាចារ្យអ៊ូ-ចុង (កូនតាក្រមង៉ុយ...), បិទសារពត៌មានខ្មែរក្រោកជាដើម ។ ដោយសារសភានីតិកាលទី២មិនព្រមធ្វើតាមបំណងរបស់ទ្រង់ សីហនុក៏ប្រកាសបិទសភានិតិកាលទី២នោះទៀត នៅថ្ងៃទី១៣ មករា ១៩៥៣ (3) ហើយចាប់សមាជិកសភាជាច្រើនដែលជំទាស់នឹងទ្រង់ញាត់គុកអស់ ក្នុងចំណោមនោះមានលោកប៉ុន-ចន្ទម៉ុលផងដែរ ។

សូមជំរាបថា កាលសម័យនោះ មានគណបក្សនយោបាយច្រើនបក្សច្រើនក្រុមណាស់ (4) តែមានតែបក្សប្រជាធិបតេយ្យទេ ដែលមានប្រជាប្រិយជាងគេ ។ បក្សទាំងនោះគឺ ៖

១- គណបក្សប្រជាធិបតេយ្យ សញ្ញាក្បាលដំរីកាន់ផ្កាឈូកបី មានលោកអៀវ-កើសជាប្រធាន ។

២- គណបក្សសេរីភាព សញ្ញារូបប្រាសាទកំពូលបី មានទ្រង់នរោត្តម-នរិន្ទដេតជាប្រធាន ។

៣- គណបក្សខេមរប៉ុន្នការ សញ្ញារូបនាងគង្ហីង មានលោកលន់-នល់ដឹកនាំ ។

៤- គណបក្សជំកើងប្រជាជាតិ សញ្ញាហនុមានទ្រផែនទីស្រុកខ្មែរ មានលោកយែម-សំបូរជាអ្នកដឹកនាំ ។

៥- គណបក្សចំរើនជាតិ សញ្ញារូបព្រួញទម្លុះកងបួន មានលោកជា-ជិនកុក ជាអ្នកដឹកនាំ ។

*(២) ទ្រង់យុត្តិវង្សជាអ្នកប្រាជ្ញខ្មែរម្នាក់ ដែលបានសិក្សាដល់ឧត្តមវិជ្ជា មានសញ្ជាតិបារាំង មានភរិយាបារាំង ។ កាលណោះហូ-ជីមិញក៏ទទួលស្គាល់ដែរថា ខ្មែរមានផ្កាយមួយរះដែរ តែផ្កាយនោះដើរផ្លូវផ្ទុយពីហូ-ជីមិញ ។ ទ្រឹស្តីបទយុត្តិវង្ស (* Théorèmes de Youthevong *) ខាងគណិតវិទ្យា មាននៅក្នុងកម្មវិធីផ្នែកឧត្តមសិក្សា នៅមហាវិទ្យាល័យវិទ្យាសាស្ត្រ ។ ទ្រង់យុត្តិវង្សបាននាំយកលទ្ធិប្រជាធិបតេយ្យ ដែលទ្រង់កោតសរសើរតាំងពីនៅឯស្រុកបារាំងនោះចូលមកស្រុកខ្មែរ ។ ទ្រង់ជាអ្នកបង្កើតគណបក្សប្រជាធិបតេយ្យមុនគេជាមួយលោកអៀវ-កើស និងជាអ្នកដែលបានព្រៀងសំណៅរដ្ឋធម្មនុញ្ញខ្មែរជាដំបូង ដោយយករដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋបារាំងទីបីជាគោល ។ ដោយទ្រង់មិនញញើតបារាំង និងចេះរារាំងកិច្ចការរបស់បារាំង ទើបបារាំងគ្រោងធ្វើគតលោក ។ តាមសេចក្តីឲ្យការណ៍របស់លោកស៊ាម-ហួត ថាទ្រង់មានជម្ងឺស្អួត ដែលមិនត្រូវគ្នានិងធាតុអាកាសត្រជាក់ឡើយ ។ បារាំងក៏រកលេសចាក់ចុចឲ្យភរិយាទ្រង់ជាតិបារាំងនោះរៀបចំ ធ្វើពិធីជប់លៀងមួយនៅពេលរាត្រីហាលសន្សើម ។ ទ្រង់យុត្តិវង្សត្រូវតែទៅចូលរួមខានមិនបាន ព្រោះភរិយាលោកបានណាត់ជាមួយអ្នកធំបារាំងរួចទៅហើយ ។ ដោយត្រូវធាតុត្រជាក់រោគលោកក៏រើបរើឡើងវិញ បារាំងគេមានថ្នាំដែរ តែគេមិនចាក់ថ្នាំនោះឲ្យទុកឲ្យលោកសុគតតាមសំរួលទៅនៅក្នុងខែកក្កដាឆ្នាំ១៩៤៧ ។ ចេតិយលោកនៅលើភ្នំព្រះរាជទ្រព្យស្រុកឧត្តុង។ សម្តេចត្រេកអរណាស់ដែលទ្រង់យុត្តិវង្សសុគតទៅ គឺលោកបាត់សត្រូវមួយហើយ ។ តាំងពីទ្រង់យុត្តិវង្សសុគតទៅ សម្តេចមិនដែលចេញព្រះវាចារំលឹកពីទ្រង់យុត្តិវង្សទាល់តែសោះ ។ ម្ចាងទ្រង់យុត្តិវង្សព្រមទាំងបុត្រពីរនាក់បានវិលទៅរស់នៅស្រុកបារាំងរហូតដល់សព្វថ្ងៃ ។*

៦- គណបក្សល្បសានមានជ័យ សញ្ញារូបទង់ជ័យពីរខ្វែងទ្រមុង មានលោកម៉ៅ-ចយ ជាអ្នកដឹកនាំ ។

៧- គណបក្សសំបុកឃ្មុំរបស់លោកម៉ម-សុទ្ធ ។

៨- គណបក្សកណ្ដាប់ស្រូវ ដឹកនាំដោយលោកសម-ញាន (៣) ។

៩- គណបក្សរួបរួមជាតិ ។

១០- គណបក្សរូបកណ្ដៀវ ។

១១-គណបក្សប្រជាជន សញ្ញារូបនង្គ័ល របស់ក្រុមខ្មែរវៀតមិញ ដែលដឹកនាំដោយក្រុម ណុប-បូផាន, នង-សួន ( ម៉ី-ផូ, ម៉ា-មួន, លាវ-កែវមុនី... ) ។

គោលបំណងរបស់សម្ដេចគឺ ក្ដោបយកអំណាចទាំងអស់ និងរំលាយគណបក្សទាំងអស់ ឲ្យមកនៅក្រោមឥទ្ធិពលរបស់ទ្រង់ ។ ដើម្បីហក់ចូលមកយកអំណាចឲ្យពេញដៃ សីហនុក៏ដាក់រាជ្យថ្វាយមាតាបិតាលោកនៅឆ្នាំ១៩៥៥ រួចទ្រង់ក៏បង្កើតគណបក្សសង្គមរាស្ត្រនិយម និងប្រើអំណាចព្រៃ រំលាយគណបក្សដទៃទៀតឲ្យចូលមកជាមួយ ។

ពួកប្រជាធិបតេយ្យដែលមិនចូលរួមជាមួយគណបក្សសង្គមរាស្ត្រនិយម ត្រូវប្អូកតិញប៉ូលីសតាមរាប់យប់ថ្ងៃ ធ្វើទុក្ខបុកម្នេញគៀបសង្កត់គ្រប់វិធី....។ សីហនុបានបង្ខំឲ្យធ្វើការបោះឆ្នោតប្រជាមតិជ្រើសរើសយកគណបក្សនយោបាយសង្គមរាស្ត្រនិយម ។ ក្នុងការឃោសនាគណបក្សនោះ សីហនុនិងពួកចៃវាំងបានប្រើអំពើព្រៃផ្សៃបំផុតក្នុងការផ្ចាញ់ផ្ចាលពួកឃោសនិកបក្សប្រជាធិបតេយ្យ ។ តាមសេចក្ដីឲ្យការណ៍របស់លោកយូ-សំបូរ អតីតនាយកបុគ្គលិកសិក្សាភ្នំពេញ សព្វថ្ងៃរស់នៅ Montreal កាណាដា បាននិយាយថា ៖ កាលនៅជាសិស្សវិទ្យាល័យស៊ីសុវត្ថិ បានតាមទៅជាមួយក្រុមឃោសនិកបក្សប្រជាធិបតេយ្យ ដែលមានលោកកេង-វ៉ាន់សាក់, អ្នកគ្រូខៀវ-ប៉ុណ្ណារី (អតីតគ្រូរបស់លោកយូ-សំបូរ)... និងគ្នាមួយចំនួនទៀតទៅឃោសនាតាមខេត្ត ។ លោកយូ-សំបូរបានឃើញពួកចៃវាំងយកក្រុមឆាំយ៉ាំទៅទះ វាយស្គរតំឡង់រំខានឆាឆៅកុំឲ្យប្រជារាស្ត្រស្ដាប់ការឃោសនាពួកប្រជាធិបតេយ្យកើត ។ នៅសៀមរាប សីហនុបញ្ជាមកដាប-ឈួន ៗក៏ប្រើប៉ូលីសអូសច្រវាក់វ៉ាវចុះវ៉ាវឡើងកាត់មុខឃោសនិកប្រជាធិបតេយ្យ ឃោសនិកប្រជាធិបតេយ្យភ័យក៏រត់ប្រាស់យករួចខ្លួន ។ នៅភ្នំពេញជិតក្រសួងឃោសនាការ សីហនុបញ្ជាឲ្យសម-សារី ( ឪពុករបស់លោកសម-រង្ស៊ី ) នាំពួកតិញទៅបាញ់លោកអៀវ-ស៊ីចូវ និងកេង-វ៉ាន់សាក់ ដែលកំពុងធ្វើការឃោសនាលើវេទិកា ។ នៅបាត់ដំបង, លោកតូច-ឈួងអ្នកនិពន្ធសៀវភៅ « បាត់ដំបងសម័យលោកម្ចាស់ » សព្វថ្ងៃរស់នៅឃុំវត្តគរ ខេត្តបាត់ដំបងបានឲ្យការណ៍ថា ៖ កាលនៅជាសិស្សអនុវិទ្យាល័យព្រះមុនីវង្ស បានចូលរួមជួយឃោសនាគណបក្សប្រជាធិបតេយ្យ ។ ពេលកំពុងឃោសនានៅផ្សារក្រោមបាត់ដំបង ពួកប៉ូលីសខេត្តបានកេណ្ឌមនុស្សមួយក្រុមខ្វង់ម្កៃនាក់ ឲ្យយកថ្មដេញគប់ ក៏នាំគ្នារត់យកតែរួចខ្លួន ។ រឿងបែបនេះមានគ្រប់ទីកន្លែងពេញស្រុកខ្មែរក្នុងឆ្នាំ១៩៥៥ រហូតមានសម្លាប់ឃោសនិកប្រជាធិបតេយ្យទៀតផង ដូចជានៅសៀ

*(៣) ជាឪពុកសម-សារី ឯសម-សារីខឹងនឹងសម្ដេចហូតងាររទូត ក៏រត់ទៅចូលជាមួយលោកសឺង-ង៉ុកថាញ់ ។*

មរាបជាដើម ។ សីហនុបានឈ្នះឆ្នោតប្រជាមតិ ដោយមធ្យោបាយដ៏ឃោរឃៅបែបនេះ ។ នៅចុងខែកញ្ញា អគ្គលេខាធិការគណបក្សប្រជាធិបតេយ្យ បានធ្វើពិធីតូចមួយចំពោះមុខសមាជិក ថ្លែងរំលាយគណបក្សប្រជាធិបតេយ្យ ដែលលោកទៀង-ឡេម៉ាន់ជាក្មួយ, សព្វថ្ងៃរស់នៅក្រុងស៊ីអាថិល, បានរំលឹកសំដីអគ្គលេខាធិការបក្សប្រជាធិបតេយ្យថា ៖ ដោយហេតុសង្គមរាស្ត្រនិយមឈ្នះឆ្នោតប្រជាមតិ អំណើះតទៅមានតែគណបក្សនយោបាយតែមួយគត់ដឹកនាំនយោបាយស្រុកខ្មែរ ប្រទេសខ្មែរក្នុងអនាគត ច្បាស់ជានឹងត្រូវទទួលរងគ្រោះព្យុះសង្ឃរាអន្តរាយជាពុំខាន ។

មុនហក់ចូលប្រឡូកក្នុងរឿងនយោបាយដណ្តើមអំណាចនេះ ស្តេចសីហនុបានចូលទៅសិក្សាចំណេះពុទ្ធចក្រ អាណាចក្រ ពីសំណាក់សម្តេចសង្ឃជួន-ណាតរាល់ៗរាត្រី ចាប់ពីរំលងអាធ្រាតទៅ ។

ក្នុងឆ្នាំ១៩៥៥ សម្តេចជួន-ណាតបានព្រមានសីហនុថា ៖ ទ្រង់នៅក្មេងសេចក្តីណាស់ គួរកុំអាលធ្វើនយោបាយអី ក្រែងនឹងនាំគ្រោះមហន្តរាយដល់ប្រទេសខ្មែរនិងប្រជារាស្ត្រខ្មែរ ! ។ សីហនុ, កាលនោះខ្ទាល់ជាខ្លាំង, ក៏រំលើកសារគុណតបថា ៖ បុណ្យទីជាសម្តេចសង្ឃនេះ គឺសីហនុជាអ្នកប្រគេន មួយទៀតរឿងធ្វើឬមិនធ្វើន-យោបាយនោះ ជារឿងផ្ទាល់ខ្លួនសីហនុ សម្តេចសង្ឃសូមកុំលូកមកជ្រៀតជ្រែករឿងនេះ ។

*　　　*
*

# សីហនុនិងប្លុកកុម្មុយនិស្ត

ប្រទេសយួននិងចិនក្រហមមិនគោរពសេចក្តីសំរេចរបស់សន្និសិទទីក្រុងហ្សឺណែវឡើយ ។ យួនវៀតមិញនៅតែបន្តនយោបាយសម្ងាត់តទៅទៀត ដោយមានបំណងយកស្រុកខ្មែរ ធ្វើជាមូលដ្ឋានរំដោះយួនខាងត្បូង ។ ចិនប្រជាមានិតុបានរកខ្សែរយៈចិនដែលធ្លាប់ចេញចូលវាំងម្នាក់ ផ្ទះនៅមុខវាំងឈ្មោះ គុច-ជី ប្រពន្ធឈ្មោះឡាន់ ឲ្យធ្វើជាមេធ្លាក់ ។ ក្នុងឆ្នាំ១៩៥៦ សម្តេចបានទាក់ទងចិនក្រហម ។ លោកជូ-អេងឡាយបានមកធ្វើទស្សនកិច្ចនៅស្រុកខ្មែរក្នុងចុងឆ្នាំ១៩៥៦ (5) កាលណោះចិននិយាយសុំឲ្យសម្តេចជួយយួន ក្នុងការវាយរំដោះវៀតណាមខាងត្បូងតែម្តង (៤) ។ តាមសំដីឪពុកខ្ញុំ អ្នកនិយាយវិទ្យុប៉េកាំងជាភាសាខ្មែរ ជាចិនកើតនៅកំពង់ចាម រៀនអក្សរខ្មែរនៅវត្តជ្រោយថ្មពីព្រះសង្ឃអាចារ្យនៅ ( ឪពុកខ្ញុំសំណាក់នៅកុដិកាលនៅជាសិស្សបឋមសិក្សា ) ។

ក្រសួងសម្ងាត់អាមេរិកាំងឃើញសម្តេចទាក់ទងចិនជួយយួនហើយ ក៏ចាប់រកខ្សែរយៈរំលំសម្តេច ។ ក្នុងផែនការនេះគេទាក់ទងបានដាប-ឈួននៅចុងឆ្នាំ១៩៥៧ គេផ្តល់លុយកាក់និងអាវុធ វិទ្យុទាក់ទងជាច្រើនដឹកតាមយន្តហោះពីយៀកណាមខាងត្បូងមកឲ្យដាប-ឈួននៅសៀមរាបពេលរាត្រី ។ ដាប-ឈួនគ្មានចំណេះថែមទាំងគ្មានអ្នកចេះដឹងជួយសោះ ទើបអាមេរិកាំងយកនាយទាហានយួនខាងត្បូងពីរនាក់មកជួយ ធ្វើឲ្យសម្តេចសីហនុមានការសង្ស័យ (៥) ។ ក្រោយមកអ្នកជំនាញការអាមេរិកាំងបានឲ្យរដ្ឋាភិបាលថៃជួយរកលោកសឺង-ង៉ុកថាញ់ ដោយឲ្យលោកក្រុមតម្រួតថៃជួយផង ។ លោកវ៉ងឆៈណៈបានទៅយកលោកសឺង-ង៉ុកថាញ់ពីខេត្តឡុកនិញ (៦) មក ។ អាមេរិកាំងសុំឲ្យលោកសឺង-ង៉ុកថាញ់ទៅជួយដាប-ឈួន ដើម្បីផ្តល់

(៤) *តាមសេចក្តីឲ្យការណ៍របស់លោកប៉ោ-ថន អតីតវរៈសេនិយឯកនិងជាអ្នកចាត់ចែងការទទួលបដិសណ្ឋារកិច្ចភ្ញៀវបរទេសនានាសម័យសម្តេចសីហនុ ។*

(៥) *តាមសេចក្តីឲ្យការណ៍របស់លោកស៊ិម-គិន នៅទីក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។*

(៦) *ក្រោយសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ខ្មែរឥស្សរៈ ខ្មែរវៀតមិញ ត្រូវចុះចូលទៅរួបរួមក្នុងសង្គមជាតិវិញ ។ ក្រោយពីធ្វើបុណ្យឯករាជ្យនៅលើភ្នំដងរែករួច កងទ័ពឥស្សរៈរួមខ្មែរបំរើជាតិរបស់លោកសឺង-ង៉ុកថាញ់បានដាក់អាវុធចុះចូលទៅរស់ក្នុងសង្គមជាតិដោយខ្លះទៅរៀនបន្តវិជ្ជាទៀត មានជាអាទិ លាវ-ផានអ៊ីមជាដើម ដែលរៀនបន្តជានិស្សិតវេជ្ជបណ្ឌិត ។ គ្មាននរណាម្នាក់បានទទួលបុណ្យស័ក្តិពីសម្តេចសោះឡើយ ទោះជាពួកខ្មែរវៀតមិញក៏ដោយ ។ នៅក្នុងពិធីបុណ្យនោះ លោកសឺង-ង៉ុកថាញ់បាននិយាយផ្តែផ្តាំថា ៖ ពេលនេះការតស៊ូរបស់យើងត្រូវចប់មួយរយៈ ដោយប្រទេសខ្មែរបានឯករាជ្យហើយ តែបេសកកម្មកូនខ្មែរនៅមិនទាន់ចប់នៅឡើយទេ ក្នុងការការពារទឹកដីខ្មែរឲ្យគង់វង់ ។ សីហនុសុខចិត្តទទួលកងទ័ពឥស្សរៈរួមខ្មែរបំរើជាតិទាំងអស់ លើកលែងតែសឺង-ង៉ុកថាញ់ចេញ ទ្រង់ហាមមិនឲ្យចូលមកស្រុកខ្មែរសោះឡើយ ហើយចោទលោកសឺង-ង៉ុកថាញ់ថា ជាជនក្បត់ជាតិទៀតផង ។ លោកសឺង-ង៉ុកថាញ់ក៏រស់នៅលើភ្នំដងរែកជាមួយទាហានជំនិត៣០នាក់ នាំគ្នាធ្វើចំការចិញ្ចឹមជីវិត ។ ក្នុងឆ្នាំ១៩៥៦ សម្តេចប្រើឲ្យដាប-ឈួននាំទ័ពទៅវាយបន្ទាយលោកឆេះខ្មៅខ្មី ។ លោកថាញ់ក៏ភៀសខ្លួនចូលទៅក្នុងដីថៃ លោកនាយតម្រួតថៃកាលនោះជាស័ក្តិបីរាជតម្រួត បានយកឧទ្ធម្ភាគចក្រទៅទទួលលោកសឺង-ង៉ុកថាញ់ ឲ្យលាក់ខ្លួននៅក្នុងក្រុងបាងកក ។ ក្រោយបន្តិចមកសម្តេចព្រះមហាក្សត្រីយានីកុសុមៈបានយាងទៅធ្វើទស្សនកិច្ចក្រុងបាងកក ហើយបានសុំឲ្យរាជរដ្ឋាភិបាលថៃចាប់លោកសឺង-ង៉ុកថាញ់ប្រគល់មកឲ្យ*

*រដ្ឋាភិបាលខ្មែរ ទោះជាថៃចង់បានសគុណជាមាសប៉ុន្មានគីឡូក៏ដោយ ។ លោកសឹង-ង៉ុកថាញ់បានលបមកជួបទាហានជំនិតលោកនៅជាយដែនវិញ ផ្ដែផ្ដាំឲ្យទៅរស់នៅបន្លំធ្វើជាប្រជាជននៅក្នុងស្រុកថៃសិន ។ រួចដោយលោកមិនទុកចិត្តលោកនាយតម្រួតថៃទៀត ខ្លាចយកលោកទៅលក់ឲ្យខ្មែរសីហនុ ពេលរាត្រីលោកក៏លួចគេចឡើងរទេះភ្លើងចូលទៅស្រុកភូមា រួចទាក់ទងទូតជប៉ុនទៅសំណាក់នៅតូក្យូមួយរយៈតូច រួចក៏ធ្វើដំណើរទៅស្រុកយួនយៀកណាមខាងត្បូង ទៅជួបនឹងប្អូនលោកឈ្មោះសឹង-ថាយង្វៀងនៅក្រុងព្រៃនគរ សំណាក់នៅទីនោះមួយរយៈទៀត ទើបលោកចេញទៅសម្ងំលាក់ខ្លួននៅក្នុងខេត្តឡុកនិញ ធ្វើចំការជាមួយអ្នកជំនិតម្នាក់ឈ្មោះតាហាយ នៅក្នុងភូមិបុស្សធំ ។ លោកតែងតែតាមដានស្រុកទេសជានិច្ច ដោយអានសារពត៌មានយួននិងបារាំងដែលប្អូនលោកផ្ញើមកឲ្យ ។ នៅទីនោះលោកបានផ្ញើសំបុត្រទៅប្រាប់ទាហានជំនិតនៅថៃនាមញ៉ឹក-គិមឡុង ( កែឈ្មោះថៃ វីរ៉ាត់-ថងឌី ហៅក្រៅថា សារ៉ាត់ ) ព្រមទាំងលោកឡឹក-សំអឿន ដែលនៅទីនោះដែរថា លោកសព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ លោកសឹង-ង៉ុកថាញ់បានឃើញសេចក្ដីប្រកាសរកូបលោកចុះក្នុងសារពត៌មានជាភាសាបារាំង ដែលប្អូនលោកផ្ញើមកឲ្យ ។ លោកក៏ត្រៀមខ្លួនហើយរើសទាហានខ្លះៗចាំជាស្រេច ។ ហេតុនេះហើយទើបលោកនាយតម្រួតថៃអាចទៅរកលោកសឹង-ង៉ុកថាញ់ឃើញ ហើយនាំមកជួបនឹងតំណាងសហរដ្ឋអាមេរិក ដែលកំពុងតែរកូបលោក ឲ្យទៅជួយដាប-ឈ្លួនធ្វើរដ្ឋប្រហារទម្លាក់សម្ដេច តែលោកមិនទុកចិត្តដាប-ឈ្លួនទើបលោករារែក ។ រហូតដល់ពេលដែលលោកយល់ព្រម ហៀបនឹងឡើងយន្តហោះទៅចុះនៅសៀមរាប តែពេលនោះផែនការដាប-ឈ្លួនត្រូវបែកការ ហើយសម្ដេចបានឲ្យប៉ូលីសខេត្តនិងទាហានទៅព័ទ្ធចាប់ដាប-ឈ្លួន ។ កាលនោះដាប-ឈ្លួនបានគេចចេញពីវិមាន រួចឡើងទៅភ្នំគូលែនថ្វាយបង្គំព្រះសិរិទ្ធពីរអង្គ ដែលដាប-ឈ្លួនតែងជឿនិងគោរពណាស់ ហៅថានាងចេកនាងចម ។ លោកចំរើន-ស៊ិនឲ្យលោកស័ក្តិបីហេងតាមទៅរកដាប-ឈ្លួន ព្រោះជាជំនិតនិងស្គាល់ទីកន្លែងនោះ ។ មួយដោយខ្លាចបែកការក្នុងរឿងរួមដៃ និងមួយដោយខឹងនឹងដាប-ឈ្លួនរំលោភកូនក្រមុំខ្លួនផង ស័ក្តិបីហេងក៏សម្លាប់ដាប-ឈ្លួនទាក់កអូសមក ។ កាលសម័យសាធារណរដ្ឋ លោកសឹង-ង៉ុកថាញ់តែងតែពោលប្រាប់សហការីលោកថា ៖ កាលនោះក៏ជាកំហុសរបស់លោកដែរ ដោយខ្លាចដាប-ឈ្លួនពេក តែនេះក៏ជាវាសនាអកុសលស្រុកខ្មែរ ដែលនឹងត្រូវតែវិនាសអន្តរាយក្រោមស្នាដៃសីហនុ ។ ពត៌មាននេះផ្ដល់ដោយលោកស៊ិម-គិន ( នៅទីក្រុងស៊ីអាថិល ) និងលោកតាំង-ប៊ុនធឿន ។ លោកតាំង-ប៊ុនធឿនជាអ្នកបានចូលរួមក្នុងការហ៊ុំព័ទ្ធវិមានដាប-ឈ្លួន កាលលោកនៅជាកងប៉ូលីសខេត្តសៀមរាប សព្វថ្ងៃរស់នៅទីក្រុងតាខូម៉ា រដ្ឋវ៉ាស៊ិនតោន ។*

ឃោបល់និងរៀបចំគំរោងធ្វើរដ្ឋប្រហារទម្លាក់សម្ដេច តែលោកសឹង-ង៉ុកថាញ់មិនព្រម ព្រោះដាប-ឈ្លួនជាមនុស្សចិត្តឆៅអាចនឹងហ៊ានសម្លាប់លោក ។ តាមសុន្ទរកថារបស់សម្ដេចដែលថ្លែងនៅកំពង់ចាមថ្ងៃទី១៣មករា១៩៥៩ ថាសម-សារីបានក្បត់ចូលរួមជាមួយដាប-ឈ្លួន ធ្វើរដ្ឋប្រហារដោយមានតំណាងវៀតណាមខាងត្បូងនៅភ្នំពេញឈ្មោះង៉ោ-ទ្រុងហ៊ីវ ( Nho Trong Hieu ) ក្រោយមករដ្ឋមន្ត្រីសង្គមកិច្ចនិងសកម្មភាពចិត្តសាស្ត្រក្នុងការិយាល័យលោកងោ-ឌិនឌៀម (6) និងភ្នាក់សម្ងាត់ស៊ីអាយអេ (CIA) វិចទ័រ-ម៉ាត់ស៊ូ ( Victor Matsui ) ក្នុងស្ថានទូតអាមេរិកាំងនៅភ្នំពេញជួយរៀបចំក្នុងការប្រុងធ្វើរដ្ឋប្រហារនេះ ។ ផែនការនេះពន្យាពេលអស់ជាងប្រាំមួយខែ ក៏ត្រូវបែកការណ៍ ដោយអ្នកបើកឡានសម-សារីក្បត់ (៧) ។ អ្នកបើកឡានបានយកសំបុត្រសំងាត់ដែលសម-សារីផ្ញើទៅលោកអ៊ីវ-យ៉ាង ទៅថ្វាយសម្ដេច ។ ពួកអតីតឥស្សរៈរួមខ្មែរបំរើជាតិត្រូវសម្ដេចចាប់ចងព្រមគ្នាតែម្ដងក្នុងពាក់កណ្ដាលអាធ្រាតមាន លោកអ៊ីវ-យ៉ាង, សាំង-សាវាត, គាំ-រ៉េត, ដួង-ច័ន្ទសារាត និងគ្នាមួយចំនួនទៀត ។

*(៧) ពត៌មានមួយទៀតថា ប្រពន្ធដាប-ឈ្លួន (យាយក្ដុំស័ក្តិកណ្ដាញ់ក្រោម) បានមកទូលសម្ដេចឯភ្នំពេញ ។ នេះជាសេចក្ដីបញ្ជាក់របស់លោកស៊ិម-គិន នៅទីក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។*

មុននេះមួយខែ លោកសឺង-ង៉ុកថាញ់បានផ្ញើសំបុត្រសំងាត់មកលោកអ៊ីវ-យ៉ាង ឲ្យឆាប់នាំគ្នាចេញទៅក្រៅដែរ ព្រោះស្ថានការណ៍ស្រុកទេសនឹងមានការប្រែប្រួល តែពុំដឹងថាយ៉ាងណាទើបមានការថ្លោះធ្លោយបែបនេះ (7) ។ ពេលដែលសម្តេចបញ្ជាឲ្យនាយទាហានទៅចាប់លោកទាំងកណ្តាលអាធ្រាតនោះ លោកបានលាក់សំបុត្រសំងាត់នោះទាន់ពេល ។ លោកអ៊ីវ-យ៉ាងត្រូវជាប់ពន្ធនាគារអស់កំឡុង៧ឆ្នាំកន្លះ, លោកគាំ-វ៉េតអស់បីឆ្នាំ ដោយមានខ្សែទាក់ទងជាមួយពួកស្តេច, លោកដួង-ច័ន្ទសារាត៥ឆ្នាំ ។ ឯលោកហង្ស-ធុនហាក់បានរួចខ្លួនដោយសារមានសគុណក្នុងសិល្បៈល្ខោនជាមួយព្រះមហាក្សត្រីយានី, លោកប៉េង-គិត រួចខ្លួនដោយសារចេះតម្លើងប៉ុស្តិ៍វិទ្យុ និងលោកអៀរ-ស៊ីចូវក៏បានរួចខ្លួនដែរ ប្រហែលដោយមានសគុណជាមួយនឹងហ្លួងសុរាម្រិត ? ។ អ្នកខ្លះទៀតត្រូវគេសម្លាប់ចោលបណ្តោយដូចជាលោកសាំង-សាវ៉ាត ( សេក-សំអៀតបានសារភាពប្រាប់លោកឡឹក-សំអឿនឆ្នាំ ១៩៦៩ នៅព្រំដែនថៃកាលពួកខ្មែរសេរីធ្វើជាមកសុំចុះចូលនឹងសម្តេចសីហនុ ) និងអ្នកអតីតឥស្សរៈរួមខ្មែរបំរើជាតិទាំងអស់ម្ភៃនាក់ ( សូមអានប្រវត្តិកៅ-តក់ក្នុងលេខមុនកន្លងមក ) ។

សូមបញ្ជាក់ដែរថា សម-សារីដែលប្រែជាប្រឆាំងនឹងសម្តេចសីហនុ ហើយទៅចូលដៃជាមួយដាប-ឈួន ហើយរត់រួចខ្លួនទៅចូលដៃជាមួយលោកសឺង-ង៉ុកថាញ់ទៀត គឺដោយសារតែរឿងផ្ទាល់ខ្លួនស្មោះ ។ ដោយសារសម-សារីធ្លាប់មានសរគុណជាទីប្រឹក្សាផ្ទាល់របស់សម្តេចក្នុងការទាមទារឯករាជ្យ មួយទៀតសម-សារីបានជួយសម្តេចកំចាត់ពួកប្រជាធិបតេយ្យ (៩) សម-សារីបានត្រូវចាត់តាំងជាអគ្គរាជទូតប្រចាំប្រទេសអង់គ្លេស ។ ពេលរត់ទៅស្រុកយួនខាងត្បូងនោះ លោកសឺង-ង៉ុកថាញ់មិនចង់ទទួលទេ ព្រោះធ្លាប់ស្គាល់ចរិតបុគ្គលនេះច្បាស់ណាស់ តែដោយសមសារីជាអ្នកប្រឆាំងនឹងសម្តេចដែរ នោះទើបលោកព្រមទទួលឲ្យរួមជាមួយលោក តែឲ្យទៅកាន់កាប់ជាមួយកងទ័ពខ្មែរសេរីនៅប្រទេសថៃ ។ តាមសំដីលោកឡឹក-សំអឿនថា ៖ សម-សារីបានលួចសរសេរសំបុត្រសុំចូលមករួបរួមជាមួយសម្តេចវិញ ដោយឲ្យអ្នកបើកបរឡានជាតិថៃយកទៅដាក់ប៉ុស្តិ៍ តែគេមិនផ្ញើក៏យកប្រគល់ឲ្យអាមេរិកាំង ។ សំបុត្រដែលសម-សារីសរសេរមកសម្តេចមានចំនួនបីហិបស្បែក ( តាមពាក្យលោកឡឹក-សំអឿន ) សេអ៊ីអាយល់ថា សម-សារីមានចិត្តមិនត្រង់ អាចរត់ទៅចូលជាមួយសម្តេចវិញ ទើបថៃក៏នាំសម-សារីទៅជាយដែនលាវ ថាមកមើលទីតាំងថ្មី រួចក៏សម្លាប់សម-សារីចោលនៅទីនោះទៅ (១០) ។

ការមិនព្រមទទួលស្គាល់បូរណភាពទឹកដីខ្មែរដោយប្រទេសអង់គ្លេស ជាពិសេ

*(៩) ក្នុងពិធីជប់លៀង សម-សារីបានទះកំភ្លៀងប្រពន្ធចុង (បវរកញ្ញាខ្មែរសម័យនោះ) ហើយនិយាយប្រាប់អ្នកសារព័ត៌មានថា ការវាយស្រីបំរើដែលធ្វើការមិនសមរម្យ ជាការធម្មតារបស់ខ្មែរទូទៅ ។ អ្នកសារព័ត៌មានបានវាយទូរលេខមកសួរសម្តេចៗក៏កោះហៅសម-សារី មកប្រទេសខ្មែរវិញ រួចហូតងាររទូត ។ សម-សារីខឹងក៏បង្កើតសារព័ត៌មានសរសេរដៀមដាមឲ្យសម្តេច ។ ក្រោយមកចូលរួមជាមួយដាប-ឈួន ប្រុងធ្វើរដ្ឋប្រហាររំលំសម្តេចក្នុងចុងឆ្នាំ១៩៥៨ ហើយរត់ចូលនឹងសឺង-ង៉ុកថាញ់ ។*

*(១០) តាមសេចក្តីឲ្យការណ៍របស់លោកស៊ិម-គិន រស់នៅទីក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។*

សសហាររដ្ឋអាមេរិក បូករួមនឹងគំរោងរដ្ឋប្រហារមិនសំរេចនេះ រឹតតែធ្វើឲ្យសម្ដេចយល់ថា ប្លុកលោកសេរីជាគ្រោះថ្នាក់ដល់ប្រទេសកម្ពុជា ( តាមពិតគ្រោះថ្នាក់ចំពោះព្រះអង្គផ្ទាល់ទៅវិញទេ ) ។ សម្ដេចក៏ងាកទៅរកចាប់ដៃជាមួយប្លុកកុម្មុយនិស្ដរឹតតែជិតដិតទៀត ជាពិសេសជាមួយប្រទេសចិនប្រជាមានិត្ ដែលបានសន្យានឹងសម្ដេចថា នឹងគោរពទទួលស្គាល់បូរណភាពទឹកដីខ្មែរ ។

ចិនចាប់ផ្ដើមផ្ដល់ជំនួយសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា មានការសង់ផ្លូវរទេះភ្លើងពីភ្នំពេញទៅកំពង់សោម ក្រុងព្រះសីហនុ, រោងចក្រតម្បាញនៅកំពង់ចាមជាដើម ។ រាល់ពេលដែលសម្ដេចយាងទៅសម្ពោធសមិទ្ធិផលនានាឯខេត្តក្រៅ សម្ដេចតែងតែអួតសរសើរប្រាប់ប្រជារាស្ត្រខ្មែរថា ជំនួយរបស់ចិនជាជំនួយគ្មានចំណង មិនដូចជាជំនួយចក្រពត្តិអាមេរិកាំងទេ ។ នេះហើយជាល្បិចទាក់យកសីហនុរបស់ប្លុកកុម្មុយនិស្ដដោយវិធីមិនចេញមុខ ដោយវិធីធ្វើជាមិត្តចូលឲ្យបានជិតដើម្បីផ្ដួលនិងទាញសីហនុឲ្យនាំស្រុកខ្មែរចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនដែរ ។

❑ ❑

❑

# ការដឹកអង្ករ ថ្នាំពេទ្យ សាស្ត្រាវុធ
# នៅឲ្យកងទ័ពវៀតកុង

មេរៀនប្រវត្តិសាស្ត្រសម័យបាក់បែកបន្ទាយលង្វែកមិនគ្រប់គ្រាន់ជាមេរៀនឲ្យមេដឹកនាំខ្មែរ យកជាមេរៀនដឹកនាំស្រុកសោះ ។ ព្រះសត្ថាដែលបានបញ្ជូនព្រះមហាឧបរាជស្រីសុរិយោពណ៌ ឲ្យលើកកងទ័ពខ្មែរទៅជួយប្រទេសសៀម ដែលទ័ពភូមាកំពុងហ៊ុំព័ទ្ធទីក្រុងថៃនោះ បានធ្វើឲ្យថៃសងគុណខ្មែរវិញ ដោយវាយកំទេចយកនគរខ្មែរដាក់ជាចំណុះ, បន្ទាយលង្វែកត្រូវបាក់បែកក្នុងឆ្នាំ១៥៩៣ (១១) ។ ការដែលខ្មែរបានបញ្ជូនទ័ពពីរម៉ឺនទៅបង្ក្រាបពួកតៃស៊ឺងឲ្យស្តេចយួន ( កាលនោះស្តេចយួនរត់មកពួនក្នុងខេត្តខ្មែរក្រោម ហើយសុំជំនួយទ័ពពីស្តេចខ្មែរ ) រហូតទ្រឿងមិញយ៉ាងយកស្រុកខ្មែរទាំងមូល និងអស់ដីកម្ពុជាក្រោម ក៏នៅតែមិនមែនជាមេរៀនសំរាប់មេខ្មែរដែរ ។

ចាប់ពីឆ្នាំ១៩៦០ម្ល៉េះ ដែលសីហនុលូកដៃទៅជួយយួនវៀតកុង-វៀតណាមខាងជើង ឲ្យស្ថាបនាផ្លូវលំចាក់គ្រួសក្រហម បន្តភ្ជាប់ផ្លូវលំហូ-ជីមិញ ពីសេប៉ូនកាត់មកស្ទឹងត្រែង រតនគិរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កាត់តាមឧដុង្គ ចាក់ទៅផែកំពង់សោម ។ ផ្លូវលេខ១៩នេះស្ងាត់ណាស់ គេប្រើប្រាស់ផ្លូវនេះ ក្នុងការដឹកសម្ភារៈសឹកឆ្លងកាត់ស្រុកខ្មែរ ទៅផ្តល់ឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើង នៅឯមេមត់ ជប់ ក្រែក ស្នួល ។ ផ្លូវនេះស្ថាបនាដោយកងយោពលខេមរភូមិន្ទ តាមព្រះរាជបញ្ជារបស់សម្តេចសីហនុ (១២) ។

ដើម្បីរាវរកខ្សែនាំអង្ករទៅឲ្យទ័ពវៀតកុង ទូតចិនប្រជាមានិតុធ្វើជាសុំទិញឈើខ្មែរនាំទៅស្រុកចិនក្នុងឆ្នាំ១៩៦០ ចំនួនមួយម៉ឺនបួនពាន់ម៉ែត្រគីប ។ កាលនោះមានចិនកើតនៅស្រុកខ្មែរម្នាក់ឈ្មោះ គួច-អាន (១៣) នៅក្រចេះ ប្រកបរបរធ្វើដង្ហៅឈើហ៊ុប មានយីហោថា « ក្រុមហ៊ុនមហាសាគរ » បានធានារ៉ាប់រងឈើចំនួនមួយម៉ឺនម៉ែត្រគីប ។ ឯបួនម៉ឺនម៉ែត្រគីបទៀតបានផ្តល់ដោយឈ្មួញចំរុះមួយក្រុម ដែលក្នុងចំណោមនោះមានលោក ស៊ាម-ហួត ម្នាក់ផង ។ ទូតចិនបានបញ្ជូនរូបិយប័ណ្ណចូលទៅក្នុងធនាគារខ្មែរ ឲ្យឈ្មួញទាំងនេះទៅបើកជាប្រាក់រៀល ។ ចិនទិញឈើខ្មែរតែម្តងនេះគត់ ហើយគេបានទាក់ទាញឈ្មួញ គួច-អាននៅពេលនោះ ឲ្យទទួលដឹក

*(១១) សូមអានឯកសារមហាបុរសខ្មែរ របស់លោកអេង-សុត ចាប់ពីផែនដីព្រះសត្ថាទៅ ។*
*(១២) តាមសេចក្តីបញ្ជាក់របស់លោកប៉ោ-ថន អតីតវរៈសេនីយឯកក្នុងទីអគ្គសេនាធិការកងទ័ពខ្មែរ ។*
*(១៣) គួច-អានធ្លាប់ទៅរៀនបន្តនៅប៉េកាំងទៀត ក្រោយដែលបានរៀនចប់សាលាចិននៅក្នុងក្រុងភ្នំពេញ ។ គេប្រកបរបរធ្វើដង្ហៅឈើហ៊ុបនៅក្រចេះបន្តពីឪពុកគេមក ។ តាមសេចក្តីបញ្ជាក់របស់លោក ស៊ាម-ហួត ថា ៖ ក្នុងការដឹកអង្ករ ថ្នាំពេទ្យ ទៅឲ្យទ័ពវៀតកុងនេះ គួច-អានបានចំណេញបក់ក្តោង ហើយក្លាយជាអ្នកមានម្នាក់នៅស្រុកខ្មែរសឹងស្មើតាន់ប៉ា ។ ក្រោយមក គួច-អាន បានទិញកប៉ាល់ជំនួញចំនួនដប់នៅហុងកុង ។ ប្រាក់ចំណេញដែលបានមកក្នុងការដឹកអង្ករនេះ គួច-អានលៃចែកទៅអ្នកម្នាងម៉ូនីច និងអ៊ុំ-ម៉ាណូរិនផងដែរ ទើបវាមានលិខិតអនុញ្ញាតពិសេសនោះ ។*

អង្ករ ទៅផ្ដល់ឲ្យទ័ពវៀតកុង-វៀតណាមខាងជើងនៅជប់-មេមត់ ។ ម្ដងនេះ គួច-
អានបានសុំឲ្យស្ថានទូតចិនក្រហម បញ្ជូនរូបិយវត្ថុទៅធនាគារហុងកុងវិញ ដែលគេ
បានចំណេញមួយជាពីរជាបីតាមតម្លៃផ្សារងងឹត ។ ក្នុងការដឹកអង្ករនេះ គេមានសំបុ
ត្រអនុញ្ញាតពិសេសពីចំការមន ដែលគ្មាននរណាហ៊ានឆែកឆេឬឃាត់បានឡើយ ។
យប់មួយក្នុងឆ្នាំ១៩៦៥ ឪពុកខ្ញុំដែលត្រូវវេនទទួលខុសត្រូវជានាយល្បាត បានបំរុង
ឆែកឆេឡានដឹកជាងម្ភៃកាំមីញ៉ុង តែដល់គេហុចលិខិតអនុញ្ញាតដឹកនាំពិសេសនោះ
មក ឪពុកខ្ញុំក៏មិនហ៊ានប៉ះពាល់ (១៩) ។

ក្បួនឡានអង្ករចេញតែពេលយប់ប៉ុណ្ណោះ ដើម្បីលាក់កុំឲ្យពួកបរទេសដឹង ។
បន្ទាប់ពីឈ្មួញ គួច-អាន មាននាយទាហានខ្លះ និងព្រះរាជវង្សខ្លះ ដែលទៅរំអុកសុំ
សម្ដេចឪ សុំនាំអង្ករទៅលក់ផង ព្រោះខ្លួនក្រណាស់ដូចជាករណីម្ចាស់ប៉ាំងជាដើម

សម្ដេចក៏ទ្រង់អនុញ្ញាតឲ្យទៅ (8) ។ បន្តិចមកក៏ផ្សើលដល់ប្រជាជននាំគ្នាឱបអង្ករ
ថ្នាំ ពេទ្យតាមកង់ម៉ូតូ នាំយកទៅលក់ឲ្យពួកវៀតកុងឈ្មូរឆរដែរ ។ ប៉ូលីស គិញ គយ

*(១៩) លុះព្រឹកឡើង ឪពុកខ្ញុំបាននិយាយប្រាប់កូនៗទាំងអស់នៅពេលបាយជុំគ្នាថា ៖ មើលទៅ
ស្រុកខ្មែរច្បាស់ជាមិនបានសុខទេ ព្រោះខ្មែរដឹកអង្ករ ថ្នាំពេទ្យ ទៅផ្ដល់ឲ្យទ័ពវៀតកុង ។ លោកឪពុ
កខ្ញុំបានបន្តទៀតថា ៖ ពេលខ្មែរបានឯករាជ្យឆ្នាំ១៩៥៤នោះ ចៅហ្វាយបារាំងរបស់គាត់បានប្រាប់
ថា ឲ្យលាជាតិខ្មែរចូលជាតិបារាំង ហើយតាមទៅធ្វើការនៅស្រុកលាវមួយរយៈ ទើបទៅនៅឯស្រុក
បារាំងតែម្ដង ។ ឪពុកខ្ញុំយល់ព្រមតែនៅមុខចៅហ្វាយគាត់ ព្រោះតាមសំដីថា ចៅហ្វាយនេះស្រឡា
ញ់ឪពុកខ្ញុំណាស់ ។ ឪពុកខ្ញុំលួចធ្វើពាក្យចូលជាទាហានខ្មែរវិញ ។ ដល់ខាងខ្មែរធ្វើលិខិតទៅសុំ
យកឪពុកខ្ញុំទើបចៅហ្វាយគាត់ដឹង ។ ចៅហ្វាយគាត់ខឹងជាខ្លាំង ហើយកាក់ឪពុកខ្ញុំទុកចំនួនប្រាំមួ
យខែទៀត ឲ្យជួយធ្វើការជំរះបញ្ជីផ្សេងៗ មុននឹងប្រគល់កិច្ចការមកឲ្យខាងខ្មែរ ។ លោកឪពុកខ្ញុំ
មានប្រសាសន៍ថែមទៀតថា ៖ ពេលដែលចៅហ្វាយគាត់រៀបចេញទៅនោះ បានហៅឪពុកខ្ញុំទៅ
ជួបនិយាយគ្នាតែពីរនាក់ម្ដងទៀត ដើម្បីឲ្យព្រមតាមការបបួលពីមុននោះ ។ ឪពុកខ្ញុំបានតបទៅវិញ
ថា គាត់មិនអាចទៅចោលស្រុកបានឡើយ ហើយឥឡូវនេះទៀត ស្រុកខ្មែរក៏បានឯករាជ្យពេញ
លេញហើយ ។ ចៅហ្វាយគាត់បានប្រាប់ទៀតថា ៖ ស៊ា ( ឈ្មោះឪពុកខ្ញុំ ) ឯងចាំសំដីខ្ញុំណា ព្រោះ
ខ្ញុំស្រឡាញ់ស៊ាឯង ! ស្រុកខ្មែរនឹងមិនបានសុខយូរទេ ព្រោះខ្មែរមិនចេះធ្វើចៅហ្វាយខ្លួនឯងទេ
ចេះធ្វើត្រឹមតែខ្ញុំគេ ស្រុកខ្មែរនឹងត្រូវមានសង្គ្រាមជាមិនខាន យ៉ាងយូរដប់ឆ្នាំទៅមុខទៀត ។ បារាំង
ស្គាល់ខ្មែរច្បាស់ណាស់ ។ ឪពុកខ្ញុំមានសេចក្ដីអន់ចិត្តនឹងចៅហ្វាយគាត់ដែលមាក់ងាយខ្មែរ តែ
ក្រោយមកទៀតក្នុងរបបសាធារណរដ្ឋ ទើបគាត់នឹកស្ដាយនូវពាក្យសំដីចៅហ្វាយគាត់ជាខ្លាំង ថា
ចៅហ្វាយគាត់និយាយត្រូវដូចមើលឃើញ ទើបលោកទូន្មានឲ្យកូនទាំងអស់ខិតខំរៀនដើម្បីចេញ
ទៅស្រុកក្រៅ ។ ក្នុងឆ្នាំ១៩៧១ ប្អូនប្រុសខ្ញុំម្នាក់បានចេញទៅស្រុកបារាំង ដោយសោហ៊ុយបងប្អូន
មាមីងជួយ ( ហ៊ិន-ស៊ីហ៊ាន ) និងម្នាក់ទៀតចេញនៅឆ្នាំ១៩៧២ ( ហ៊ិន-ស៊ីថុន ) ។ ក្នុងឆ្នាំ១៩៧២
នោះទៀត លោកទូន្មានឲ្យខ្ញុំឈប់ធ្វើគ្រូ ឲ្យទៅស្រុកបារាំងតាមប្អូនទាំងពីរទៀត ។ តែខ្ញុំឆ្លើយថា បើ
ទៅទាំងអស់គ្នា នឹងគ្មាននរណាមើលថែទាំឪពុកម្ដាយដែលកាន់តែចាស់ហើយ ( សូមជំរាបថាកា-
លនោះ ខ្ញុំនៅមិនទាន់មានគ្រួសារនៅឡើយ ហើយចេញមកជាសាស្ត្រាចារ្យ មសបភ មកបង្រៀន
នៅវិទ្យាល័យអ៊ាប-ឃុត និងនេត-យ៉ង់ ក្នុងឆ្នាំ១៩៦៨ ចំពេលដែលមានការបះបោរនៅសំឡូត
ដោយសារតែអាជ្ញាធរខេត្តនាំគ្នាពុករលួយ ជិះជាន់ ប្លន់យកដីចំការរបស់រាស្ត្រ ដែលគ្មានប្លង់កាន់
កាប់ដី ហើយនាំគ្នាទាំងចៅហ្វាយខេត្ត អ្នកសាលាស្រុក នាយទុនខ្មែរ-ចិន នាំគ្នាធ្វើប្លង់កម្មសិទ្ធិដី
សំឡូត ) ។ ហេតុដែលខ្ញុំបោះបង់ការរៀនសូត្រសិន ព្រោះឪពុកខ្ញុំចូលរ៉េយីរ៉ែត្រែត, កូនៗកំពុងរៀន
ឯខ្ញុំជាបងគេបង្អស់ក្នុងចំណោមប្អូនចំនួន៧នាក់ ហើយគ្រួសារខ្ញុំជាគ្រួសារមធ្យមផង មិនអាចទប់
ទល់បានឡើយ ។*

ចាប់តែវាស្គុតូចតាចទេ ឯឡានកាំមីញ៉ងរាប់សិប ផ្ទុកអង្ករថ្នាំពេទ្យពេញៗនោះមើ-លមិនឃើញឡើយ ។ តាមសំដីមាស-សុផាត នៅក្រូចឆ្មារកំពង់ចាម សព្វថ្ងៃរស់នៅក្រុងតាខ្មៅ រដ្ឋវ៉ាស៊ិនតោនបានឲ្យការណ៍ថា ៖ ក្នុងឆ្នាំ១៩៦៥ បានឱ្យប៉ុលប្រាក់គេនាំអង្ករ ថ្នាំពេទ្យ និងវត្ថុចាំបាច់ខ្លះទៀត ទៅលក់ឲ្យវៀតកុងឯជប់-មេមត់ ហើយត្រូវពួកកូនតិញ គយ ប៉ូលីសចាប់យកអស់ ស៊ីវិញមិនបានទាល់តែសោះ ។ សុផាតមានសេចក្តីក្តៅក្រហាយណាស់ ដោយឃើញអយុត្តិធម៌ពេក ឡានធំៗដឹកអង្ករ ថ្នាំពេទ្យពេញណែន គេមិនរវល់ទេ ហើយអនុញ្ញាតឲ្យចេញយ៉ាងធូររហុយ ។ ដោយមួយគ្មានប្រាក់សងជំពាក់គេផង ណាមួយទៀតឈឺចិត្តនឹងប៉ូលីស តិញ គយផង សុផាតក៏រត់ទៅខាងយួនវៀតកុងបណ្តោយ ។ ពេលចូលទៅដល់ភ្លាម ពួកវៀតកុងបានធ្វើប័ណ្ណសំគាល់ខ្លួន ជាគណកម្មការពិសេសខាងផ្នែកទាក់ទងឲ្យ ខាងស្តាំគឺរូបសម្តេច ឯខាងឆ្វេងគឺរូបសាមីខ្លួនសុផាត ។ គឺប័ណ្ណនេះហើយ ដែលបានជួយសុផាតឲ្យរួចខ្លួន ពេលដែលខ្មែរក្រហមឈ្នះ ហើយជម្លៀសចេញពីក្រុងប៉ៃលិន ។ ដោយកាលនៅប៉ៃលិនជាប់កំណែនជាកងកុម្មង់ដូ សុផាតមានសល់គ្រាប់កាំភ្លើងខ្លះក្នុងបាតកាបូបដែលយួរមកតាមផ្លូវ ។ ពួកខ្មែរក្រហមឆែកឃើញគ្រាប់នោះ តែសុផាតចេះនឹកឃើញហុចប័ណ្ណនោះទៅ ទើបខ្មែរក្រហមដែលឆែកនៅតំបន់ត្រែងអនុញ្ញាតឲ្យសុផាតចេញមកដោយស្រួល ព្រោះវាយល់ថាជាគ្នាវា ។

មាស-សុផាតបាននិយាយថា ៖ ពេលថ្ងៃមិនសូវឃើញទាហានវៀតកុងទេ តែដល់វេលាយប់ មិនដឹងវាចេញមកពីណាទេ ខ្មៅមីរដូចហ្វូងស្រមោចអញ្ចឹង ! អង្ករមួយឡានចំនួនប៉ែតសិបបាវ ពួកវាជញ្ជូនតែដប់នាទីអស់រលីង ។ តាមសុផាតថា មិនមែនមានតែអង្ករទេ មានទាំងថ្នាំពេទ្យគ្រប់មុខ ជាពិសេសប៉េនីស៊ីលីនរាប់ម៉ឺនដប មានទាំងកាំភ្លើងតូចធំ និងគ្រាប់គ្រប់មុខផង ( មាស-សុផាតបានចាកចេញពីតំបន់វៀតកុងកាន់កាប់មកវិញនៅឆ្នាំ១៩៦៨ រួចមកជីកត្បូងនៅបរប៉ៃលិន ) ។ ពួកវៀតកុងបានទាំងយកស្រីយួនស្អាតៗមកឲ្យសុផាតរើសយកតាមចិត្តចង់ផង ។ សុផាតបាននិយាយទៀតថា ពុំដឹងជាពួកវៀតកុងបានលុយមកពីណាសុទ្ធតែក្រដាស់ប្រាំរយរៀលថ្មីៗថែស ទាំងហិបៗយកមកទិញឥវ៉ាន់ខ្មែរ ( យួនបោះប្រាក់ក្លែងក្លាយ ) ។

នៅតាមទីផ្សារឬភូមិតាមជាយដែនខ្មែរយួន ពួកទាហានវៀតកុងអាចទិញវត្ថុដែលពួកវាត្រូវការពីឈ្មួញ (ឬប្រជាជន) ខ្មែរដែលនាំយកមកលក់ (9) ។ សម្ភារៈដែលទិញឬដឹកឆ្លងកាត់ស្រុកខ្មែរនិងមូលដ្ឋាននៅតាមជាយដែន មានសារៈសំខាន់ណាស់ចំពោះយួនកុម្មុយនិស្តក្នុងការខិតខំតស៊ូ (ជាមួយអាមេរិកាំងនិងយួនខាងត្បូង) (10) ។ ការដឹកអង្ករ ថ្នាំពេទ្យ ខោអាវ គ្រឿងសាស្ត្រាវុធ សម្ភារៈសឹកសព្វបែបយ៉ាងយកទៅផ្តល់ឲ្យពួកវៀតកុង បានប្រព្រឹត្តយ៉ាងខ្លាំងនិងចេញមុខ បន្ទាប់ពីការវាយស្ថានទូត អាមេរិកាំងឆ្នាំ១៩៦៣ ដោយសីហនុឲ្យទាហានហ្លួងស្លៀកពាក់ស៊ីវិល ទៅកេណ្ឌសិស្សពីវិទ្យាល័យនានាក្នុងក្រុងភ្នំពេញ ឲ្យឃឹម-ទីតធ្វើជាមេដឹកនាំ (ស្មេរខ្ញុំជាសិស្សថ្នាក់ទី៨វិទ្យាល័យស៊ីសុវត្ថិ បានតាមទៅនឹងគេដែរ តែមិនបានចូលហ៊ុនទេ), ជាពិសេសក្រោយផ្តាច់ទូតជាមួយសហរដ្ឋឆ្នាំ១៩៦៥ ។

ក្នុងឆ្នាំ១៩៦៦-៦៧ សីហនុបានអនុញ្ញាតឲ្យអ្នកបច្ចេកទេសរុស្ស៊ី មកសង់រោង

ចក្រយ៉ាងធំមួយ ធ្វើគ្រាប់កាំភ្លើងតូចធំ ធ្វើមីន គ្រាប់បែកដៃ នៅក្នុងព្រៃស្ទឹងច្រាល អនុខេត្តកំពង់សីលា ។ គេធ្វើគ្រាប់កាំភ្លើងគ្រប់ធុន ជាពិសេសគ្រាប់កាំភ្លើង អាកាតែម្តង ។ គ្រាប់ធ្វើរួចគេដឹកទៅឲ្យទ័ពវៀតកុង ឯកងទ័ពខេមរភូមិន្ទមិនដែលបានគ្រាប់ពីរោងចក្រនេះទៅប្រើទាល់តែសោះ (១៥) ។ នៅក្នុងព្រៃភ្នំគិរីរម្យ សីហនុបានបញ្ជាឲ្យលោកស័ក្តិប្រាំព្រីង-ទុំ ទទួលមុខងារខាងកាត់រថយន្តហ្សេអិមសេ (GMC) កង់ដប់ ប្រើតែកង់បួនវិញដើម្បីឲ្យចំណោញសាំង រួចហើយនាំយកទៅប្រគល់ឲ្យទ័ពវៀតកុងប្រើប្រាស់សំរាប់ដឹកសម្ភារៈសឹកក្នុងព្រៃមេមត់ ជប់ ក្រែក ស្នួល រតនគីរី (១៦) ។

ក្នុងឆ្នាំ១៩៦៧ កប៉ាល់ចិនចំណុះ៨៥,០០០តោន បានដឹកសម្ភារៈសឹកមកចតនៅកំពង់ផែក្រុងព្រះសីហនុ (កំពង់សោម) ។ សម្តេចបានបញ្ជាឲ្យស័ក្តិប្រាំគាត-ម៉ាន់ត្រួតមើលការខុសត្រូវ ក្នុងការជញ្ជូនសម្ភារៈសឹកចេញពីកប៉ាល់នោះ ។ មានកាំភ្លើងនិងគ្រាប់គ្រប់ធុន តាំងពីអាកា កាណុងមិនធាក់ថយ ( Canons sans recul ) ធ្វើនៅស្រុកចិន ។សម្តេចបញ្ជាឲ្យដកទាហានក្នុងមួយថ្ងៃចំនួន១០០នាក់ ពីកងវរៈសេនាតូចនានា តាំងពីខេត្តកំពង់ស្ពឺ, កំពត, កំពង់សោម ឲ្យទៅជញ្ជូនគ្រឿងសម្ភារៈសឹកអស់ទាំងនោះចេញពីកប៉ាល់ ។ ការជញ្ជូនចេញក្នុងមួយអាទិត្យ បានធ្វើឲ្យកប៉ាល់នោះងើបឡើងបានមួយហត្ថប៉ុណ្ណោះ ។ ការជញ្ជូនបានប្រព្រឹត្តទៅជាងបីខែ ទើបយកឡាំងសម្ភារៈសឹកទាំងនោះអស់ ។ សម្តេចបានចាត់ឲ្យលោកស័ក្តិប្រាំសឺន-ចូវ (ប្អូនលោកសឺន-សាន) ទទួលខុសត្រូវខាងក្បួនរថយន្តដឹកសម្ភារៈចំបាំងទាំងនោះ ។ ឪពុកមាខ្ញុំ (ខាងម្តាយខ្ញុំ) ល្មុត-សំអុន អតីតស័ក្តិប្រាំនៅកោះកញ្ជរក៏ជាប់កំណែនការពារក្បួនដឹកនាំអាវុធដែរ (សព្វថ្ងៃរស់នៅរដ្ឋ Maryland ) ។ ក្បួនដឹកចេញដំណើរតែវេលាយប់ ពេលមកដល់អង្គស្នួល ក្បួនរថយន្តត្រូវបត់ចូលតាមផ្លូវលំចាក់ក្រួសតំបន់បាត់ដឹង-ឧដុង្គ នាំយកទៅទុកនៅក្នុងបន្ទាយលង្វែក (ខេត្តកំពង់ឆ្នាំង) ។ នៅទីនោះសម្តេចបានចាត់ឲ្យស័ក្តិប្រាំដែលទ្រង់ទុកចិត្តឈ្មោះ ផេង-ផាន់អ៊ី ធ្វើជាចាងហ្វាងត្រួតពិនិត្យអាវុធចិនទាំងនោះ ។ លោកផេង-ផាន់អ៊ីដោយមានអ្នកបច្ចេកទេសចិនចំនួន១០នាក់ (ម្នាក់ជាស័ក្តិប្រាំចិនផង) បានតម្លើងកាំភ្លើងធំទាំងអស់នោះ ។ លុះតម្លើងរួចអស់សព្វគ្រប់ហើយ សម្តេចចាត់ឲ្យវរៈសេនិយឯកប៉ោ-ថន ជាអ្នកទទួលខុសត្រូវក្នុងការដឹកអាវុធទាំងនោះ ទៅប្រគល់ឲ្យទ័ពវៀតកុងនៅជប់-មេមត់ (ខេត្តកំពង់ចាម) ។

ក្នុងខែមិនា១៩៦៨ សម្តេចទ្រង់យាងទៅជួបមេវៀតកុង ង្វៀង-វ៉ាន់ផាត់ នៅខេត្តកំពង់ចាម រួចហើយសម្តេចទ្រង់យាងទៅប្រារព្វពិធីច្រត់ព្រះនង្គ័លនៅទីរួមខេត្តស្វាយរៀង ។ នៅទីនោះ ទ្រង់បានវាយខ្សែលួសមកអគ្គសេនាធិការដ្ឋានកងទ័ពខេមរភូមិន្ទ ឲ្យរកឡានកាត់កាត់ (4X4) ចំនួន១៥០គ្រឿងឲ្យបានក្នុងមួយថ្ងៃ ។ លោកប៉ោ-ថនជាអ្នករកឡានតាមចំនួនដែលសម្តេចត្រូវការ ហើយនាំយកទៅដល់អ្នក

*(១៥) និង (១៦) តាមសេចក្តីឲ្យការណ៍របស់លោកប៉ោ-ថន អតីតវរសេនិយឯក ។*
*(១៧) តាមសេចក្តីឲ្យការណ៍របស់លោកមាស-សូផាត ក្រុងតាខ្មៅ និងលោកប៉ោ-ថន ។*

លឿង ដើម្បីដឹកថ្នាំពេទ្យទៅឲ្យពួកវៀតកុង-វៀតណាមខាងជើងនៅជប់-មេមត់ ( កំពង់ចាម) ។ ឡានិមួយៗផ្ទុកថ្នាំពេទ្យចំនួនម្ភៃបាវ ។ ថ្នាំមានគ្រប់មុខតាំងពីអាស្ពីរីនឡើងទៅ តែជាពិសេសគឺថ្នាំប៉េនីស៊ីលីនរាប់សែនដប ដែលបណ្តាញចារកិច្ចវៀតកុងក្រុងភ្នំពេញបានប្រមូលទិញពីហាហហ្វាម៉ាស៊ីនានាទៅគរទុកនៅឯអ្នកលឿង ។

ចាប់ពីឆ្នាំ១៩៦៥ ពេលដែលសហរដ្ឋសំរេចបើកយន្តហោះបេ-៥២ ទម្លាក់គ្រាប់បែកលើផ្លូវលំហូ-ជីមិញមក កងទ័ពវៀតណាមខាងជើងត្រូវគេដឹកតាមកប៉ាល់មកចុះនៅកំពង់ផែព្រះសីហនុ រួចដឹកតាមរថយន្តកាំមីញ៉ុងបឺទដំបូលជិត កាត់ស្រុកខ្មែរឡើងទៅជប់-មេមត់ ដើម្បីវាយវៀតណាមខាងត្បូង និងកងទ័ពអាមេរិកាំង (១៧) ។

តាមសំដីមាស-សូផាត ថាបានឃើញនាយទាហានវៀតកុងស្លៀកពាក់ស៊ីវិលមកដើរលេងស៊ីគុយទាវនៅទន្លេបឹទ (ក្រុងកំពង់ចាម) (១៩៦៨) រាល់ថ្ងៃ ។

អតីតប៉ូលីសខេត្តៗកណ្តាលម្នាក់ (សុំមិនឲ្យបញ្ចេញឈ្មោះ) សព្វថ្ងៃរស់នៅក្រុងតាខ្មៅបានឲ្យការណ៍ថា ៖ ខ្លួនគាត់ជាអ្នកទទួលបញ្ជាឲ្យទារលុយប្រចាំខែពីវៀតកុង និងបញ្ជាបីចៅហ្វាយខេត្ត (ដែលទទួលបញ្ជាបន្តមកពីម្ចាងម៉ូនិច) ឲ្យរាប់ចំនួនវៀតកុងដែលតាំងនៅលើទឹកដីខ្មែរ និងទារតម្លៃក្បាល២,០០០រៀលប្រចាំខែសំរាប់វៀ-តកុងម្នាក់ ។ ឯសៀវភៅ War in peace ក៏បានសរសេរដែរពីនិគមយួនម្នាក់ៗដែលចូលមករស់នៅតាមទូកតាមមាត់ទន្លេ ជាពិសេសតំបន់កំពង់ផ្សារតូច ត្រូវបង់ជូនម្ចាងម៉ូនិចចំនួនប្រាំរយរៀលជារៀងរាល់ខែ ។

ក្នុងសៀវភៅ «សង្គ្រាមនិងសេចក្តីសង្ឃឹម» ( War and Hope ) ត្រង់ទំព័រ៥៩ សម្តេចបានសរសេរថា ៖ ការធ្វើអ្វីៗសព្វបែបយ៉ាងដែលអាចធ្វើបានដើម្បីជួយអ្នកជិតខាង (យួនវៀតកុង) ដែលកំពុងត្រូវចក្រពត្តិកំហែងគំរាមនោះ គឺជាករណិយកិច្ចរបស់រាជាណាចក្រកម្ពុជា ដែលមិនត្រូវគេចវេះពីកាតព្វកិច្ចនេះឡើយ ។

( តើស្រុកខ្មែរជាកម្មសិទ្ធិដាច់មុខរបស់សីហនុឬ បានជាសីហនុយកអំពើក្បត់ជាតិទៅជួយហូ-ជីមិញនេះ ជាកាតព្វកិច្ច ( Obligation ) របស់ប្រទេសខ្មែរនិងរាស្ត្រខ្មែរទៅវិញ ? នៅទីកបង្ហើយយើងបានឃើញថា មេដឹកនាំយួនបានសងគុណសីហនុបែបយ៉ាងណានោះ, រហូតក្តាប់ស្ថានភាពប្រទេសខ្មែរទាំងមូលក្នុងកណ្តាប់ដៃវាទាំងស្រុង ដោយបន្តុបក្រុមអាយ៉ងហេង-សំរិន (អតីតអ្នករកស៊ីកាប់ជ្រូក) និងហ៊ុន-សែនអតីតសិស្សថ្នាក់ទី៨ទំនើប Classe de quatrième moderne វិទ្យាល័យព្រះសីហនុកំពង់ចាម ( <u>កកន</u> ៖ បើយោងតាមកាព្យ ដែលហ៊ុន-សែនបានសរសេរផ្តោះផ្តងខ្សែបខាយ ជាមួយអ្នកមេម៉ាយម្នាក់ យើងសង្កេតឃើញពាក្យខ្លះ សរសេរមិនត្រូវអក្ខរាវិរុទ្ធ និងពាក្យខ្លះជាពាក្យខ្មែរសម័យចាស់ ដូចជាពាក្យ «ហ្បើ» ជាដើម ។ យើងជឿថា ៖ បើហ៊ុន-សែន ជាសិស្សរៀននៅថ្នាក់ទី៨ទំនើបដូច្នេះ ពិតជាមិនសរសេរអក្សរ «ហ្បើ» នេះទៀតទេ ពីព្រោះសិស្សជំនាន់មុនហ៊ុន-សែន១០ទៅ១៥ឆ្នាំលែងសរសេរ«ហ្បើ» អស់ទៅហើយ... គេសរសេរ «ហើយ» ជាជំនួសវិញ ។ មានតែសិស្សរៀនសូត្រនៅតាមសាលាវត្តទេ ដែលនៅសរសេរ «ហ្បើ» ដូច្នេះ ។ កា-ព្យនេះបានត្រូវឱម-ឃិនទៀងទីប្រឹក្សាជំនិតរបស់ហ៊ុន-សែនអះអាងថា ជាកាព្យរបស់ចៅហ្វាយខ្លួនពិតប្រាកដមែន ) ។ ឲ្យទៅធ្វើជាតុក្កតាទូរបញ្ជា របស់មេដឹកនាំយួន

របហូត ( Toy remoted by Viet leader, Nguyen Co Thach ) គ្មានថ្ងៃណានឹងរើខ្លួនរួចសោះឡើយ ។ យួនប្លន់យកត្រីសមុទ្រ ត្រីទន្លេសាប (ចាប់ដោយសម្លាប់បំផ្លិចបំផ្លាញស្ទើរពោយអស់ត្រី), កាប់ព្រៃឈើខ្មែរដឹកជញ្ជូនទៅស្រុកយួន គាស់យកបូរាណវត្ថុពីប្រាសាទនានា បោះក្រដាស់ប្រាក់មកទិញស្រូវខ្មែរយ៉ាងថោក ដឹកយកទៅចិញ្ចឹមរាស្ត្រយួន និងនាំចេញទៅក្រៅប្រទេសក្រោមយីហោ Product of Vietnam ។ យួនដែលធ្លាប់ជាស្រុកខ្វះអង្ករស៊ី សព្វថ្ងៃបានក្លាយទៅជានាំអង្ករចេញជាប់លេខបីបន្ទាប់ពីសហរដ្ឋនិងប្រទេសថៃ ។

នៅទំព័រទី៦១ សម្តេចបានសរសេរពីនយោបាយខុសរបស់ទ្រង់ថា ៖ « ការសំរេចចិត្តរបស់ខ្ញុំក្នុងការជួយពួកគេ (វៀតកុង-វៀតណាមខាងជើង) ក្នុងកំឡុងឆ្នាំ១៩៦០នោះ ខ្ញុំសុំស្បថថា ខ្ញុំមិនបានទទួលប្រាក់ពីយួនទាល់តែសោះ ហើយសព្វថ្ងៃនេះទៀត ជាជនអធន... គ្រួសារខ្ញុំនិងខ្ញុំជនរស់រួចជីវិតដោយសារតែសេចក្តីសប្បុរសនិងការស្វាគមន៍ជាបងប្អូន ពីសំណាក់ប្រទេសចិនប្រជាមានិតុ ។ ខ្ញុំសូមស្បថថាលេសដែលខ្ញុំបានសំរេចចិត្តធ្វើសហការជាមួយវៀតណាមនោះ គឺខ្ញុំចង់ឲ្យយួនកុម្មុយនិស្តជំពាក់គុណកម្ពុជា, ក្នុងផ្លូវបែបនេះ យួនមិនអាចហ៊ាននឹងធ្វើអំពើអាក្រក់មកលើប្រទេសខ្មែរ ប្រជារាស្ត្រខ្មែរឡើយ ។ បើប្រសិនជាវាផ្ទុយពីការនេះទៅវិញនោះយួននឹងត្រូវបាត់បង់កិត្តិយសជាមិនខានឡើយ » ។ ( <u>កកន</u> ៖ សព្វថ្ងៃនេះ យើងឃើញយួនកាន់តែមានកិត្តិយស ហើយស្តេចសីហនុកាន់តែអាប់ឱនទៅៗ និងធ្លាក់ខ្លួនធ្វើជាទីងមោងឲ្យពួកអាយ៉ងយួនថែមទៀត ) ។

តើលេសប៉ុណ្ណេះអាចចាត់ទុកថាគ្រប់គ្រាន់ឬទេ ដែលសម្តេចសីហនុបានជួយខ្លាយួនឲ្យមានកម្លាំងខាំទំពារក្បាលខ្មែរ យកស្រុកខ្មែរនេះ ? សូមជួយពិចារណាផងចុះ ! ។ អ្នកម្នាងម៉ូនិច (រួមជាមួយបងឈ្មោះអ៊ុំ-ម៉ាណូរិន) បានយកឥទ្ធិពលជាប្រពន្ធប្រមុខរដ្ឋមករកស៊ី លក់ដីលក់ស្រុកឲ្យយួនហូ-ជីមិញ ។ យើងជាខ្មែរមិនជឿទាល់តែសោះថា សីហនុមិនបានដឹង ឮមិនបានចូលហ៊ុនក្នុងរឿងក្បត់ជាតិ ក្បត់រាស្ត្រខ្មែរនេះ ។

តើកាលយួនយកដីកម្ពុជាក្រោមនោះ យួនមានខូចបាត់បង់កិត្តិយសឬទេ ? តើសម្តេចមានវិប្បដិសារីឬទេ ដែលមិនបានធ្វើការតវ៉ាអ្វីសោះកាលសភាបារាំងសំរេចប្រគល់ដីកម្ពុជាក្រោមទៅ ក្នុងយប់ថ្ងៃទី២១ ឧសភា ១៩៤៩ និងការដែលទ្រង់បានរាំងយាត់មិនឲ្យលោកទ្រៀង-កាង ធ្វើការទាមទារកម្ពុជាក្រោមទៅតុលាការអន្តរជាតិ ? ឬមួយកាលនោះសីហនុជឿជាក់ថា យួននឹងទុកឲ្យទ្រង់សោយសុខលើកម្ពុជាមួយជីវិត ?

នៅវគ្គមុនសម្តេចបានសរសេរថា ៖ លោកលន់-នល់ជានាយករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលឆ្នាំ១៩៦៩ រហូតដល់ថ្ងៃប្រឆាំងធ្វើរដ្ឋប្រហារសីហនុថ្ងៃទី១៨មិនា១៩៧០ បានចាប់និងចែក (ឲ្យកងទាហានខ្មែរ) នូវសាស្ត្រាវុធគ្រប់ធុន, គ្រាប់កាំភ្លើង, សម្ភារៈសឹកចិន,រុស្ស៊ីនិងប្រទេសសង្គមនិយមដទៃទៀតដែលដែលបញ្ជូនទៅឲ្យកងទ័ពវៀតណាមខាងជើង-វៀតកុងតាមកំពង់ផែក្រុងសីហនុ ។ លោកលន់-នល់ធ្វើតាមតែបញ្ជាសីហនុ ក្នុងការដឹកអាវុធទាំងអស់នោះប៉ុណ្ណោះ ( ទៅឲ្យវៀតកុង ) ។

ក្រោយពេលសម្ដេចឲ្យទាហានហ្លួងទៅវាយស្ថានទូតអាមេរិកាំងក្នុងឆ្នាំ១៩៦៣ ចិនប្រជាមានិតុបានឲ្យឡានកាមីញ៉ុងចំនួន៦០គ្រឿង ទុកនៅក្នុងចំការម៉ៃនសំរាប់ដឹកសម្ភារៈសឹកផ្ដល់ឲ្យទ័ពយួន ។ រថយន្តទាំងនោះសរសេរប៉ាយថា កងយោធពលខេមរភូមិន្ទ ( FARK ) ។

ក្នុងឆ្នាំ១៩៦៥ តាមការបញ្ជាក់របស់អ្នកបររថយន្ត ដែលមិនចង់បញ្ចេញឈ្មោះសព្វថ្ងៃនៅរដ្ឋ Oregon ថា ៖ ការដឹកសាស្ត្រាវុធបានប្រព្រឹត្តយ៉ាងខ្លាំងក្លាណាស់ក្នុងឆ្នាំនោះ ឡានដែលគាត់បើកនិងឡានដទៃទៀត មានបិទផ្លាកធំៗថា « រ.រ.វ. = រថយន្តរាជវាំង » ហើយដើម្បីកុំឲ្យយន្តហោះអាមេរិកាំងមើលពីលើមកឃើញ ឡានដាក់ផ្លាក រ.រ.វ. និមួយៗ គេ-តចង្កៀងលយទៅមុខក្បាលឡាន ឲ្យចាំងចុះទៅដីវិញចៀសវាងកុំឲ្យពន្លឺសាចជះទៅលើឡើយ ។

ក្នុងឆ្នាំ១៩៦៩ សម្ដេចសីហនុបានឲ្យធ្វើកន្លែងស្ដុកមួយដាក់គ្រាប់កាំភ្លើង និងថ្នាំពេទ្យនៅតាមដងស្ទឹងសេសាន រតនគិរី សំរាប់ផ្ដល់ឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ។ សម្ភារៈអស់ទាំងនោះ គឺដឹកតាមយន្តហោះដឹកទៅស្ដុកទុកនៅទីនោះ។

ជំនួយដែលសម្ដេចបានជួយខ្លាយួនមានច្រើនណាស់ ទាំងផ្លូវអន្តរជាតិ និងសម្ភារៈសឹក និងកងទ័ពយួនខាងជើងដឹកឆ្លងកាត់ស្រុកខ្មែរ ពីកំពង់ផែក្រុងព្រះសីហនុ កំពង់សោម ឡើងទៅគ្រប់មូលដ្ឋានទ័ពយួននៅតាមបណ្ដោយព្រំដែនខ្មែរ ។ មានតែសម្ដេចមួយអង្គគត់ដែលអាចដឹងអស់ និងឆ្លើយប្រាប់យើងថា តើសម្ដេចបានជួយយួនច្រើនប៉ុណ្ណា ? តើសីហនុ, អ្នកម្នាងម៉ូនីច, អ៊ុំ-ម៉ាណូរិនបានទទួលលុយយួនប៉ុណ្ណា ? មេដឹកនាំយួនបានសន្យានឹងសីហនុយ៉ាងណាខ្លះ បានជាមេខ្មែរនេះគ្មានការពិចារណាបន្តិចសោះ ?

❑ ❑

❑

# មូលដ្ឋានសឹកនិងអគ្គសេនាធិការដ្ឋាន វៀតកុងលើដែនដីខ្មែរ

គឺតួអង្គសម្តេចសីហនុតែម្តង ដែលបានយល់ព្រមឲ្យទ័ពវៀតកុងមកតាំងមូលដ្ឋានសឹកនៅលើដីខ្មែរ តាមជាយដែនខ្មែរ-វៀតណាមខាងត្បូង ដោយមិនជាអ្នកជួយថែចូវឲ្យ ។ សម្តេចសីហនុបានជួយយួនវៀតកុង-វៀតណាមខាងជើង ដោយគ្រប់មធ្យោបាយក្នុងចំបាំងជាមួយអាមេរិកាំង (12) ។




មូលដ្ឋានទ័ពយួនវៀតកុង-វៀតណាមខាងជើង

(សម្តេចសីហនុបានអនុញ្ញាតឲ្យកងទ័ពយួនហូ-ជីមិញតាំងមូលដ្ឋានលើដែនដីខ្មែរ ចាប់តាំងពីឆ្នាំ១៩៦០ និងបានជួយផ្គត់ផ្គង់ទ័ពយួននេះគ្រប់មធ្យោបាយ ផ្តល់អង្ករ ថ្នាំពេទ្យ គ្រាប់រំសេវ សាស្ត្រាវុធគ្រប់ធុន ដែលដឹកតាមកប៉ាល់មកកំពង់ផែសីហនុ កំពង់សោម ជាពិសេសកងទ័ពវៀតណាមខាងជើង ដែលមកចុះផែនៅកំពង់សោម ក្នុងពេលដែលយន្តហោះបេ-៥២ ទំលាក់គ្រាប់បែកលើផ្លូវលំហូ-ជីមិញយ៉ាងខ្លាំង ចាប់ពីឆ្នាំ១៩៦៥មក ។

មូលដ្ឋានសឹកអស់ទាំងនោះបានចាប់ផ្ដើមកតាំងពីឆ្នាំ១៩៦០ ។ ខ្លះទៀតជាមូលដ្ឋានចាស់ តាំងពីសម័យសង្គ្រាមតស៊ូជាមួយបារាំងម្ល៉េះ ។ មូលដ្ឋានសឹងតែទាំងអស់ តាំងនៅតាមបណ្ដោយព្រំដែនខ្មែរ-យួន គឺតាំងពីព្រំរួមបីប្រទេស (លាវ-ខ្មែរ-យួន) ក្នុងខេត្តរតនគិរី លំផាត់ ឡាបានសៀក អូរាំង ស្នួល មេមត់-ជប់ ក្រែក ព្រំដែនខេត្តស្វាយរៀង តាកែវ កំពង់ត្រាច ។

តាំងតែពីច្រើនឆ្នាំមកហើយ... សម្ដេចសីហនុធ្មេចភ្នែកធ្វើមិនឃើញនូវអ្វីៗ ដែលបានកើតមានឡើងនៅតាមតំបន់ជាយដែន (ខ្មែរ-វៀតណាម) (13) ។

ទីបញ្ជាការនៃការិយាល័យកណ្ដាលភូមិភាគវៀតណាមខាងត្បូង ( COSVN, Central Office South Vietnam ) តាំងនៅមេមត់ ជាប់នឹងចំការកៅស៊ូតែម្ដង ។

ទីបញ្ជាការនៃរណសិរ្សរំដោះជាតិ ( NLF - National Liberation Front of South Vietnam ) មានទីតាំងនៅទល់មុខក្រែក ក្នុងខេត្តកំពង់ចាម ។

ឯទីស្នាក់ការកណ្ដាលនៃរដ្ឋាភិបាលបណ្ដោះអាសន្នបដិវត្តន៍វៀតណាមខាងត្បូង ( PRG = Provisinal Revolutionary Government of South Vietnam ) មានទី តាំងនៅទល់មុខកំពង់ត្រាច ក្នុងខេត្តស្វាយរៀង ។

នៅតាមមូលដ្ឋានទាំងនោះ មានសង់មន្ទីរពេទ្យ ដែលអាចដាក់គ្រែ ដែលអាចដាក់គ្រែអ្នកជម្ងឺបានជាងប្រាំរយ ឃ្លាំងស្ដុកសម្ភារៈសឹករាប់តោន សំរាប់ប្រើប្រាស់វាយលុកចូលវៀតណាមខាងត្បូង ដូចជាករណីការវាយលុកក្រុងព្រៃនគរ កាលពីបុណ្យតែតចូលឆ្នាំចិនយួន (១៩៦៨) ។

ក្នុងខែមិថុនា១៩៦៧ ដោយមានការតវ៉ាពីសាធារណរដ្ឋវៀតណាម និងពីស្ថានទូតអាមេរិកាំងថា មានកងទ័ពវៀតកុងតាំងនៅទល់មុខកំចាយមារ ជាប់លើព្រំដែនខ្មែរ-យួន ទទឹងទំហំ៥គីឡូម៉ែត្រ និងបណ្ដោយ១៥គីឡូម៉ែត្រ ។ លោកវរសេនិយឯក សេង-ស៊ុនថៃ បាននាំកងយោធពលខេមរភូមិន្ទទៅដេញ ព្រោះគណកម្មការខាងបទត្រួតត្រា ( ឥណ្ឌា, កាណាដា, ប៉ូឡូញ ) មកត្រួតពិនិត្យ ។ មេវៀតកុងបានមកជួបនឹងលោកសេង-ស៊ុនថៃ ហើយហុចនាមប័ណ្ណសម្ដេចសីហនុមកផង ។ វៀតកុងបាននិយាយថា ៖ សម្ដេចបានចុះខសន្យាយល់ព្រមឲ្យពួកគេនៅលើដីខ្មែរ ដើម្បីគេចពីការដេញតាមនៃកងទ័ពវៀតណាមខាងត្បូងនិងអាមេរិកាំង ។ កាលណាគណកម្មការខាងបទត្រួតត្រាទៅផុតអស់ ពួកខ្ញុំស៊ីវិលត្រឡប់មកវិញ ។ ទ័ពវៀតកុងក៏ដកថយចេញពីតំបន់ភូមិត្រឡោកបែកយួនរយៈពេលតូច ។ ដល់គណកម្មការខាងបទត្រួតត្រាទៅមើល បានឃើញតែទាហានខ្មែរចាស់ម្នាក់ កំពុងអង្គុយបិតឫស្សីនៅក្នុងរោងដោលយ៉ាងធំ ។ ការនេះវាផ្ទុយគ្នាពីរូបថត ដែលយន្ដហោះអាមេរិកាំងថតបានទៅវិញ (១៨) ។

ចាប់ពីឆ្នាំ១៩៦៩ សហរដ្ឋអាមេរិកសំរេចប្រើយន្ដហោះបេ-៥២ វាយលុកទម្លាក់គ្រាប់បែកកំទេកមូលដ្ឋានសឹកវៀតកុង-វៀតណាមខាងជើង តាមព្រំដែនខ្មែរ-យួនយ៉ាងខ្លាំងក្លា ។ ទ្រាំមិនបានពួកកងទ័ពវៀតកុង-វៀតណាមខាងជើង និងអគ្គបញ្ជាការវាបានរត់ថយចូលជ្រៅមកសំរាកយកកម្លាំងក្នុងដែនដីខ្មែរ តំបន់ព្រៃខេត្តក្រចេះ

*(១៨), (១៩) តាមសេចក្ដីឲ្យការណ៍របស់លោកប៉ោ-ថន អតីតវរសេនិយឯកសាធារណរដ្ឋខ្មែរ ។*

ចម្ងាយ១៥០គ.ម.ភាគខាងជើងផ្លូវជាតិលេខ៧ ។ ដោយប្រើប្រាស់ខេត្តខ្មែរភាគខាងជើង ពួកវៀតកុង-វៀតណាមខាងជើងបានរួចផុតមិនអន្តរាយដោយសារយន្តហោះ
ចម្ងាយ១៥០គ.ម.ភាគខាងជើងផ្លូវជាតិលេខ៧ ។ ដោយប្រើប្រាស់ខេត្តខ្មែរភាគខាងជើង ពួកវៀតកុង-វៀតណាមខាងជើងបានរួចផុតមិនអន្តរាយដោយសារយន្តហោះ
បេ-៥២ ។ ដោយកងកម្លាំងគេបានត្រួតត្រាតំបន់នេះតាំងតែពីកាលមុនមក ពួកគេអាចសម្ងំយកកម្លាំងមុននឹងចូលវាយលុក (យួនខាងត្បូង) ទៀត (14) ។

មូលដ្ឋានសឹកក៏ដកថយចូលជ្រៅមកក្នុងស្រុកខ្មែរ មកតាំងទីនៅលើត្រើយខាងលិចទន្លេមេគង្គ ជិតក្រចេះក្រុង ។

នៅថ្ងៃទី២៤មេសា១៩៧០ មួយអាទិត្យមុនពួកវៀតកុង-វៀតណាមខាងជើងកសាងមូលដ្ឋាន និងបញ្ជាការសឹកថ្មីលើច្រាំងទន្លេមេគង្គក្នុងខេត្តក្រចេះនោះ ពួកមេដឹកនាំឥណ្ឌូចិនប្រឆាំងនឹងចក្រពត្តិអាមេរិកាំង បានជួបគ្នាជាកំពូលនៅក្រុងកង់តុង ដោយមានវត្តមានសម្តេចសីហនុជាអ្នកចំណូលថ្មីផង ។ ផាំ-វ៉ាន់ដុងឲ្យកោះហៅខាងប៉ាថេតឡាវ គឺទ្រង់សុផានុវង្ស, ប្រធានរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងង្វៀង-ហ៊ូថូ និងសម្តេចសីហនុឲ្យចូលរួមផង ។ ពេលនោះសម្តេចបានថ្កោលទោសសហរដ្ឋអាមេរិក ហើយបានប្រកាសអនុញ្ញាតដោយចេញមុខឲ្យវៀតកុង-វៀតណាមខាងជើងប្រើប្រាស់ដែនដីខ្មែរទៀតផងក្នុងការធ្វើសង្គ្រាមជាមួយសត្រូវរួម គឺចក្រពត្តិអាមេរិកាំង (15) ។

សូមសួរថា តើសីហនុក្លាយជាអ្វីហើយនៅពេលនេះ ចំពោះស្រុកខ្មែរនិងចំពោះប្រជារាស្ត្រខ្មែរ ? ព្រោះហេតុអ្វី ដើម្បីអ្វី ទើបសីហនុចូលរួមជាមួយសត្រូវជាតិខ្មែរនេះ ?

ចាប់តាំងពីឆ្នាំ១៩៧០រហូតមកដល់បច្ចុប្បន្ននេះ តើសីហនុមានដែលមានបន្ទូលថា ទ្រង់បានធ្វើខុស ឬនយោបាយទ្រង់ខុស នៅទីណា ថ្ងៃណាម្តងហើយឬនៅ ?

ស្ទើរគ្រប់តែសុន្ទរកថា សីហនុស្រែកជេរក្តែងៗ ថ្កោលទោសខ្មោចលោកលន់នល់និងសិរិមតៈរហូត ខំលាងខ្លួនពីឧក្រិដ្ឋកម្មជាតិឯងនេះ សីហនុមិនដែលខុសទាល់តែសោះ ។ ស្រុកខ្មែរទៅជាយ៉ាងនេះ មកពីពួកអាក្បត់អស់នេះ វាធ្វើរដ្ឋប្រហារទម្លាក់ខ្ញុំព្រះករុណាខ្ញុំ ! សូមកូនចៅមេត្តាជ្រាប !

ទ្រង់មើលមិនឃើញគ្រោះថ្នាក់នៃវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើងលើដីខ្មែរ ថែមពីលើនេះ សីហនុបានជួយសត្រូវលេបទឹកដីខ្មែរនេះសព្វបែបយ៉ាងដោយជឿយ៉ាងស៊ប់ទៅលើសំដីបោកប្រាស់របស់ជូ-អេងឡាយនិងហូ-ជីមិញ ដោយគ្មានពិចារណា ។

មានតែសីហនុនិងប្រទេសខ្មែរតែមួយគត់ ដែលព្រមទទួលស្គាល់និងដាក់ទូតជាមួយវៀតកុង ។

នៅឆ្នាំ១៩៦៩ មានតែសម្តេចសីហនុមួយអង្គគត់, ក្នុងឋានៈជាប្រមុខរដ្ឋខ្មែរ, ដែលបានទៅសម្រក់ទឹកភ្នែកស្រណោះស្រណោកគោរពវិញ្ញាណខ័ន្ធមេឃាតករ និងមេរៀបចំផែនការលេបទឹកដីខ្មែរ ដែលបានស្លាប់ទៅមុនបានសំរេចមហិច្ឆិតារបស់វា



សម្តេចសីហនុរហូតដល់ទៅយករូបថតខ្មោចហូ-ជីមិញ មកតាំងក្នុងវាំងដើម្បី
គោរពវិញ្ញាណក្ខ័ន្ធថែមទៀតផង

# សីហនុនិងរបបដឹកនាំក្រោយឯករាជ្យ

តាំងពីបានឯករាជ្យពេញលេញពីបារាំង សីហនុគ្មានបានធ្វើអ្វីក្រៅតែពីការពារអំណាចដែលទ្រង់យល់ថា, រហូតមកដល់ឥឡូវក៏ដោយ, ជាកម្មសិទ្ធិដាច់មុខ ជាកេរ្តិ៍មរតកប្រចាំត្រកូលរបស់ទ្រង់តែម្នាក់គត់ ទើបទ្រង់ចាប់កសាងទុនប្រជាប្រិយភាពប្រជាភិថុតិ បញ្ឆោរបោកវាស្ត្រខ្មែរល្ងង់ខ្លៅ ដោយទ្រង់យល់ថាទុននេះអាចរក្សាអំណាចរបស់ទ្រង់ជាម្ចាស់ផែនដីខ្មែរឲ្យនៅស្ថិតស្ថេរបានយូរអង្វែងតទៅ ។ ហើយដោយទ្រង់យល់របៀបនេះហើយ ទើបទ្រង់ចាត់ចែងរចនានយោបាយដឹកនាំរបស់ទ្រង់ទៅតាមតែទំនើងចិត្តចង់ តាមតែបំណងផ្ទាល់ខ្លួន និងជាផលប្រយោជន៍សំរាប់អ្នកម្នាងម៉ូនិចផង ដោយយកស្រុកខ្មែរ រាស្ត្រខ្មែរទាំងអស់ជាឧបករណ៍ល្បែងឥតពិចារណារបស់ទ្រង់ ។ ដោយខ្លាចសឺង-ង៉ុកថាញ់ដណ្តើមទុននេះពីដៃទ្រង់ សីហនុបានអនុវត្តបន្សាបពិសសឺង-ង៉ុកថាញ់ ដោយចោទថា លោកថាញ់ជាជនក្បត់ជាតិក្បត់រាជបល្ល័ង្ក ហើយមិនអនុញ្ញាតឲ្យលោកថាញ់ចូលមករួបរួមក្នុងសង្គមជាតិសោះឡើយ ក្រោយសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ព្រោះស្រុកខ្មែរទាំងមូល រាស្ត្រខ្មែរទាំងអស់ជាសម្បត្តិដាច់ថ្លៃរបស់សីហនុតែម្នាក់គត់ សូម្បីលោកថាញ់បានសរសេរសំបុត្រផ្ទាល់ខ្លួនមកសុំចូលរួបរួមជាមួយទ្រង់ ក៏ទ្រង់មិនយល់ព្រមទាល់តែសោះ ។ ក្រោយមកឆ្នាំ១៩៥៧ លោកថាញ់បានសរសេរលិខិតផ្ទាល់ខ្លួនចំនួនបីផ្តល់ឱវាទសីហនុ

ថា « សម្តេចកំពុងធ្វើនយោបាយនាំសេចក្តីវិនាសមកឲ្យប្រទេសខ្មែរនិងប្រជារាស្ត្រខ្មែរហើយ » ក៏សម្តេចមិនឈឺក្បាលយកចិត្តទុកដាក់ ។ សន្តិសិទហ្សឺណែវបានឲ្យខ្មែររក្សានូវបុណ្យស័ក្តិរបស់អ្នកចុះចូលដូចកាលពីដើម  តែសីហនុមិនបានគោរពលក្ខ័ណនេះឡើយ ។ ពួកខ្មែរវៀតមិញក៏ដូចតែខ្មែរឥស្សរៈ និងក្រុមភ្នំដងរែក, ពួកសឺង-ង៉ុកថាញ់, ដែរ  គ្មាននរណាម្នាក់បានទទួលបុណ្យស័ក្តិពីសម្តេចសីហនុសោះឡើយ  មិនត្រឹមតែប៉ុណ្ណោះសម្តេចសីហនុបានទាំងចាត់ពួកគិញតាមអង្កេតគ្រប់អ្នកចុះចូលជារៀងរាល់ថ្ងៃ ។ អង្កេតតាំងពីសកម្មភាពប្រចាំថ្ងៃ ពាក្យសំដីបើនិយាយទិតៀនដល់នយោបាយសីហនុ  ក៏នឹងត្រូវគិញចាប់ញាត់គុកភ្លាម  ដូចករណីលោកវ៉ាន់ឈួង, អតីតខ្មែរឥស្សរៈសឺង-ង៉ុកថាញ់ (១), លោកឆាយ-យ៉ត (២), លោកកេង-វ៉ាន់សាក់ជាដើម ។

*(១) ដោយមិនបានបុណ្យពីសីហនុ ពួកខ្មែរឥស្សរៈភ្នំដងរែក, ក្រោយពីចូលមករួមរស់ក្នុងសង្គមជាតិហើយ, ក៏ទៅរកប្រកបរបរផ្សេងៗចិញ្ចឹមជីវិត ។ លោកលាវ-ធានស៊ីបានមកអែបជាមួយលោកលន់-នល់ ព្រោះធ្លាប់ជាសិស្សនាយទាហាន ហើយជិតដិតទៀតផង ឯប្អូនឈ្មោះលាវ-ធានអ៊ីមត្រូវជាមិត្តភក្តិរួមថ្នាក់ជាមួយលន់-ណុនផង  ។  លោកលន់-នល់បានឲ្យលោកលាវ-ធានស៊ីធ្វើជាចាងហ្វាងវិទ្យាល័យឯកជនខេមរា ដែលជាកម្មសិទ្ធិរបស់លោលលន់-នល់ផ្ទាល់ ។ លោកលាវ-ធានស៊ីបានបើកតូបលក់សៀវភៅមួយ  ឈ្មោះសារិកា  នៅត្រង់ចំណតរថយន្តឈ្នួលនៅផ្សារថ្មី ។ លោកដួង-ច័ន្ទសាវ៉ាតបានទៅរកស៊ីលក់សាំងនៅទន្លេបឹទ ខេត្តកំពង់ចាម ។ លោកសាំង-សាវ៉ាតធ្វើជាចាងហ្វាងសារពត៌មានខ្មែរថ្មី, ទៅមុខ, ឈាមខ្មែរ ហើយបាននិពន្ធប្រលោមលោកដ៏សែនពិរោះ មានស្នេហាខ្ពង់ខ្ពស់ និងមានស្នេហាជាតិដ៏បេះមុតរបស់តួអង្គ គឺរឿង «តេជោក្រហម» និង «មហាចោរនៅទល់ដែន» រហូតដល់លោលសេក-សំអៀតចាប់យកទៅសម្លាប់ចោល នៅដើមឆ្នាំ ១៩៥៩ ។ ស្មេរខ្ញុំបានអានសៀវភៅទាំងពីរនេះ (១៩៥៦) ដោយមាខ្ញុំម្នាក់មានតូបលក់សៀវភៅរំលងគ្នាបួនតូប ។ ឯលោកអ៊ីវ-យ៉ាងធ្វើជាគ្រូបង្រៀនឯកជន និងស៊ីឈ្នួលធ្វើមេធាវីជាមួយជាតិក្លឹងឥណ្ឌាម្នាក់នៅក្រុងភ្នំពេញ។ លោកគាំ-វ៉េតធ្វើការជាមួយក្រុមហ៊ុនជំនួញ «មហាបូព៌ាពាណិជ្ជ» ខាងជើងផ្សារធំថ្មី ខាងផ្នែកនាំទំនិញចេញចូល (* **Import-Export** *) ។ លោកហង្ស-ធុនហាក់ចូលទៅអែបជាមួយមហាក្សត្រីយានីកុសមៈ ដើម្បីកាឡៃល្ខោននិងសិល្បៈបំរើគោលគំនិតកែប្រែសង្គមខ្មែរតាមបំណងរបស់លោកសឺង-ង៉ុកថាញ់បានផ្តែផ្តាំ ដោយសរសេររឿងល្ខោនដូចជា ៖ «រៀមច្បងយើង, ចៅកែចិត្តចោរ, សំបុកឥតមេបា, កញ្ញាចរិយា, វិបត្តិស្នេហា, ចិញ្ចៀនបញ្ចាំចិត្ត, ដើមធ្លកក្សាជាតិ, ថ្មវាំ » តែលោកមិនដាក់ឈ្មោះលោកជាអ្នកនិពន្ធឡើយ ។*

*(២)  លោកឆាយ-យ៉តក៏ជាអតីតខ្មែរក្រុមសឺង-ង៉ុកថាញ់ដែរ  សីហនុចាប់ដាក់គុកជាមួយគ្នានឹងលោកអ៊ីវ-យ៉ាង ។ លន់-ណុនបានទទួលបញ្ជាពីសីហនុទៅចាប់ពួកភ្នំដងរែកព្រមៗគ្នាតែម្តងនៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៥៩ ដោយទ្រង់សង្ស័យថា បានចូលរួមដៃជាមួយសម-សារី, ដាប-ឈួនប្រុងធ្វើរដ្ឋប្រហារតាមសេចក្តីឲ្យការណ៍របស់អ្នកស្រីអ៊ីវ-យ៉ាង សព្វថ្ងៃរស់នៅក្រុងប៉ារីស ប្រទេសបារាំង  ។ ឯលោកសាំង-សាវ៉ាតត្រូវលោកស័ក្តិបីសេក-សំអៀតជាអ្នកចាប់  ។ លោកសេក-សំអៀតបានយកជើងទៅឈ្ងូសសំណៅនិពន្ធរបស់លោកសាំង-សាវ៉ាត  ធ្លាក់រាត់រាយ  (តាមសេចក្តីឲ្យការណ៍របស់លោកស៊ឹម-គិន  )  រួចហើយយកលោកសាំង-សាវ៉ាតទៅសម្លាប់ចោលបណ្តោយទៅ ។ សេក-សំអៀត ក្រោយពីប្រមូលលុយកាក់ដោយលក់ព្រៃឈើ បូរាណវត្ថុតំបន់បន្ទាយឆ្មារ (ហ៊ុនគ្នាជាមួយហ៊ុល-ទន ) មានលុយរាប់លានបាត ហើយបានសង់រោងកុន ម៉ាស៊ិនកិនស្រូវ សង់វីឡានៅស្រុកសៀម  ដោយឃុបឃិតជាមួយសុង-សាក់ ។*

*(២) លោកឆាយ-យ៉តក៏ជាអតីតខ្មែរក្រុមសឹង-ង៉ុកថាញ់ដែរ     សីហនុចាប់ដាក់គុកជាមួយគ្នានឹង*

លោកអ៊ីវ-យ៉ាង ។ លន់-ណុនបានទទួលបញ្ជាពីសីហនុទៅចាប់ពួកភ្នំដងរែកព្រមៗគ្នាតែម្តងនៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៥៩ ដោយទ្រង់សង្ស័យថា បានចូលរួមដៃជាមួយសម-សារី, ដាប-ឈួន ប្រុងធ្វើរដ្ឋប្រហារតាមសេចក្តីឲ្យការណ៍របស់អ្នកស្រីអ៊ីវ-យ៉ាង សព្វថ្ងៃរស់នៅក្រុងប៉ារីស ប្រទេសបារាំង ។ ឯលោកសាំង-សារ៉ាតត្រូវលោកស័ក្តិបីសេក-សំអៀតជាអ្នកចាប់ ។ លោកសេក-សំអៀតបានយកជើងទៅឈូសសំណៅនិពន្ធរបស់លោកសាំង-សារ៉ាត ធ្លាក់រាត់រាយ (តាមសេចក្តីឲ្យការណ៍របស់លោកស៊ីម-គិន ) រួចហើយយកលោកសាំង-សារ៉ាតទៅសម្លាប់ចោលបណ្តោយទៅ ។ សេក-សំអៀត ក្រោយពីប្រមូលលុយកាក់ដោយលក់ព្រៃឈើ បូរាណវត្ថុតំបន់បន្ទាយឆ្មារ ( ហ៊ុនគ្នាជាមួយហ៊ុល-ទន ) មានលុយរាប់លានបាត ហើយបានសង់រោងកុន ម៉ាស៊ិនកិនស្រូវ សង់វីឡានៅស្រុកសៀម ដោយឃុបឃិតជាមួយសុង-សាក់ ។ ក្រោយសេក-សំអៀតអស់អំណាចដោយខ្មែរក្រហមឈ្នះ ហើយជិះឧទ្ធម្ភាគចក្ររត់ទៅស្រុកសៀម ដោយសង្ឃឹមរោងកុនវីឡាទាំងនោះ តែត្រូវសុង-សាក់ដាក់ឈ្មោះវាទាំងអស់ សេក-សំអៀតសល់តែក្តិតខោ ហើយមកអាល័យតែជាប់ដៃយកប្រពន្ធម៉ៅ-សន, ចាងហ្វាងតុលាការសឹកបាត់ដំបង, ប្រពន្ធដើមសេក-សំអៀតក៏រត់ចោលទៅនៅស្រុកបារាំងជាមួយកូនស្រី(កូនចិញ្ចឹមជាក្មួយខាងប្រពន្ធ) ទៅ ។ ក្រោយមកសេក-សំអៀតបានសូកថៃចូលមកជំរំឆុនបូរី តែគ្មានប្រទេសណាមួយព្រមទទួលយកសោះ ទាំង Père Venet, ទាំងខាងសហរដ្ឋបានប្រាប់សេក-សំអៀតថា ៖ « ប្រទេសគេគ្មានកន្លែងឲ្យគាត់ទៅរស់នៅទេ (ឆ្នាំ១៩៨១) » ។ ស្មេរខ្ញុំបានមកទាន់ឃើញសេក-សំអៀតនៅក្នុងជំរំឆុនបូរី ។ កាលនោះសេក-សំអៀតបានចូលរួមជាមួយព្រះតេជព្រះគុណហុក-សាវណ្ណ (សព្វថ្ងៃគង់នៅប្រទេសកាណាដា ) ធ្វើជាញត្តិផ្ញើទៅអង្គការសហប្រជាជាតិ គាំទ្រសម្តេចសីហនុ ហើយដើរគៀរគេឲ្យជួយចុះហត្ថលេខាលើញត្តិនោះ តែខ្ញុំដែលទទួលខុសត្រូវខាងសលាលាមធ្យមសិក្សាឆុនបូរី បានប្រឆាំងមិនព្រមចុះហត្ថលេខាលើញត្តិនោះ ព្រោះសំអាងថា នយោបាយសម្តេចសីហនុមិនច្បាស់លាស់សម្តេចសីហនុជាមេខ្មែរក្រហម ។ លោកសេក-សំអៀតថែមទាំងស្អប់ និងបានទាំងកត់ឈ្មោះខ្ញុំទុកក្នុងបញ្ជីខ្មៅរបស់គាត់ទៀតផង ។

ក្រោយមកសេក-សំអៀតបានសូកថៃកែឈ្មោះ ហើយធ្វើ Visa ក្លែងបន្លំ បានចេញទៅស្រុកបារាំង ទៅរស់នៅលាក់មុខក្នុងក្រុងប៉ារីស៍រហូតដល់ឆ្នាំ១៩៩០ ។

(កកន ៖ នៅឆ្នាំ១៩៩៣ សេក-សំអៀតបានវិលត្រឡប់ចូលស្រុកខ្មែរវិញ ហើយលក់ក្បាលជាមួយនរោត្តម-បុប្ផាទេវី, នរោត្តម-ចក្រពង្ស និងនុត-ណារាំង ក្នុងជួរគណបក្សប្រជាជនកម្ពុជា ។ ឆ្នាំ១៩៩៨ សេក-សំអៀត, នរោត្តម-បុប្ផាទេវី និងនរោត្តម-ចក្រពង្ស ក៏វិលក្បាលមកចុះចូលខាងគណបក្សហ៊្វុនស៊ិនប៉ិចវិញ ។ សព្វថ្ងៃនេះសេក-សំអៀត បានធ្វើជាសមាជិកព្រឹទ្ធសភាខាងគណបក្សហ៊្វុនស៊ិនប៉ិច ) ។

សីហនុបានក្លាយជាមហាវីរបុរស ដោយទាមទារឯករាជ្យបានពីអាណានិគមបារាំងដើម្បីក្រសេបយកអំណាចឲ្យពេញដៃ សម្តេចសីហនុបានដាក់រាជសម្បត្តិដល់មាតាបិតាក្នុងឆ្នាំ១៩៥៥ ហើយហក់ចូលមកប្រឡូកបង្កើតគណបក្សនយោបាយមួយឈ្មោះ « សង្គមរាស្ត្រនិយម » ។ មានខ្មែរខ្លះបានលួចខ្សិបនិយាយគ្នាថា គណបក្សនយោបាយរបស់សីហនុបើឲ្យឈ្មោះថា « សង្គមរាស្ត្រយំ » ទើបត្រូវជាង ។
(កកន ៖ « សង្គមរាស្ត្រនិយម » បើដកតែពាក្យរាស្ត្រចេញគឺគណបក្ស « សង្គមនិយម » ។ ដើម្បីឲ្យរឹតតែដូចសង្គមនិយមមែនទែន សម្តេចសីហនុបានឲ្យសមាជិកនៅក្នុងបក្សហៅគ្នាថា « សហជីវិន ឬសហជីវិនី » ជាដើម ) ។ ទ្រង់បានកំទេចគណបក្សនយោបាយដទៃទៀត ដោយប្រើវិធីឃោរឃៅបំផុត ដូចជាឲ្យមនុស្សយកគ្រាប់បែកទៅគប់សម្លាប់លោកអៀវ-កើស ជាប្រធានរដ្ឋសភា និងជាប្រធានគណបក្សប្រ

ជាធិបតេយ្យ, ឲ្យលោកសម-សារីយកពួកគិញ្ញនិងទាហានហ្លួង ទៅបាញ់លោកអៀរ ស៊ីចូវ, កេង-វ៉ាន់សាក់ជាឃោសនិកបក្សប្រជាធិបតេយ្យ ដែលកំពុងឃោសនានៅមុខក្រសួងឃោសនាការក្នុងឆ្នាំ១៩៥៥ តែគ្រោះល្អគ្រាប់កាំភ្លើង បែរជាមកត្រូវអ្នកបើកបរឡានសម-សារីទៅវិញ (៣) ។

ក្រុមបក្សនយោបាយទាំងអស់ ដោយខ្លាចសីហនុធ្វើបាបសម្លាប់ចោល ក៏ព្រមចូលរួមជាមួយគណបក្សសង្គមរាស្ត្រនិយម ដែលមានសីហនុជាប្រធានអស់ ខ្លះទៀតក៏រស់នៅតែឯកឯង មិនហ៊ានធ្វើសកម្មភាពនយោបាយអ្វីទៀតឡើយ ដូច្នេះគ្មានអ្នកជំទាស់ប្រឆាំងនឹងសម្តេចសីហនុទៀតទេ ។ សីហនុក៏អនុវត្តនយោបាយរបៀបជិះសេះបែរខ្នងលែងដៃ ធ្វើស្រេចនឹងចិត្តទ្រង់នឹកឃើញ គ្មាននរណាមួយហ៊ានជំទាស់រារាំង សូម្បីតែអ្នកដែលសីហនុបានតែងតាំងជាទីប្រឹក្សាផ្ទាល់របស់ទ្រង់នោះ ក៏មិនហ៊ានផ្តល់ឱវាទផ្ទុយពីការយល់ឃើញរបស់សម្តេចសីហនុសោះឡើយ ។ ខ្មែរកាលណោះតែងតែនិយាយគ្នាថា ៖ « តាមតែព្រះបញ្ញាញាណដ៏ភ្លឺស្វាងរបស់ព្រះអង្គចុះ » ជាពិសេសលោកម៉ា-ឡៅពី ដែលជាអ្នកធ្វើអត្ថាធិប្បាយថែមថយយ៉ាងពិរោះក្នុងពិធីសិមិទ្ធិផ្សេងៗ ដែលមានសីហនុជាអធិបតី ផ្សាយតាមសម្លេងវិទ្យុជាតិ ។

( <u>កកន</u> ៖ លោកម៉ា-ឡៅពី បានវិលត្រឡប់ទៅស្រុកខ្មែរវិញក្នុងសម័យរដ្ឋកម្ពុជា ហើយបានចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ លោកនៅតែប្រព្រឹត្តល្បែងជល់មាន់ដដែល ជាចំណូលចិត្តរបស់លោកតាំងតែពីដើមរហូតមក ។ លោកបានស្លាប់នៅស្រុកខ្មែរដោយរោគបេះដូង (មិនចាំឆ្នាំ ឬប្រហែលមុនពេលបោះឆ្នោតអ៊ុនតាក់ ) ) ។

គេសង្កេតឃើញមានមតិយល់ឃើញបីចំពោះរូបតួអង្គសម្តេចសីហនុ ៖

១- ពពួកកសិករខ្មែរនៅស្រុកស្រែចំការ ដោយមិនបានទទួលការសិក្សាអប់រំផ្នែក «វិជ្ជាពលរដ្ឋ ( Instruction civiques - Social studies ) មានជំនឿថា « សីហនុ ជាអ្នកមានបុណ្យ » ជា « ព្រះបាទធម្មិក » តាមក្បួនពុតទំនាយ (៤) ត្រង់វគ្គ « ចិន លីគម្ពីរដើររកព្រះបាទធម្មិក » ។

កាលខ្ញុំនៅជាសិស្សវិទ្យាល័យសន្តិភាពក្រុងកំពង់ស្ពឺ ក្នុងឆ្នាំ១៩៦០ កាលនោះសម្តេចបានយាងទៅសម្ពោធអាគារវិទ្យាល័យមួយទើបនឹងសង់ថ្មី ។ ពួកយើងជាសិ

*(៣) តាមសេចក្តីឲ្យការណ៍របស់លោកស៊ិម-គិន នៅរដ្ឋវ៉ាស៊ិនតោន ។*

*(៤) ព្រះបាទធម្មិកប្រែថា ស្តេចដែលប្រកបដោយធម៌ អនុវត្តច្បាប់ទសពិតរាជធម៌ ( ធម៌ទាំង១០ប្រការ ដែលស្តេចល្អត្រូវអនុវត្តគោរពតាម ) ។ ព្រះបាទធម្មិកនេះមានក្នុងក្រាំងទំនាយរបស់តាពុតតែខ្មែរអ្នកចម្លងតៗមក ដោយចង់ឲ្យគេជឿកាន់តែខ្លាំងនោះ, ក៏សរសេរកែទៅជា «ពុទ្ធទំនាយ» ទៅវិញ ។ តាមពិតព្រះពុទ្ធគង់នៅប្រទេសឥណ្ឌាឯណោះ ពុំបានធ្វើការទស្សន៍ទាយពីស្រុកខ្មែរទេ។ ទំនាយតាពុតបានថែងថា ៖ ដល់ពាក់កណ្តាលសាសនា (ពុទ្ធសករាជ២៥០០) នៅស្រុកខ្មែរនឹងមានអសុរប្រាំបីទិស ច្បាំងកាប់ចាក់គ្នាឈាមដាបពោះដំរី ហើយនិងមានចិនពីស្រុកចិន លីគម្ពីរដើរស្វះស្វែងរកព្រះបាទធម្មិក មកជួបលោកសង្ឃធុតុង្គចីពររហែកគង់លើថ្ម ហើយស្គាល់ថាជាព្រះបាទធម្មិក ក៏នាំស្តេចធម្មិកនេះឲ្យទៅបង្ក្រាបពួកអសុរទាំងនោះឲ្យឈប់ច្បាំងគ្នា រាស្ត្រខ្មែរស្រុកស្រែក៏នាំគ្នាកាត់យល់ថា សីហនុជាព្រះបាទធម្មិក ។*

ស្សស្ងៀកពាក់ឯកសណ្ឋានយុវ៍ន ខោអាវកាគី មានចងក្រវ៉ាត់ខ្មៅយ៉ាងតឹងបំពង់កនិងសក្តិបន្តោងរូបសម្តេចសីហនុ ផ្លាក«យុវជនរាជសង្គមនិយមខ្មែរ» រណោងរ-ណោងយ៉ាងធុញទ្រាន់ ។ ពួកយើងបានទទួលបញ្ជាពីលោកចាងហ្វាង ងួន-ស្រេងឲ្យក្រោកតាំងពីព្រលឹមស្រាងៗ ត្រៀមខ្លួនមកឈរចាំទទួលបដិសណ្ឋារកិច្ចសម្តេចសីហនុ តាំងតែពីព្រមឹមម៉ោងប្រាំមួយរហូតដល់ថ្ងៃត្រង់ក្តៅហែង ។ ភ្នែកទាំងរាស្ត្រទាំងសិស្សទាំងអស់គ្នា ខំសម្លឹងមើលទៅលំហអាកាស ក្រែងឃើញយន្តហោះកន្ទុំរុយស្តេចឱហោះមក ។ ពេលឧទ្ធម្ភាគចក្រហោះឆ្វែលពីលើ សីហនុបានបោះក្រ-ណាត់ឃីហោ«សង្គម»។ ក្មេងៗរាស្ត្រទាំងស្រីទាំងប្រុសរត់ជាន់គ្នាតាមដណ្តើមក្រ-ណាត់នោះ ។ នៅជិតខ្ញុំមានមីងម្នាក់ ស្រាប់តែក្រណាត់ធ្លាក់មកចំគាត់តែម្តង ខ្ញុំឃើញទឹកមុខគាត់ត្រេកអរណាស់ ដៃអោបក្រណាត់នោះយ៉ាងជាប់ ឈរភ្លឹកភ្លេចខ្លួនមួយសន្ទុះធំ ។ ក្រោយមកគាត់ពុំបានយកក្រណាត់ធុនថោកនោះទៅកាត់ស្លៀកពាក់ឡើយ គាត់ជឿថាជាវត្ថុពិសិដ្ឋិរបស់ព្រះបាទធម្មិក ។ គាត់បានយកក្រណាត់នោះទៅតំកល់លើហ៊ិងជាមួយព្រះពុទ្ធរូប ថ្វាយបង្គំរាល់ថ្ងៃ (៥) ។ សុន្ទរកថាយ៉ាងវែងអន្លាយ បែកជាអូរហូរជាស្ទឹង សម្តេចតិះដៀលបង្អាប់អាមេរិកាំងថា «អាតាំង» (៦) មិនចេះធ្វើស្រែខ្វះអង្ករស៊ី (តាមពិតអាមេរិកាំងជាប្រទេសលេខមួយក្នុងការដឹកអង្ករចេញទៅលក់ក្រៅប្រទេស) ជេរនាយករដ្ឋមន្ត្រីសៀមថា « អាថ្នមកាទិកាចន កាតន កាឆា » ផង ជេរយួនង៉ោ-ឌិនឌៀមផង ។ ប្រជារាស្ត្រស្រុកស្រែ, ជាពិសេសតាយាយចាស់ៗ អង្គុយចោងហោងស្តាប់សុន្ទរកថាសម្តេចសីហនុ ហើយឧិនលើកដៃប្រ-ណម្យដាក់លើក្បាល ដូចគេស្តាប់លោកទេសន៍អញ្ជ៉ឹង ។

រាស្ត្រស្រុកស្រែចំការ មុននឹងនិយាយដល់ព្រះនាមទ្រង់ គេតែងតែលើកដៃបន្ទូលឡើងទៅលើក្បាល នឹករំលឹកដល់ព្រះអង្គជានិច្ច ព្រោះទ្រង់ជាអ្នកមានបុណ្យ ។ អ្នកខ្លះ មានទាំងពួកព្រះអង្គម្ចាស់ខ្លះផងអួតថា នឹងជឿថា «វង្សស្តេចខ្មែរជាវង្សព្រះពោធិសត្វ» ថែមទៀតផង ។ រាស្ត្រខ្មែរខ្លះទៀត បានទាំងហាមកូនចៅកុំឲ្យតិទៀនពីទ្រង់ ព្រោះនឹងមានបាបធ្ងន់ណាស់ ។

២- ចំពោះមតិបញ្ញវ័ន្តខ្មែរវិញ ពួកគេយល់ឃើញថា សម្តេចសីហនុលោភលន់អំណាចហួសហេតុ ក្រសោបយកកិច្ចការនាយករដ្ឋមន្ត្រីមកកាន់ផ្ទាល់ យកកិច្ចការរបស់តុលាការមកធ្វើជាការចូលគាល់សវនាការតាមបែបស្តេចខ្មែរជំនាន់ដើម ទ្រង់ឲ្យរាស្ត្រឈប់ឈ្លោះគ្នា ហើយសន្យាឲ្យប្រាក់ប៉ុណ្ណេះប៉ុណ្ណោះ ។ លោកតាហ៊ុល ឬ

*(៥) គ្រប់តែចាស់ៗ ជាពិសេសគ្រូមន្តអាគម បានយកក្រណាត់សង្គមនោះ ឬក៏រូបថតសម្តេចសីហនុដាក់លើហ៊ិងជាមួយទេវគ្រូ កន្សែងយន្ត្រ ព្រះពុទ្ធរូប ថ្វាយបង្គំរាល់ថ្ងៃ ។*

*(៦) ពាក្យសីហនុហៅអាមេរិកាំង ។ តាមរឿងបុរាណខ្មែរដែលសរសេរតែពីរឿងស្តេច ដូចជាព្រះជិនវង្ស, រតនាវង្ស, ទិព្វសង្វារ...។ល។ គេសរសេររបៀបតែមួយ គឺមានកូនស្តេចចេញទៅរៀនមន្តអាគមគាថាពីតាឥសីនៅព្រៃហេមពាន្ត ។ គ្រប់ៗតែរឿងបែបនេះ, តាឥសីមានក្មេងបំរើម្នាក់ឈ្មោះថា «អាតាំ» (អាតាំងចៅតា) ។ អាតាំងល្ងង់មហាសែនល្ងង់ រស់នៅជាមួយលោកតាឥសីរាប់សិបឆ្នាំមកហើយ ស្អីក៏អាតាំងមិនចេះដែរ កុំសូម្បី «នខ្វាក់» ក៏មិនចេះផង ។ សីហនុយកឈ្មោះអាតាំងនេះមកហៅមកដាក់ឲ្យអាមេរិកាំង ថាអាមេរិកាំងល្ងង់ (មានតែសីហនុទេដែលចេះ) អាមេរិកាំងខ្វះអង្ករស៊ីជាដើម ។*

លោកឃឹម-ទិតដែលកាន់លុយនោះ មិនដែលបើកប្រាក់ឲ្យរាស្ត្រនោះៗ តាមបន្ទូលរបស់សម្តេចទេ គាត់លួចកិបទ្បិបលាក់ទុកផ្ទាល់ខ្លួនគាត់យ៉ាងសន្ធឹកសន្ធាប់ ។ ចំពោះអាហារូបករណ៍ទៅរៀនឯបរទេសវិញ (៧) ទ្រង់អនុញ្ញាតឲ្យខ្លះៗដែរ តែផ្នែកខាងតិកនិកបច្ចេកទេសស្មោះ ឯខាង «នយោបាយ, សេដ្ឋកិច្ច, សង្គមកិច្ច, ច្បាប់» ទ្រង់មិនអនុញ្ញាតឲ្យជាដាច់ខាត ដោយសីហនុសំអាងថា ខ្លាចនាំមនោគមវិជ្ជាបរទេសផ្តេសផ្តាសចូលស្រុក ។ តាមពិតគឺសីហនុខ្លាចគេចេះជាង ហើយមកដណ្តើមអំណាចពីទ្រង់ទៅវិញទេ ។

សីហនុជាស្តេចចិត្តស្រី ឆាប់ខឹង មាយាងរង៉ក់ច្រើន កំញើញចង់លាលែងរាប់រយដង (តែសីហនុនៅតែលើអំណាចរហូត) ឲ្យគេអង្វរនាំគ្នាធ្វើញត្តិ ឬឈរទាមទារសុំឲ្យព្រះអង្គនៅជា «អគ្គមគ្គទេ្ទសក៍ឆ្មើមតទៅទៀត» ខាតពេលវេលាអស់សន្ធឹក ។

សីហនុអួតអាងខាងពូកែធ្វើកុន ដូចជាបង្កើតពាក្យ «ធីងមោង» ជាដើម ។ តាមប្រភពច្បាស់ការណ៍ថា សម្តេចសីហនុខូចមែន ចូលចិត្តស្រីណាស់ (៨) ។ នាម៉ឺនខ្មែរម្នាក់ ដោយចង់យកគាប់គួរជាមួយសម្តេចសីហនុ ក៏នាំភរិយាដ៏ស្រស់ក្មេងទៅចូលគាល់សម្តេចទតឃើញក៏សព្វព្រះទ័យ ទាញដៃលោកជំទាវក្មេងចូលបន្ទប់បាត់ទៅ ។ នាម៉ឺននោះស្ទើរតែនឹងធ្វើអត្តឃាតខ្លួនព្រោះតែរឿងនេះ តែដោយសម្តេចសីហនុដម្លើងបុណ្យស្មើនឹងរដ្ឋមន្ត្រី ក៏ពេញចិត្តបាត់មាត់ឈឹងតែម្តងទៅ (៩) ។ ដូចប្រពន្ធចុងប្រធានាធិបតីឥណ្ឌូណេស៊ីស៊ូការណូ ជាមួយគ្រូក្មេងខេត្តសៀមរាបម្នាក់ ។ អ្នកស្រីស៊ូការណូបានមកនៅជាមួយសម្តេចសីហនុ ឯជំណាក់ភ្នំបូកគោចំនួនមួយអាទិត្យតែពីរនាក់ ។

សម្តេចសីហនុជាបិតាគ្រប់វិស័យ ៖ បិតាឯករាជ្យជាតិ, បិតាកីឡាជាតិ, បិតាសិក្សាធិការជាតិ, បិតាសិល្បៈ (តួឯកភាពយន្ត), បិតាចម្រៀង មានបទកូលាបលួងប្រាបាង្គ (រហូតបានម្តាងលាវមួយ), ពេលរាត្រីជួបភ័ក្ត្រ...។ល។ ជួនកាលទ្រង់ឡើងប្រគុំភ្លេងផង, បិតាកាស៊ីណូជាតិ, បិតារៀតកុង និងចង់ធ្វើជាបិតាដេញរៀតកុងទៀត តែទ្រង់សិរិមតៈនិងលន់-នល់មិនអនុញ្ញាតទុកឱកាសឲ្យ ។

*(៧) អាហារូបករណ៍ជាជំនួយពីប្រទេសជឿនលឿន តាមរយៈអង្គការសហប្រជាជាតិ មាន* UNESCO *ជាដើម ដល់ប្រទេសទន់ខ្សោយ ឲ្យបញ្ជូនសិស្សទៅរៀននៅស្រុកគេ មានបារាំង, អាមេរិកាំង អង់គ្លេស... តែដើម្បីបានអាហារូបករណ៍ទាំងអស់នោះ គេត្រូវសូកប្រាក់ខ្ពង់១០ម៉ឺនរៀល ដល់អ្នកដែលកាន់កាប់ខាងអាហារូបករណ៍នោះ បើពុំនោះទេ គេបញ្ជូនតែកូនចៅគេ កូននាម៉ឺនដែលប៉ៅទ្បៅឲ្យទៅរៀនរៀនទៅវិញ ។*

*(៨) នេះជាទម្លាប់របស់នាម៉ឺនខ្មែរតាំងពីបូរាណមក ដើម្បីបានបុណ្យស័ក្តិពីស្តេច គេយកកូន, ជូនកាលជាប្រពន្ធ ឲ្យតែស្តេចសព្វព្រះទ័យ, ទៅថ្វាយស្តេចដូចជាកថាថនញ៉ាញ, ឪពុកកថាថនឃុំ, ស្តេចត្រាញ់ខេត្តបាត់ដំបង, បានយកកូនស្រីមួយទៅថ្វាយហ្លួងនរោត្តម និងកូនស្រីមួយទៀតទៅថ្វាយស្តេចសៀមជាដើម ។*

*(៩) សូមអានសេចក្តីសម្ភាសន៍របស់សីហនុ ក្នុងទស្សនាវដ្តី* Playboy Vol.34 No.5- May 1987 *ផងចុះ តែទ្រង់ពុំបានលាតត្រដាងអស់ពីរឿងពិតរបស់ទ្រង់ ជាមួយអស់លោកជំទាវ លោកស្រីខ្លះៗនោះទេ ។*

សម្តេចសីហនុមានចរិតប្រែប្រួល គ្មានច្បាស់លាស់ មានគោលដៅរក្សាតែអំណាចផ្ទាល់ខ្លួន បន្ទាត់នយោបាយតាមនឹកឃើញ ថ្ងៃនេះអញ្ចេះ ស្អែកឡើងប្រែជាអញ្ចុះទៅវិញ ស៊ីជោរ និងចូលចិត្តឲ្យគេបញ្ចោរកោតសរសើរពីខ្លួនឯង ។

សីហនុគឺកម្ពុជា ! កម្ពុជាគឺសីហនុ ! នរណា ខ្មែរណាដែលមិនយល់ស្រុបតាមយោបល់ទ្រង់ទេ គឺជាជនក្បត់ជាតិ ។ សម្តេចសីហនុយកលោកព្រាប-អ៊ិន (១០), សៅ-ង៉ុយ, ស៊ីសុមុត-សុវណ្ណរី... និងខ្មែរសេរីជាច្រើនទៀត ទៅបាញ់ចោលនៅត្រពាំងក្រឡឹង (កំពង់ស្ពឺ) រួចហើយថតបញ្ចាំងក្នុងកម្មវិធីទូរទស្សន៍ គ្រប់រោងកុនក្នុងក្រុងភ្នំពេញនិងខេត្តក្រៅ ព្រមទាំងចុះក្នុងទស្សនាវដ្តី «សង្គម» ដែលមានទ្រង់ជាចាងហ្វាងផង ។

សម្តេចសីហនុបានបង្កើតឲ្យលេងបៀរប៉ោ អាប៉ោង ល្បែងស៊ីសងគ្រប់មុខពេលចូលឆ្នាំខ្មែរម្តងៗ ធ្វើឲ្យបាត់បង់អស់ល្បែងប្រជាប្រិយខ្មែរ ហើយប្រជារាស្ត្រខ្មែរនៅលេងល្បែងស៊ីសងជាច្រើនខែបន្តទៅទៀត ។ ទ្រង់បើកកាស៊ីណូរដ្ឋយកប្រាក់ចូលជួយទប់ថវិកាជាតិអោនថយ ។ ប្រជារាស្ត្រ នាម៉ឺនខ្មែរវិកវរព្រោះតែកាស៊ីណូជាតិ ខ្លះលែងលះគ្នា ដូចជាករណីលោកសឺង-ភៀកថ (១១) ជាដើម ខ្លះទៀតចងកសម្លាប់ខ្លួន លោតទឹក ស្រីៗខ្លះក្លាយជាស្រីលក់ខ្លួន ចោរកម្មចោរឆក់កើតពាសពេញក្រុងភ្នំពេញ កុងស៊ីបញ្ចាំងកាន់តែកើតច្រើនឡើងនៅមុខរោងកាស៊ីណូមាត់ទន្លេជិតសាលចតុមុខ, នាម៉ឺន គយ ប៉ូលីសកាន់តែស៊ីសំណូក ពុករលួយកាន់តែខ្លាំង ដើម្បីយកលុយទៅស្រង់ដើមក្នុងកាស៊ីណូរដ្ឋ ។

ឯមាតាសីហនុ, ក្សត្រីកុសុមៈ និងអ្នកម្នាងម៉ូនិចក៏ខំរកស៊ីតែរៀងៗខ្លួនដែរ ។ ក្សត្រីកុសុមៈជាមាតាសម្តេចសីហនុនិងអ្នកម្នាងម៉ូនិចមិនត្រូវគ្នាទេ ខំប្រជែងប្រណាំងដណ្តើមប្រើអំណាចឥទ្ធិពលជាមាតា ជាប្រពន្ធប្រមុខរដ្ឋរៀងៗខ្លួន ដោយតែងតាំងមនុស្សជាទីសំណប់ចិត្ត ចេញសំបុត្របោះត្រារាជវាំង តាំងភួង-ម៉ារហ្គាំងឲ្យធ្វើជាចាងហ្វាងអេសស្កាដេ (S.K.D.) ជាដើម ។ អ្នកម្នាងជាមួយបងខ្លួនគឺអ៊ុំ-ម៉ាណូរិនឆ្លៀតរកស៊ីហ៊ុនជាមួយពួកឃួនវៀតកុងហុង-យូផង, រត់ពន្ធមាសប្លាទីនតាមយន្តហោះផង (១២) (គយម្នាក់ដែលចាប់ដោយមិនបានដឹងថា ជារបស់អ្នកម្នាងម៉ូនិច ក៏ត្រូវគេផ្លាស់ចេញ២៤ម៉ោង វិសតែនឹងអស់បុណ្យស័ក្តិថែមទៀត), ដឹកអង្ករ ថ្នាំពេទ្យ

*(១០) កាលនោះសម្តេចសីហនុបានប្រកាសតាមវិទ្យុ ឲ្យខ្មែរសេរីចូលមកចរចាគ្នា ។ លោកសឺង-ង៉ុកថាញ់សួររកអ្នកស្ម័គ្រចិត្តចូលមកស្រុកខ្មែរ តាមខេត្តតាកែវ ដែលកាលណោះលោកអ៊ិន-តាំធ្វើជាចៅហ្វាយខេត្ត ។ សីហនុបានកែប្រែពីចរចាជាមួយខ្មែរសេរី ត្រឡប់ជាយកព្រាប-អ៊ិន ទៅឲ្យក្មេងជេរម្តាយប្រាស់ឆ្អេះយ៉ាងអាក្រក់អាក្រី ផ្សាយតាមសម្លេងវិទ្យុជាតិ ។ លោកអ៊ិន-តាំបានប្រាប់ព្រាប-អ៊ិនឲ្យសុំទោសសម្តេចទៅនឹងបានរួចខ្លួនហើយ តែព្រាប-អ៊ិនមិនព្រម ។ សម្តេចឲ្យយកព្រាប-អ៊ិនទៅបាញ់ចោលនៅត្រពាំងក្រឡឹង ថតបញ្ចាំងគ្រប់រោងភាពយន្ត ។*

*(១១) ផ្ទះខ្ញុំនៅរំលងពីរផ្ទះពីផ្ទះលោកសឺង-ភៀកថ ដែលជារដ្ឋមន្ត្រីម្តង និងជាចាងហ្វាងសារពត៌មាន «មាតុភូមិ» តែក្រោយមកត្រូវសីហនុបិទចោល ក៏បោះរៀងចិនមាន ដាវទិព្វស៊ូឡុង, ទេពឥន្ទ្រីសេនាក្លាហាន...។ល។ វិញ ។*

*(១២) សេចក្តីឲ្យការណ៍របស់លោកម៉ែៈ-សៅរី ជាក្មួយខាងភរិយាលោកអ៊ិន-តាំ សព្វថ្ងៃរស់នៅក្រុងភ្នំពេញ ។*

កាំភ្លើង គ្រាប់រំសេវ ជាមួយចិនគួច-អាន ទៅផ្តល់ឲ្យទ័ពវៀតកុង-វៀតណាមខាងជើង នៅមូលដ្ឋានតាំងលើដីខ្មែរ តាមខេត្តជាប់ជាយដែនខ្មែរ-យួន ។ មួយទៀតគ្រួសារខែក-វណ្ណឌី (មានទំនាក់ទំនងជិតដិតជាមួយអ្នកម្នាងផង) បានទទួលឯកសិទ្ធិពិសេសក្នុងការរកស៊ីធ្វើជំនួញ ដោយយកក្រុមហ៊ុនរដ្ឋធ្វើជាត្រីមុខ ( Magasin d'Etat ) ក្នុងការនាំទំនិញចូលពីបរទេស, ពិសេសពីស្រុកបារាំងមកលក់ ។

ព្រោះតែរបៀបយ៉ាងនេះហើយ ទើបប្រទេសខ្មែរដែលផ្តាច់ជំនួយអាមេរិកាំងក៏មានវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ហេតុមកពីមេដឹកនាំនិងនាម៉ឺនតូចធំគ្មានវិចារណញ្ញាណគិតខ្លាចរលាយអស់ស្រុកដល់បន្តិចសោះ ។ រហូតសព្វថ្ងៃនេះហើយក៏ដោយគេនៅតែឆ្លើយដាក់ថា « មកតែពីពួកប្រទេសមហាអំណាច, មកតែពីពួកគ្រូចូលជាមួយខ្មែរក្រហម (សំដីពួកនាយទាហានខ្លះ) » តែត្រង់សីហនុ ត្រង់នាម៉ឺនខ្មែរធ្វើការឲ្យខ្មែរក្រហម ធ្វើការឲ្យយួនមកយកស្រុកនោះ ពួកគេហាក់ដូចជាមើលមិនឃើញសោះ ។ តាមពិតអ្នកចូលជាមួយខ្មែរក្រហមមិនមែនមានតែគ្រូទេ មានគ្រប់ក្រសួងតាំងពីពេទ្យ ចៅក្រម វិស្វករ...។ល។ ឯសម្តេចសីហនុសោតក៏ជាមេខ្មែរក្រហមថែមទៅទៀត ។

៣- តាមទស្សនៈអ្នកនិពន្ធបរទេស ជាពិសេសពួកបស្ចឹមប្រទេស គេមើលឃើញថា សីហនុជាស្តេចសក្តិភូមិតាំងពីឆ្នាំ១៩៤១ (1) ដល់ឆ្នាំ១៩៧០, ជាប្រមុខរដ្ឋ, ជានាយករដ្ឋមន្ត្រី, ជាប្រធានបក្សនយោបាយតែមួយគត់ (សង្គមរាស្ត្រនិយម), អ្នកដឹកនាំប្រគុំវង់ភ្លេង Jazz, ចាងហ្វាងទស្សនាវដ្តី (សង្គម, ផ្សេងៗ), ចាងហ្វាងថតភាពយន្ត និងជាតួឯកផង, ជាអ្នកបើកកាស៊ីណូ, ជាអ្នកសាកល្បងរួមបញ្ចូលទ្រឹស្តីពុទ្ធនិយមនិងលទ្ធិប្រជាធិបតេយ្យ (តាមឱវាទរបស់ប្រធានាធិបតីរ៉ូម៉ានី ដែលត្រូវប្រហាជីវិតនៅខែធ្នូ១៩៨៩ ដើម្បីរក្សាអំណាចទ្រង់ឲ្យបានមួយជីវិត) ។ ជាមនុស្សឥតបានការ ឆាប់ខ្ញាល់ ចូលចិត្តអួតអាងពីថ្វីដៃខាង«ធ្វើកុន», មិនអនុញ្ញាតអត់ទោសដល់ការទិតៀននិងការខ្វែងយោបល់ផ្ទុយពីទ្រង់ឡើយ, ចាត់ទុកទីប្រឹក្សានិងអ្នកជំនួយថាមានសមត្ថភាពមិនដល់ទ្រង់, ចិត្តល្អណាស់ជាមួយអ្នកដែលចេះយកចិត្ត លុតក្រាបគាប់គួររណោបរណាបស្របតាមទ្រង់ (ដែលភាសាសាមញ្ញនិយាយថា ចេះត្រឹមតែ «កូណាសេសៗប៉ុណ្ណោះ), តែម្នាក់ៗខ្លាចញញើតណាស់និងចរិតឆាប់ខឹងច្រឡោតរបស់ទ្រង់ ។ សុន្ទរកថារបស់សម្តេចសីហនុជាសំដី «ចោលដឹងទាំងដង» មានលក្ខណៈពិសេសឡប់ៗម្យ៉ាង (Idiosyncratic) ហើយឯការពន្យល់របស់ទ្រង់ច្រើនមានន័យមិនប្រាកដមិនច្បាស់លាស់ ។ ក្នុងពេលជាមួយគ្នានោះ សម្តេចសីហនុមានទេពកោសល្យប៉ិនប្រសប់ខាងផ្នែកនយោបាយ មានសម្ពស្សរឹងប៉ឹងនិងមានប្រាជ្ញាវៀងវៃ (តែគួរស្តាយនូវមេដឹកនាំនេះ ដែលមិនបានទទួលការអប់រំខាងផ្នែកដឹកនាំសោះ ) ។ បន្ទាប់ពីការចាប់ផ្តើម (រៀនធ្វើនយោបាយទទ្រឹបទទ្រាប មិនច្បាស់លាស់មួយពីដំបូងទីមក សម្តេចសីហនុក្រេបជញ្ជក់យកបានលក្ខណៈទាំងអស់នេះ ក្នុងផលប្រយោជន៍នៃបុព្វហេតុដ៏ខ្ពង់ខ្ពស់មួយ -គឺការរក្សាប្រទេសកម្ពុជាឲ្យស្ថិតនៅក្នុងសន្តិភាពនិងឯករាជភាពបានមួយរយៈ រួចផុតពីការរំលោភរបស់អ្នកជិតខាង (សៀម-យួនខាងត្បូង តែសីហនុឲ្យយួនខាងជើងរំលោភតាំងសេនាធិការសឹកនៅលើដីខ្មែរ)

ទំនាក់ទំនងនេះបានធ្វើឲ្យទ្រង់អាចយកជ័យជំនះលើសត្រូវខាងក្រៅ ក៏ដូចជាអត្តាធិបតេយ្យនៃសត្រូវខាងក្នុងប្រទេសដែរ ។ មិនតែប៉ុណ្ណោះសោត គឺទំនាក់ទំនងរបស់ទ្រង់ជាមួយប្រជារាស្ត្រខ្មែរ និងជាមួយប្រទេសមហាអំណាចបរទេស – ជាពិសេសជាមួយសហរដ្ឋអាមេរិកដែលមកជំនួសបារាំង មានអំណាចជាធំក្នុងជ្រោយឥណ្ឌូចិននោះ – ជាផ្នែកដ៏សំខាន់មួយនៃប្រវត្តិសាស្ត្រក្នុងការរលាយវិនាសអន្តរាយរបស់ប្រទេសកម្ពុជានេះ ។

❑ ❑

❑

# បុព្វហេតុនៃការទំលាក់សីហនុ

ចាប់តាំងពីឆ្នាំ១៩៦០រៀងមក សម្តេចសីហនុបានធ្លាក់ចូលទៅក្នុងអន្ទាក់របស់មេដឹកនាំយួននិងចិនប្រជាមានិត ព្រោះតែសម្តេចសីហនុមិនស្គាល់ខ្លួនលោក និងមិនស្គាល់នរណាជាសត្រូវ នរណាជាមិត្តឲ្យបានច្បាស់លាស់ ។ តាមការពន្យុះរបស់មេដឹកនាំចិនជូ-អេងឡាយ សម្តេចសីហនុបានបញ្ឈប់លែងឲ្យសហរដ្ឋអាមេរិកបន្តការកសាងផ្លូវថ្នល់ក្នុងស្រុកខ្មែរតទៅទៀត ព្រោះមេដឹកនាំចិនបានបំភ័យសម្តេចសីហនុថា ៖ « អាមេរិកាំងសង់ផ្លូវធំៗ គឺមានបំណងងាយស្រួលចុះយន្តហោះចំបាំងដណ្តើមអំណាចពីសីហនុ » ។ នេះគឺជាយុទ្ធវិធីរបស់ចិន (និងយួនហូ-ជីមិញ) ដែលចង់ឲ្យទីជនបទស្រុកខ្មែរនៅដាច់ស្រយាលពីសង្គមដឹកនាំ ពីការទាក់ទងជាមួយទីក្រុង ឲ្យជីវភាពប្រជាជននៅជនបទផ្ទុយគ្នាស្រឡះ ពីជីវភាពរាស្ត្រក្នុងទីក្រុង ក្នុងគោលដៅកុំឲ្យទីជនបទខ្មែររីកចំរើនបាន ដើម្បីទុកឱកាសឲ្យយួននិងខ្មែរក្រហមងាយស្រួលក្នុងការធ្វើឃោសនា ទាក់ទាញរាស្ត្រខ្មែរឲ្យស្រឡាញ់ទ្រឹស្តីក្រហម ដូចដែលម៉ៅ-សេទុងបានធ្វើបានជោគជ័យក្នុងចំណោមប្រជារាស្ត្រចិនក្រីក្រនៅទីជនបទស្រែចំការឯស្រុកចិនពីមុនមកនោះ ។

ដើម្បីផ្គាប់ចិត្តមេដឹកនាំចិននិងព្រមានសហរដ្ឋអាមេរិកផង សម្តេចសីហនុបានបញ្ជាលោកឃឹម-ទិតនាំទាហានហ្លួងស្លៀកពាក់ស៊ីវិល ចេញទៅប្រមូលសិស្សានុសិស្សពីគ្រប់វិទ្យាល័យរដ្ឋនិងឯកជនក្នុងក្រុង (ជាពិសេសសិស្សពីវិទ្យាល័យចំរើនវិជ្ជា-កម្ពុជបុត្រ) ទៅវាយស្ថានទូតអាមេរិកាំង, ស្ថានទូតអង់គ្លេស (ជិតវិមានឯករាជ្យ កាលនោះស្មេរដែលជាសិស្សថ្នាក់ទី៥វិទ្យាល័យស៊ីសុវត្ថិ បានតាមទៅ ហើយឈរមើលលើចិញ្ចើមវិថីព្រះនរោត្តមខាងលិច ឃើញសិស្សមួយក្រុមកំពុងរើកកាយហ្វីលកុនទម្លាក់តាមបង្អួចពីជាន់លើមកក្រោម), វាយបំផ្លាញទីចាត់ការទស្សនាវដ្តីលោកសេរី (ជាប់ខាងត្បូងវិទ្យាល័យស៊ីសុវត្ថិ) ក្នុងឆ្នាំ១៩៦៣ ផ្តាច់«ជំនួយមានចំណាង» របស់សហរដ្ឋអាមេរិក ហើយបង្កើន«ជំនួយឥតចំណាង»របស់ចិនប៉េកាំង រុស្ស៊ី និងប្រទេសកុម្មុយនិស្តដទៃទៀតវិញ ហើយដល់ឆ្នាំ១៩៦៥ សីហនុក៏ផ្តាច់ចំណងទូតជាមួយសហរដ្ឋអាមេរិកជាស្ថាពរតែម្តង ។

ការផ្តាច់ជំនួយសហរដ្ឋបានធ្វើឲ្យសេដ្ឋកិច្ចខ្មែរស្ទះ មានវិបត្តិយ៉ាងធ្ងន់ ។ ថវិកាជាតិត្រូវចុះអោនថយ ព្រោះចំណាយច្រើនជាចំណូល ដោយប្រព័ន្ធដឹកនាំខ្មែរគ្មានប្រសិទ្ធិភាព ។ សម្បត្តិធម្មជាតិមានត្បូងកណ្តៀងត្បូងទទឹម ( Sapphires, rubies ) រាប់កោដិដុល្លារ រត់ពន្ធចេញតាមខេត្តចន្ទបូរី ( ទៅហុងកុង រួចទៅស្វីស ក្រុមហ៊ុនឆ្នៃត្បូងស្វីសស្គាល់ថា ប៉ៃលិនស្ថិតនៅក្នុងស្រុកថៃ ហើយត្បូងកណ្តៀងប៉ៃលិនជាត្បូងជាប់លេខមួយ ) (១៣) ។ រដ្ឋមិនចេះរកប្រយោជន៍ ហើយទុកភោគផលសមុទ្រ

*(១៣) ដីខ្សាច់ជាងហាសិបគីឡូម៉ែត្រក្រឡាមានរ៉ែត្បូងកណ្តៀងខៀវ កណ្តៀងស កណ្តៀងលឿង ( ប៊ុតណាំថង) ត្បូងទទឹម ពេជ្រថៃ ត្បូងតង...។ ឆ្នាំ១៩៧៣ ស្មេរបានទៅរកស៊ីទិញលក់ត្បូងនៅប៉ៃលិន (កុងសៃ) ត្បូងខៀវមិនទាន់ឆ្នៃតូចៗ (ពីរឬបីគ្រាប់ទម្ងន់មួយការ៉ាត) កាលនោះមានគេជីកបានត្បូងខៀវមួយទម្ងន់ជាងបីរយការ៉ាត ទំហំប៉ុនពងមាន់ថៃ អ្នកជីកបានៗតែពីរលានរៀលទេ ត្បូង*

*នោះត្រូវចៅហ្វាយខេត្តកិបឡិបយកបាត់ទៅ ។ រឿងនេះល្បីដល់ភ្នំពេញ លោកអ៊ិន-តាំបានមកមើលតែត្រូវពួកឈ្មួញនិងចៅហ្វាយខេត្តនាំពង្វាង បន្លប់ថាគ្មានត្បូងច្រើនទេ មានតែបន្តិចបន្តួចសំរាប់ឲ្យរាស្ត្រគ្មានរកស៊ីចិញ្ចឹមជីវិតប៉ុណ្ណោះ ។ ថៅកែទិញត្បូងច្រើនមកពីហុងកុង ដូចជាប៉ាំងស៊ុង (មានជាងគេទិញត្បូងគ្រាប់ធំៗ) , ស៊ីគង់ (ទិញត្បូងគ្រាប់ល្អិត) និងមានថៅកែកូឡា ដែលមានដើមកំណើតនៅប៉ៃលិន តាំងតែពីជីដូនជីតាគេមក ដូចជាថៅកែគួន-ជីង មានត្បូងមួយទំហំប៉ុនមុខនាឡិកាដៃ គាត់និយាយថា បានទិញកាលពីឆ្នាំ១៩៤៨ តម្លៃបួនពាន់រៀល ។ រឿងត្បូងប៉ៃលិននេះ ស្រុកខ្មែរគ្មានបានកំរៃបង់ពន្ធចូលរដ្ឋសោះ ។*

ឲ្យយួននិងឈ្មួញសៀមចូលមកកៀរយក ដោយត្រូវគ្នាជាមួយចៅហ្វាយខេត្តខ្មែរ (១៩) ព្រៃឈើត្រូវពួកឈ្មួញសៀមចូលមកកាប់ដោយចៅហ្វាយខេត្ត មានសេក-សំអៀតជាដើមហ៊ុនគ្នាជាមួយសុង-សាក់ ជាមួយពួកឈ្មួញសៀម ។ ការដឹកនាំចេ-ញជ័រកៅស៊ូនិងស្រូវមិនគ្រប់គ្រាន់ឡើយ ។ ថែមពីលើវិបត្តិនេះទៀត តម្លៃជ័រកៅស៊ូត្រូវចុះថោកក្នុងផ្សារអន្តរជាតិទៀត ។ សម្តេចសីហនុ, ដោយជឿស្តាប់តាមគំនិតពួកឆ្វេងនិយមនិងមេដឹកនាំចិន ក៏សំរេចធ្វើជាតូបនិយកម្មសហគ្រាសនានា, ក្រុមហ៊ុនដឹកនាំទំនិញចេញចូល ( Import-Export ) រោងចក្រឯកជន...។ តែអ្នកកាន់ការពុករលួយគ្មានមនសិការជាតិគ្មានការអប់រំហ្វឹកហ្វឺនខាងផ្នែកសេដ្ឋកិច្ច ហើយជំនួយពីប្រទេសកុម្មុយនិស្តក៏មិនគ្រប់គ្រាន់ និងគ្មានគុណភាពថែមទៀត ។ លើសពីនេះទៅទៀតនោះ អង្ករត្រូវចេញតាមផ្សារងងឹត ដោយចិនគួច-អានហ៊ុនគ្នាជាមួយអ្នកម្នាងម៉ូនិច, អ៊ុំ-ម៉ាណូរិន, នាយទាហានខ្លះ, ប្រជាជនខ្លះ នាំយកទៅលក់ឲ្យពួកវៀតកុង យកជាប្រាក់រៀលក្លែងក្លាយសុទ្ធសាធ មិនបានរូបិយប័ណ្ណអន្តរជាតិសោះ ។

កំហុសនយោបាយដ៏ធ្ងន់មួយ គឺការអនុញ្ញាតរបស់សម្តេចសីហនុឲ្យយួនវៀតកុង-វៀតណាមខាងជើង តាំងមូលដ្ឋាននិងទីអគ្គសេនាធិការសឹកលើដីខ្មែរ បានផ្ត-ល់ផលអាក្រក់ច្រើនជាងល្អ ។

ពួកយួនវៀតកុង-វៀតណាមខាងជើងបានបញ្ចេះឲ្យប្រជាពលរដ្ឋខ្មែរលើបះ-បោរទាមទារដីពីខ្មែរ ក្នុងខែឧសភាឆ្នាំ១៩៦៨ និងបង្កើតគាំទ្រផ្គត់ផ្គង់អប់រំពួកខ្មែរក្រហមដែលមានទីតាំងនៅទីជិតៗមូលដ្ឋានគេ ។

ការជួយយួនកុម្មុយនិស្តដែលសម្តេចសីហនុយល់ថា ជាមធ្យោបាយអាចបញ្ចៀសសង្គ្រាមនៅក្នុងស្រុកខ្មែរនោះ ត្រឡប់ជាហុចផលផ្ទុយទៅវិញ គឺទ្រង់បាននាំស-ង្គ្រាមឲ្យរាលដាលចូលមកក្នុងស្រុកខ្មែរទៅវិញសោះ ។

សហរដ្ឋអាមេរិកបានសំរេចតាមកំទេចមូលដ្ឋានអគ្គបញ្ជាការយួនវៀតកុង-វៀតណាមខាងជើងក្នុងដែនដីខ្មែរ ព្រោះគេមានភស្តុតាងគ្រប់គ្រាន់ ក្នុងការដែលរាជាណាចក្រខ្មែរ បានជួយជំរកទាហានយួនវៀតកុង-វៀតណាមខាងជើង ជួយជញ្ជូនផ្គត់អង្ករនិងសម្ភារ:សឹក ដែលយន្តហោះអាមេរិកាំងថតបានជាច្រើន និងបានស្ទូច

*(១៩) មិត្តភក្តិជំនាន់ជាមួយខ្ញុំបានចេញទៅបង្រៀននៅកោះកុងបានឲ្យការណ៍ថា កូនប៉ូលីស អ្នករាជការកំប៉ិកកំប៉ុកឆ្លៀតសុំច្បាប់មានកូនទូកនេសាទ ទូកនោះសំរាប់ជួលឲ្យពួកសៀមចូលមកចាប់ត្រី បង្គារ ក្នុងដែនទឹកខ្មែរ ដល់ខែចាំតែទទួលកំរៃចំនួនពីរម៉ឺនរៀល ចំពោះកូនទូកដាក់ម៉ាស៊ីនតូចមួយ (ឆ្នាំ១៩៦៧) ។*

យកទាំងឡានដឹកអង្ករ ថ្នាំពេទ្យ សាស្ត្រាវុធទៅឲ្យវៀតកុងនោះផង ។

សហរដ្ឋអាមេរិកប្រើយន្តហោះបេ-៥២ ឲ្យទៅទម្លាក់គ្រាប់បែកតាមព្រំដែនខ្មែរ-វៀតណាមខាងត្បូង ហៅថា «ប្រតិបត្តិការសឹកអាហារពេលព្រឹក Operation Breakfast » ហើយបន្ថែមដោយ « ប្រតិបត្តិការអាហារថ្ងៃត្រង់, ប្រតិបត្តិការអាហារពេលល្ងាច »...។ល។ ជាបន្តបន្ទាប់ហូរហែ ។

យល់គ្រោះអាសន្នមកដល់ សម្តេចសីហនុក៏យល់ព្រមសុខចិត្តភ្ជាប់ចំណងទូតជាមួយសហរដ្ឋអាមេរិកវិញក្នុងខែមិថុនាឆ្នាំ១៩៦៩ ។

សម្តេចសីហនុកាលនោះដោយទោរទន់ទៅតាមអ្នកម្នាងម៉ូនិច ដែលចង់ឲ្យសីហនុធ្វើពិធីរាជាភិសេក (ដើម្បីខ្លួនបានឡើងជាអគ្គមហេសីពេញយស) និងហាក់ដូចជាចង់ដកខ្លួនពីនយោបាយមកសោយរាជ្យជាស្តេចវិញ ដោយគ្រប់ពិធីច្រតព្រះនង្គ័ល សម្តេចសីហនុចេញមុខទទួលធ្វើ និងយកអ្នកម្នាងចេញមុខ ឲ្យប្រជារាស្ត្រខ្មែរបានស្គាល់គ្រប់គ្នាផងក្នុងពិធីនោះ នៅគ្រប់ខេត្តក្នុងស្រុកខ្មែរ ។

ដោយអស់ផ្លូវនឹងដេញទ័ពវៀតកុង-វៀតណាមខាងជើងចេញពីដែនដីខ្មែរនោះ សម្តេចសីហនុក៏រកលេសចេញទៅព្យាបាលជម្ងឺនៅឯប្រទេសបារាំង នៅថ្ងៃទី៦ មករា ១៩៧០ ។ បើតាមការពិតវិញនោះ គឺសម្តេចសីហនុចេញទៅរកការអង្វរករសុំឲ្យមេដឹកនាំចិន រុស្ស៊ីធ្វើសម្ពាធបង្ខំឲ្យកងទ័ពយួនកុម្មុយនិស្តដកថយចេញផុតពីដែនដីខ្មែរ ។ ប្រាកដណាស់ គឺនៅដើមឆ្នាំ១៩៧០នេះឯង ដែលសម្តេចឈ្វេងយល់ថា « សង្គ្រាមបានរាលដាលចូលមកក្នុងប្រទេសខ្មែរហើយៗទ្រង់បានបញ្ចេញកំហឹងជាសាធារណៈប្រឆាំងនឹងពួកកុម្មុយនិស្ត (2) » ។

ឆ្លៀតពេលនោះទ្រង់សិរិមតៈដែលមានទំនាស់រាជវង្សជាមួយសីហនុ (១៥) ប្រណែន ក៏រួមដៃជំរុញលោកលន់-នល់ជាមិត្ត ដោយមានការគាំទ្រពីក្រុមសឺង-ង៉ុកថាញ់ផង ឲ្យទម្លាក់សីហនុ ដោយបង្កើតឲ្យមានបាតុកម្មទាមទារឲ្យយួនវៀតកុង-វៀតណាមខាងជើងដកថយចេញពីដែនដីខ្មែរ និងការវាយស្ថានទូតវៀតកុងនិងស្ថានទូតវៀតណាមខាងជើង (១៦) នៅក្រុងភ្នំពេញ ។

*(១៥) តាមច្បាប់រាជត្រកូលខ្មែរ ក្រោយហ្លួងស៊ីសុវត្ថិ-មុនីវង្សសុគតដោយស្ទះ ព្រោះសៀមយកខេត្តបាត់ដំបង សៀមរាបនោះ ត្រូវស៊ីសុវត្ថិ-មុនីរ៉េតឡើងសោយរាជ្យ តែបារាំងយល់ឃើញថាទ្រង់មុនីរ៉េតជាមនុស្សចាស់ ពិបាកពត់ឲ្យបំរើផលប្រយោជន៍បារាំងនោះ បារាំងក៏សំរេចយកសិស្សនៅព្រៃនគរ, នរោត្តម-សីហនុ, ព្រះជន្ម១៧ឆ្នាំមកសោយរាជ្យវិញ ព្រោះជាក្មេងងាយស្រួលពង្វក់បញ្ឆោរដឹក ។ នេះហើយជាទំនាស់រាជវង្សខ្មែរ រវាងខ្សែនរោត្តមដែលមានសីហនុជាតំណាង និងវង្សស៊ីសុវត្ថិ (ស៊ីសុវត្ថិសិរិមតៈជាតំណាង) ក្នុងវិបត្តិនយោបាយខ្មែរ ជាបុព្វហេតុមួយដែរ ក្នុងការទម្លាក់សម្តេចសីហនុនេះ ។ ការដែលបារាំងយកសម្តេចសីហនុមកសោយរាជ្យនោះ គឺចង់យករាស្ត្រខ្មែរទាំងមូលទុកជាកញ្ជះបារាំង ការនេះដូចគ្នានឹងវៀតណាម ដែលយកហ៊ុន-សែនលើកឡើងឲ្យធ្វើជានាយករដ្ឋមន្ត្រីខ្មែរសព្វថ្ងៃដែរ ។*

*(១៦) ការដែលសិស្សចូលទៅវាយស្ថានទូតនោះ គេយកបានឯកសារសម្ងាត់យួន ដែលសិក្សាពីចំណុចខ្សោយរបស់នាម៉ឺនខ្មែរ មេដឹកនាំខ្មែរថា « មេដឹកនាំខ្មែរ នាយទាហានខ្មែរ មន្ត្រីខ្មែរ ចូលចិត្តលុយលេខមួយ ស្រីលេខពីរ បក្សពួកនិងអំណាចលេខបី » ។ ឯកសារនោះត្រូវក្រសួងសម្ងាត់ខ្មែរគេបំបិទចោលបាត់ទៅ មិនយកមកសិក្សា ឬផ្សព្វផ្សាយឲ្យរាស្ត្រខ្មែរ ឬមេដឹកនាំខ្មែរដឹងឡើយ ។*

# រដ្ឋប្រហារទំលាក់សម្តេចសីហនុ

ដប់ថ្ងៃចុងក្រោយក្នុងឋានៈជាប្រមុខរដ្ឋខ្មែរ សម្តេចសីហនុមិនទាន់សំរេចចិត្តយ៉ាងណានៅឡើយទេ ។ បុព្វហេតុជំរុញលោកលន់-នល់និងទ្រង់សិរិមតៈយកមកប្រើនោះ ក៏នៅតែមិនច្បាស់ជាអ្វីដែរ ។ នៅថ្ងៃទី៨មិនា១៩៧០ មានបាតុកម្មប្រឆាំងកងទ័ពយួនវៀតកុង-វៀតណាមខាងជើង ដែលតាំងនៅលើដីខ្មែរ ជាពិសេសនៅតំបន់ចំពុះសេកតែម្តង ដែលយន្តហោះបេ-៥២បានធ្វើការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរ (3) ។

សម្តេចសីហនុដែលយាងចេញទៅទីក្រុងប៉ារីស៍ ថាដើម្បីទៅព្យាបាលរោគនោះ គឺមកពីទ្រង់មានកំហុសទទាក់ទទាមក្នុងការឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើងតាំងមូលដ្ឋានលើដែនដីខ្មែរ ហេតុនេះទ្រង់ត្រូវតែដកឃ្លាសិន ទុកឱកាសឲ្យលោកលន់-នល់ចាត់ការបណ្តេញកងទ័ពយួនកុម្មុយនិស្តចេញសិន រួចស្តេចសីហនុនឹងយាងវិលត្រឡប់មកស្រុកខ្មែរវិញ ហើយបានរួចខ្លួនពីការចោទប្រកាន់ផ្សេងៗ បានព្រះនាមថ្មីមួយទៀតថា «បិតាដេញយៀកកុង» ពីដែនដីខ្មែរ តែសីហនុមិននឹកដល់ទេថា ទ្រង់សិរិមតៈបានរួមគ្នាជាមួយលន់-នល់ គ្រោងរៀបចំទម្លាក់ទ្រង់ពីប្រមុខរដ្ឋខ្មែរសោះ ។

តាមការពិតទៅវិញនោះ លោកលន់-នល់និងទ្រង់សិរិមតៈ បានធ្វើការទាក់ទងជាមួយសឺង-ង៉ុកថាញ់រៀងរហូតមក ។ ជាឧទាហរណ៍ក្នុងចុងឆ្នាំ១៩៥៨ ពេលដែលសម្តេចសីហនុបញ្ជាឲ្យកងយោធពលខេមរភូមិន្ទ ទៅព័ទ្ធចាប់ដាប-ឈួននៅសៀមរាប និងនៅថ្ងៃទី២០មករា១៩៥៩ ចាប់បក្សពួកលោកសឺង-ង៉ុកថាញ់ទាំងអស់នៅទីក្រុងភ្នំពេញនោះ លោកលន់-នល់បានឲ្យលោកលាវ-ធានស៊ឺ (ចាងហ្វាងវិទ្យាល័យឯកជនខេមរា) គេចដោះខ្លួនមួយរយៈសិន ហើយទៅធ្វើការទាក់ទងគ្នាជាមួយលោកសឺង-ង៉ុកថាញ់នៅឯវៀតណាមខាងត្បូង ។ តែលោកសឺង-ង៉ុកថាញ់បានឲ្យលោកលាវ-ធានស៊ឺវិលចូលមកស្រុកខ្មែរវិញធ្វើជារនុកក្នុង ព្រោះជិតដិតនឹងលោកលន់-នល់ ។ ឯគំរោងការទម្លាក់សម្តេចសីហនុ ក៏រៀបចំដោយលោកសឺង-ង៉ុកថាញ់ដែរ តែទ្រង់ស៊ីសុវត្ថិ-សិរិមតៈ ដែលចង់ធ្វើស្តេចដោយច្រណែននឹងសីហនុនោះ ក៏រៀបចំទម្លាប់សីហនុដែរ គឺបានសំរេចឲ្យធ្វើគតសម្តេចតែម្តង តែលន់-នល់មិនយល់ព្រមតាម ទុកឲ្យសម្តេចយាងចេញទៅក្រៅប្រទេសខ្មែរសិន ទើបទម្លាក់ទ្រង់ជាក្រោយ ដូចជាលោកលន់-នល់រុញសម្តេចសីហនុ ឲ្យចូលរួមជាមួយខ្មាំងសត្រូវរបស់ប្រទេសខ្មែរ (យួនខាងជើងនិងខ្មែរក្រហម) តែម្តង ។

ថ្ងៃទី៤ ដល់៩ ខែមករាឆ្នាំ១៩៦៨ ក្នុងគំរោងការរៀបចំនេះ (១៧) លោកសឺង-

*(១៧) ខ្មែរសេរី២០៥នាក់សុំចុះចូលតាមខេត្តបាត់ដំបង មានទាំងក្បួនច្បាប់តស៊ូ ក្បួនឃោសនាមកជាមួយផង ចែកចាយដល់ទាហានខ្មែរឲ្យភ្ញាក់រលឹក ។ ក្នុងអត្ថបទឃោសនាមានថែងពីគ្រោះថ្នាក់នៃនយោបាយខុសរបស់សីហនុ ។ ក្រោយពីបានអានអត្ថបទទាំងពីរនោះខ្លះៗមក ពេលយាងចាប់ដៃនាយទាហានខ្មែរសេរីចុះចូលនោះ សីហនុហាក់ដូចជាយល់ពីកំហុសនយោបាយទ្រង់ដែរ ទើប*

*សម្ដេចទ្រង់ព្រះសន្សៀង (យំ) ជាខ្លាំង នៅនឹងមុខនាយទាហានខ្មែរសេរីចុះចូល និងនាយទាហានខេមរភូមិន្ទ ។ ទ្រង់មានបន្ទូលថា ៖ « ហេតុអ្វីបានជាខ្មែរបែកបាក់គ្នា ខ្លះជាខ្មែរក្រោម ខ្លះជាខ្មែរកណ្ដាល នេះមកតែពីមនោគមបរទេស » ។ ទាហានខ្មែរសេរីចុះចូលនោះគឺមាន៩៨នាក់ ដឹកនាំដោយលោកតោ-ខាញ់ មកពីបុសអំពៅ, ១០៧នាក់ដឹកនាំដោយលោកថាច់-សួន មកពីប៉ុស្តិ៍ថ្កូវ, ១២០នាក់ជាក្រុមចល័តដឹកជញ្ជូនស្បៀង អាវុធ និងប្រាក់ខែ នៅប៉ុស្តិ៍កាប់ជើង ។*

ង៉ុកថាញ់បានឲ្យទ័ពខ្មែរសេរីនៅស្រុកសៀមធ្វើជាមកសុំចុះចូល ហើយកាលនោះសម្ដេចសីហនុបានធ្វើពិធីទទួលពួកគេ ដែលមានលោកថាច់-សួនជាតំណាងខ្មែរសេរី នៅក្នុងបរិវេណវាលមេរុ ។ ក្នុងកងទ័ពខ្មែរសេរីនោះ មានលោកស៊ិន-គិននៅក្នុងនោះផងដែរ ដែលបានឃើញសម្ដេចសីហនុទ្រង់ព្រះកន្សែង(យំ) មកពីទ្រង់ហាក់ដូចជាយល់ឃើញពីកំហុសនយោបាយខុសរបស់ទ្រង់ខ្លះៗដែរ ក្នុងរឿងខ្មែរបែកបាក់គ្នានេះ ។

សម្ដេចសីហនុបានវាយខ្សែរលួសមកថា ទ្រង់នឹងចូលមកស្រុកខ្មែរវិញ ដើម្បីយកលោកលន់-នល់និងទ្រង់សិរិមតៈ ឲ្យទៅឆ្លងឆ្លើយគ្នានៅនឹងមុខប្រជារាស្ត្រ ។ សីហនុបានសំរេចថា នឹងយាងនិវត្តន៍ចូលភ្នំពេញវិញនៅថ្ងៃទី១៨ មិនា ១៩៧០ ។ ថ្ងៃនោះពួកសីហនុនិយមបានយកទង់ជាតិទៅដោតហូរហែរ តាមដងផ្លូវមិត្តភាពខ្មែរ-សូវៀត តាំងពីវាលចំណតយន្តហោះពោធិចិនតុង រហូតដល់ក្រុងភ្នំពេញ ។ ម្នាក់ៗនឹកថា លោកលន់-នល់និងទ្រង់សិរិមតៈ មុខជានឹងទទួលទារុណកម្មក្នុងការរឹងទទឹងប្រុងធ្វើរដ្ឋប្រហារនេះ ។ ក្នុងពេលជាមួយគ្នានោះ ក្រុមសីហនុនិយមនិងក្រុមប្រឆាំងសីហនុ កំពុងគៀកគរគ្នាដើរប្រមូលរកកម្លាំងគាំទ្រ (4) ។

ពួកប្រឆាំងជាមួយសម្ដេចសីហនុមានលោកលន់-នល់, ទ្រង់ស៊ីសុវត្ថិ-សិរិមតៈ និងកងទ័ពជាតិ បុគ្គលិកខុទ្ទកាល័យ ព្រមទាំងរដ្ឋសភាផង ។ ឯពួកគាំទ្រសម្ដេចសីហនុមានអ៊ុំ-ម៉ាណូរិន (បងថ្លៃសម្ដេច), ខែក-វ៉ាន់ឌី, នាយទាហានបីនាក់, គូ-រុន និងកងប៉ូលីស, លេខាធិការកងទ័ពជើងគោកនិងសុស្ដែន-ហ្វែរណង់ដែស និងពួកអភិបាលខេត្តភាគច្រើន (5) (ជាពិសេសសេក-សំអៀត) ។

ក្នុងភាពអាសន្ននោះ លោកលន់-នល់បានចាត់ឲ្យលោកវរសេនិយឯកសេង-ស៊ុនថៃ (១៨) ចាត់ចែងការពារទប់ទល់ ក្រែងមានចលាចលបាញ់គ្នារវាងគ្នាឯង និងរៀបចំទប់ទល់ជាមួយកងទ័ពយួនវៀតកុង-វៀតណាមខាងជើងផង ។

*(១៨) ក្នុងចំណោមនាយទាហានជំនាន់ទី១និងទី២ មានតែលោកសេង-ស៊ុនថៃទេ ដែលមានប្រាជ្ញាឈ្លាសវៃ ស្មោះត្រង់ និងមានគំនិតសាធារណរដ្ឋនិយមផង ។ សូមបញ្ជាក់ដែរថា នាយទាហានខ្មែរជំនាន់ទី១ មានលោក ៖ ស្រី-សាម៉ន, អ៊ុយ-សយ, ហ៊ុល-ឃុន (ជាកូនលោកប៊ូ-ហ៊ុលជិតដិតនឹងសីហនុ), ផេង-ផាន់អ៊ី, ឋាប្បនា-ងិន, ឆាយ-ឡាយ, ហ៊ូ-ថ្វក, សក់-ស៊ុតសាខន, ប៉ុក-សំអាន ។ នាយទាហានជំនាន់ទី២មាន ៖ លោកសេង-ស៊ុនថៃ, ពៅ-លឹមវ៉ា, ក្រូច-សំរេច, សុស្ដែន-ហ្វែរណង់ដែស(ជាប់ខ្សែលោហិតពីពួកក្រុមផ្សងព្រេងព័រទុយហ្គេស អេស្ប៉ាញ៉ុល) អ៊ុំ-ម៉ាណូរិន (បានត្រូវសីហនុតម្លើងសក្ដិ ពីនាយចំណង់, ដោយ, មកជានាយទាហានក្នុងឆ្នាំ១៩-៥២ ដោយសីហនុសព្វព្រះទ័យនឹងនាងកញ្ញាម៉ូនិច-អ៊ីស៊ី ឪពុកជាតិអ៊ីតាលី ជាប្អូនលោកអ៊ុំ-ម៉ាណូរិន ឪពុកសក្ដិបីអ៊ុំ, ឪពុកផ្សេងគ្នាម្ដាយជាមួយ), និងដួង-ច័ន្ទសារ៉ាត ។*

*ក្រុមនាយទាហានដែលគាំទ្រសម្ដេចសីហនុទាំងបីមានលោក ៖ ហ៊ុល-ឃុន, ផេង-ផាន់អ៊ី និងក្រូច-សំរេច ។ តាមសេចក្ដីឲ្យការណ៍របស់លោកប៉ោ-ថន ថា ៖ លោកក្រូច-សំរេចប្រុងយកកាំភ្លើងម៉រជេបីដើមបាញ់ផ្ដក់ផ្ដោងចូលផ្ទះលោកលន់-នល់ ក្នុងផែនការធ្វើឃាតលោកសេង-ស៊ុនថៃនោះ ។ អត្តចរិតរបស់លោកសេង-ស៊ុនថៃ គឺមិនងាយទុកចិត្តនរណា ហើយមិនដែលទៅផ្ទះនរណាទាំងឯកសណ្ឋានសោះឡើយ លើកលែងតែមិត្តជិតដិតលោកម្នាក់ឈ្មោះប៊ូ-កាបូ ។ លោកលន់-ណុនបានឲ្យពួកអាវុធហត្ថ (ក្រុមកូសដៃឆៅសំរាប់លន់-ណុន ប្រើកំចាត់នរណា នាម៉ឺនណាដែលហ៊ានប្រឆាំង) បួននាក់មកចូលរួមដៃចាត់ចែងឃាតកម្ម លើរូបលោកសេង-ស៊ុនថៃនេះ ។ យប់នោះគឺថ្ងៃទី២១ មិនា ១៩៧០ ក្រោយការប្រកាសទម្លាក់សីហនុបីថ្ងៃ ។ លោកប៉ោ-ថនដែលបាននៅជាប់នឹងលោកសេង-ស៊ុនថៃ បានលាចេញទៅរកស្រស់ស្រូបបាយសិន នៅម៉ោង៨យប់ ព្រោះអត់ពេញមួយថ្ងៃមកហើយ តែមុននឹងចេញបានផ្ដាំផ្ញើហ្វាយគាត់ថា «កុំឲ្យចេញទៅក្រៅឲ្យសោះ ទោះជានរណាមកហៅក៏ដោយ សុំឲ្យលោកប្រយ័ត្នខ្លួន» ។ លោកសេង-ស៊ុនថៃដោយអស់កម្លាំងពេក បានទាញប៉ៅអ៊ីបត់មកទំរេកខ្លួនសំរាកយកកម្លាំងបន្តិច ។ តើក្រុមនេះគេរៀបចំផែនការយ៉ាងណា ដើម្បីឲ្យលន់-ណុនបានរួចខ្លួន ? ។*

*ពួកក្រុមលោកហ៊ុល-ឃុន និងពួកកូសរបស់លន់-ណុនទាំងបួន បានទៅបាញ់សម្លាប់លោកប៊ូ-កាបូនៅឯផ្ទះលោក រួចបើករថយន្តរបស់លោកប៊ូ-កាបូ មកឃ្លាំចាំនៅជិតទីអគ្គសេនាធិការផ្ទះលោកលន់-នល់ រង់ចាំឱកាសល្អ ។ គឺពេលាដែលលោកប៉ោ-ថនបានចេញទៅរកស្រស់ស្រូបបាយនោះឯង ដែលពួកឃាតករបានបើកឡានចូលទៅភ្លាម ។ ក្រុមកូសដៃឆៅម្នាក់បានស្រែកពីក្នុងឡានមកថា « សូមតេជគុណអញ្ជើញឡើងឡាន! លោកកាបូឲ្យខ្ញុំបាទមកទទួល!» ។ ងាកទៅឃើញច្បាស់ជាឡានលោកកាបូជាមិត្តជិតដិតមែន ក៏គ្មានការសង្ស័យបន្តិចសោះ ។ លោកសេង-ស៊ុនថៃក៏ព្រមឡើងឡានដោយគ្មានបានផ្ដាំទាហានណាម្នាក់ថា លោកទៅទីណាសោះ ។ នៅលើរថយន្ត ក្រុមកូសដៃឆៅរបស់លន់-ណុន ក៏គ្រៀកវាយបំបាក់កសម្លាប់លោកសេង-ស៊ុនថៃទៅរួចហើយពួកគេក៏យកសាកសពលោកសេង-ស៊ុនថៃ ទៅដាក់នៅលើផ្ទះលោកសេង-ស៊ុនថេង ( បងបង្កើតលោកស៊ុនថៃ តែបានទទួលគ្រោះថ្នាក់ឡានចំនួនបីឆ្នាំមុនមកហើយ ហើយផ្ទះនោះនៅទំនេរ លោកសេង-ស៊ុនថៃជាអ្នកទទួលរាប់រងរក្សា) នៅផ្លូវកម្ពុជាក្រោម ទល់មុខផ្ទះលោកប៊ូ-កាបូ ។ នៅលើផ្ទះគេរៀបចំដបស្រា មានកែវបួន ចានបបរពេញចំនួនបួន ។ ពួកគេបានយកកាំភ្លើងរបស់លោកប៊ូ-កាបូ មកបាញ់សពលោកសេង-ស៊ុនថៃ ពីថ្ពាល់ខាងស្ដាំធ្លាយមកចំហៀងក្បាលខាងក្រោយ ផ្នែកខាងឆ្វេង ។ កាំភ្លើងនោះគេដាក់ផ្ទាប់និងសាច់សាកសព រួចទើបបានគេកេះកៃបាញ់ (អ្នកបាញ់គឺលោកហ៊ុល-ឃុន) ព្រោះតាមការសង្កេតឃើញ រន្ធគ្រាប់ចូលតូចទំហំប៉ុនគ្រាប់ឯរន្ធចេញធំ ។ គេយកកាំភ្លើងរបស់លោកប៊ូ-កាបូ ដើម្បីឲ្យគេជឿថា ទាំងពីរនាក់ឈ្លោះគ្នាមែនតែវាមិនសមត្រង់ថា មនុស្សអង្គុយទល់មុខគ្នា គ្រាប់បាញ់ចូលតាមថ្ពាល់ខាងឆ្វេង ទើបត្រូវនឹងរឿងប្រឌិតនេះ ហើយមួយទៀតអ្នកស្រុកដែលនៅជិតខាងផ្ទះនោះបានឲ្យការណ៍ថា គេបានឮស្នូរកាំភ្លើងតែមួយគ្រាប់គត់ ។*

*(១៨) (ត) ពួកគេបង្កើតលើករឿងក្លែងថា «លោកសេង-ស៊ុនថៃបានផឹកស្រាស្រវឹង ហើយឈ្លោះគ្នាជាមួយលោកប៊ូ-កាបូ រួចហូតកាំភ្លើងបាញ់គ្នាទៅវិញទៅមក ស្លាប់តាំងពីរនាក់ទៅ ។*

*ម៉ោងប្រាំបួនយប់ថ្ងៃទី២១មិនាដដែលនោះ លោកប៉ោ-ថនបានវិលត្រឡប់មកវិញ ហើយសាកសួរនរណាក៏មិនដឹងថា លោកសេង-ស៊ុនថៃទៅទីណាសោះឡើយ ។ លោកប៉ោ-ថនក៏ឆោឡោជាមួយលោកច័ន្ទ-ណុន ហើយទូរស័ព្ទទាក់ទងជាមួយលោកប៊ូ-យ៉ាន រកអស់មួយម៉ោងទៀតក៏នៅតែមិនដឹងថាលោកសេង-ស៊ុនថៃទៅទីណា ។ លោកប៉ោ-ថនបានតាមរករហូតដល់នាក់លឿងជាមួយលោកច័ន្ទ-ណុន រហូតដល់ម៉ោង១២អាធ្រាត្រ ។ នៅម៉ោងពីរមានទាហានមកតាមទៅស្រស់ស្រូបបបរសិន រួចព្រឹកឡើងម៉ោង៦ ក៏នាំគ្នីគ្នាចេញតាមរកទៀត មកប៉ែកខាងលិចម្ដង ហើយមកជួបលោកជុំ-សាវ៉ននៅអង្គស្នួល ក៏នៅតែគ្មានដំណឹងពីលោកសេង-ស៊ុនថៃទៀត ហើយ*

*បានវិលត្រឡប់មកលំនៅលោកលន់-នល់វិញនៅម៉ោងបីរសៀល ។ នៅម៉ោងបួនល្ងាច លោកហ៊ុល-ឃុនបានហៅលោកប៉ោ-ផនទៅផ្ទះលោក រួចសំឡុតទារយកកូនសោរទូដែកដើម្បីចាក់យកឯកសារ ហើយបានប្រាប់ថា ៖ « អាសេង-ស៊ុនថៃវាស្លាប់ហើយ ដោយវាចាញ់សំបថ ឲ្យទៅយកសពវាមកចុះនៅឯផ្ទះលោកសេង-ស៊ុនថេង ឯផ្លូវកម្ពុជាក្រោមឯណោះ » ។ លោកប៉ោ-ផនបានចាកចេញទៅជាមួយលោកសរ-បួន ទៅយកសពលោកសេង-ស៊ុនថៃមកដឹកលំ ។*

ដើម្បីឲ្យសម្ដេចសីហនុយាងចូលមកកម្ពុជាវិញ ដោយគ្មានឧបសគ្គនោះ ក្នុងរាត្រីថ្ងៃទី២១មិនា១៩៧០ ក្រុមលោកហ៊ុល-ឃុនបានរៀបចំផែនការណ៍ធ្វើឃាតលោកសេង-ស៊ុនថៃយ៉ាងស្ងាត់ ។ រឿងឃាតកម្មដ៏អាថ៌កំបាំងលើរូបលោកសេង-ស៊ុនថៃនេះ មានទាំងលន់-ណុន (លន់-នល់យល់ព្រមផងដែរ) ចូលរួមដៃ ដោយបានយកក្រុមសីហនុនិយម មកធ្វើជាខែលបឹទបាំងអំពើដ៏គំរុកនេះ ។ សម្ដេចប្រុងនឹងចូលទៅក្រុងសៀមរាប តែពួកលោកលន់-នល់បានយកធុងសាំង ទៅដាក់ពាសពេញផ្លូវកុំឲ្យយន្ដហោះចុះកើត មួយថ្ងៃក្រោយពីឃាតកម្មលើរូបលោកសេង-ស៊ុនថៃនោះមក, លោកលន់-នល់បានចេញបញ្ជាឲ្យឃាត់ខ្លួននាយទាហានទាំងអស់ ជាពិសេសពួកដែលមានការទាក់ទិននឹងឃាតកម្មនេះ ទើបចលនាគាំទ្រសីហនុប្រឆាំងលន់-នល់បានស្ងប់ស្ងាត់ទៅវិញ ។

ហេតុអ្វីបានជាលន់-ណុននិងលន់-នល់ សំរេចចិត្តសម្លាប់លោកសេង-ស៊ុនថៃ ដែលជួយលោកទៅវិញ ក្នុងការទម្លាក់សីហនុពីឋានៈប្រមុខរដ្ឋនោះ ?

គួររំលឹកឡើងវិញដែរថា កាលដែលលោកសឺង-ង៉ុកថាញ់វិលត្រឡប់ពីជីវភាពនិរទេសឯស្រុកបារាំង ហើយចូលព្រៃភ្នំដងរែក ធ្វើការតស៊ូវាយអាណានិគមបារាំងទាមទារឯករាជ្យនោះ លោកស័ក្តិពីរដួង-ច័ន្ទសារាត បាននាំទាហាន១៥០ឡាន កាំភ្លើងរត់ទៅចូលជាមួយ ។ ឯសេង-ស៊ុនថៃក៏នាំទាហានរត់ទៅតាមលោកសឺង-ង៉ុកថាញ់ដែរ តែត្រូវបារាំងតាមទាន់នៅត្រង់ភ្នំត្បែងមានជ័យ (ឈប់ឲ្យកាន់ទាហានតាំងពីនោះ) ។

ហេតុដែលលន់-នល់និងលន់-ណុនចំរេចធ្វើឃាតលោកសេង-ស៊ុនថៃ ក៏ព្រោះតែខ្លាចលោកសេង-ស៊ុនថៃធ្វើរដ្ឋប្រហារយកអំណាចទៅឲ្យលោកថាញ់វិញនោះឯង ។ ហេតុដែលខ្ញុំហ៊ានអះអាងយ៉ាងនេះ ព្រោះលោកស៊ឹម-គិន (ជួបសម្ភាសន៍ជាមួយលោកសំអឿននៅកាលីហ្វ័រនិញ៉ា១៩៨៨) បានឲ្យការណ៍ថា ៖ « ដោយនៅតែមិនទុកចិត្ត លោកលន់-នល់ក៏សាកសួរលោកឡឹក-សំអឿន ដែលទើបចុះពីស្រុកថៃទៅនោះថា តើលោកថាញ់មានចំណង់ដណ្ដើមមុខនាទីប្រមុខរដ្ឋ ឬប្រធានាធិបតីស្រុកខ្មែរនេះឬទេ ? » ។ លោកសំអឿនក៏ឆ្លើយតបវិញថា ៖ « គោលដៅរបស់លោកថាញ់ គឺឲ្យតែស្រុកខ្មែរបានក្លាយទៅជាសាធារណរដ្ឋ នោះលោកសប្បាយចិត្តណាស់ទៅហើយ ទោះជានរណាបានកាន់អំណាចក៏ដោយ វាគ្មានសារៈសំខាន់អ្វីចំពោះលោកទេ ! » ។ តែក្រុមលន់-ណុន/លន់-នល់នៅតែមិនជឿលោកទៀត រហូតពួកគេនាំគ្នាបំបែកទាហានខ្មែរក្រោម « ម៉ែកហ្វ័ក Mike's Force » ខ្ទេចខ្ទី ហើយពួកគេនៅមានការសង្ស័យលើរូបលោកឧត្ដមសេនិយ អ៊ុំ-សាវុត ថែមទៀត ដែ-

លឧស្សាហ៍មកលេងសាកសួរសុខទុក្ខលោកសឹង-ង៉ុកថាញ់ ។ លន់-ណុនក៏សំរេចសម្លាប់លោកអ៊ុំ-សាវុតចោលម្នាក់ទៀត គឺបីថ្ងៃក្រោយដែលលោកអ៊ុំ-សាវុធមកភ្នំពេញតាមការកោះហៅរបស់លន់-នល់មកប្រាប់ថា ខ្លួនគាត់មិនមែនពិការទាំងអស់ទេ គឺគាត់អាចមានកូនដូចគេឯងដែរ ។ កាលនោះជាលើកទី៨ហើយ ដែលលោកអ៊ុំសាវុតឈោងចូលទៅលេងសួរសុខទុក្ខលោកសឹង-ង៉ុកថាញ់ និងទទួលឱវាទពីការស្នេហាជាតិ ពលិកម្មដើម្បីជាតិពីលោកថាញ់ ។ ក្នុងឃាតកម្មលើរូបលោកអ៊ុំ-សាវុតនេះ លន់-ណុនបានរៀបចំឆាកថា លោកអ៊ុំ-សាវុតបានទទួលគ្រោះដល់ស្លាប់ ដោយគ្រោះថ្នាក់ក្រឡាប់ឡានទៅវិញ ។

នៅថ្ងៃទី១៣មិនា១៩៧០ សម្តេចសីហនុក៏សំរេចចិត្តយាងចេញពីក្រុងប៉ារីស៍ទៅមូស្គូដើម្បីសុំជំនួយគាំទ្រ ។ ពួកមេដឹកនាំសូវៀតបានឃាត់សីហនុឲ្យនៅក្រុងមូស្គូ កុំយាងទៅប៉េកាំធ្វើអ្វី តែសីហនុមិនព្រម ព្រោះមេដឹកនាំសូវៀតគ្មានបានសន្យាថា នឹងយកអំណាចមកឲ្យទ្រង់វិញសោះ សីហនុក៏សំរេចចិត្តបន្តដំណើរឆ្ពោះទៅក្រុងប៉េកាំងតែម្តង ។ កាលនោះមេដឹកនាំក្រុងប៉េកាំងនៅទ្រឹងមួយសន្ទុះដែរ ដោយគេឲ្យពួកទូតចិននៅភ្នំពេញ ធ្វើការតថ្លៃជាមួយលោកលន់-នល់បន្តិចទៀតសិនក្រែងបានផល ។

ក្រោយថ្ងៃទី១៨មិនា១៩៧០ ចិនប៉េកាំងនៅមិនទាន់ផ្តាច់ចំណងទូតជាមួយប្រ-ទេសខ្មែរនៅឡើយទេ ។ អ្នកតំណាងការទូតចិនប៉េកាំងបានធ្វើការទាក់ទងជួបតថ្លៃជាមួយលោកលន់-នល់ជាច្រើនដង ស្នើសុំឲ្យរដ្ឋាភិបាលខ្មែរនៅបន្តជួយកងទ័ពវៀតកុង-វៀតណាមខាងជើងតទៅទៀត ដូចដែលរាជរដ្ឋាភិបាលខ្មែរសម័យសម្តេចសីហនុបានធ្លាប់ធ្វើកាលពីមុនមកនោះ ។ តំណាងទូតចិនបាននិយាយថា ៖ « ការទំលាក់សម្តេចសីហនុជារឿងផ្ទៃក្នុងរបស់ខ្មែរទេ... ក្រុងប៉េកាំងមិនរវីរវល់ជាមួយសម្តេចសីហនុទេ ហើយចិននៅតែបន្តគោរពរដ្ឋអំណាចខ្មែរតទៅទៀតបើ ៖

១- ខ្មែរព្រមអនុញ្ញាតផ្តល់សម្ភារៈសឹក សាស្ត្រាវុធ ថ្នាំពេទ្យ ពីស្រុកចិនទៅឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលប្រទេសកម្ពុជាធ្លាប់ធ្វើពីមុនមក ដើម្បីឲ្យវៀតណាមអាចបន្តធ្វើសង្គ្រាមជាមួយអាមេរិកាំង វាយរំដោះយកវៀតណាមខាងត្បូងឲ្យបាន ។

២- ខ្មែរនៅតែអនុញ្ញាតឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើង តាំងនៅលើទឹកដីខ្មែរតទៅទៀត ។

៣- ខ្មែរនៅតែបន្តធ្វើការឃោសនាគាំទ្រមិត្តយួនវៀតកុង-វៀតណាមខាងជើងដូចមុនទៀត

ក្រោយពីជួបចរចាជាមួយលន់-នល់ជាច្រើនដង រហូតដល់ថ្ងៃទី៥ឧសភា១៩-៧០ គឺមួយខែម្ភៃថ្ងៃក្រោយទម្លាក់សីហនុរួច... តំណាងទូតចិនយល់ឃើញថា គ្មានការរីកចំរើនគួរជាទីពេញចិត្តសោះនោះ គេក៏ឲ្យដំណឹងទៅប៉េកាំងៗក៏សំរេចប្រកាសផ្តាច់ចំណងទូតជាមួយប្រទេសខ្មែរ រួចហើយចិនក៏ងាកមកគាំទ្រ ទទួលស្គាល់និងសន្យាថា យកអំណាចមកថ្វាយទ្រង់វិញ តែសម្តេចសីហនុត្រូវគោរពលក្ខ័ណមួយ

គឺត្រូវចូលរួមដៃជាមួយពួកយួនហាណូយ និងជាមួយបនខ្មែរក្រហម ។

ចិនចង់ឲ្យខ្មែរជួយយួនកុម្មុយនិស្តទើបគេនិយាយថា គេមិនខ្វល់ជាមួយសីហនុទេ គឺចិនយកសីហនុមកធ្វើជាឧបករណ៍ជួយយួនវៀតកុង-វៀតណាមខាងជើង (6)

ទ័ពយួនវៀតកុង-វៀតណាមខាងជើងចាប់ផ្ដើមវាយប្រហារស្រុកខ្មែរជាដំបូងក្នុងថ្ងៃទី២មេសា១៩៧០ ។ ក្នុងស្ថានការណ៍ដ៏ដុនដាបនេះ លោកលន់-នល់ក៏សុំជំនួយទ័ពម៉ែកហ្វ័ករបស់លោកសឺង-ង៉ុកថាញ់ពីវៀតណាមខាងត្បូង មកជួយជាបន្ទាន់ដែរ ។ កាលនោះឧត្ដមសេនិយអាមេរិកាំង Haig បានព្រមានលោកថាញ់ថា ៖ « កុំឲ្យលោកនាំទ័ពចូលស្រុកខ្មែរជាបន្ទាន់ពេក ឲ្យនៅរង់ចាំចូលទៅជួយពីខាងក្រៅទៅវិញ ទើបមានប្រសិទ្ធិភាព » ។ នេះក៏ជាកំហុសលោកថាញ់ដែរ ដែលនៅតែយល់ថា « ខ្មែរទាំងអស់នៅតែស្រឡាញ់រូបលោកដូចកាលសម័យឆ្នាំ១៩៥២ដដែល » លោកក៏ហក់ចូលទៅក្នុងអន្ទាក់ពួកស្រើងអំណាចលន់-ណុន, លន់-នល់ ដែលបានរៀបចំកំទេចក្រុមលោក និងបំផ្លាញគ្រោងការទាំងអស់ ដែលលោកថាញ់ត្រូវចូលមកការពារប្រទេសខ្មែរឲ្យរួចផុតពីផែនការសហភាពឥណ្ឌូចិននៃហូ-ជីមិញ (២០) ។ កងទ័ពលោកសឺង-ង៉ុកថាញ់បានដឹកចូលមកស្រុកខ្មែរទាំងថ្ងៃទាំងយប់ តាមយន្ត-ហោះនិងតាមរថយន្ត មានអាវុធគ្រប់ដៃ ។ ឯកងទ័ពខ្មែរវិញបានសម្ភារៈសឹក កាំភ្លើងគ្រាប់ ខោអាវវៀតកុង ដែលកាក់ដកហូតមិនដឹកយកទៅឲ្យទ័ពយួនខាងជើងនោះមកធ្វើការទប់ទល់ ។ ទាហានម្ភៃបួនម៉ោងបានរើសជាបន្តបន្ទាប់ភ្លាមៗ ។ សរសេរដល់ត្រង់នេះ ស្មេរខ្ញុំសូមគោរពដល់វិញ្ញាណក្ខ័ន្ធសិស្សខ្ញុំទាំងឡាយ ដោយកាលនោះខ្លួនខ្ញុំបានជំរុញឲ្យពួកគេ ចូលធ្វើទាហានចេញទៅវាយពួកយួនវៀតកុង-វៀតណាមខាងជើង រហូតបាត់បង់ជីវិតអស់ជាច្រើន ក្នុងសង្គ្រាមឥតន័យនៃរបបលន់-នល់នោះ ។

កងទ័ពវៀតកុង-វៀតណាមខាងជើងបានវាយលុកយកបានខេត្តរតនគីរី ស្ទឹងត្រែង មណ្ឌលគីរី ក្រចេះ ដោយប្រើវិធីចាក់ខ្សែអាត់ស្នូរកាំភ្លើង ធ្វើឲ្យទាហានខ្មែរលន់-នល់ និងចៅហ្វាយខេត្តភ័យស្មានតែវៀតកុងច្រើន ក៏រត់យករួចតែខ្លួនមាន តុំសារាវ៉ាន់ (ត្រូវទោសប្រហារជីវិត) និងចេង-សាឃុំប៊ិនជាដើម...។

មួយខែក្រោយមក ទើបសហរដ្ឋព្រមផ្ដល់ជំនួយកងទ័ពដល់ប្រទេសកម្ពុជា ។

ចាប់ពីខែមេសា១៩៧០ មកទល់នឹងខែមិនា១៩៧៣ គឺកងទ័ពវៀតកុង-វៀតណាមខាងជើងសុទ្ធសាធ ដែលវាយលុកប្រទេសខ្មែរ មិនទាន់មានទ័ពខ្មែរក្រហមសោះឡើយ ។ យួនកុម្មុយនិស្តបានវាយរំដោះកាន់កាប់ដែនដីខ្មែរមួយផ្នែកយ៉ាងធំ ហើយគេត្រួតត្រាតំបន់រំដោះទាំងនោះដូចជាដែនដីយួនអញ្ចឹង ដោយបានចាត់ចែងតែងតាំងផ្នែករដ្ឋបាលខេត្ត ស្រុក ឃុំ ជាយួនទាំងអស់ ។

*(២០) តាមសេចក្ដីឲ្យការណ៍របស់លោកសឺង-ឡេ្យ រដ្ឋវ៉ាស៊ិនតោន (អតិតទាហានម៉ែកហ្វ័ក) និយាយថា ៖ « លោកថាញ់បានសុំយកកងទ័ពខ្មែរក្រោមរបស់លោកទៅដាក់ការពារផ្លូវពួកយួនវៀតកុង-វៀតណាមខាងជើង នៅតាមខេត្តប៉ែកខាងកើតស្រុកខ្មែរ និងនៅខេត្តសៀមរាប កំពង់ធំ វាយស្ទាក់ផ្លូវទ័ពយួនខាងជើង កុំឲ្យចូលមកក្នុងស្រុកខ្មែរបាន... តែលោកលន់-ណុននិងលន់-នល់មិនព្រមទាល់តែសោះតាមផែនការនេះ » ។*

# ជម្លោះរវាងខ្មែរក្រហមនិងយួនកុម្មុយនិស្ត

នៅដើមឆ្នាំ១៩៧០ យួនហាណូយបានយកខ្មែរវៀតមិញ (២១) ចំនួន២,៣០០នាក់ (7) និងសឹង-ង៉ុកមិញ (ហៅអាចារ្យមៀន) ដែលបានភៀសខ្លួនទៅសម្ងំនៅហាណូយ (២២) ក្រោយសន្និសិទហ្សឺណែវ ខែកក្កដា១៩៥៤ មកឲ្យដឹកនាំចលនាខ្មែរកុម្មុយនិស្ត ។ ការដែលកងទ័ពវៀតកុង-វៀតណាមខាងជើងវាយលុកសាធារណរដ្ឋខ្មែរនោះ ពួកនេះបានយកទុនប្រជាប្រិយសីហនុមកឃោសនាបោកប្រាស់រាស្ត្រខ្មែរដែរ ដូចជាយករូបថតសម្តេចសីហនុដាក់លើប័ណ្ណគណកម្មាធិការទាក់ទងជាដើម ។ ឯចិនប៉េកាំងក៏បានយកទុនប្រជាប្រិយសីហនុមកប្រើដែរ ។ សព្វថ្ងៃនេះទៀតក៏ដោយ (១៩៨៧) ដើម្បីចំហៀវខ្លាញ់សីហនុជាផលប្រយោជន៍យួន និងផលប្រយោជន៍កូនជីងខ្លួន (ខ្មែរក្រហម) ចិនប៉េកាំងបានបោះរូបសម្តេចសីហនុ រាប់សែនសន្លឹកចែកឲ្យពួកយោធាខ្មែរក្រហម កាន់ចូលទៅស្រុកខ្មែរ ចែកចាយដល់ប្រជារាស្ត្រខ្មែរ ឲ្យយល់ច្រឡំម្តងទៀតថា ពួកខ្មែរក្រហមជាកងទ័ពរបស់សម្តេចឪ មកច្បាំងយកអំណាចឲ្យសម្តេចឪវិញ ។

នេះហើយលទ្ធផលនៃ «នយោបាយប្រជាមតិ» របស់សម្តេចសីហនុ ដែលជាបុព្វហេតុសាវវន្តមួយដ៏ជាក់ច្បាស់ ក្នុងវិនាសកម្មជីវិតនៃប្រជារាស្ត្រខ្មែរបីលាននាក់ និងការរលាយប្រទេសខ្មែរសព្វថ្ងៃនេះ ។

( កកន ៖ ដូច្នេះនៅក្នុងការកាត់ទោសខ្មែរក្រហម ពីបទសម្លាប់រង្គាល ដែលនឹងធ្វើឡើងនាពេលខាងមុខនេះ... សម្តេចសីហនុគឺជាមេដឹកនាំយ៉ាងសំខាន់ជាងគេទាំងអស់ នៃអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, អំពើឧក្រិដ្ឋកម្មសង្គ្រាម និងអំពើសម្លាប់ជាតិឯង ។ បើទ្រង់មិនស្ម័គ្រចិត្តដើរចូលទៅឲ្យគេកាត់ទោសដោយខ្លួនឯង តាមដូចព្រះបន្ទូលទេ... តុលាការត្រូវកោះហៅសម្តេចសីហនុមុនគេទាំងអស់ ។ « សឹងឯងឈ្មោះអី បានជាឪឈ្មោះម៉ៅ-សេទុង ? » ) ។

ជាថ្នូរនឹងអង្ករ យួនកុម្មុយនិស្តបានផ្តល់គ្រឿងសាស្ត្រាវុធឲ្យពួកខ្មែរក្រហមខ្លះ តែមិនបានគ្រប់គ្រាន់តាមការត្រូវការរបស់បនខ្មែរក្រហមសោះឡើយ ។ នៅពេលដែលពួកខ្មែរក្រហមបានទទួលជំនួយពីចិនប៉េកាំងល្មមគ្រប់កម្លាំងគេ តាមការជួយ

*(២១) ពួកខ្មែរវៀតមិញបានបង្កើតគណបក្សនយោបាយឈ្មោះ «គណបក្សប្រជាជន» មានរូបនង្គ័លជាសញ្ញាសំគាល់ និងដឹកនាំដោយណុប-បូផាន ។ ក្រោយណុប-បូផានត្រូវគិញ្ចសីហនុសម្លាប់ចោលទៅ, នង-សួន (កើតនៅគីរីវង្ស, ខេត្តតាកែវ) បានឡើងមកជំនួស រួចចូលព្រៃរួមដៃជាមួយខ្មែរក្រហម ។*

*(២២) សឹង-ង៉ុកមិញ មិនមែនជាប្អូនលោកសឹង-ង៉ុកថាញ់ទាល់តែសោះ អ្នកខ្លះនៅតែយល់ច្រឡំរឿងនេះ តាមការឃោសនារបស់យួនហាណូយ ដែលវាប្រើជាមធ្យោបាយសំរាប់ទាក់ទាញពួកខ្មែរកណ្តាល ខ្មែរក្រោម ឲ្យចូលបំរើចលនាយួនវៀតមិញ គឺយកប្រទេសកម្ពុជា រួមជាមួយលាវ វៀតណាមធ្វើជា «សហព័ន្ធឥណ្ឌូចិន» ។ ដើម្បីនឹងគុណអាចារ្យមៀនឬសឹង-ង៉ុកមិញ ដែលបានបំរើប្រយោជន៍យួន ៗបានបោះរូបថតអាចារ្យមៀនលើតែម៍សំបុត្រតម្លៃមួយរៀល និងលើប្រាក់១០០រៀលរបបហេង-សំរិនសព្វថ្ងៃនេះ ។*

ជ្រោមជ្រែងពីសម្ដេចសីហនុនៅប៉េកាំងនោះ ពួកខ្មែរក្រហមឆ្វេងដាច់ខាតនិយម លទ្ធិម៉ៅ ក៏ចាប់ប្រលេះយកពួកខ្មែរវៀតមិញរបណ្ដើរៗ ដែលពួកគេចោទថា « ក្បាលយួនខ្លួនខ្មែរ » ។



ទិដ្ឋភាពនៃការពិឃាតប្រជាជនថ្មីទាំងគ្រួៗនៅភូមិភាគឧត្តរទិសនិងបូព៌ាទិស (កំពង់ធំ-កំពង់ចាម) គូរដោយលោកអ៊ឹង-ប៊ុនហ៊ាង ( លោកអ៊ឹង-ប៊ុនហ៊ាង បានផ្ដល់សំណៅរូបគំនូរនេះដល់ខ្ញុំ កាលនៅជំរំខៅ-អ៊ីដាង ឆ្នាំ១៩៨០ )

ដោយខ្លាចយួន សឺង-ង៉ុកមិញ ក្លាយជាមេដឹកនាំទៅថ្ងៃមុខនោះ ប៉ុល-ពតក៏រៀបចំគំរោងការណ៍សម្លាប់អាចារ្យមៀនចោល ។ ប៉ុល-ពត ឬសាឡុត-សរ បានឲ្យអ្នកជំនិតជាខ្មែរលើឈ្មោះ អាប៉ង់ លបយកថ្នាំបំពុលខ្មែរលើទៅដាក់ក្នុងអាហារសម្លាប់សឺង-ង៉ុកមិញក្នុងឆ្នាំ១៩៧២ (8) ។ រួចហើយ ប៉ុល-ពតខ្លួនឯងក៏ឡើងធ្វើជាប្រធានលេខាធិការបក្សកុម្មុយនិស្តខ្មែរ ដែលកាលណោះគេបិទបាំងដោយដាក់ឈ្មោះថា «រណសិរ្សរួបរួមជាតិកម្ពុជា» ព្រោះមានក្រុមសីហនុចូលរួមជាមួយផង ។ សម្តេចសីហនុកាលនោះធ្វើជាប្រធានរាជរដ្ឋាភិបាលរួបរួមជាតិ តាំងនៅក្រៅស្រុក (នៅក្រុងប៉េកាំង) ។

តាមពិតទៅ សម្តេចគ្មានឥទ្ធិពលអ្វីបន្តិចទៅលើចលនារណសិរ្សរួបរួមជាតិកម្ពុជាសោះ ហើយមិនអាចមកជាន់ដីស្រុកខ្មែរ ដោយគ្មានការអនុញ្ញាតពីប៉ុល-ពតនិងបនខ្មែរក្រហមឡើយ ព្រោះថា ៖ « អង្គការមិនឲ្យសីហនុមកស្រុកខ្មែរ... ព្រោះបើឲ្យសីហនុមក ច្បាស់ជាប្រជាជនរត់ទៅរកសីហនុហើយ... ចំណែកយើងវិញ យើងមុខជាបោសគូថទទេ » (9) ។ ដូច្នេះខ្មែរក្រហមគ្រាន់តែយកសីហនុមកធ្វើត្រឹមតែជាឈ្នាន់ឃោសនាគៀងគរប្រមូលកម្លាំងគាំទ្របនគេពីដំបូងទីប៉ុណ្ណោះ ព្រោះកាលណោះទន់ប្រជាប្រិយភាពរបស់សម្តេចឪ នៅមានឥទ្ធិពលខ្លាំងក្លាណាស់ក្នុងចំណោមប្រជារាស្ត្រខ្មែរស្រុកស្រែចំការ ។ ថ្វីបើជារបបផ្តាច់ការដូចគ្នា របបរាជានិយមនិងរបបកុម្មុយនិស្តជាសត្រូវស្លាប់រស់ ពួកខ្មែរក្រហមមិនអាចយកសម្តេចសីហនុឲ្យមកត្រួតក្បាលពួកគេនោះឡើយ ។ រណសិរ្សនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមា-នតែឈ្មោះប៉ុណ្ណោះ តាមពិតផ្ទៃក្នុងគណកម្មាធិការផ្ទៃក្នុងសុទ្ធតែជាខ្មែរក្រហម-ខ្មែរវៀតមិញទាំងអស់ ។

ពួកខ្មែរក្រហមក្រោយពីបានជំរុះពួកខ្មែរវៀតមិញបណ្តើរៗមក គេក៏ចាប់ផ្តើមប្រឆាំងចេញមុខជាមួយនឹងពួកយួនវៀតកុង-វៀតណាមខាងជើង រហូតដល់មានការប៉ះទង្គិចប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាយ៉ាងធ្ងន់ធ្ងរ ។ តើបណ្តាលមកពីហេតុអ្វី ? ដូចតែកាលសម័យឥស្សរៈដែរនោះ ពួកយួនទុកពួកខ្មែរក្រហមជាកញ្ជះ ជាខ្ញុំ សំរាប់បំរើផលប្រយោជន៍វៀតណាមមួយមុខប៉ុណ្ណោះ ដោយជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ពួកខ្មែរក្រហម ធ្វើខ្លួនជាម្ចាស់ ជាចៅហ្វាយលើក្បាលខ្មែរក្រហម ។ ការនេះគឺយួនចង់បង្ហាញថា យួនមានបំណងយកស្រុកខ្មែរទាំងមូលជាពិតប្រាកដ ។

ដូចកាលសម័យឥស្សរៈដែរ កាលនោះពួកខ្មែរឥស្សរៈបានធ្វើការកាប់សម្លាប់យួនអស់ជាច្រើន ក៏មកដល់សម័យបនខ្មែរក្រហម ក៏យួននៅតែធ្វើរបៀបតែមួយដោយមេដឹកនាំយួនគ្មានការស្មោះត្រង់ ។ ត្រង់នេះហើយដែលលោកសេក-សំអៀតជឿតាមសំដីរបស់សីហនុ ហើយខំបញ្ជូនកាំភ្លើង គ្រាប់ទាំងឡានៗទៅផ្តល់ឲ្យកងទ័ពស្តេចឪរាល់ៗខែមិនដែលខាន ដើម្បីបានបុណ្យស័ក្តិខ្ពង់ខ្ពស់ទៀត កាលណាបើស្តេចឪវិលមកកាន់អំណាចវិញនោះ ។

នៅចុងឆ្នាំ១៩៧៣ ដោយត្រូវវាយលុកវៀតណាមខាងត្បូងឲ្យខ្លាំងក្លាក្នុងរដូវក្តៅឆ្នាំ១៩៧២ផងនោះ កងទ័ពយួនកុម្មុយនិស្តដោយមានជម្លោះជាមួយពួកខ្មែរក្រហមផងនោះក៏ដកកងទ័ពឈប់វាយសាធារណរដ្ឋខ្មែរ, ទៅជាយដែនខ្មែរ-យួនភាគខាងកើត

ទុកភារៈឲ្យរណសិរ្សរួបរួមជាតិកម្ពុជាម្តងវិញ  តែឃួនកុម្មុយនិស្តនៅតែកាន់កាប់មូលដ្ឋានសឹកខ្លះៗនៅក្នុងដែនដីខ្មែរនៅឡើយ ។ ផែនការជំរុះពួកខ្មែរវៀតមិញ និងពួកសីហានុនិយមក៏បានចាប់ធ្វើជាបន្តស្ងាត់ៗ  រហូតមកដល់ពាក់កណ្តាលឆ្នាំ១៩៧៨ទៀត  ដូចជាការចាប់មូល-សម្បត្តិ  និងពួកពាយ័ព្យទិសសម្លាប់ចោលនៅថ្ងៃទី១៨មិថុនាឆ្នាំ១៩៧៨ជាដើម ។ នៅពេលឈ្មោះរបបសាធារណរដ្ឋលន់-នល់ភ្លាម ប៉ុល-ពតក៏កំទេចកងទ័ពនិងពួកសីហានុនៅតំបន់ខេត្តកំពត  និងខេត្តនានាខ្លះទៀត  ដែលមិនបានប្រុងខ្លួនជាមុនខ្ទេចខ្ទីអស់គ្មានសល់ ដូចជាចេង-សាឃុំប៊ិនជាដើម ។ល។

❑ ❑

❑

# ជំពូកទី៦
# លទ្ធផលនៃផែនការហ្វូ-ជីមិញ

មុននឹងឈានចូលទៅដល់លទ្ធផលជាស្ធូរេចរបស់មេដឹកនាំហ្វូ-ជីមិញ ជាបឋម ខ្ញុំសូមបរិយាយខ្លះៗអំពីជ័យជំនះរបស់ខ្មែរក្រហម លើសាធារណរដ្ឋលន់-នល់នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។

## បុព្វហេតុនៃជ័យជំនះរបស់ខ្មែរក្រហម និងបរាជ័យរបស់របបសាធារណរដ្ឋខ្មែរ

ប៉ុល-ពតតែងតែអួតក្អេងក្អាងថា ពួកវាបានវាយឈ្នះចក្រពត្តិអាមេរិកាំងនិងបរិវារលន់-នល់ ដោយសារតែនយោបាយដ៏ភ្លឺស្វាងរបស់អង្គការនិងកងទ័ពប្រដាប់អាវុធប្រជាជនកម្ពុជាដ៏ខ្លាំងក្លាមហាអស្ចារ្យ ដូចចំរៀងមួយរបស់វាច្រៀងថា ៖ នយោបាយរួមផ្សំអាវុធ ប្រសើរមោះមុតរបស់អង្គការ...។ល។

តាមពិត ជ័យជំនះរបស់ពួកខ្មែរក្រហម បានមកដោយសារតែយួននិងចិនប៉េកាំងទៅវិញទេ បើគ្មានជំនួយសម្ភារៈសឹកសន្ទឹកសន្ធាប់ពីចិនប្រជាមានិត្ត និងជំនួយពីកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលវាយខ្មែរសាធារណរដ្ឋពីខែមេសា ១៩៧០ មកខែមិនា១៩៧៣ ព្រមទាំងសភាសហរដ្ឋសំរេចឲ្យបញ្ឈប់លែងប្រើយន្តហោះបេ-៥២ ទៅទម្លាក់គ្រាប់បែកលើដែនដីខ្មែរទៀត ចាប់ពីឆ្នាំ១៩៧៣ទេនោះ បន ប៉ុល-ពតច្បាស់ជារកមិនឃើញជ័យជំនះថ្ងៃទី១៧មេសា១៩៧៥នោះទាល់តែសោះ។

ថែមពីលើនេះទៅទៀត មានកត្តាបីធំៗបានធ្វើឲ្យសាធារណរដ្ឋខ្មែរដួលរលំដៃដល់ខ្ញុំសូមធ្វើតារាងប្រៀបធៀបដូចតទៅ ៖

| ខ្មែរក្រហម | ខ្មែរសាធារណរដ្ឋ |
|---|---|
| ១-គ្មានខ្ចាំងផ្ទៃក្នុង : ប៉ុល-ពតបានធ្វើការបោសសំអាតសម្លាប់ពួកខ្មែរវៀតមិញនិងពួកសីហនុនិយម ។ | ១-មានខ្ចាំងផ្ទៃក្នុងៈ ចៅហ្វាយខេត្តភាគច្រើនដូចជាសេក-សំអៀត ជាពិសេសនាយការិយាល័យទី២ តិមអេង-គួរុនដេត ដែលផ្តល់ចំណុចខ្សោយក្រុមសាធារណរដ្ឋនិងការសម្ងាត់នៃប្រតិបត្តិការសឹកទៅខ្មែរក្រហម ។ |
| ២-គ្មានអំពើពុករលួយៈ វិន័យដែកថែបគ្មានយោគយល់ គ្មានមនោសញ្ចេតនា (គ្មានបេះដូង) | ២-ពុករលួយលើសជំនាន់សីហនុ១ជា ១០ នាយទាហានលន់-នល់សង់វីឡា មានប្រពន្ធចុងរាប់សិប... |

| | |
|---|---|
| ៣-នយោបាយចិត្តសាស្ត្រខ្លាំង | ៣-គ្មានប្រើនយោបាយចិត្តសាស្ត្រៈ នាយទាហានបំរើខ្លាំង លក់ថ្នាំពេទ្យ លក់គ្រាប់ ។ល។... |

១- នៅក្នុងជួរខ្មែរក្រហម អ្នកដែលគេអនុញ្ញាតឲ្យចូលជាបេក្ខជនបាននោះ លុះត្រាតែមានប្រវត្តិរូបស្អាតស្អំ ហើយថែមទាំងបានបំពេញលក្ខណៈមួយចំនួនធំ ដែលអង្គការតម្រូវឲ្យធ្វើ ។ អគ្គលេខាធិការបក្សកុម្មុយនិស្តខ្មែរប៉ុល-ពត អាចក្តាប់ត្រួតត្រាបានលើក្រុមខ្មែរក្រហមទាំងមូល ដោយប្រើវិន័យដែកថែប និងអំណាចផ្តាច់ការវណ្ណៈអធន ។ ផ្ទុយទៅវិញ លោកលន់-នល់មិនអាចត្រួតត្រា ឬក្តាប់អ្នកក្រោមបង្គាប់លោកឲ្យបានដូចពួកខ្មែរក្រហមសោះឡើយ ។ ការទម្លាក់សីហនុមិនចាត់ទុកថាជាបដិវត្តន៍បានឡើយ គឺជាការដណ្តើមអំណាចដោយគ្មានការបង្ហូរឈាមមួយ ។ កំហុសដ៏ធំមួយរបស់លន់-នល់គឺ មួយមិនយល់ព្រមតាមយោបល់ទ្រង់សិរិមតៈ ដែលឲ្យធ្វើគត់សីហនុ... ពីរលន់-នល់បានទុកម៉ាស៊ីនចាស់រថយន្តលោកនៅដដែល គ្រាន់តែលោកឡើងជាអ្នកបើកបរថ្មីម្នាក់តែប៉ុណ្ណោះ ពោលគឺអ្នកដែលគាំទ្រសីហនុនៅតែទាំងអស់ក្នុងស្ថាប័ននិងប្រព័ន្ធដឹកនាំរបស់លោក ទាំងផ្នែករដ្ឋបាល ទាំងផ្នែកកងទ័ព ។ អ្នកទាំងនោះបានខ្វាស់កង់សាធារណរដ្ឋមិនឲ្យវិលទៅមុខផង និងមួយទៀតបានជួយជាកម្លាំងដល់សត្រូវនៃសាធារណរដ្ឋខ្មែរ (ខ្មែរក្រហមនិងសីហនុ) ផង ។ ពួកគេបានជញ្ជូនកាំភ្លើង គ្រាប់ ថ្នាំពេទ្យ ទៅផ្តល់ឲ្យខ្មែរក្រហម ។ ចាប់ពីនាយទាហានជាន់ខ្ពស់ រហូតដល់ចៅហ្វាយខេត្ត សុទ្ធតែបានជួយកងទ័ពរបស់សីហនុ (ខ្មែរក្រហម) សឹងតែទាំងអស់ ។ សូម្បីតែលន់-ណុនជាប្អូនលោកលន់-នល់ ក៏បានដឹកគ្រាប់កាំភ្លើងទៅឲ្យខ្មែរក្រហមដែរ ។ ក្នុងកំឡុងជាប់ដៃប្រយុទ្ធគ្នានៅតំបន់ទួលលៀប ពេលយប់លោកលន់-ណុនបានបញ្ជាឲ្យទាហានជំនិត ដឹកគ្រាប់យកទៅឲ្យខ្មែរក្រហមនៅភ្នំប្រាសិទ្ធិ បាក់ដឹង (១) ។ ឯលោកសេក-សំអៀត អភិបាលខេត្តបាត់ដំបង ជាជនពុករលួយម្នាក់ក្នុងចំណោមពួកពុករលួយជាច្រើនទៀតនៃរដ្ឋាភិបាលលន់-នល់ ដោយបានផ្តល់គ្រាប់រំសេវ និងគ្រឿងសាស្ត្រាវុធទៅឲ្យខ្មែរក្រហម ។

ក្នុងខែមេសាឆ្នាំ១៩៧៤ ពេលដែលប្អូនថ្លៃលោកដៀប-សៀនបានចាប់ខោអាវបួនបាវ ស្បែកជើងបួនបាវ និងប្រាក់៣៧ម៉ឺនរៀល (២) នៅត្រង់ភូមិទួលក្រសាំង ពីរ

*(១) តាមសេចក្តីឲ្យការណ៍របស់លោក ស៊ុម-គិន ក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន ។*

*(២) សេចក្តីឲ្យការណ៍របស់លោកសឺន-ឡេ អតីតមេបញ្ជាការនៅបន្ទាយត្រែង ។ កាលនោះភ្នាក់ងារសម្ងាត់បានឲ្យការណ៍ថា មានខ្មែរយៈខ្លាំងបានដឹកសម្ភារៈ ទៅឲ្យខ្មែរក្រហមនៅភូមិទួលក្រសាំង ។ ដោយគ្មានបង្អែក លោកសឺន-ឡេបាននិយាយវិទ្យុទាក់ទងឲ្យប្អូនដៀប-សៀន (អភិបាលអនុខេត្តប៉ៃលិន) ឈ្មោះស្វាយ-សាមឿនមកចាប់ ។ អនុសេនិយឯកស្វាយ-សាមឿននិងសហការីបួននាក់ បានមកទាក់ទងនឹងលោកសឺន-ឡេៗក៏បានបន្ថែមភ្នាក់ងារសម្ងាត់លោកពីរនាក់ទៀត ។ ក្រុមនេះបានចេញពីស្ពៅនៅម៉ោង៨ល្ងាច ទៅហ៊ុំព័ទ្ធភូមិទួលក្រសាំង រួចចាប់បានអ្នកបើកបរឡានដឹកឈើពីរនាក់ និងគ្រូបឋមសិក្សាម្នាក់ (ភ្លេចឈ្មោះ) ដែលកំពុងនាំរបស់ទៅឲ្យខ្មែរក្រហម។ មនុស្សនិងរបស់ភស្តុតាងបានយកមកទុកនៅបន្ទាយត្រែង ។ ពេលព្រឹកឡើងលោកដៀប-សៀន និងចៅកែអ៊ូ បានទៅសួរចម្លើយ ។ អ្នកជាប់ចោទបានឆ្លើយថា ជាឥវ៉ាន់របស់លោកសេក-សំអៀត ប្រើឲ្យនាំទៅឲ្យខ្មែរក្រហម ។ មនុស្សនិងវត្ថុជាភស្តុតាង បានបញ្ជូនទៅបាត់ដំបង ។ សេក-សំអៀតក៏បានដោះលែងឲ្យរួចខ្លួនទៅ ។*

គីឡូម៉ែត្រពីស្ទឹង តាមផ្លូវទៅកំពង់គល់, សេក-សំអៀតបានហៅអ្នកចាប់មកស្តីបន្ទោសថា ៖ ហេតុអ្វីបានជាពួកឯងចាប់ពួកគេ ? គឺពួកគេដែលឲ្យពួកឯងសុខ ! ការនេះគឺខ្ញុំបានផ្ញើមកជាយូរយារមកហើយ ព្រោះពួកគេច្បាំងតែជាមួយយួនមួយសន្ទុះទេ នឹងចូលមករួបរួមជាមួយយើងហើយ ។

លោកស្មឹក-យ៉េ, សព្វថ្ងៃរស់នៅក្រុងតាខ្មៅ បានឲ្យការណ៍ថា ខ្លួនធ្លាប់បានដឹងពីរឿងសេក-សំអៀត ដឹកកាំភ្លើង ដឹកគ្រាប់តាមឡានទាហានម្តងៗខ្ទង់ពី៨ទៅ១០ឡានជារៀងរាល់ខែ នាំទៅឲ្យខ្មែរក្រហមតាមផ្លូវពីស៊ីសុផុនទៅសៀមរាប ។ កាលនោះលោកស្មឹក-យ៉េជានាចំណង់នៅបន្ទាយព្រៃជ្រូក ក្រឡាញ់កំពង់ថ្កូវសៀមរាប ។ កូនទាហានពីរនាក់អត់មិនបានក៏សួរថា ហេតុអ្វីបានជាគេដឹកកាំភ្លើង ដឹកគ្រាប់ចូលទៅតំបន់ខ្មាំងយ៉ាងនេះ បើទាហានកំពុងតែខ្វះគ្រាប់នោះ ? ។ កូនទាហានពីរនាក់នោះក៏ត្រូវមេបញ្ជាការឈ្មោះម៉ា-អួន យកទៅសម្លាប់បំបិទមាត់ចោល (ឆ្នាំ១៩៧០-៧១) ។

លោកគិមអេង-គួរុនដេតជានាយការិយាល័យទី២ផ្នែកយកការណ៍សម្ងាត់ ជារនុកក្នុងរបស់សីហនុ-ខ្មែរក្រហម បានផ្តល់ការសម្ងាត់ទាំងអស់ទៅយួនវៀតកុងខ្មែរក្រហម ។ ហេតុនេះហើយទើបគ្រប់ប្រតិបត្តិការសឹកនានា មានចេនឡាទី១ ចេនឡាទី២... ត្រូវបរាជ័យរហូត ។ លោកគិមអេង-គួរុនដេតសព្វថ្ងៃ (១៩៩០) នេះ រស់នៅក្នុងជួរខ្មែរក្រហមឯជាយដែនខ្មែរ-ថៃ ។

ក្នុងកងទ័ពសឹងតែគ្រប់កងឯកភាព មានការលួចបំបាត់ចំនួនកូនទាហាននៅឯប៉ុស្តិ៍ប្ញបន្ទាយ ហើយត្រូវសត្រូវយួន-ខ្មែរក្រហមវាយខ្ទេចខ្ទី ។

កងទ័ពគ្មានវិន័យទាល់តែសោះ ខ្លះទៅប្លន់អុកឡុកហាងទំនិញ បរិភោគបាយប្ញគុយទាវមិនឲ្យលុយជាដើម... ខ្លះទៀតចាប់ស្រី កូនក្រមុំគេទាំងថ្ងៃដាក់ឡាន រំលោភរួចយកទៅលក់ឲ្យបនស្រីពេស្យាទៀត ។

២- បើនិយាយពីអំពើពុករលួយវិញ ខ្លាំងជាងសម័យសីហនុមួយជាដប់ជាម្ភៃ។ ចៅហ្វាយខេត្តចូលហ៊ុនជាមួយនាយទុន ចិនផ្សារនាំចូលរបស់រត់ពន្ធ ដឹកទាំងទូរទេះភ្លើង ។ ប៉ុស្តិ៍កុងត្រូលត្រួតពិនិត្យនិមួយៗ ត្រូវរកលុយឲ្យចៅហ្វាយនាយ (៣) ។

ក្នុងសម័យប្រឡងមធ្យមសិក្សាបឋមភូមិ ( Diplôme ), មធ្យមសិក្សាប័ត្រភាគទី១ ( BAC I ), មធ្យមសិក្សាប័ត្រភាគទី២ ( BAC II ) នៅចុងឆ្នាំ១៩៧០, ១៩៧១ ជាគំរូអាក្រក់ដល់បុគ្គលិកសិក្សា ។ ចៅហ្វាយខេត្តបានផ្ញើកូនស្រីឲ្យនាយកមធ្យមសិក្សា ( DP= Directuer Provincial de l'Enseignement Secondaire ) ជួយយ៉ាងឲ្យ

*(៣) នៅក្រុងបាត់ដំបង ក្រោយទម្លាក់សីហនុរួចមក ចៅហ្វាយខេត្តបានឲ្យសិស្សវិទ្យាល័យនិងសាស្ត្រាចារ្យចែកវេនគ្នាយាមឆែកឆេរច្រកចូលក្រុង ក្នុងមួយថ្ងៃសិស្សចំនួនពី១៥ទៅ២០នាក់ ហើយមានគ្រូពីរនាក់មើលខុសត្រូវ ។ ខ្លួនខ្ញុំផ្ទាល់ក៏បានចូលរួមក្នុងក្រុមឆែកឆេរនេះដែរ ។ ពួកយើងឆែកឆេររកតែរបស់ដែលទាក់ទិននិងខ្មាំងសុទ្ធសាធ របស់រត់ពន្ធមិនត្រឹមត្រូវដែលច្រើនហួសហេតុ ។ ខ្ញុំសូមជំរាបថា ពួកយើងមិនដែលបានទទួលយកសំណូកទាល់តែសោះ ។ ដោយពួកសិស្សនិងគ្រូមិនចេះរកលុយឲ្យគេនោះ ទើបកន្លះឆ្នាំក្រោយមក គេក៏បញ្ឈប់លែងឲ្យសិស្សវិទ្យាល័យនិងសាស្ត្រាចារ្យធ្វើការឆែកឆេរតទៅទៀត គេដាក់ពួកគិញ កងស្វ័យត្រាន និងបុគ្គលិកក្រសួងផ្សេងៗដែលចេះរកលុយវិញ ។*

តែបានជាប់, ទាហានស្ពាយកាំភ្លើងចូលទៅប្រឡង ហើយបើកមើលតាមចិត្ត ។ បុគ្គលិកគយគិញ សូកលុយប្រធានគណមេប្រយោគ ( President de jury ) ដើម្បីបានជាប់និងបានឡើងបុណ្យស័ក្តិ ។ រឿងមួយដែលខ្ញុំចាំមិនភ្លេចនោះ គឺសម័យប្រឡងមធ្យមសិក្សាបត្រភាគទី២ក្នុងឆ្នាំ១៩៧២នៅបាត់ដំបងក្រុង (៤) ។ សិស្សម្នាក់ជាកូននាយទាហាននៅបាត់ដំបង, ប្រហែលជាគេអាងថាបានសូកប្រធានគណៈមេប្រយោគរួចហើយ ទើបគេបានចម្លើយគណិតសាស្ត្រទាំងអស់មកចំឡងដាក់បណ្តោយ ។ ខ្ញុំក៏ចាប់សិស្សនោះ មេប្រយោគពីរនាក់ទៀតក្នុងសាលប្រឡងនោះក៏ត្រូវចុះហត្ថលេខាលើវិញ្ញាសាររបស់បេក្ខជននោះ ភ្ជាប់ជាមួយឯកសារចាប់បាន វិញ្ញាសារនោះនឹងត្រូវបានពិន្ទុសូន្យ ( តាមច្បាប់បើមានភស្តុតាង ហើយបើវិញ្ញាសារណាមួយបានសូន្យនោះ គេមិនបូកពិន្ទុទេ ) ។ តែគេបានត្រូវរ៉ូវគ្នាជាមួយប្រធានគណៈមេប្រយោគនិងអ្នកកាត់ក្បាលក្រដាស់បេក្ខជនដាក់លេខសម្ងាត់ គេក៏ដាក់ក្រដាស់បេក្ខជនដែលធ្វើល្អត្រឹមត្រូវឥតខ្ចោះជំនួស ដកឯកសារចាប់បានគ្រវាត់ចោល ។ បេក្ខជននោះក៏បានជាប់សញ្ញាប័ត្រមធ្យមសិក្សាភាគទី២ទៅ ។ ក្រោយមកទើបខ្ញុំបានដឹងថា គេចំណាយអស់ជាង៣០ម៉ឺនរៀល ។ នេះហើយជាគំរូដែលជំរុញឲ្យក្រសួងអប់រំជាតិចាប់ពុករលួយដែរ ចាប់ពីឆ្នាំ១៩៧២មក ។

តាំងពីសម័យសីហនុមកដល់ឆ្នាំ១៩៧០, ១៩៧១ បុគ្គលិកសិក្សានៅស្អាតស្អំល្អណាស់ ដែលពួករាជការបុរង្គការគ្រប់ក្រសួង និងនាយទុន ចិនផ្សារនាំគ្នាហៅថា នាម៉ឺនដីស ឬពួកប្រាក់ខែងាប់ ឬពួកពស់ព្រលិត ។ ស្ថានការណ៍សង្គ្រាមធ្វើមិនឲ្យគ្រូប្រាក់ខែងាប់រស់កើត បូករួមទាំងកំហើញអំពើពុករលួយគ្រប់ក្រសួងនានាផង ហើយពួកគេទាំងនោះរស់បានស្រួល ពួកបុគ្គលិកសិក្សាក៏ចាប់ស៊ីសំណូកចេញមុខតែម្តងដែរ ខ្លះទៀតបាននិយាយថា បើវាដូច្នេះទៅហើយនោះ គួរនាំគ្នាជួយរុញសាធារណរដ្ឋនេះទម្លាក់ទឹកបណ្តោយទៅ ព្រោះវាអស់ផ្លូវកែហើយ លក្ខន្តិកៈលើស្តូបសាធារណរដ្ឋមុខអតិតរាជវាំង ត្រូវគេបំភ្លេចចោល បោះចោលក្នុងភក់ជ្រាំអស់ ។ ឯពួកគ្រូដែលមាននិន្នាការក្រហម បានធ្វើឲ្យលេចឮក្នុងចំណោមគ្រូមធ្យមសិក្សាថា ពួកពុករលួយអស់នេះ មើលទៅគ្មានផ្លូវកែទាល់តែសោះ មានតែផ្លូវម៉្យាងគឺសម្លាប់ចោល ។ ថែមពីលើនេះទៅទៀតនោះ សិស្សវិទ្យាល័យ ជាពិសេសនៅក្រុងភ្នំពេញ ភាគច្រើនជាកូននាយទាហាន គ្មានគោរពវិន័យសាលាទាល់តែសោះ យកកាំភ្លើងចូលបន្ទប់រៀន ដាល់គ្រូ ច្រឡោមខាម (៥) ដូចជាក្រុមអាម៉ូវមេប្លន់ជាដើម ។

*(៤) ដើម្បីសំរួលដល់កូនសិស្ស ព្រោះផ្លូវចរាចរដាច់ ក្រសួងអប់រំជាតិសំរេចឲ្យបើកមណ្ឌលប្រឡងមធ្យមសិក្សាបឋមភូមិ, មធ្យមសិក្សាភាគទី១នៅតាមខេត្ត កែនិងប្រកាសលទ្ធផលនៅតាមខេត្តតែម្តង លើកលែងតែមធ្យមសិក្សាបត្រភាគទី២ចេញ វិញ្ញាសារបេក្ខជនត្រូវប្រមូលយកទៅកែនៅភ្នំពេញទាំងអស់ ។*

*(៥) ក្នុងឆ្នាំ១៩៧២ នៅវិទ្យាល័យនេតយ៉ង់ មានសិស្សម្នាក់ជាកូនលោកស័ក្តិប្រាំតុលាការសឹកបាត់ដំបង (ភូឈ្មោយលោកម៉ៅ-សន) ។ សិស្សនារីម្នាក់បានឡើងពីក្រោមទៅជាន់លើ ឯកូនលោកស័ក្តិប្រាំនោះចុះពីលើមក ហើយចាប់ឱបសិស្សនារីនោះនៅជាន់ទី២ ដែលធ្វើឲ្យសិស្សនារីនោះខ្មាស់គេជាខ្លាំង ។ ព្រឹកស្អែកឡើង គណកម្មការវិន័យនិងសាស្ត្រាចារ្យទាំងអស់បានរួមប្រជុំ ក្រោមអធិបតី*

*លោកចាងហ្វាង ហើយសំរេចបណ្តេញសិស្សនោះ ឈប់ឲ្យចូលរៀនសាលារដ្ឋនានាទាំងអស់ ទោះបីជាឪពុកសិស្សនោះបានខំធ្វើអន្តរាគមន៍យ៉ាងណាក៏ដោយ ។ នៅវិទ្យាល័យបាត់ដំបង (អតិតវិទ្យាល័យព្រះមុនីវង្ស) មានសិស្សម្នាក់ដោយខឹងនឹងលោកគ្រូ ដែលបានបណ្តេញឲ្យឈប់រៀនមួយអាទិត្យ ដោយបទព្រហើននិងរំខានសិស្សនារីក្នុងថ្នាក់ ។ ថ្ងៃមួយក៏ចូលមកក្នុងថ្នាក់រៀន រួចដាល់លោកគ្រូដែលកំពុងបង្រៀន រួចហក់ចេញតាមបង្អួចទៅ ។ សិស្សនោះក៏ជាកូនស័ក្តិប្រាំម្នាក់ទៀតដែរ ។*

រឿងពុករលួយដែលធ្វើឲ្យពួកសាស្ត្រាចារ្យចាំមិនភ្លេចនោះ គឺការកាត់យក៣០% លើប្រាក់ម៉ោងរបស់គ្រូម្នាក់ៗ បើពុំដូច្នោះទេពួករតនាគារមិនព្រមធ្វើឡើយ គេពន្យាទុកឲ្យយូរ ដោយយកលេសថា ថវិកាគ្មាន ត្រូវចាំបួនប្រាំឆ្នាំតទៅទៀត ។ សូមជំរាបថា សាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិមានប្រាក់ខែ៨,៥០០រៀល (កាលណោះមាសមួយជំឡឹងថ្លៃ៣,០០០រៀល) ។ បើបង្រៀននៅបឋមភូមិ (ថ្នាក់ទី៦ទៅទី៣ទំនើប) ត្រូវបង្រៀន១៨ម៉ោងក្នុងមួយអាទិត្យ បើលើសពីនោះគឺជាម៉ោងបន្ថែម ដែលត្រូវទទួលកំរៃចំនួន១៦០រៀលក្នុងមួយម៉ោង ។ បើបង្រៀននៅទុតិយភូមិ (ថ្នាក់ទី២ដល់ថ្នាក់ទីបញ្ចប់) នោះត្រូវបង្រៀនតែ១៦ម៉ោងទេក្នុង១អាទិត្យ លើសពីនោះគឺម៉ោងបន្ថែមត្រូវបានកំរៃ១៨០រៀលក្នុងមួយម៉ោង ។ បើជាសាស្ត្រាចារ្យទុតិយភូមិ (បរិញ្ញាបត្រ) វិញ ( ប្រាក់ខែ១០,០០០រៀល) នោះត្រូវបានកំរៃប្រាក់ម៉ោងបន្ថែមចំនួនតែ៧ម៉ោងកន្លះទេក្នុងមួយអាទិត្យ បើលើសពីនេះត្រូវបង្រៀនទទេដោយគ្មានកំរៃ ។ ពួកគ្រូប្រាក់ខែងាប់បានធូរធារមួយកំរិត ក៏ដោយសារតែប្រាក់ម៉ោងបន្ថែមនេះ ហើយត្រូវពួករតនាគារកាត់យក៣០% ទាំងអយុត្តិធម៌ ដែលធ្វើឲ្យអ្នកខ្លះមានគំនិតក្រហមឡើង ។ សាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិម្នាក់ៗត្រូវបានកំរៃប្រាក់ម៉ោងនេះចំនួនពី៣,០០០ទៅ៥,០០០រៀលក្នុងមួយខែ តាមបង្រៀនតិចឬច្រើនម៉ោង ។ ក្នុងការធ្វើប្រាក់ម៉ោងនេះ ពួករតនាគារគេតថ្លៃជាមួយនាយគណនេយ្យខាងបុគ្គលិកសិក្សា ។ នាយគណនេយ្យយកមកពិភាក្សាជាមួយនាយកខេត្តខាងមធ្យមសិក្សា ជាមួយចាងហ្វាងវិទ្យាល័យ ។ចាងហ្វាងវិទ្យាល័យបើកប្រជុំសុំយោបល់ភាគច្រើនពីពួកសាស្ត្រាចារ្យក្នុងការតថ្លៃនេះ ។ ប្រាក់ម៉ោងនោះគេបើកមកគ្រប់តាមបញ្ជីត្រឹមត្រូវ តែក្នុងបញ្ជីងងឹតវិញ នាយគណនេយ្យខាងបុគ្គលិកសិក្សាកាត់យកប្រាក់៣០% ប្រគល់ក្រោមតុទៅឲ្យពួករតនាគារគេចែកចាយគ្នាគេ ។ តើហេតុអ្វីបានជាគេត្រូវធ្វើបែបនេះ ព្រោះនេះជាមុខងារ ជាភារកិច្ចរបស់ពួកគេសោះនោះ ? ។ រឿងនេះហើយដែលបណ្តាលជាបុព្វហេតុក្តៅក្រហាយមួយដែរចំពោះពួកសាស្ត្រាចារ្យ ។ ប្រព័ន្ធរដ្ឋបាលផ្នែកពុករលួយ រហូតចិនផ្សារ ឬពួកកូនចៅចិននៅបាត់ដំបងគេនិយាយថា « គេមិនឲ្យកូនទៅគ្រូប្រាក់ខែងាប់ទេ គេសុខចិត្តលើកឲ្យកូនប៉ូលីសប្រាក់ខែ២,០០០រៀលប្រសើរជាង » ។ ឯចៅហ្វាយខេត្តប្រាក់ខែ៧,០០០រៀល ហេតុអ្វីក៏ហ៊ឺហារម្លេះបានលុយមកពីណា ? ។

៣- នយោបាយចិត្តសាស្ត្រគ្មានយកមកប្រើទាល់តែសោះ អ្នកដែលទៅសិក្សាវិជ្ជានេះពីកូរ៉េខាងត្បូង គ្រាន់តែមានៗប៉ុណ្ណោះ ។ ពួកស្នងការនយោបាយពាក់តែស័ក្តិលំអទីក្រុង សូត្រទ្រឹស្តីប្រឆាំងកុម្មុយនិស្តឲ្យតែសិស្សនិងគ្រូស្តាប់ តែនាយទា

បាន អស់លោកចៅហ្វាយខេត្តមិនរីវរល់អើពើ ឬធ្វើតាមគំនិតសង្គ្រាមចិត្តសាស្ត្រ នៃពួកស្នងការនយោបាយទាល់តែសោះ ហើយថែមទាំងពួកគេមើលងាយថា ពួកស្នងការនយោបាយដែលភាគច្រើនជានាយទាហានអាស៊ីមីឡេ ( Assimilés )នោះ ចេះមិនដល់ពួកគេជានាយទាហាន ដែលបានសិក្សាចេញពីសាលាយោធាខ្មែរ ( EMK - Ecole Militaire Khmère ) ទាល់តែសោះ ។ ផ្ទុយទៅវិញ ពួកមេខ្មែរក្រហមពុំដែលសិក្សាទ្រឹស្តីសាលាយោធាណាមួយទេ តែពួកនេះបានយកទ្រឹស្តីសង្គ្រាមទ័ពឆ្មក់មកអនុវត្តបានជោគជ័យមួយរយភាគរយ កាន់កាប់ជាម្ចាស់លានប្រយុទ្ធបាន ( Maître du terrain ) ឯពួកអតិតសិស្សសាលាយោធាបែរជាអនុវត្តទ្រឹស្តីសង្គ្រាមតាំងពីសម័យអាណានិគម ប្រមូលផ្ដុំគ្នាតែនៅក្នុងបន្ទាយ ទុកទីខាងក្រៅឲ្យខ្មាំងធ្វើសកម្មភាពបាន១០០% ជាពិសេសនៅពេលយប់ ពួកខ្មែរក្រហមអនុវត្តសង្គ្រាមចិត្តសាស្ត្រនេះខ្លាំងក្លាណាស់ ហើយបានជោគជ័យជាទីពេញចិត្តរបស់គេ ។ គេឃោសនានិងធ្វើវិទ្ធង្សនា បង្កវិទ្ធេទកម្មឲ្យផ្ទៃក្នុងសាធារណរដ្ឋច្របូកច្របល់ ប្រជាជនលែងមានជំនឿលើរដ្ឋការលន់-នល់ ហើយនឹកសរសើរស្រឡាញ់ពួកខ្មែរក្រហម ល្អត្រឹមត្រូវ ស្អាតស្អំ មិនលួចប្លន់អ្នកស្រុក (បើពួកគេបេះផ្លែម្ទេសមួយ គេដាក់លុយលើដើមម្ទេសនោះ) សរសើរថាពេទ្យបដិវត្តន៍ចេះចាក់ម្ជុលវិទ្យាសាស្ត្រតាមបែបចិន ( Acupuncture ) ពូកែស័ក្តិសិទ្ធិ, មិនស៊ីសំណូក ។ល។

កម្លាំងសាធារណរដ្ឋដែលត្រូវយកមកវាយខ្មាំងនោះ ត្រឡប់ជាយកមកកាប់ចាក់សម្លាប់តែគ្នាឯងផ្ទៃក្នុងទៅវិញ ( លន់-ណុនដាក់គ្រាប់បែកប្រុងធ្វើឃាតលោកនាយករដ្ឋមន្ត្រីសឺង-ង៉ុកថាញ់, ធ្វើឃាតលោកសេង-ស៊ុនថៃ, ធ្វើឃាតលោកថាច់-ជានិងបណ្ឌិតកែវ-សាំងគីម, សម្លាប់លោកអ៊ុំ-សាវុធ... ) ។ពួកក្រុមលន់-ណុន ដោយខ្លាចក្រុមលោកសឺង-ង៉ុកថាញ់ដណ្ដើមអំណាចពីបងគាត់ ( នល់-នល់ ) ក៏បំបែកកងទ័ពពិសេស កងទ័ពម៉ែកហ្វ៊កខ្មែចខ្ទីឲ្យខ្សោយលែងមានប្រសិទ្ធិភាព ។ កងវរសេនាណាដែលខ្លាំង ដូចជាកងទ័ពឆ័ត្រយោង, កងទាហានលោកអ៊ុំ-សាវុធ... ត្រូវក្រុមលន់-ណុនបញ្ជូនឲ្យទៅវាយគ្រប់សមរភូមិ រហូតស្លាប់អស់គ្មានសល់ រហូតលោកអ៊ុំ-សាវុធក៏ត្រូវស្លាប់បាត់បង់ជីវិតដោយសារស្នាដៃលន់-ណុនថែមទៀត គឺឃាតកម្មបានធ្វើបីថ្ងៃ ក្រោយដែលអ៊ុំ-សាវុធបានទៅជួប ( ទទួលឱវាទប្រៀនប្រដៅពីលោកសឺង-ង៉ុកថាញ់ ) ជាគំរប់លើកទីប្រាំមក ។

គេមិនឲ្យគ្រាប់ ឬរថយន្តដឹកទាហានទេ លុះណាតែមេបញ្ជាការសូកលុយ ទើបគេព្រមឲ្យ ។ បើចង់យន្តហោះទៅទម្លាក់គ្រាប់បែក មេបញ្ជាការត្រូវតែសូកលុយដែរ បើមិនដូច្នោះទេ កងវរៈសេនានោះៗក៏ត្រូវពួកខ្មែរក្រហមនិងពួកយួនខាងជើងវាយស្លាប់ខ្ទេចខ្ទីអស់ទៅ ។

ខោអាវជាជំនួយអាមេរិកាំងគេមិនបើកឲ្យទាហានទេ គេទៅប្រទះឃើញទាំងគំនរលក់នៅតាមផ្សារនានា ដូចជាផ្សារអូឡាំពិចជាដើម ។ បើបែរជាបើកឲ្យទាហានវិញ គឺមេបញ្ជាការនឹងកាត់ប្រាក់ខែថ្លៃខោអាវនោះ ។ក្នុងឱកាសហែរក្បួនទទួលលោកអគ្គរដ្ឋទូតអាមេរិកាំងហ្គុន-ធ័រដៀននៅបាត់ដំបងនោះ ទាហានដើរក្បួនស្លៀកខោអាវរហែក លោកដៀនបានយកខ្សៀលោកទៅគោះផ្កាយធ្វើពីមាស លើស្មាសេក-

សំអៀត ហើយមានប្រសាសន៍ថា ៖ ផ្កាយលោកធ្វើសុទ្ធតែពីមាស តែរាស្ត្រ និងទាហានលោកអត់បាយ ! ។

តើហេតុអ្វីបានជាពួកនាយទាហានសាធារណរដ្ឋជួយពួកខ្មែរក្រហម ? ព្រោះ ៖

១- ពួកគេនាំគ្នាជឿតាមព្រះរាជបន្ទូលសីហនុ ដែលស្រែកក្តែងៗពីប៉េកាំងមកថា ឲ្យកូនចៅនាំគ្នារត់ចូលព្រៃ វាយកំចាត់បនក្បត់លន់-នល់ និងចក្រពត្តិអាមេរិកាំង ។ ហេតុនេះហើយបានជាខ្មែរក្រហម អាចប្រមូលកងទ័ពបានយ៉ាងឆាប់រហ័ស ដោយបានរាជបន្ទូលសីហនុជួយស្រែកពីប៉េកាំងផង និងដោយទុនប្រជាប្រិយភាពសីហនុនៅខ្ពស់ ក្នុងស្រទាប់ចិត្តគំនិតកសិករខ្មែរស្រុកស្រែចំការផង ។

២- ពួកគេនៅតែមានជំនឿថា ( រហូតសព្វថ្ងៃពួកសីហនុនិយម ក៏នៅតែជឿងដែល ) ទៅថ្ងៃមុខ សម្តេចសីហនុមុខជាមកដឹកនាំប្រទេសខ្មែរវិញជាមិនខាន ។ ហេតុនេះហើយ បើបួកគេជួយកងទ័ពសីហនុនៅពេលនេះ ( ១៩៧០-៧៥ ) ទៅថ្ងៃមុខពួកគេច្បាស់ជាបានបុណ្យស័ក្តិកាន់តែធំឡើងថែមទៀត នៅពេលដែលសម្តេចសីហនុយាងមកកាន់កាប់អំណាច ជាប្រមុខរដ្ឋខ្មែរវិញនោះ ។ ក្នុងគំនិតយល់ច្រឡំបែបនេះឯង ទើបបួកគេមិនយកចិត្តទុកដាក់សិក្សាពីបនខ្មែរក្រហមដល់បន្តិចសោះ ។ ក្នុងជំនឿរបៀបនេះ ទើបបានជាលន់-ណុនបានបញ្ជូនគ្រាប់កាំភ្លើងទៅឲ្យខ្មែរក្រហមដែរ ។

បរាជ័យនៃរបបសាធារណរដ្ឋខ្មែរ គឺមានក៏ដោយសារតែលោកលន់-នល់ផ្ទាល់តែម្តង ដែលមានគំនិតខ្លី គឺមួយមិនព្រមធ្វើតាមគំនិតរបស់ទ្រង់សិរិមតៈ ដែលឲ្យធ្វើគតសីហនុ ដើម្បីការពារកុំឲ្យសីហនុរត់ទៅចូលជាមួយខ្មាំង ( ប្រហែលជាលន់-នល់ខ្លាចឥទ្ធិពលទឹកសម្បថ ដែលបាគួយកព្រះខាន់រាជ្យកូរឲ្យផឹកហើយស្បថថាមិនក្បត់ធ្វើគតសីហនុទេ ព្រោះលន់-នល់ជឿលើអាគមអូមអាមពាក្យសម្បថណាស់ ) ។ ទី២-គឺលន់-នល់មិនព្រមដកពួកសីហនុនិយមឲ្យអស់សោះ ។ ថែមពីលើនេះទៀត តាំងពីលន់-នល់ក្លាយជាពិការស្លាប់ដៃជើងមក ( ខំត្រដរឱបអំណាចតទៅទៀត ) លន់-នល់ថ្មីនេះមិនដូចលន់-នល់កាលមុនសោះ ។ ជាឧទាហរណ៍គ្រាន់តែប្រពន្ធថ្មីក្មេងបានកូន ក៏អួតប្រាប់គេឯង ប្រកាសតាមវិទ្យុ កោះហៅអ៊ុំ-សាវុធពីលានប្រយុទ្ធកំពុងខ្លាំងក្លា មកប្រាប់ដំណឹងចំកួតមិនសមហេតុផលនេះ ។ កាលខ្មែរក្រហមវាយភ្នំពេញខ្លាំងក្លានោះ លន់-នល់បានធ្វើសីមាជុំថ្ម រួចហើយឲ្យយន្តហោះយកទៅបោះទម្លាក់ជុំវិញទីក្រុងភ្នំពេញ ជាសិមាការពារកុំឲ្យពួកទមិឡចូលមកក្នុងក្រុងបាន ។ លន់នល់ឲ្យគ្រូស្លៀកសពាក់ស ស្ពាយថង់យាមគ្រវាសបាចអង្ករនាំមុខកងទ័ព ចូលទៅវាយទ័ពយួនយៀកកុង-យៀកណាមខាងជើង និងខ្មែរក្រហម ។ល។ គឺលន់-នល់ចាត់ទុកពួកយួនយៀកកុង-យៀកណាមខាងជើង និងខ្មែរក្រហមជាទមិឡ ជាខ្មោចព្រាយបិសាច ជាសត្រូវអរូបិយ ដែលគាត់ជឿថា ត្រូវតែចុះចាញ់ឥទ្ធិពលរបស់ពុទ្ធមន្តជាដាច់ខាត (?!) ។

❑ ❑

❑

# បដិវត្តន៍ឃាតករ

ថ្ងៃទី១៧ មេសា ១៩៧៥ ជាថ្ងៃមហាជោគជ័យរបស់បនខ្មែរក្រហមលើរបបសាធារណរដ្ឋខ្មែរ និងចក្រពត្តិអាមេរិកាំង ។ ប៉ុល-ពតបានបញ្ជាភ្លាមឲ្យដេញជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ដោយគ្មានការអនុគ្រោះសោះឡើយ ។ ប្រជាជនជាងបីលាននាក់ (៥) បានត្រូវចាកចេញចោលផ្ទះសំបែងទាំងបង្ខំ បាក់បែកព្រាត់ប្រាស់ម៉ែឪ កូនប្ដីប្រពន្ធទៅទីទៃៗ ដោយខ្លះនៅឯការិយាល័យ នៅសាលារៀន ទៅផ្សារ ទៅពេទ្យសួរអ្នកជម្ងឺ នៅផ្ទះបងប្អូនឬមិត្តភក្តិ..។ គ្រូពេទ្យដែលគ្រាន់តែសុំពន្យាពេលមើលអ្នករបួស ក៏ត្រូវឃោធាបាញ់ចោលភ្លាម ។ ទាហានសាធារណរដ្ឋដែលភ្លេចដោះឯកសណ្ឋានចោល ត្រូវពួកឃោធាបាញ់ស្លាប់ចង្រ្កាងៗចោលនៅលើផ្លូវថ្នល់ ។ អ្នកដែលសាកល្បងពន្យាពេលអ៊ែអ៊ែរ ក៏ត្រូវឃោធាបាញ់ចោល ឬគប់គ្រាប់បែកចូលក្នុងផ្ទះស្លាប់ទាំងគ្រួសារ ។ មនុស្សណែនណាន់តាន់តាប់ប្រជ្រៀតគ្នាចេញលើគ្រប់ផ្លូវចេញពីទីក្រុងភ្នំពេញ ។ ក្មេង មនុស្សចាស់ជរា អ្នកជម្ងឺត្រូវស្លាប់ ហើយត្រូវបោះបង់សាកសពចោលគ្មានពេលវេលានឹងកប់ឲ្យបានស្រួលឡើយ គ្រាន់តែគ្របនឹងក្រណាត់សំពត់ឬកន្ទេល កូនចៅឬម៉ែឪ ក៏ធ្វើដំណើរគ្មានគោលដៅតទៅមុខទៀត ព្រោះខ្លាចអាជ្ញាពិឃាតរបស់ពួកខ្មែរក្រហម ។

ឪពុកខ្ញុំបែកពីម្ដាយខ្ញុំ (៦) ជាប់ជាមួយប្អូនប្រុសបន្ទាប់ឈ្មោះហ៊ិន-ស៊ីផន និងអាមុំជាប្រពន្ធ ព្រមជាមួយប្អូនស្រីទី៥ ជាសិស្សវិទ្យាល័យ១៨មិនា ឈ្មោះហ៊ិន-ចាន់ធី (៧) ធ្វើដំណើរតាមផ្លូវក្បាលថ្នល់ ព្រែកឯង ហើយទៅរស់នៅក្នុងស្រុកកំណើតអាមុំជាកូនប្រសារស្រី ( ប្រពន្ធស៊ីផន ) នៅខេត្តព្រៃវែង ត្រើយខាងកើតទន្លេមេគង្គក្នុងភូមិភាគបូព៌ាទិស ។ ដល់រដូវច្រូតកាត់ឆ្នាំ១៩៧៥ អង្គការបូព៌ាបានជម្លៀសប្រជាជនថ្មី ឲ្យទៅនៅត្រើយខាងលិចខ្លះក្នុងខេត្តកំពង់ចាម ។ ឪពុកខ្ញុំនិងកូនទាំងអស់គ្នាបួននាក់ ក៏ត្រូវអង្គការដាក់ទិសនេះដែរ ហើយបានទៅនៅក្នុងភូមិត្រពាំងឫស្សីសង្កាត់ជយោ ស្រុកចំការលើ ខេត្តកំពង់ចាម តំបន់៥ ភូមិភាគឧត្តរទិស ។ ដោយខ្វះជាតិប្រូតេអ៊ីន ព្រោះរបបអាខ្មែរក្រហមវាមិនផ្ដល់អាហារគ្រប់គ្រាន់ដល់ប្រជាជនទេ ឪពុកខ្ញុំហើមក្លាយជាដំបៅដោយគ្មានថ្នាំព្យាបាល ។ ពួកវាបានដាក់ទិសឪពុកខ្ញុំឲ្យជួយបិតឫស្សីធ្វើកញ្ជ្រែងល្អីជាមួយក្រុមតាចាស់ៗនៅក្នុងភូមិ ។ ឯប្អូនស្រី

*(៥) ប្រជាជនកើនឡើងដោយសាររត់គេចពីសង្គ្រាមខេត្តក្រៅចូលមកកកកុញក្នុងក្រុងភ្នំពេញ ។*

*(៦) ព័ត៌មានស្ដីពីដំណើរជម្លៀសរបស់ឪពុកខ្ញុំ គឺមិត្តតែ-ម៉េងលីបានរៀបរាប់ប្រាប់ខ្ញុំ ។ តែ-ម៉េងលី ជាអតិតសាស្រ្ដាចារ្យអក្សរសាស្រ្ដខ្មែរ-បារាំងនៅវិទ្យាល័យនេត-យ៉ង់ដែរ ។ នៅឆ្នាំ១៩៧២ បានផ្លាស់ទៅបង្រៀនសមណសិស្សនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត (ភ្នំពេញ) ។ ពេលខ្មែរក្រហមជម្លៀសប្រជាជននោះ មិត្តតែ-ម៉េងលី បានទៅរស់នៅក្នុងឃុំជាមួយគ្រួសារឪពុកខ្ញុំ ដោយភរពួកវាថា ជាចិនអ្នករកស៊ីពីដើម ។ តែ-ម៉េងលីបានទៅលេងជាមួយប្អូនប្រុសខ្ញុំ ពេលច្រូតស្រូវនាឆ្នាំ១៩៧៥ ។ ខ្ញុំបានជួបតែ-ម៉េងលី ក្រោយពេលដែលកងទ័ពយួនចូលឈ្លានពានកាន់កាប់ស្រុកខ្មែរ សព្វថ្ងៃមិត្តតែ-ម៉េងលី បានរស់នៅក្នុងក្រុង QUEBEC ប្រទេសកាណាដា ។*

*(៧) ប្អូនប្រុសនេះសព្វថ្ងៃនៅរស់ឯខេត្តពោធិសាត់ ។*

ហ៊ិន-ចាន់ធី ដោយនៅលីវ ប្អូនវាក៏ចាត់បញ្ចូលទៅក្នុងក្រុមចល័តនារី មិនបាននៅជួបជុំឪពុកខ្ញុំទេ ។ យូរៗទើបបានសុំច្បាប់គេមកលេងឪពុកនិងបងៗបានម្តង ។ ពេលវេលាចេះតែកន្លងទៅ មិត្តតែ-ម៉េងលីបានត្រូវអង្គការដាក់ទិសឲ្យទៅភ្ជួរស្រែ លើក ទំនប់ ជីកប្រឡាយ លើកភ្លឺស្រែ ហើយបានជួបគ្នាជាមួយប្អូនប្រុសខ្ញុំជាញឹកញាប់ ។ ក្នុងខែមេសា១៩៧៧ មិត្តតែ-ម៉េងលីបានទៅលេងឪពុកខ្ញុំទៀតតែប្អូនខ្ញុំបានប្រាប់ថា ឪពុកខ្ញុំបានត្រូវអង្គការដាក់ទិសឲ្យទៅយាមទំនប់កាលពីប្រាំថ្ងៃមុន (ព្រោះកាលនោះ អង្គការខ្មែរក្រហមឧត្តរទិស បានកេណ្ឌប្រជាជនកងចល័តទាំងប្រុសទាំងស្រីរាប់ម៉ឺននាក់ទៅលើកទំនប់ទឹកឆា) ។ ប្អូនខ្ញុំបាននិយាយប្រាប់តែ-ម៉េងលីថា ៖ មិត្តតូច(កងឈ្លប) បានយកកង់មកដឹកឪពុកខ្ញុំ ដោយឲ្យគាត់រៀបចំខោអាវ ព្រោះត្រូវមានទិស ទៅជួយយាមទំនប់ ។ វាប្រាប់ថា វាដឹកទៅជាសង្កាត់ៗ វាដឹកឪពុករបស់ខ្ញុំតាមឡានជាមួយនិងតាៗដទៃទៀត ដែលមកពីភូមិផ្សេងៗមកជួបជុំគ្នា ។ តាំងពីពេលនោះ មក បាត់ដំណឹងឪពុកខ្ញុំរហូត ។ ប្អូនខ្ញុំទាំងបីបានចាំៗមើលផ្លូវឪពុកមិនឃើញវិលត្រឡប់មកវិញសោះ ។ ដល់មកថ្ងៃទី២កក្កដា១៩៧៧ អង្គការខ្មែរក្រហមភូមិភាគឧត្តរតំបន់៥ ចាប់ជម្លៀសប្រជាជនថ្មីស្ទើរអស់ពីភូមិ ថាយកទៅឲ្យបង្កបង្កើនផលនៅស្រុក ថ្មីមួយផ្សេងទៀត មិនចាំបាច់យកឥវ៉ាន់ច្រើនទេនាំពិបាក ព្រោះនៅទីនោះអង្គការមានរបស់អាចផ្គត់ផ្គង់បានសព្វគ្រប់ទាំងអស់ ។ ពួកវាបានប្រាប់ថា អង្គការនឹងដាក់ទិស ឲ្យប្រជាជនថ្មីទៅនៅតាមដងផ្លូវជាតិទៅភ្នំពេញ ។ ឮថាបានអង្គការផ្គត់ផ្គង់សព្វគ្រប់ នោះ អ្នកខ្លះ ដែលគ្មានទិសក៏សុំគេទៅជាមួយដែរ ដើម្បីបានជួបជុំបងប្អូនកូនចៅ ។ កាលនោះ ប្អូនស្រីខ្ញុំនៅក្នុងកងចល័ត កំពុងជិរះស្មៅចំការមន ដល់ឮថាបងប្រុសបងស្រីត្រូវគេជម្លៀស ក៏ទំលាក់ចបចោលរត់រលះរលាំងមកជួបបង ហើយសុំទៅជាមួយគេដែរ ។ ប្រជាជនថ្មីទាំងអស់ត្រូវពួកវាដឹកទាំងឡានៗ (ឡានទ្រុង) យ៉ាងណែនយក ទៅវាយសម្លាប់កប់រណ្តៅនៅក្នុងចំការកៅស៊ូអូរអណ្តូង ចម្ងាយ២០គ.ម.ពីភូមិ ។ ពួកវាបានជីករណ្តៅយ៉ាងធំដូចជាស្រះទឹកទុកជាមុនខ្ទង់មួយខែ ។ វាសម្លាប់តាំងពីទារក ក្មេងតូច មនុស្សប្រុសស្រីគ្រប់វ័យ ទាំងស្រីមានផ្ទៃពោះផង ។ ដើម្បីកុំឲ្យ សំរែក ឈឺចាប់នៃពួកអ្នកទោសឮស្នូរទៅដល់ភូមិ ពួកវាបានចាក់មេក្រូភ្លេងនិងចំរៀងបដិវត្តន៍ (រំលាយស្រុករំលាយសង្គមខ្មែរ) លាន់ឮខ្លាំងកងរំពង ។ ការកាប់សម្លាប់ នេះ គឺប៉ុល-ពតចេញបញ្ជាពីភ្នំពេញមកក្រោយ ដែលវាសម្លាប់បានគណភូមិភាគបូព៌ាក្បត់ចូលដៃយួនឈ្មោះសោ-ភឹមនោះមក ។ ប៉ុល-ពតបានឲ្យបញ្ជាសម្លាប់ទាំង យោធាក្បត់ រួមទាំងប្រជាជនថ្មីក្នុងភូមិភាគឧត្តរនិងបូព៌ាទិស ។ វាយកយន្តហោះទៅ ទម្លាក់ខិតប័ណ្ណ ឲ្យពួកយោធាបូព៌ាដាក់អាវុធចុះចូលអង្គការនឹងអភ័យទោសឲ្យ តែក្រោយហូតអាវុធអស់ហើយ ប៉ុល-ពតបញ្ជាឲ្យដឹកយោធាបូព៌ាទិសទាំងអស់ខ្ទង់ បួនម៉ឺននាក់ យកមកវាយទម្លាក់រណ្តៅនៅត្រង់រកាកោង ខោអាវ មួក នៅចោលរាត់រាយ ឯក្លិនស្អុយខ្មោចពួកយោធាបូព៌ាភាយរហូតដល់ត្រើយម្ខាងខាងល្វាទេរ នេះបើតាមសេចក្តីរាយការណ៍របស់លោកយូ-សំបូរ អតីតនាយកបុគ្គលិកមធ្យមសិក្សាក្រុងភ្នំពេញ សព្វថ្ងៃរស់នៅក្រុងម៉ុងរ៉េអាល់ប្រទេសកាណាដា ។

ឯម្តាយខ្ញុំវិញបានជម្លៀសចេញទៅស្រុកកំណើតនៅកោះខ្សាច់កណ្តាល ខាង

កើតជ្រោយចង្វា តែដោយជាប្រជាជនថ្មី ប្រាំមួយខែក្រោយក៏ត្រូវអង្គការជន្លៀសចេញបន្តមកដល់ខេត្តពោធិសាត់  ចុះទៅឆ្ងាយដាច់ស្រយាលពីថ្នល់ជាតិជាង៣០គ.ម. ជាតំបន់ព្រៃគ្មានត្រីសាច់ ជាមួយប្អូនប្រុសលីវ ហ៊ិន-ស៊ីថា (ប្អូនទី៦) ប្អូនស្រីហ៊ិន-ស្រី (ប្អូនទី៧) និងប្អូនប្រុសពៅហ៊ិន-វណ្ណដារា ហៅហ៊ុច (៧) ។ ប្អូនប្រុសស៊ីថា ត្រូវប្រធានកងចល័តកងឈ្លបចាប់យកទៅចាក់កសម្លាប់ ពីបទលួចកាច់ពោតមួយសំរន់ក្រពះ ដែលរបបអង្គការវាកំណត់ឲ្យអង្ករមួយកំប៉ុង (ទម្ងន់ខ្ទង់២០០ក្រាម) សំរាប់គ្នា១០នាក់ក្នុង១ថ្ងៃ ។ ម្តាយខ្ញុំដោយមានរោគជម្ងឺក្រពះប្រចាំកាយផង ណាមួយអត់អាហារផង  ហើយដល់ទទួលដំណឹងពីប្អូនខ្ញុំត្រូវពួកអាថ្លើមខ្មៅប៉ុល-ពតសម្លាប់ចោលទៀតនោះ ក៏បណ្តាលរោគកាន់តែខ្លាំង ។ ពេលជិតផុតដង្ហើម, តាមសំដីប្អូនប្រុសពៅ,  ម្តាយខ្ញុំបានឲ្យប្អូនខ្ញុំទៅសុំស្ករត្នោតមួយស្លាបព្រាពីមីចុងភៅរោងបាយរួម  តែមេសាមាន្យនោះវាឆ្លើយតបវិញថា ៖ « គ្មានស្ករគ្មានស្អីទេ ពួកមី១៧មេសាឲ្យវាស្លាប់ស្រឡះឲ្យអស់ទៅ ! » ។ ម្តាយខ្ញុំបានទទួលមរណភាពទាំងក្តីវេទនានិងឈឺចាប់ ។ ប្អូនប្រុសខ្ញុំបានបញ្ចុះសពម្តាយខ្ញុំផ្ទាល់ដៃ (ឆ្នាំ១៩៧៧) ។ ឯប្អូនស្រីទី៧ក៏មានជម្ងឺគ្មានថ្នាំព្យាបាល ហើយបាត់បង់ជីវិតនៅទីនោះដែរ ។

ការកាប់សម្លាប់មានសភាពខ្លាំងក្លាណាស់ក្នុងកំឡុងឆ្នាំ១៩៧៧ ។ នៅភូមិភាគឧត្តរនិងបូព៌ាទិស  ជាពិសេសនៅក្រោយដែលសោ-ភឹមបានក្បត់ចូលដៃគាំទ្រយួនហើយលើកទ័ពសំដៅមកភ្នំពេញ ។ ក្រោយសម្លាប់សោ-ភឹមរួចហើយ ប៉ុល-ពតបញ្ជាឲ្យយោធាខ្មែរក្រហមវាយសំរុកចូលទៅក្នុងដីវៀតណាម  សម្លាប់ប្រជាជនខ្មែរក្រោមអស់ជាច្រើនពាន់ ។ តាមសេចក្តីឲ្យការណ៍ពីខ្មែរក្រោមម្នាក់ឈ្មោះថាច់-ឈ្នោង សព្វថ្ងៃរស់នៅក្រុងអូឡាំពីយ៉ា រដ្ឋវ៉ាស៊ិនតោនថា ៖ « យួនបានដឹងស្ថានការណ៍នេះមុន  ហើយឲ្យដំណឹងប្រជាជនយួនដកខ្លួនថយ  ឯខ្មែរក្រោមគេមិនឲ្យដឹងសោះឡើយ  ទ័ពប៉ុល-ពតកាប់សម្លាប់ភាគច្រើន  ជាជាតិយួនសញ្ជាតិដើមខ្មែរក្រោមប៉ុណ្ណោះ ។ មុននឹងទ័ពយួនចូលឈ្លានពានស្រុកខ្មែរ ពួកប៉ុល-ពតមិនអាចកាន់កាប់តំបន់ខាងកើតត្រើយទន្លេមេគង្គភូមិភាគបូព៌ាបានទេ  ប្រជាជនមានការរំជើបរំជួលបះបោរតទល់ស្លាប់រស់ជាមួយពួកកងឈ្លប ។ មានរឿងអ្នកខ្លាំងពូកែចេញជួយអ្នកស្រុក  មានរឿងលោកតាសក់ស  (ចារបុរសយួន)  ចូលមកបង្កចលាចលពួកប៉ុល-ពតបើយោធាដេញតាមក៏គេចខ្លួនបាត់រកមិនឃើញឡើយ  (៨)  ។ ឯនៅបាត់ដំបងមានពាក្យចចាមអារាមខ្សឹបតគ្នាពីមាត់មួយទៅមាត់មួយថា  ៖ «  អ្នកមានបុណ្យជិតកើតហើយ... ខ្លះទៀតថាកើតហើយ  តែចេញតាមឆ្អឹងជំនីម្តាយ  មិនដូចមនុស្សសាមញ្ញធម្មតាទេ... ខ្លះទៀតថាពួកយោធាប្រុងសម្លាប់ទាំងម្តាយទាំងកូន តែយោធានោះត្រូវស្លាប់ខ្លួនឯងវិញ » ។ បើតាមស្មេរ... នេះជាសង្គ្រាមចិត្តសាស្ត្ររបស់ពួកយួនហេង-សរីន  បំផុសឲ្យខ្មែរដែលមានជំនឿរង់ចាំតែអ្នកមានបុណ្យមកជួយនោះ  ឲ្យគាំទ្រពួកវា ។

ឯការកាប់សម្លាប់ប្រជាជនតំបន់ភូមិភាគឧត្តរនិងបូព៌ានោះ    គឺធ្វើដោយរបៀប

*(៧) ប្អូនប្រុសនេះសព្វថ្ងៃនៅរស់ឯខេត្តពោធិសាត់ ។*
*(៨) តាមសេចក្តីឲ្យការណ៍របស់លោកហុក-អូនលាងនៅក្រចេះ សព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រនិញ៉ា។*

ឃោរឃៅបំផុត ដូចជាពុំមែនជាជាតិខ្មែរដូចគ្នាបន្តិចសោះ ។ ប៉ុល-ពតបញ្ជាឲ្យសម្លាប់ចោលទាំងគ្រួៗ ។ សូម្បីចល័តដែលគ្មានឪពុកម្តាយ គ្មានដឹងរឿងអ្វីសោះ ក៏ត្រូវពួកវាអូសកយកទៅសម្លាប់ចោលដែរ គឺវាធ្វើតាមសុភាសិតចិនថា ៖ « ជីរះស្មៅគឺជីកទាំងឫស » បង្ការកុំឲ្យមានការសងសឹកនឹងពួកវាទៅថ្ងៃក្រោយ ។ កូនក្មេង ទារកត្រូវពួកវាចាប់បោកសម្លាប់នឹងគល់ត្នោត គល់ស្វាយ គល់ដូង បោះឡើងលើយកជិពុះទុងរង ។ វារំលោភស្រីរួចសម្លាប់ចោល ។ វះមនុស្សទាំងរស់យកថ្លើមទៅឆារស៊ី យកប្រមាត់ផឹកក្លែមស្រា និងបញ្ជូនទៅស្រុកចិនធ្វើថ្នាំចិនសែកែរោគ ។ រណ្តៅធំៗពេញដោយខ្មោចរាប់ពាន់ ។ គល់ដូង គល់ត្នោត នៅប្រឡាក់ឈាមនៅឡើយពេលទ័ពយួនចូលមកឈ្លានពានស្រុកខ្មែរ ហើយយកបានភ្នំពេញនៅថ្ងៃទី៧ មករា ១៩-៧៩នោះ ។

ក្នុងពាក់កណ្តាលឆ្នាំ១៩៧៨ ប៉ុល-ពតបញ្ជាឲ្យជន្លៀសប្រជាជនខេត្តស្វាយរៀងមកភ្នំពេញយកក្រមាពណ៌បៃតងម្នាក់មួយ រួចហើយដឹកជញ្ជូនតាមរទេះភ្លើងមកទម្លាក់ចោលនៅខេត្តពោធិសាត់ ។ ពួកអ្នកមានក្រមាពណ៌បៃតងនេះ គឺត្រូវអង្គការខេត្តពោធិសាត់ទទួលបញ្ជាពីប៉ុល-ពតមកឲ្យសម្លាប់ចោលទាំងអស់ ព្រោះសុទ្ធជាពួកក្បត់ ក្បាលយួនខ្លួនខ្មែរ ។ គេអូសកយកពួកស្វាយរៀងទាំងអស់ មិនថាជាប្រជាជន មេកង គណៈឃុំ គណៈអ្វីៗទេ យកទៅវាយកាប់សម្លាប់ចោលនៅឯវាលស្រែក្រៅភូមិ ។ មានមេកងនារីម្នាក់ក្លាហានណាស់បាននិយាយថា ៖ តើពួកគេមានកំហុសអ្វីបានអង្គការយកពួកគេមកសម្លាប់យ៉ាងនេះ ? ពួកយើងបានបំរើអង្គការ ស្មោះត្រង់អង្គការអស់ពីចិត្តពីថ្លើម នៅទីបញ្ចប់ពួកយើងបានទទួលផលបែបនេះទៅវិញ! មិនបាច់ចងមុខយកទៅទេ សម្លាប់យើងនៅទីនេះចុះ ! ។ ក្មេងស្រីម្នាក់អាយុប្រាំបួនឆ្នាំត្រូវពួកពេជ្ឈឃាតយកទៅវាយសម្លាប់តែមិនចំធ្ងន់គ្រាន់តែសន្លប់ ងើបដឹងខ្លួនពីសន្លប់ក៏ដើរចូលមកក្នុងភូមិវិញ ។ ប្រជាជនមូលដ្ឋានបានប្រាប់ឲ្យរត់គេចខ្លួនចេញទៅ តែគ្នាងឺងើមិនដឹងរត់ទៅទីណា ។ កងឈ្លបមកដល់ឃើញក៏ចាប់យកទៅដុតទាំងរស់ ស្រែកទធាក់កញ្ជ្រោលលាន់រំពងទំរាំដាច់ខ្យល់ស្លាប់ ។ ខ្មោចអ្នកខេត្តស្វាយរៀងរាប់ម៉ឺននាក់ស្លាប់គរជើងលើគ្នាគ្មានកប់ទេ ចោលរាត់រាយកណ្តាលវាលហើមស្អុយភាយមកដល់ភូមិ (៩) ។ នៅជាយដែនស្វាយរៀង មានពួកស្តូលរៀតមិញដូចហេង-សំរិន (មិនទាំងអស់ទេ) មានគំនិតស្រឡាញ់និងបំរើយួនតាំងពីសម័យឥស្សរៈមកម្ល៉េះ ។ ក្នុងសម័យសីហនុពួកនេះរស់នៅលាក់ខ្លួនធ្វើជាប្រជាជនរកស៊ីធម្មតា តែមិនចុះចូលជាមួយរបបដឹកនាំសីហនុទេ ដូចជាគ្រូប៉ាក់នៅភូមិសាង ខ្លះរកស៊ីរត់ពន្ធនាំឥវ៉ាន់យកទៅលក់ ដូចជាករណីមេខ្មែររៀតមិញហេង-សំរិន ដែលរកស៊ីដឹកជ្រូកទៅលក់នៅជាយដែនយួនជាដើម ។

*(៩) តាមសេចក្តីឲ្យការណ៍របស់អ្នកស្រីគីម-សាន នាមដើមភូ-ពូន ជាប្អូនស្រីនួន-ជា (ជាកូនចិញ្ចឹមរបស់អ៊ុំខាងប្រពន្ធខ្ញុំ) ។ ពេលមកជួបជុំជាមួយបងប្អូនម្តាយយាយពេញ នៅវត្តគរកន្លះខែក្រោយយួនយកស្រុកខ្មែរបាន ថាបានជន្លៀសមករស់នៅខេត្តពោធិសាត់ បានឃើញរឿងកាប់សម្លាប់ពួកខេត្តស្វាយរៀងនេះ ។ ឯកូនប្រុសច្បងរបស់គាត់ឈ្មោះសល់ ឈឺហើយរត់ពីកងចល័តមកដាច់ខ្យល់ស្លាប់នៅនឹងកាំជណ្តើរខ្ទមនឹងមុខម្តាយ ។ ឯកូនប្រុសម្នាក់ទៀត ត្រូវកងឈ្លបយកទៅដុតសម្លាប់ទាំងរស់ ព្រោះវាខ្ជិលពុតធ្វើឈឺ ។*

នៅបាត់ដំបង ភូមិភាគពាយព្យទិសពួកអង្គការមូល-សម្បត្តិក៏មិនអន់ដែរ ក្នុងការកាប់សម្លាប់ខ្មែរនេះ ។ ប្រជាជនតំបន់បួនខាងក្រោមអតីតក្រុងបាត់ដំបង ត្រូវស្លាប់វិនាសទាំងភូមិៗ ដោយសារពួកវាបង្អត់បាយ និងចាប់យកទៅវាយសម្លាប់ចោលបន្តគ្នា ។ អ្នកលួចរត់ចេញពីតំបន់៤សំដៅទៅជាយដែនថៃ មានសឹងរាល់ថ្ងៃ ខ្លះរត់មកសុំនៅវត្តគរ អ្នកខ្លះត្រូវឈ្លបចាប់បានក៏ត្រូវពួកវាសម្លាប់ចោលទៅ ។ ឯអ្នកឃុំវត្តគរក៏លួចរត់ទៅស្រុកសៀមដែរ ទៅម្តងជាក្រុមដប់ឬម្ភៃនាក់ ចំនួនពីរបីអាទិត្យមានដំណឹងថាមានអ្នកលួចរត់ ។ ដោយអត់ខ្លាំងពេក ប្រុសៗដែលកំពុងភ្ជួរក៏ដួលស្លាប់ភ្លាម ក្មេងៗស្លាប់មុនគេ រួចទើបមនុស្សប្រុសព្រោះខ្វះអាហារផ្តល់ថាមពលដូចជាស្ករ ជាតិប្រូតេអ៊ីន (ត្រី សាច់ ស៊ុត) ឯស្រីស្លាប់ក្រោយតែតិចព្រោះស្រីមិនសូវត្រូវការថាមពលក្នុងសពាង្គកាយទើបអាចទ្រាំទ្របានយូរជាង ។

អ្នកខ្លះដោយអត់ខ្លាំងពេកទៅ ក៏ហ៊ានទៅលួចគាស់ខ្មោចកប់ថ្មី អារយកសាច់មកលួចស្ងោរ ឬអាំងទទួលទានសំរន់ក្រពះ យកក្តិលចេកក្តិលល្ហុងមកបរិភោគលាយនិងត្រកួន នាំឲ្យចុះរាគរហូតបាត់បង់ជីវិត ។ ខ្លះទៀតទៅលួចបូតស្រូវ លួចគាស់ដំឡូង ត្រាវ ហើយត្រូវកងឈ្លបចាប់បានសម្លាប់ចោលទៅទៀត ។ ក្នុងភូមិវត្តគរដែលខ្ញុំរស់នៅ ពួកមេកងវាយការណ៍ទៅឃុំ ៗឲ្យកងឈ្លបមកយកម្តងមួយៗទៅសម្លាប់ចោលស្ងាត់ៗ ។ ឯខ្លួនខ្ញុំផ្ទាល់ក៏មានឈ្មោះក្នុងបញ្ជីខ្មៅរបស់ពួកវាដែរ ជាមួយនិងលោកតាសូរ-ជិត អតីតអនុគណខេត្តបាត់ដំបង (១០) ។ អ្នកបំពានសីលធម៌សាហាយស្មន់គ្នា ត្រូវគេយកទៅវាយសម្លាប់នៅមុខអង្គប្រជុំ ។ អ្នកខ្ជិលគេចកែមិនព្រមធ្វើការរួម អ្នកឈឺច្រើនក៏ត្រូវកងឈ្លបអូសកយកទៅដែរ ។ បងឃួង(អតីតគយ), លោកហាប់-ហួយ (នាយផ្នែកបុគ្គលិកគ្រូមធ្យមសិក្សាបាត់ដំបង) ក៏គេយកទៅដែរ ដោយភរិយាគាត់ធ្វើឲ្យលេចឮថា បើកុំតែស្រុកដូច្នេះម្ល៉េះប្តីគាត់មានបុណ្យស័ក្តិធំជាមិនខាន ។ គាត់ថាលោកសេក-សំអៀត ចៅហ្វាយខេត្តបាត់ដំបងបានស្នើរឲ្យប្តីគាត់ពាក់ស័ក្តិប្រាំ ពាក្យនេះឮចូលដល់ត្រចៀកប្រធាននារីឈ្មោះរៀប ដែលកំពុងជាន់អង្ករ រួចដល់គណៈឃុំៗក៏ជន្លៀសគ្រួសារគាត់ទៅនៅចុងឃុំវត្តគរឲ្យចែកក្តារជិតភ្នំសំពៅ បន្តិចមកឈ្លបក៏មកយកលោកគ្រូហាប់-ហួយទៅសម្លាប់នៅអណ្តូងព្រីង ។ អ្នកខ្លះទៀតដែលខំលាក់ខ្លួន ហើយត្រូវបែកការណ៍នឹងសំដីប្រពន្ធ ព្រោះមិនចេះលីបក៏បយកមកផ្តល់ឲ្យប្រពន្ធ ដែលអត់ស៊ីដោយគ្នាមានខ្លួនជាអតីតរដ្ឋការ ក៏បណ្តាលឲ្យមានជម្លោះប្តីប្រពន្ធ ប្រពន្ធស្រែកឬជេរ ធ្វើឲ្យបែកការណ៍ពីមុខដំណែងប្តី កងឈ្លបក៏មកអូសកយកទៅ... ខ្លះទៀតក៏សុខចិត្តលួចរត់ចេញទៅថៃ ដូចជាលោកបូរ៉ាន់ជាដើម ។ ពួកលួចរត់ភាគច្រើន ត្រូវថៃជាយដែនសម្លាប់ចោល យកមាសប្រាក់ដែលជាប់នឹងខ្លួន ។ ចៅប្រសារអ៊ុំខាំឈ្មោះផល្លា ( អតីតស័ក្តិបីបើកយន្តហោះ ត្រូវជាញា

*(១០) កងទ័ពយួនកាន់កាប់បានក្រុងបាត់ដំបងហើយនៅថ្ងៃទី១២មករា ប្រជាជនបានលបឆ្លងស្ទឹងចូលមកភូមិវត្តគររើយកទ្រព្យ តែត្រូវប៉ះឈ្លបយាមរបស់វា ថ្ងៃទី១៣... ឈ្លបដែលវាដាក់យាមក្នុងភូមិស្ងាត់ឈឹង ក៏បាញ់ពួកប្រជាជនដែលលបចូលទៅភូមិស្លាប់អស់ជាច្រើន ។ អ្នកដែលចូលទៅរើក្នុងផ្ទះគណៈឃុំ បានឃើញសំណៅបញ្ជីរាយឈ្មោះដែលគេត្រូវយកទៅសម្លាប់ ។ ឈ្មោះសម្លាប់រួចពួកវាគូសចោល ឈ្មោះខ្ញុំនៅត្រង់លេខ៣២៨ ។ ឈ្មោះលោកតាសូរ-ជិតនៅពីមុខខ្ញុំ នៅតែ៥នាក់ទៀតដល់វេនខ្ញុំ ។*

តិនួន-ជាផង ) ក៏ត្រូវគេយកទៅសម្លាប់កប់អង្កាមនៅអណ្ដូងព្រីងដែរ ដោយពួកឈ្លបវាមកយកថា ឲ្យទៅជួយជញ្ជូនអំបិលឯឃុំ ។ ថិតីជាតិញាក៏គេយកទៅដែរ វាយធ្វើទារុណកម្មមួយថ្ងៃៗស្រែកពោទីរំពងទំរាំស្លាប់ ។ កូនថិតីពីរនាក់ឈ្មោះកានិងកើនមិនសុខចិត្តមកប្រទេសទីពានឹងគេទេ មកចូលរួមចលនាតស៊ូរ.ជ.រ.ប.ខ.នៅជាយដែនចាំសងសឹកនឹងពួកខ្មែរក្រហមវិញ ។ នៅមានអ្នកឯទៀតជាច្រើនដែលខ្ញុំមិនចាំឈ្មោះអស់ តែក្នុងចំណោមអតីតគ្រូនិងសាស្ត្រាចារ្យវិទ្យាល័យនេត-យ៉ង់ចំនួនសែសិបនាក់ នៅសល់រស់តែប្រាំមួយនាក់រួមទាំងខ្លួនខ្ញុំម្នាក់ផង ក្រោយដែលពួកយួនកាន់កាប់ស្រុកខ្មែរបានហើយនោះ ។

ថ្ងៃខែចេះតែកន្លងទៅ មួយថ្ងៃហាក់ដូចជាមួយឆ្នាំ ពេលព្រឹកឡើងក៏នឹកថាខ្លួនបានរស់មួយថ្ងៃទៀតហើយ តែខ្ញុំរស់នៅទាំងក្ដីភិតភ័យតក់ស្លុត មិនដឹងថាថ្ងៃណានឹងដល់វេនខ្លួន ។ យប់ឡើងមានតែបន់ព្រះ វត្ថុស័ក្ដិសិទ្ធិនានា គុណឪពុកម្ដាយជួយឲ្យបញ្ចៀសរួចផុតពីគ្រោះថ្នាក់ កុំឲ្យដូចអ្នកផងដែលឈ្លបវាយកទៅថា « ឲ្យទៅរៀនសូត្រឯអង្គការលើ » នោះហើយគ្មានថ្ងៃវិលមកវិញសោះ ។ តែខ្ញុំមិនភ្លេចលាក់ដាវកេរ្តិ៍ សំលៀងយ៉ាងមុត ដាក់ក្រោមកន្ទេលដេកឡើយ ។ ដាវនេះត្រូវពួកនិរតីដកហូតយកមុនយួនចូលបន្តិច ទាំងពូថៅ ផ្គាក់ ខ្វែវគ្រប់ៗផ្ទះ ព្រោះវាខ្លាចប្រជាជនបះបោរដូចនៅភូមិភាគបូព៌ាទៀត ។ ខ្ញុំរស់នៅដោយសេចក្ដីសង្ឃឹម ( Hope ) ព្រោះមានជំនឿថា របបចំកួតលីលាបែបនេះច្បាស់ជារលាយអន្តរធានថ្ងៃណាមួយមិនខាន ។ មិត្តខ្ញុំខ្លះដូចជាជិន-សូធីរ, សាស្ត្រាចារ្យបរិញ្ញាប័ត្រធម្មជាតិវិទ្យា, សួន-ឈឹម, សាស្ត្រាចារ្យភាសាអង់គ្លេស ដោយក្ដីអស់សង្ឃឹមក្នុងជីវិត ក៏ដាច់ចិត្តចងកធ្វើអត្តឃាតស្លាប់ក្នុងឆ្នាំ១៩៧៧ ។

ខ្ញុំសូមជំរាបថា ក្រោយរដូវចំរូតឆ្នាំ១៩៧៥ ខ្ញុំត្រូវគេចាត់ឲ្យទៅធ្វើការក្នុងរោងជាងរួមប្រចាំឃុំវត្តគរ ចម្ងាយបីគីឡូម៉ែត្រខាងលើផ្ទះម្ដាយនួន-ជា ដោយសារខ្ញុំមានចំណេះខាងភ្លើងអគ្គិសនី និងជួសជុលវិទ្យុ ដោយបានរៀនតាមសំបុត្រទាក់ទងពីស្រុកបារាំងពីសាលាអឺរ៉ុលិច ( Institut Europeen d'Electronique - EUREULEC ) ។ មួយអាទិត្យ ជួនដប់ថ្ងៃទើបបានមកជួបមុខកូន (កូនច្បងទី១) និងប្រពន្ធម្ដង ។

នៅថ្ងៃទី១៨មិថុនា១៩៧៨ ពេលដែលពួកជាងភូមិវត្តគរទៅរើដែកក្នុងក្រុងបាត់ដំបង មានពួកយោធាថាមកពីភ្នំពេញ ជាពួកមជ្ឈឹមខ្ទង់ប្រមាណប្រាំពាន់នាក់ និងរថក្រោះជាងម្ភៃគ្រឿង ប្រឡាក់ដីស្រមកចូលមកក្នុងអតីតបាត់ដំបងក្រុង ដោយគ្មានឲ្យដំណឹងអ្វីជាមុនដល់ពួកភូមិភាគពាយ័ព្យទិសសោះឡើយ ។ ពួកយោធាមជ្ឈឹមបានសាកសួររកដេញពួកជាងឲ្យវិលត្រឡប់មកភូមិវត្តគរវិញ ។ ពួកមជ្ឈឹមបក្សក៏ធ្វើការចាប់ចងតាមឃុំ ស្រុក រួចខ្លះទៀតទៅចាប់គណភូមិភាគពាយ័ព្យទិស មូល-សម្បត្តិ ឬតាកៅ ( ពួកពាយ័ព្យហៅគាត់ថា រស់-ញឹមទេវិញ ) ពីផ្ទះគាត់ដែលនៅក្នុងច្បារពិសោធន៍ស្រូវជប៉ុន ជិតភ្នំតូចភ្នំធំស្រុកមង្គលបូរី ខ្លះទៀតទៅចាប់ចងគណតំបន់ សហករណ៍ គណៈស្រុក កងឈ្លប ទៅសម្លាប់ចោលដោយចោទថាក្បត់ ។ ឯពួកពាយ័ព្យនិងកងឈ្លបខ្លះ ដូចជាអាមេពេជ្ឈឃាតប្រចាំភូមិវត្តគរមាន ៖ អាពៅ, អាមឿន, អាឡឿន បានរត់ចូលព្រៃតស៊ូជាមួយពួកនិរតីរហូតដល់យួនចូល ។ ពួកមជ្ឈឹ

មបានយកពួកនិរតីមកជំនួសគ្រប់ផ្នែកក្នុងភូមិភាគពាយ័ព្យទាំងមូល ។ ឯការសម្លាប់នៅតែមានជាបន្តហូរហែរគ្មានឈប់ឈរឡើយ រាល់ៗថ្ងៃ ។ ក្នុងឃុំវត្តគរមានមេកងផៃជាអ្នកចេះអែបអបជាមួយពួកនិរតី ប្ដឹងឲ្យយកអ្នកនេះយកអ្នកនោះ ។ ក្រោយយួនចូល មេកងផៃក៏ត្រូវកងស្វៃត្រាណាឃុំវត្តគរសំរេចយកទៅបាញ់ចោលនៅផ្លូវថ្មីជិតអតីតពំនូកដី Murette ដែលគេលើកពូនធ្វើជាខ្សែក្រវាត់ការពារក្រុងបាត់ដំបងជំនាន់សាធារណរដ្ឋខ្មែរ ។

នៅដើមខែធ្នូ ក្រោយពីដកហូត ដាវ កាំបិត ពូថៅពីប្រជាជនហើយ ពួកវាបានដាក់ផែនការឲ្យចាកចេញពីភូមិ ទៅធ្វើខ្ទមនៅវាលស្រែខាងកើតភូមិវត្តគរ ហើយបង្ខំឲ្យច្រូតស្រូវទាំងមិនទាន់ទុំស្រួលបួលផងនោះ យ៉ាងរួសរាន់បំផុត ។ ពួកវាហាក់ដូចជាដឹងថា ទ័ពយួនប្រុងប្រៀបវាយចូលស្រុកខ្មែរហើយ ។ មានពួកនិរតីចេះតែមកបន្តគ្នាគ្មានឈប់ ខ្លះដេញក្របីគោទាំងហ្វូងមកផង ។ ពួកវាលើកខ្ទះបាយរួមទៅដាំស្លនៅឯស្រែដែរ ។ មេកងឈ្មោះផៃបាននិយាយដោយគំរាមចង់ស៊ីសាច់ ឮនឹងត្រចៀកខ្ញុំផ្ទាល់ថា ៖ « ពួកអារដ្ឋការសេសសល់ !... ពួកវ្អែងចាំមើលតែដល់ច្រូតស្រូវរួចនឹងដឹងគ្នាហើយ ! » ។ នៅឯភូមិស្វាយចេក វាបានហៅប្រជាជនមកប្រជុំ ហើយពួកវានិយាយថា «អង្គការត្រូវការកងទ័ពទៅវាយយួន ព្រោះយួនចូលមកវាយស្រុកយើងហើយ ហេតុនេះបើមានបងប្អូន ឬមិត្តណាដែលជាអតីតទាហានសាធារណរដ្ឋពីដើមនោះ សូមបង្ហាញខ្លួន អង្គការនឹងចាត់ឲ្យជួយកាន់កាំភ្លើងទៅវាយយួន » ។ អ្នកដែលខំលាក់ខ្លួនជាយូរមកហើយក៏ប្រាប់វាអស់ ពួកវាក៏ដឹកជញ្ជូនតាមរទេះទាំងគ្រួៗជាងពីរពាន់នាក់ ប្រាប់ថាទៅចូលជាមួយកងយោធាទៅវាយយួន ។ ចេញផុតពីភូមិប្រហែល២គ.ម. ពួកយោធាខ្មែរក្រហមក៏បាញ់សម្លាប់ពួកនោះទាំងគ្រួសារអស់គ្មានសល់ ។

នៅចុងខែធ្នូ១៩៧៨ ពីស្រែទៅ យើងមើលឃើញពួកកងទ័ពប៉ុល-ពត នាំគ្នារត់ដឹកសម្ភារៈផ្សេងៗមាន ម៉ាស៊ីនដេរ ក្រណាត់ គ្រាប់កាំភ្លើងគ្រប់ធុន ធ្វើដំណើរប្រញាប់ប្រញាល់លើផ្លូវប៉ៃលិន បឹងរាំង ។ ពួកយោធាខ្លះមកតាមរទេះភ្លើង សស្លើតសស្លាក់ស្ពាយកាំភ្លើងម្នាក់ពីរឬបីដើម សួររកផ្លូវទៅសំឡូត ភ្នំវាយចាប ។ ព្រឹកថ្ងៃទី៩មករាឆ្នាំ១៩៧៩ មានយន្តហោះមីចពីរគ្រឿងបើកយ៉ាងលឿនកាត់ពីលើក្រុងបាត់ដំបង បាញ់ទម្លាក់គ្រាប់បែកដេញពួកយោធាខ្មែរក្រហមដែលកំពុងរត់បាក់ទ័ព ។ ពួកវារាយដាក់ខ្សែត្រៀមទី១នៅត្រង់វត្តបឹងរាំង មានតាំងកាំភ្លើងធំនៅក្នុងវត្តបឹងរាំងនោះផង ។ ដោយបណ្ដោះកាំភ្លើងនិងគ្រាប់ដែលស្តុកទុកក្នុងវត្តសង្កែដ៏ល្អប្រិមប្រិយមិនទាន់ យប់ថ្ងៃទី៩មករា ពួកវាក៏បាញ់ផ្ដោងកំទេចវត្តសង្កែឆេះភ្លឺមួយចំហៀងមេឃ ។ ពួកអ្នកស្រុកក៏នាំកូនជញ្ជូនចៅរត់ចូលមកភូមិលំនៅវិញ នាំគ្នាឈរមើលភ្លើងឆេះវត្តសង្កែផ្ទុះកក្រើកដី ។ ថ្ងៃទី១០មករា ទ័ពយួនមានលាយលាវផង បានចូ-លមកដល់អតីតខ្មោចក្រុងបាត់ដំបង ។ ប្រជាជនមួយក្រុមយកបានកាំភ្លើងមួយហិប ដែលខ្មែរក្រហមយកទៅមិនទាន់ នៅខាងលើភូមិបឹងរាំងបន្តិច ហើយក៏នាំគ្នាជាមួយអតីតឈ្លបឃុំវត្តគរ ដែលរត់ចូលព្រៃលើកគ្នាទៅចែងក្ការ ស្ទាក់បាញ់ឡានហ្ស៊ីបគណៈស្រុកឆេង និងតាម៉ុក ។ តាម៉ុកគេចរួចខ្លួន ។ ប្រជាជននាំគ្នារត់ទៅភូមិខាងលើៗ មកជិតកន្លែងដែលមានទាហានយួន មកនៅកកុញគ្នានឹងវត្តគរ មាត់ស្ទឹង

សង្កែ ខ្លះទៀតបានឆ្លងទៅត្រើយម្ខាង ។ ទ័ពយួនវាយាមដាក់ខ្សែក្រវាត់ការពារវានៅ ត្រឹមផ្លូវរទេះភ្លើង ចម្ងាយខ្ទង់ពីររយម៉ែត្រពីផ្ទះដែលខ្ញុំនៅ ។ ប្រជាជនបាននាំគ្នាទៅជញ្ជូនយកក្រណាត់ខ្មៅ ស្បៃមុងពីរោងតម្បាញក្នុងវត្តគរ ខ្លះទៀតនាំគ្នាទៅចាប់មាន់ទា ជ្រូក ពីទ្រុងរួមនៅផ្លូវថ្មី ខ្លះឡើងបេះដូងអែអ៊ុកធ្វើជ្រូកមាន់ទា ។ យប់នោះពួកយោធាប៉ុល-ពតបានស្លៀកពាក់បន្លំធ្វើប្រជាជន ជាទាហានហេង-សំរិន ស្លៀកកាគីចូលមកឃុំវត្តគរ ។

យើងបានសាកសួរគ្នាថាជាពួកណាដែរ គេថាជាកងទ័ពមិត្តយើងមករំដោះទេ ។ ព្រឹកឡើងម៉ោងប្រាំ ស្មេរខ្ញុំកំពុងតែផ្ទៀងស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ស្រាប់តែឮជាដំបូងស្នូរកាំភ្លើងបីគ្រាប់ជាសញ្ញា បន្តិចមកស្នូរដូចលាជផ្ទុះ ។ ពួកយោធាខ្មែរក្រហមបានមកនៅពេញក្រោមផ្ទះ តាមផ្លូវ ហើយដេញប្រជាជនឲ្យចេញពីភូមិ ផ្ទះសំបែង តាមផ្លូវ តាមដងស្ទឹងឡើងទៅលើ អ្នកដែលប្រុងគេច ត្រូវពួកវាបាញ់សម្លាប់ចោលស្លាប់ហូរហែរតាមផ្លូវ ។ ឪពុកក្មេកនិងម្តាយក្មេកខ្ញុំត្រូវពួកយោធាខ្មែរក្រហមជន្លៀសចេញទៅអស់តាំងពីព្រលឹមស្រាងៗ ។ ខ្ញុំ ប្រពន្ធ និងកូនតូចអាយុជិតពីរឆ្នាំពួនសម្ងំនៅលើផ្ទះ ។ ខ្ញុំលបមើលតាមប្រហោងក្តារ ឃើញពួកវាកំពុងកាប់ដូងចែកគ្នាស៊ី និងផឹកទឹក ហើយជជែកគ្នារញ៉េរញ៉ៃ ។ ដល់ម៉ោងប្រហែលប្រាំបី កូនប្រុសខ្ញុំអាយុទើប២ខួបរើយំ ម្តាយខ្ទប់មាត់ដែរ តែពួកវាបានឮរួចជាស្រេច ។ គ្នាវាស្រែកថា មានមនុស្សនៅលើផ្ទះ ។ អាម្នាក់រាងដូចចោរខ្មៅស្រិលឡើងមកធាក់ទ្វារលើកកាំភ្លើងអាកាហៀបនឹងកេះកៃទៅហើយ តែបានយោធាម្នាក់ទៀតរាងសជ្រះឡើងមកទាន់គាសលើកចុងកាំភ្លើងទៅលើរួចនិយាយថា ៖ « បងអើយ! សុំទៅតាមគេសិនទៅ កុំឲ្យគេធ្វើបាប » ។ ខ្ញុំក៏នាំប្រពន្ធកូនមកដីជាប្រញាប់ រួចដើររ៉ាបតាមផ្លូវដងស្ទឹងទៅលើតាមពួកវាប្រាប់ ។ ពួកយោធាដែលជិកលេណដ្ឋានហូរហែរតាមផ្លូវស្រែកជេរខ្ញុំលាន់ទ្រហឹងសព្វបែបយ៉ាង ។ អាខ្លះវាថា « យ៉ើស! បានតែបាញ់ចោលម៉េចនៅចង់ចូលយួនអេះ ? » ។ អាខ្លះទៀតវាថា « អានេះបានតែដាក់វាឲ្យចាំយាមផ្លូវនៅត្រង់ណោះ ! » ។ល។ ខ្ញុំចេះតែនិយាយអង្វរដោះសារវាថា « មកពីកូនខ្ញុំវាគ្រុនខ្លាំង សូមមិត្តអាណិតមេត្តាផង » ។ អាខ្លះទៀតវាថា « ទៅ! ទៅ! ឲ្យឆាប់កុំឲ្យអញប្រែចិត្តទាន់ » ។ នៅតាមផ្លូវមានអ្នកជិះកង់តឿនឲ្យប្រជាជនស្រូតទៅមុខ ។ ខ្មោចស្លាប់នឹងយោធាបាញ់ចោលនៅរណោតស្អកស្ទឹងតាមដងផ្លូវ មានទាំងខ្មោចតាឡៅ-អ៊ូនិងកូនប្រុសម្នាក់ផង (១១) ។ ខ្ញុំមានអារម្មណ៍ថា បើនៅតែតាមវាទៅខាងលើតទៅទៀត ជីវិតខ្ញុំច្បាស់ជាពួកវាសម្លាប់ជាមិនខាន ព្រោះរាងរៅសម្បុរសំបកខ្ញុំមិនមែនជាអ្នកស្រែ ។ ខ្ញុំចេះតែបបួលប្រពន្ធខ្ញុំរត់ឆ្លងទៅត្រើយម្ខាង តែប្រពន្ធខ្ញុំមិនព្រមតាម ដោយចង់ស្រូតទៅឲ្យទាន់ឪពុកម្តាយដែលទៅមុនបាត់ ។ បបួលជាច្រើនដងនៅតែមិនព្រម ខ្ញុំក៏សំរេចចិត្តថាត្រូវតែគេចខ្លួនមួយរយៈសិន ។ ពេលដើរហួសរោងជាង (១២) ប្រហែលជាប្រាំរយម៉ែត្រ ដោយត្រង់នោះផ្លូវកោងវាងឆ្ងាយពីមាត់ច្រាំង

*(១១) ឡៅ-អ៊ូ ត្រូវជាមាឡៅ-បេងគន (នួន-ជា) ជាប្អូនប្រុសឡៅ-លីវ ឪពុកនួន-ជា ។*

*(១២) សូមជំរាបថា ក្រោយពីថ្ងៃដែលពួកម្ស៊ីមបក្សចូលមកចាប់មូល-សម្បត្តិ និងពួកពាយ័ព្យទិសសម្លាប់ចោលនោះ មួយអាទិត្យក្រោយ ខ្ញុំត្រូវគេដកចេញពីរោងជាង ឲ្យមកនៅក្នុងភូមិជួយសង់រោងដាក់ស្រូវ ។*

ស្ទឹង ហើយច្រាំងក៏ចោតទៀតនោះ, ចាំឲ្យប្រពន្ធខ្ញុំដើរផុតទៅមុខបន្តិច ខ្ញុំធ្វើជាចូល ទៅដងទឹកក្នុងផ្ទះគ្មានមនុស្សនៅ ។ ពេលយោធាជិះកង់តឿនប្រជាជនជិះកង់ហួស បន្តិច ខ្ញុំក៏គេចរត់លោតចុះទៅពួនអែបនឹងមាត់ច្រាំងចោតសម្ងំនៅទីនោះទៅ ។ ខ្ញុំឮ សូរអាក្រុមកាំភ្លើងត្បាល់ប្រាំ-ប្រាំមួយនាក់ ដែលកំពុងថយបណ្តើរបាញ់ផ្តោងបណ្តើរ និយាយសើចក្អាកក្អាយនឹងជោគជ័យពួកវានេះ ។ ខ្ញុំចាំរហូតទល់យប់ ទើប ហ៊ានហែលឆ្លងទឹកទៅត្រើយម្ខាង ។ ហេតុដែលខ្ញុំគេចក៏ជាការសន្និដ្ឋានដ៏ត្រឹមត្រូវ របស់ខ្ញុំមែន ព្រោះក្រោយខ្ញុំជួបប្រពន្ធខ្ញុំវិញ ឮថាពេលយប់ ពួកអាយោធាខ្មែរក្រហម វាដើរឆ្លុលពិលមើលមុខអ្នកវត្តគរដែលវាជន្លៀសនោះ នរណាមានរូបរាងស្អាតបាត មិនសមជាអ្នកស្រែ វាក៏អូសកយកទៅសម្លាប់ចោលបន្តគ្នា ។ កន្លែងសង្ស័យមុន នឹងឆ្លងកាត់ផ្លូវត្រើយខាងកើត ខ្ញុំចូលពួនក្នុងដុបស៊ុបទ្រប់សិន សំរាករួចព្រឹកឡើង បានដើរកាត់ង៉ាកឆ្វេងសំដៅទៅភូមិអូរដំបង ក្រោយវត្តតាមឹម ទល់មុខនឹងភូមិវត្តគរ ។ ពីរ-បីថ្ងៃក្រោយមក អ្នកដែលហ៊ានឆ្លងស្ទឹងចូលទៅយកឥវ៉ាន់ក្នុងភូមិវត្តគរ ត្រូវ ពួកឈ្លបបាញ់ស្លាប់អស់ជាច្រើន ។ ពេលរត់ចេញពីគំនៀរខ្មែរក្រហមវិញ ប្រពន្ធខ្ញុំ ខំដើរអើតមើលតាមច្រាំងមាត់ស្ទឹងក្រែងឃើញសពខ្ញុំ រហូតបានជួបអតិតសិស្សខ្ញុំ ម្នាក់ដែលប្រាប់ថាខ្ញុំនៅរស់នៅឡើយ (១៣) ។

ខ្ញុំភ្លេចជំរាបថា នៅថ្ងៃទី៧មករា១៩៧៩ ពេលដែលទ័ពយួនយកបានក្រុងភ្នំពេញហើយនោះ ប៉ុស្តិ៍វិទ្យុបានផ្សាយឲ្យប្រជាជនគាំគ្នាក្រោកឈរឡើង វាយកំចាត់កំទេចរបបពួកប៉ុល-ពត ។ ខ្ញុំព្រមទាំងគ្នាមួយចំនួនបានបើកវិទ្យុក្នុងរោងបាយរួម ដឹងថា គេដេញពួកខ្មែរក្រហម យកបានភ្នំពេញហើយ ។ ឈ្មោះម៉ឿត, យ៉ឺន, សារិ និងគ្នាមួយចំនួនទៀតដែលខ្ញុំមិនចាំឈ្មោះ ក៏កំរើកចិត្តក្លាហាន នាំគ្នាចាប់គណាកងពួកនិរតី ឈ្មោះតាមាំង តាក្បាលធំនិងប្រពន្ធ (មិនចាំឈ្មោះ) យកទៅកាប់សម្លាប់កប់ចោល នៅក្រោយភូមិវត្តគរ ត្រង់ចុងចំការចិកស៊ុយ ។ មិត្តមាយជាគណាឃុំនិរតី ដែលមកជំនួសមិត្តយ៉េន (ពាយ័ព្យទិស) បាននាំពួកយោធាជាងសាមសិបនាក់ មានកាំភ្លើងគ្រប់ដៃតាមរកពួកអ្នកដែលសម្លាប់គ្នាគេ ។ ពួកបះប៉ុន្មាននាក់នោះក៏ឆ្លៀតគេចទៅ ប្រុងចាប់ប្រពន្ធមិត្តមាយយកទៅសម្លាប់ទៀត តែនាងនោះកូនខ្ចីផង បានអង្វរសុំឲ្យទុកជីវិតព្រោះខ្លួនមិនបានដឹងរឿងអ្វីទេ ហើយមួយទៀតនាងនោះក៏មានចិត្តថ្លើមមិនកាចសាហាវដូចប្តីជាគណាឃុំ ទើបពួកគេលែងមិនសម្លាប់ ។ ដោយសារតែរឿងនេះ ពួកយោធាក៏ធ្វើការសងសឹកវិញ ដោយបាញ់សម្លាប់ពួកកងចល័ត ដែលវិលត្រឡប់មកពីការដ្ឋានទំនប់ទឹកខ្លះ ការដ្ឋានស្រែវាលទ្រាខ្លះ មកជួបជុំឪពុកម្តាយឯភូមិវិញ ស្លាប់អស់ជាងបីរយនាក់នៅត្រង់ភូមិខ្សាច់ពោយ (អតីតភូមិយួនកាតូលិក) និងខ្លះទៀតវាឆ្លុលពិលមើលមុខយកទៅសម្លាប់ពេលកំពុងជន្លៀស ។ ហេតុនេះហើយទើបខ្ញុំដាច់ចិត្តបែកប្រពន្ធនិងកូនសិន ហើយមួយទៀតដោយសារខ្ញុំយល់ថា ស្រីៗពួកវាមិនសូវជាយកចិត្តទុកដាក់ ឬធ្វើបាបទេ ពេលដែលពួកវាកំពុងភ័យស្លន់ស្លោររត់នឹងកងទ័ពយួនដេញពីក្រោយនោះ ។

យួនបានដេញតាមពួកយោធាប៉ុល-ពតយ៉ាងប្រកិត និងផ្តោងកាំភ្លើងធំដាក់ថៃ

*(១៣) គឺប្រាំបួនថ្ងៃក្រោយមក ពេលនោះកូនប្រុសច្បងខ្ញុំគ្រុនក្តៅជាខ្លាំង និងចេញកញ្ជ្រិលផង ។*

មទៀត ធ្វើឲ្យអ្នកជន្លៀសនិងពួកយោធាខ្មែរក្រហមភិតភ័យជាខ្លាំង នឹងគ្រាប់ផ្លោងយួន ។ ពួកវាឆែកឆេរខ្ញុំយកនាឡិកាដៃនិងខ្សែកដែលលាក់ទុក ហើយចោទខ្ញុំថា បានចូលជាមួយយួនទៀត មុនពេលដែលខ្ញុំសំរេចចិត្តបែកពីប្រពន្ធខ្ញុំនោះ ។ លោកគ្រូឈើន-ឆាយក៏ត្រូវពួកវាឆែកឆេរដែរ តែគាត់ចេះនឹកឃើញល្បិចមួយថា អូ! កងទ័ពយួនគ្នាជាងសាមសិបនាក់ទើបនឹងជួបខ្ញុំត្រង់នោះអំបាញមិញ ! អាយោធាបីនាក់ដែលប្រុងឆែកឆេរយកនាឡិកាដៃ ខ្សែក ក៏ភ័យស្លោរ ងាកមើលឆ្វេងស្តាំ រួចដាក់មេថាយបណ្តោយ ។ កងទ័ពយួនទៅតាំងនៅភូមិឃុំណា វារើសគណៈកម្មការភូមិ កងស្វ័យត្រានយាមភូមិរួចហើយ យួនវាដកចេញដោយគ្មានប្រាប់ជាមុនសោះ ។ ពេលយប់ឡើងពួកខ្មែរក្រហមវាដឹងក៏ចូលមកបាញ់សម្លាប់កងស្វ័យត្រានគ្មានកាំភ្លើង និងប្រជាជនស្លាប់អស់គ្មានសល់ ។ នេះហើយជាល្បិចមួយរបស់យួន ក្នុងការខ្ចីដៃខ្មែរក្រហមសម្លាប់រាស្ត្រខ្មែរស្លូតត្រង់ ហើយខ្មែរគ្មានពិចារណាខ្លះនៅតែយល់ថាយួនវាមានគុណលើខ្មែរទៀត ។ បើប្រជាជនចាប់បានខ្មែរក្រហម យួនវាទៅយកមកឃុំទុក ឲ្យបាយទឹករួចលែងអាខ្មែរក្រហមនោះទៅវិញ វាក៏នាំយោធាគ្នាវាចូលមកសម្លាប់អ្នកចាប់វានិងប្រជាជនភូមិនោះអស់ទៅ ។ កន្លែងខ្លះទៀត ដែលប្រជាជនចាប់បានពួកឈ្លបដែលសម្លាប់ឪពុកម្តាយបងប្អូនគេ ហើយប្រុងប្រៀបនឹងសម្លាប់សងសឹកវិញ យួនធ្វើជាទៅឃាត់យកល្មមើល រួចបន្តិចមកពួកយួននោះក៏បើកដៃឲ្យអ្នកចងគំនុំនឹងឈ្លបខ្មែរក្រហមនោះកាប់សម្លាប់ជនឃាតករនោះទៅ ។ ពួកមេកង មេភូមិ ពាណិជ្ជឈ្លបដែលមានខ្លួនខ្លះ ដែលមានចិត្តសាហាវសម្លាប់គេជំនាន់ប៉ុល-ពត ក៏ត្រូវគេសម្លាប់វិញ ខ្លះក៏រត់គេចខ្លួនទៅនៅទីដទៃឆ្ងាយៗ ហើយពួកជំពូកនេះក៏បានមកប្រទេសទី៣ ជាពិសេសសហរដ្ឋអាមេរិកក៏មិនតិចដែរ ដូចជាករណីមិត្តភៀង (គណឃុំជ្រៃ) មេពេជ្ឈឃាតប្រចាំខេត្តបាត់ដំបងជាដើម ដែលសព្វថ្ងៃរស់នៅក្នុងរដ្ឋខូណេតធីខាត់ ។

❑ ❑

❑

# យួនបនិយកម្មក្នុងសម័យ
# ហេងសំរិន_ហ៊ុនសែន

ដើម្បីឲ្យប្រជាជនគាំទ្រ យួនបានរៀបចំដាក់ហេង-សំរិន, អតីតខ្មែរវៀតមិញ នៅជាយដែនយួន-ស្វាយរៀង ឲ្យធ្វើជាប្រធានរដ្ឋទីងមោង ហើយប្រែឈ្មោះស្រុកខ្មែរជា « កម្ពុជាប្រជាមានិត » តែយួនក្ដាប់ត្រួតត្រារបបនេះនិងសង្គមខ្មែរដល់ជំរៅ ខ្លាំងជាងសម័យទ្រឿង-មិញយ៉ាង ជ្រៅជាងអាណានិគមបារាំងទៅទៀត ។ មេដឹកនាំហូ-ជីមិញបានសិក្សាពីបរាជ័យភាពក្នុងការធ្វើវៀតណាមូបនិយកម្មកម្ពុជាមិនសំរេចជំនាន់ក្សត្រីខ្មែរអង្គម៉ី ។ ព្រោះមកពីហេតុអ្វីទើបយួនូបនិយកម្មនោះមិនសំរេច ? ព្រោះ ៖

១- មេដឹកនាំយួនមិនបានសិក្សាពីសង្គមខ្មែរឲ្យបានជ្រៅជ្រះ ។ យួនឃុំយកតែស្ដេចខ្មែរជាប់ក្នុងកណ្ដាប់ដៃ គេក៏មានជំនឿថា គេអាចរំលាយស្រុកខ្មែរ ជាខេត្តយួនជាពិតប្រាកដ ។ យួនអាចក្ដាប់បានតែទីក្រុង តែតាមជនបទ ភូមិ ឃុំ យួនមិនបានគិតគូរសោះ ។ នេះហើយជាចន្លោះផ្លូតរបស់មេទ័ពទ្រឿង-មិញយ៉ាង ក្នុងការធ្វើយួនូបនិយកម្មកម្ពុជាទាំងមូលមិនបានសំរេចនោះ ។

២- មេយួនមិនស្គាល់ទឹកចិត្តប្រជារាស្ត្រខ្មែរ។ ខ្មែរសម័យនោះគេស្រឡាញ់គោរពស្ដេចណាស់ ទុកស្ដេចជាម្ចាស់លើសិរីសា ជាម្ចាស់ផែនដី ។ ការដែលយួនចាប់ឃុំស្ដេចខ្មែរ ជាការមួយបញ្ជាក់ថា យួនមានបំណងរំលាយវង្សក្សត្រខ្មែរ ហើយយកយួនឲ្យមកធ្វើជាស្ដេចលើរាស្ត្រខ្មែរវិញ ។ មួយវិញទៀត រាស្ត្រខ្មែរមិនចូលចិត្តឲ្យជាតិសៃសាសន៍ មកធ្វើការបង្ខិតបង្ខំគេទេ ។

៣- មេដឹកនាំយួននិងទាហានយួនមិនចេះភាសាខ្មែរ ដែលជាការមួយពិបាកក្នុងការប្រាស្រ័យទាក់ទងឲ្យយល់ចិត្តខ្មែរផង និងជាពិសេសពិបាកក្នុងការស៊ើបយកការណ៍សម្ងាត់ពីចលនាតស៊ូខ្មែរផង ។

៤- យួនមិនស្គាល់ភូមិសាស្ត្រទឹកដីខ្មែរ ដែលជាការពិបាកក្នុងការត្រួតត្រា ។

៥- ការយកពុទ្ធសាសនាមហាយានមកបង្ខំឲ្យខ្មែរទាំងប្រទេសព្រមទទួល និងធ្វើការគោរពព្រះសង្ឃយួនដែលស្លៀកខោអាវផ្ទុយពីស្បង់ចីពរ រំលាយវត្តអារាមព្រះវិហារខ្មែរ រួចសង់វិហារបែបយួន បង្ខំឲ្យស្រីខ្មែរស្លៀកអាវបំពង់វែងរបៀបយួនឲ្យមន្ត្រីខ្មែររៀនភាសាយួន ជាការមួយប្រឆាំងនឹងទំនៀមទំលាប់របស់ខ្មែរ ដែលបានអនុវត្តរាប់ពាន់ឆ្នាំមកហើយ ។

៦- ការដែលយួនប្រើអំពើកាចឃោរឃៅមកលើរាស្ត្រខ្មែរ បង្ហាញខ្មែរឲ្យមើលឃើញថាយួនមានបំណងរំលាយជាតិខ្មែរប្រទេសខ្មែរជាពិតប្រាកដណាស់ ។

៧- ផែនការយួនដែលប្រុងដកចៅហ្វាយខេត្តខ្មែរហើយយកយួនមកជំនួនវិញនោះ បានធ្វើឲ្យចៅហ្វាយខេត្តខ្មែររួបរួមដៃជាមួយប្រជារាស្ត្រវាយកំចាត់យួនវិញ ។

បុព្វហេតុទាំង៧ប្រការនេះហើយដែលធ្វើឲ្យខ្មែរចេះរួបរួមគ្នា ក្រោកឡើងបង្កជា

ក្រុមជាស្ន័គ្របក្សពួកបះបោរទូទាំងប្រទេសខ្មែរ ប្រឆាំងតទល់នឹងសត្រូវបរទេស ដែលចង់រំលាយសាសន៍ខ្មែរ រំលាយប្រទេសខ្មែរ ។ ការសន្ធត់គ្នាគ្រប់មេបះ ធ្វើការ បោសសំអាតយួនទាំងទាហានទាំងស៊ីវិល កំឡុង៨ថ្ងៃទូទាំងប្រទេសខ្មែរ ធ្វើឲ្យមេ ទ័ពយួនទ្រឿង-មិញយ៉ាងមិនអាចទប់ទល់បានឡើយ ហើយទោះបីជាទ្រឿង-មិញ យ៉ាងបានប្តូរផែនការប្រុងបោករាស្ត្រខ្មែរ ដោយព្រមយកវង្សក្សត្រខ្មែរអង្គម៉ីមក ឲ្យសោយរាជ្យវិញនោះ ក៏វាជាការហួសពេលទៅហើយដែរ ព្រោះរាស្ត្រខ្មែរលែង ជឿលែងទុកចិត្តយួនថាមានចិត្តស្មោះត្រង់ មិនបោកប្រាស់ទៀត ដូចសុភាសិតខ្មែរ តែងរំលឹកប្រាប់កូនចៅថា ៖ « សៀមមិនចោលក្បួន យួនមិនចោលពុត » ។ ថែមពី លើនេះទៅទៀតនោះ ព្រឹត្តិការណ៍ « កំពប់តែអុង » ក៏ទើបតែនឹងកន្លងទៅថ្មីៗ ជាង ១០ឆ្នាំប៉ុណ្ណោះ ដែលកាលណោះយួនបានធ្វើការសម្លាប់ខ្មែរដោយភាពសាហាវព្រៃ ផ្សៃហួសហេតុពេកក្នុងការជ្ជានជីកព្រែក « វិញតេ » ។ ព្រឹត្តិការណ៍កំពប់តែអុងនេះ ដូនតាម៉ែឪខ្មែរ លើកលែងតែស្តេចខ្មែរមួយចេញ តែងលើកយកមកតំណាលប្រាប់ កូនចៅឲ្យចងចាំ ស្គាល់ពីចិត្តគំនិតយួន បំណងរបស់យួន ។ ទោះបីជាមេដឹកនាំខ្មែរ មួយក្តាប់តូចស្រឡាញ់យួនក៏ដោយ តែរាស្ត្រខ្មែរស្រទាប់ក្រោមមិនស្រឡាញ់ មិន ចូលចិត្តយួនសោះឡើយ ព្រោះយួនជាជាតិសាសន៍មានពុតត្បុត ក្រលិចក្រលុច ណាស់ តែខ្មែរមិនមែនមានគំនិតប្រកាន់ពូជសាសន៍ Racialist របៀបដូចក្នុងសង្គម អាមេរិកាំងសម័យមុន ដែលស្បែរបរទេសខ្លះបានសរសេរនោះទេ ។

ហេតុដូច្នេះហើយ ដើម្បីក្រសោបលេបប្រទេសខ្មែរ ក្នុងដំណើរឆ្ពោះមកទិស ខាងលិចលើកទី២ទៀតនោះ ហូ-ជីមិញបានរៀបផែនការវាយ៉ាងល្អិតល្អន់ ព្រមទាំង សិក្សាស្រាវជ្រាវពីបុព្វហេតុនៃបរាជ័យរបស់ដូនតាវា ដែលធ្វើវៀតណាមូបនិយកម្ម កម្ពុជាមិនបានសំរេចនោះ ។

ផែនការថ្មីរបស់ហូ-ជីមិញគឺ ៖

១- រៀបចំសង្គមខ្មែរឲ្យផ្ទុយខុសស្រឡះពីសង្គមប៉ុល-ពត ។

២- ធ្វើឲ្យខ្មែរស្រឡាញ់យួន កែប្រែប្រវត្តិសាស្ត្រ ថាយួនជាមិត្តមកជួយខ្មែរ ។

៣- ពង្វក់ឲ្យខ្មែរឆ្កួតវង្វេង ពុករលួយ រាំរែក ស្រីញី បញ្ចូលស្រីយួនឲ្យមកធ្វើជា ប្រពន្ធចុងពួកមេដឹកនាំធំៗ និងពួកអាជ្ញាធរខ្មែរហេង-សំរិន ។

៤- យកក្រុមខ្មែរវៀតមិញមកដឹកនាំស្រុកខ្មែរ ។

៥- ប្រើវិធានការពន្យាពេល ដើម្បីរៀបចំផ្ទៃក្នុង និងឲ្យខ្មែរភ្លេចជឿយណាយ ផ្សាំឲ្យរាស្ត្រខ្មែរអាចរស់នៅក្រោមការត្រួតត្រារបស់យួន ឲ្យមតិពិភពលោកព្រមទទួ លស្គាល់របបអាយ៉ងហេងសំរិន-ហ៊ុនសែន ព្រមទទួលដឹងឮ Status quo ក្នុងស្ថា នភាពស្រុកខ្មែរសព្វថ្ងៃ ថាយួនជាម្ចាស់នៃកម្ពុជា ។

៦- យកនិគមយួនមកតាំងនៅលើទឹកដីខ្មែរឲ្យកាន់តែច្រើន ដើម្បីតាមពិនិត្យស កម្មភាពខ្មែរ បង្កាត់ពូជខ្មែរយួនឲ្យមានកូនកាត់យួនខ្មែរកាន់តែច្រើន ។ នេះគឺជាផែន ការរំលាយជាតិខ្មែរក្នុងរយៈពេលវែងមួយ ដែលយួនបានធ្លាប់ធ្វើមកបានជោគជ័យ រួចហើយនៅប្រទេសចាម និងថ្មីៗក្នុងចុងសតវត្សទី១៩និងដើមសតវត្សទី២០នេះ នៅកម្ពុជាក្រោម ។

ក្នុងបំណងមួយទៀតដែរ គឺឲ្យហេង-សំរិន, ហ៊ុន-សែនទទួលយកពួកនិគមយួនថ្មីៗនេះ ឲ្យចូលជាសញ្ជាតិខ្មែរទាំងអស់ ក្នុងបំណងយកឈ្នះ បើប្រសិនជាអង្គការសហប្រជាជាតិបង្ខំឲ្យមានការបោះឆ្នោតនោះ ។

៧- បំផុសលើកយកតែពីឧក្រិដ្ឋកម្ម តែអំពីគ្រោះថ្នាក់របស់ខ្មែរក្រហមមកប្រាប់មតិជាតិខ្មែរក្នុងប្រទេស និងជាពិសេសពិភពលោក ដើម្បីបិទបាំងនូវឧក្រិដ្ឋកម្មរបស់យួនមកលើរាស្ត្រខ្មែរ និងបិទបាំងគោលបំណងយួន ក្នុងការលេបប្រទេសខ្មែររួមធ្វើសហព័ន្ធឥណ្ឌូចិនទៅអនាគត ។

ក្នុងវិធានការណ៍យកឈ្នះលើពួកខ្មែរក្រហម បំភ័ន្តមតិពិភពលោក និងលេបស្រុកខ្មែរយ៉ាងឆ្ងាញ់ ដូចយួនលេបប្រទេសចាមនិងប្រទេសលាវនោះ យួននិងអាយ៉ងហេង-សំរិន ធ្វើជាបើកឲ្យមានសេរីភាព (ក្លែងក្លាយ) ប្រជាជនអាចដើរចុះឡើងបាន តែត្រូវមានលិខិតអនុញ្ញាតដើរផ្លូវ (គេត្រូវចាយលុយសូកទើបបានលិខិតនោះ) អ្នកណានៅស្រុកណាអាចវិលទៅរស់នៅស្រុកនោះវិញ ។ បង្កើតក្រដាស់ប្រាក់បោះដោយវៀតណាម យកមកទិញភោគផលខ្មែរយ៉ាងថោកដឹកចេញទៅក្រៅប្រទេសក្រោមឃ្លាថា Product of Vietnam ។ បើកឲ្យមានផ្សារលក់ដូរ បើកសាលារៀន វិទ្យាល័យ តែគេមិនឲ្យសិក្សាពីប្រវត្តិខ្មែរ មិនឲ្យសិក្សាពីអក្សរសាស្ត្រខ្មែរសោះឡើយ ។ គេបង្រៀនឲ្យកូនខ្មែរចេះស្រឡាញ់យួន ថាយួនល្អ យួនជាមិត្តមកជួយខ្មែរ ។ សិស្សដែលជាប់មធ្យមសិក្សាប័ត្រភាគទី២ ( Bacc II ) ហើយ មិនអាចយកចំណេះទៅបំរើស្រុកបានឡើយ ។ របស់អស់ទាំងនេះដែលគេបង្កើតឡើង វាគ្រាន់តែជាបំណងបង្ហាញពិភពលោកឲ្យឃើញ ហើយគាំទ្ររបបអាយ៉ង ស្អប់របបប៉ុល-ពត ហើយភ្លេចសូន្យឈឹងតែម្តងពីវៀតណាមូបនិយកម្មកម្ពុជាទាំងមូលជា « ត្រាន់តាយថាញ់» របស់យួន ។

គោលបំណងរបស់ហូ-ជីមិញបានសំរេចជាស្ថាពរហើយ ដោយសាវ័កគាត់បានដើរតាមមាគ៌ាត្រាយទុក ហើយយកបានកម្ពុជាទាំងមូលក្នុងថ្ងៃទី៧ មករា ១៩៧៩ ។

យួនវាដាក់ខ្មែរវៀតមិញ ដែលទទួលការអប់រំនៅហាណូយជំនាន់ទី១ (១៨) ហេង-សំរិន, អតីតអ្នករត់ពន្ធជ្រូកនៅស្វាយរៀង, ឲ្យធ្វើជាប្រធានាធិបតីអាយ៉ងកម្ពុជា រួចយកពួកខ្មែរវៀតមិញជំនាន់ទី២ឲ្យជួយធ្វើការ តែយួនបានដាក់ស្នងការនិងភ្នាក់ងារ (ស្រីយួនប្រពន្ធចុង) វាឲ្យនៅត្រួតត្រាតាមដានពួកក្រុមអាយ៉ងហេង-សំរិន, ហ៊ុន-សែន ។ សេចក្តីសំរេចអ្វីៗ ឬការត្រូវធ្វើយ៉ាងណាៗនោះ ត្រូវតែសាកសួរស្នើ

*(១៨) ពួកជំនាន់ទី១គឺពួកខ្មែរវៀតមិញ ដែលតាមយួនទៅនៅហាណូយក្រោយសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ មានអាចារ្យមៀន ឬសឺង-ង៉ុកមិញ, ហេង-សំរិន...។ ពួកជំនាន់ទី២គឺពួកក្មេងៗនិងពួកជំទង់កូនខ្មែរ ដែលយួនចាប់យកទៅអប់រំនៅហាណូយ ចាប់ពីរវាងឆ្នាំ១៩៥២មក គឺសម័យ « ប្រមាត់ប្រមង់ ឬអាវ៉ាប់ចាប់កូនក្មេង » មានពួកប៉ែន-សុវណ្ណ, ជា-ស៊ីម, រស់-សម័យជាដើម ។ សព្វថ្ងៃពួកខ្មែរវៀតមិញជំនាន់ទី២នេះមានប្រពន្ធយួន ឯខ្លះដោយយួនចាប់ទៅពីក្មេងពេក មិនទាំងស្គាល់ស្រុកកំណើត ឬម៉ែឪបងប្អូនផង ។ ពួកជំនាន់ទី៣ គឺពួកក្មេងកំព្រាខ្មែរ ដែលយួនប្រមូលយកពេលប៉ុល-ពតបាក់ទ័ពរត់មកជាយដែនថៃ ។ ជំនាន់ទី៣នេះ យួននឹងយកមកប្រើទៀត បើខ្មែររំដោះស្រុករួចនៅពេលនេះ ។*

សុំការយល់ព្រមពីមេដឹកនាំយួនជាមុនសិន បើតំណាងឬមេដឹកនាំយួនមិនព្រម គឺមិនអាចធ្វើឬចាត់ការបានទាល់តែសោះ ។

ផែនការវៀតណាមូបនិយកម្មថ្មីនេះ គឺយួនមិនគ្រោងដកចៅហ្វាយខេត្ត ចៅហ្វាយស្រុកខ្មែរ ហើយដាក់យួនមកជំនួសដូចដែលទ្រឿង-មិញយ៉ាង (១៥) បានអនុវត្តតាមបញ្ជាស្តេចមិញ-ម៉ាងកាលពីឆ្នាំ១៨៤០ ក្នុងរាជក្សត្រីអង្គម៉ីនោះទៀតទេ។ យួនវាយកខ្មែរដែលបានទទួលការអប់រំបញ្ចុកទ្រឹស្តីយួនឱ្យបនិយកម្មនៅហាណូយជាយូរឆ្នាំមកហើយនោះ ឲ្យត្រួតត្រារាស្ត្រខ្មែរគ្នាឯង តែយួនវាត្រួតពីលើក្បាលពួកអាយ៉ងហេង-សំរិន, ហ៊ុន-សែនទៀត ហើយមេដឹកនាំយួនបានបង្កប់ភ្នាក់ងារគេនៅក្នុងស្រទាប់អាជ្ញាធរហេង-សំរិន ជាពិសេសនៅក្នុងស្រទាប់ប្រជាជនខ្មែរតែម្តង ដើម្បីកុំឲ្យខ្មែរងើបបះបោររួចនៅក្នុងប្រទេសខ្មែរដូចសម័យទ្រឿង-មិញយ៉ាងទៀត ។ បុគ្គលិកធំៗគ្រប់ក្រសួង ទោះមានប្រពន្ធខ្មែរខ្មែររួចទៅហើយក៏ដោយ ក៏ត្រូវតែយកប្រពន្ធចុងជាយួនមួយទៀត ។

នៅតាមវិទ្យាល័យនានា គេឲ្យរៀនភាសាយួនជាភាសាទី២ចាប់ពីថ្នាក់ទី៥ឡើងទៅ ក្នុងមួយអាទិត្យចំនួន២ម៉ោង ។ តាមលិខិតឆ្លងឆ្លើយរបស់លោកតូច-ឈួង, អតីតអ្នកនិពន្ធសៀវភៅ «បាត់ដំបងសម័យលោកម្ចាស់ » បានសរសេរប្រាប់ថា ៖

នៅតាមវិទ្យាល័យនានា គេឲ្យរៀនភាសាយួនជាភាសាទី២ចាប់ពីថ្នាក់ទី៥ឡើងទៅ ក្នុងមួយអាទិត្យចំនួន២ម៉ោង ។ តាមលិខិតឆ្លងឆ្លើយរបស់លោកតូច-ឈួង, អតីតអ្នកនិពន្ធសៀវភៅ « បាត់ដំបងសម័យលោកម្ចាស់ » បានសរសេរប្រាប់ថា ៖

« សិស្សដែលប្រឡងឌីប្លូម គេធ្វើ Classement ជ្រើសរើសយកភាគរយឲ្យចូលថ្នាក់ទី៨ ( Classe de seconde ពីដើម ) តែពិន្ទុមិនដល់គេហៅថាធ្លាក់កៅអី ត្រូវស្ទូកដើរទាត់ខ្យល់ ត្រូវប៉ាច់ធ្វើទាហាន ។ ប្រឡងសព្វថ្ងៃគេត្រូវការលុយកាក់ អាក្រក់អាក្រីជាងសម័យលន់-នល់ទៅទៀត ។... តែ Taux វាមិនដល់ ជាការឥតប្រយោជន៍ ។ និយាយពីកិរិតវិជ្ជាសិស្សខ្សោយហួសវិស័យ ខ្លះជាប់ Bac ហើយមិនចេះ Fraction ផង ។

មេដឹកនាំយួនពង្វក់ខ្មែរគ្រប់ក្រសួងរដ្ឋឲ្យឈ្លក់វង្វេង ពុករលួយដល់ឆ្អឹង ដើម្បីងាយកាន់កាប់ត្រួតត្រា ព្រោះខ្មែរម្នាក់ៗគិតតែពីបញ្ហាគ្រួសារ ក្រពះ លែងគិតគូពីជាតិ ពីប្រទេសត្រូវនៅជាកញ្ជះយួន ឬទៅជាស្អីទៀតហើយ ។

គ្រូបឋមសិក្សាបានប្រាក់ខែ១៧៥រៀល ឯគ្រូមធ្យមសិក្សាបាន២៥០រៀលក្នុងមួយខែ ។ អ្នករដ្ឋការមធ្យមបានប្រាក់ខែខ្ពង់២០០រៀល ឯពួកហោ-ណាំហុង, គង់-សំអុល... បានខ្ពង់៣០០រៀលក្នុងមួយខែ តែពួកនេះជិះឡានសុទ្ធតែម៉ាកមែរសីដែស បើគិតជាលុយសន្សំប្រាក់ខែ ពួកនេះត្រូវធ្វើការចំនួនពីររយឆ្នាំទើបទិញឡានធុននេះបានជិះ ។

ដោយសារពួកខ្មែរវៀតមិញសុទ្ធតែជាមនុស្សល្ងង់ខ្លៅ មិនអាចធ្វើឲ្យប្រព័ន្ធដឹកនាំប្រទេសដើរទៅមុខបាន យួនក៏ជ្រើសរើសយកពួកជួរទី៣ មកជួយធ្វើការពួកអាយ៉ងយួននេះមាន គង់-សំអុល ( អតីតនិស្សិតនៅ Georgia សហរដ្ឋអាមេរិក ),

*(១៥) សូមអានជំពូកទី១ ។*

ហោ-ណាំហុង និងពួកអតីតរាជការជំនាន់សីហនុ និងពួករដ្ឋការជំនាន់សាធារណ-រដ្ឋមកជួយទៀត ។ ពួកក្រោយនេះ ដំបូងឡើយគេយកមកគ្រាន់តែជាបំរើពួកជួរទី១ និងជួរទី២ប៉ុណ្ណោះទេ តែក្រោយដែលជួរទី១និងទី២បាក់បែកគ្នា បន្ទាប់ពីយួនចាប់ប៉ែន-សុវណ្ណយកទៅហាណូយបាត់ទៅនោះ ពួកជួរទី៣ ដូចជាគង់-សំអុល, ហោ-ណាំហុង ក៏បានឡើងទឹកមួយកំរិតយ៉ាងខ្ពស់ ហើយតាំងខ្លួនជាកញ្ជះយួនជាច់ថ្លៃតែម្តង ព្រោះតែអំណាច ។

ដើម្បីធ្វើឲ្យក្រុមចលនាតស៊ូខ្មែរខ្សោយ ពួកយួនបានធ្វើនយោបាយទាក់ទាញយកពួកខ្មែរបរទេសដូចជា ៖ ហាំង-ង៉ោ, ឱត-ប្រុន, ប៉ែល-ណាល់, យ៉ង-សែម, អ៊ិន-តាំ, ឆាំង-សុង...។ល។ ក្នុងគោលដៅពីរ ៖ គឺមួយឲ្យគាំទ្ររបបអាយ៉ងហេង-សំរិន, ហ៊ុន-សែន និងឃោសនារបបនេះឲ្យខ្មែរនៅបរទេស និងមតិបរទេសទទួលស្គាល់របបនេះ និងគោលដៅទី២ គឺទាក់ទាញយកលុយរូបិយវត្ថុទៅជួយស្តារសេដ្ឋកិច្ចយួន ដែលពួកនេះបានរកស៊ីនាំយកលុយដុល្លារ លុយហ្វ្រង់ទៅឲ្យបងប្អូននៅស្រុកខ្មែរ តែយួនប្រមូលយករូបិយប័ណ្ណទាំងអស់ទៅព្រៃនគរ ទុកប្រាក់រៀលដែលយួនបោះឲ្យធនាគារហេង-សំរិន ជាជំនួសលុយដុល្លារទៅវិញ ។

ដើម្បីជាល្បិចលេបស្រុកខ្មែរ យួនបានឲ្យហេង-សំរិនចុះហត្ថលេខាយល់ព្រមឲ្យកងទ័ពយួនតាំងនៅលើទឹកដីខ្មែរចំនួន២៥ឆ្នាំ និងចុះហត្ថលេខាក្នុងការរាប់អានគ្នាដ៏ជិតស្និទ្ធ រវាងប្រជាជនវៀតណាម-លាវ-កម្ពុជាជាបងប្អូនយូរអង្វែងឆ្នាំ ។ ក្នុងភាសានយោបាយឬទូត ពួកគេនិយាយថា « នយោបាយរបស់ប្រទេសឥណ្ឌូចិនទាំងបី » ។

យួនបានបង្ខំឲ្យហេង-សំរិនចុះហត្ថលេខាប្រគល់កោះសេះ ដែលមានប្រេងកាតទៅឲ្យយួន កាត់បន្ថយព្រំដែនខ្មែរ ចម្ងាយពី៥ទៅ៣០គ.ម. ចាប់ពីព្រំរួមបីប្រទេសខ្មែរ-លាវ-យួន ចុះមកដល់មាត់សមុទ្រជាប់ខេត្តពាម ( Hatien ) (១៦) ។

មេដឹកនាំយួនបាននិយាយថា ៖ « ដើម្បីកុំឲ្យប្រជាជនយួននិងខ្មែរចេះតែទាស់ទែងគ្នាមិនចេះចប់ទៀតនោះ គួរខ្មែរកាត់ប្រគល់ដីចំពុះទាក្នុងខេត្តស្វាយរៀងឲ្យទៅយួន » ។

❑ ❑

❑

*(១៦) សូមអាន « កាលប្បវត្តិវិទ្យានៃប្រទេសកម្ពុជា » របស់ស្មេរ ។*

# សម្ដេចសីហនុជាប្រធានចលនាខ្មែរចំរុះ

នៅឆ្នាំ១៩៦៩ ពេលខ្មែរសេរី២០៥នាក់ចុះចូល ដែលកាលនោះសីហនុបានអានអត្ថបទខ្មែរសេរី ចែងពីគ្រោះថ្នាក់នយោបាយខុសរបស់ទ្រង់ សម្ដេចបានដឹងរួចហើយ ដោយកំហឹងចង់សងសឹកពួកលន់-នល់, សិរិមតៈ សីហនុបានចូលរួមដៃជាមួយយួនកុម្មុយនិស្តនិងខ្មែរក្រហម ។ ឲ្យទ័ពយួនហូ-ជីមិញវាយប្រទេសខ្មែរ សម្លាប់ខ្មែរ ។

ក្នុងសៀវភៅ Sihanouk's Sideshow ត្រង់ទំព័រ១៥៥ សីហនុបានសារភាពប្រាប់អ្នកនិពន្ធថា ៖ « I have had to take a sedative in order to sleep ». Princess Monique guards her husband's supply of barbiturates, just as she did during the years they were help captive by the Khmer Rouge. He wanted to commit suicide, but she refused to give him the potion. He, too, tells me ( the author ), « I owe my life and sanity to my wife ».

ហេតុអ្វីបានជាសម្ដេចសីហនុចង់ធ្វើអត្តឃាត? ព្រោះអស់សង្ឃឹម ឬដោយសារមានវិប្បដិសារី ? ។

ក្នុងសំនេរ « សង្គ្រាមនិងសេចក្ដីសង្ឃឹម » ( War and Hope ) ក៏សម្ដេចសីហនុបានសារភាពពី « បុព្វហេតុអ្វីបានជាទ្រង់ទៅជួយយួនវៀតណាមខាងជើង » ដែរ តែគ្រាន់តែជាលេសដែលទ្រង់យកមកសរសេរសំរាប់ការពារមុខមាត់ ( Sauver sa face ) ប៉ុណ្ណោះ ។ ការសំខាន់គឺទ្រង់បានសារភាពថា « សីហនុបានជួយយួនគ្រប់បែបគ្រប់យ៉ាងមែន » ។

នៅគ្រប់សុន្ទរកថា នៅគ្រប់ទីកន្លែងដែលទ្រង់យាងទៅ សម្ដេចសីហនុនៅតែមិនទទួលថា « នយោបាយរបស់ទ្រង់ខុស ឬក៏ខ្មែរទាំងបីលាននាក់ស្លាប់គឺមានទ្រង់ជាអ្នកចូលរួមជាមួយពួកឃាតករខ្មែរក្រហមទេ » ។ ទ្រង់នៅតែជំទាលជេរថា « មកតែពីពួកអាសាធារណរដ្ឋ អាលន់-នល់, សិរិមតៈ បនក្បត់ធ្វើរដ្ឋប្រហារទម្លាក់ទ្រង់ពីតំណែងប្រមុខរដ្ឋ ទើបបានជាស្រុកទៅជាយ៉ាងនេះ » ។

ក្នុងនាមជាប្រធានចលនាតស៊ូចំរុះ សម្ដេចសីហនុនៅតែធ្វើនយោបាយក្រោមទូរបញ្ជារបស់មេដឹកនាំយួន ។ ទ្រង់លាលែង លែងលាជាច្រើនដង ។ តថ្ងៃប្រាក់ខែជាមួយយួន ក្នុងពេលយួនជាមួយហេង-សំរិន ប្រើមធ្យោបាយល្បួងទាក់យកសម្ដេច ហើយឯសម្ដេចវិញងាកមកបរិហារ ផ្ដល់ការទន់ខ្សោយផ្ទៃក្នុងចលនាតស៊ូខ្មែរទៅមេដឹកនាំយួនអស់រលីង ។

សព្វថ្ងៃនេះទៀត ( ខែធ្នូ១៩៩០ ) សម្ដេចសីហនុកំពុងតែដើរតួថតកុននៅកូរ៉េខាងជើង ដើម្បីយកទៅបញ្ចាំងឲ្យរាស្ត្រខ្មែរមើល ក្នុងគោលបំណងលាងកំហុសលាងបាតដៃទ្រង់ឲ្យជ្រះឈាមរាស្ត្រខ្មែរ ដែលទ្រង់កាលនោះ ជាប្រធានរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ធ្វើសហការរួមដៃជាមួយមេដឹកនាំយួនផង ជាមួយបនខ្មែរក្រហមផង និងដូចកាលមុនដដែល គឺស្រង់ «នយោបាយប្រជាភិថុតិ ប្រជាប្រិយភាព »

របស់ទ្រង់ឡើងវិញ ។

តើតំណាទៅថ្ងៃមុខ សម្តេចសីហនុនឹងដូរឥរិយាបថ សុខចិត្តធ្វើពលិកម្មខ្លះ ដើម្បីស្រោចស្រង់មុខមាត់របស់ទ្រង់ក្នុងប្រវត្តិសាស្ត្រសកល ជាពិសេសក្នុងប្រវត្តិសាស្ត្រខ្មែរឬទេ ?

សកម្មភាពរបស់ទ្រង់ជាមួយអ្នកម្នាង ព្រមទាំងបុត្រ សព្វថ្ងៃនេះជាការបញ្ជាក់ប្រាប់យើងជាខ្មែរទាំងអស់គ្នារួចស្រេចទៅហើយ ! ។

❑ ❑

❑

# គោលដៅនិងបំណងខ្មែរក្រហមនាអនាគត

ទាំងមតិសកលលោក ជាពិសេសមតិរាស្ត្រខ្មែរ មិនជឿថា ខ្មែរក្រហមកែប្រែចិត្តគំនិត លះបង់ទ្រឹស្តីម៉ៅនិយមឆ្វេងហួសហេតុ ( Radical Maoism ) ប្តូរចរិតសាហាវលែងកាប់សម្លាប់ខ្មែរ និងមិនមកដណ្តើមអំណាចទៀត ។ ចំណុចនេះហើយដែលមេដឹកនាំវៀតណាមយល់ច្បាស់ ហើយយកមកធ្វើជាលេសក្នុងការកាន់កាប់ស្រុកខ្មែរទាំងមូលដោយសំអាងថា ការពាររាស្ត្រខ្មែរឲ្យរួចពីពួកឃាតករប៉ុល-ពត ។

បនខ្មែរក្រហមនៅតែមានជំនឿថា « បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ » និង « បដិវត្តន៍វប្បធម៌ » ដ៏លីលារពីរវាយតាមចំក្អួតម៉ារស៊ីស-ម៉ៅនិយមស្ទើរវានោះជិតបានសំរេចដល់គោលដៅទៅហើយ បើកុំតែវៀតណាមចូលមកឈ្លានពានដេញពួកវាចេញពីអំណាចនោះ ។

ពួកនិស្សិតខ្មែរដែលវិលត្រឡប់ចូលស្រុកវិញក្រោយថ្ងៃ១៧មេសា១៩៧៥ ខ្ទង់បីពាន់នាក់ ឯអ្នកដែលនៅសល់រស់ពីស្លាប់ដោយស្នាដៃប៉ុល-ពត វាលត់ដំមានជាងបីរយនាក់ ។ ក្នុងចំណោមពួកដែលនៅសល់ជីវិតនេះ មានខ្លះនៅតែជឿដូចបនប៉ុល-ពតដែរ ។ ខ្លះបានវិលទៅជួបម៉ែឪនៅខេត្តកំពង់ចាម ហើយខំអួតថា ៖ « ខ្មែរយើងនៅតែបន្តិចទៀតមានបាយហូបបីដងនិងមានបង្អែមផង » តែត្រូវបងប្អូនបានហាមឲ្យបឹទមាត់ឈប់និយាយតទៅទៀត បើពុំនោះទេនឹងត្រូវប្រជារាស្ត្រខ្មែរអូសកជាមិនខាន ។

ក្នុងពិធីជប់លៀងមួយនៅញូវយ៉កក្នុងឆ្នាំ១៩៨២ ដែលមានសម្តេចសីហនុនិងអ្នកម្នាងសីហនុបានចាត់ចែងឡើងនោះ ភ្ញៀវសំខាន់លើកលែងតែអ្នកការទូតបរទេសចេញ គឺមានមេដឹកនាំខ្មែរក្រហមធំបានចូលរួម មានខៀវ-សំផនជាដើម ។ ខៀវសំផនបានឆ្លើយតបនឹងសំនួរ ៖ « តើលោកបានសម្លាប់ប្រជារាស្ត្រប៉ុន្មាននាក់ ? មួយលាន់នាក់ ? ពីរលាននាក់ ? » ថាជា « ពាក្យភូតភររបស់ពួកចក្រពត្តិ, ចក្រពត្តិវៀតណាមឈ្លានពានបានមកសម្លាប់រាស្ត្រខ្មែរទាំងនោះ » ។

ប៉ុល-ពតតែងតែបើកវគ្គអប់រំរៀនសូត្រតំរង់គោលជិហារនយោបាយវាពុំដែលលោះខានឡើយ ជាពិសេសការអប់រំពួកគណៈដឹកនាំធំៗ ពួកមេកងយោធាជាដើម ។ ការបើកវគ្គរៀនសូត្រមួយនៅតំបន់៨៧ក្នុងខេត្តត្រាត (ស្រុកថៃ) ជិតជំរំខ្មែរក្រហមក្បែរទល់ដែនខ្មែរនោះមានទាំងពួកមេដឹកនាំនៃដែនដីពិឃាត ( The Killing Fields ) បានចូលរួមផងគឺ ៖ សុន-សេន, នួន-ជា, ខៀវ-សំផន, អៀង-សារី, តាម៉ុក ។ ជំរំនេះជាមូលដ្ឋានយោធាធំរបស់ខ្មែរក្រហម ដែលមានចំនួនពី៣៥ពាន់ទៅបួនម៉ឺននាក់ ។ នៅតំបន់៨៧ ប៉ុល-ពតបានរៀបចំយុទ្ធវិធីចាស់ដដែល ដើម្បីក្តាប់យកជនបទខ្មែរ ( កាន់កាប់ក្នុងពេលយប់ ថ្ងៃបង្កប់ខ្លួន ) ឡោមហ៊ុំព័ទ្ធទីក្រុងភ្នំពេញពុករលួយនិងរដ្ឋបាល (ហេង-សំរិន) បាក់បែក ។

ពួកខ្មែរក្រហមមិនប្រើយុទ្ធសាស្ត្រវាយសង្គ្រប់ចូលទីក្រុងភ្នំពេញ ដូចកាលឆ្នាំ១៩៧៥ទៀតទេ តែពួកវាផ្តេកផ្តួលទៅតាមនយោបាយនៃការទូតអន្តរជាតិ និងការចរ

ចាទាក់ទិនជាមួយកងទ័ពឆ្នក់ (ទ័ពចលនាតស៊ូខ្មែរ ) ។ ប៉ុល-ពតបានយល់យ៉ាងច្បាស់ថា បើកាលណាកងទ័ពខ្មែរក្រហមចូលកាន់តែជិតទីក្រុងភ្នំពេញនោះ សហគមអន្តរជាតិក៏នឹងឆ្លេឆ្លាធ្វើសម្ពាធបង្ខំឲ្យមានការដោះស្រាយនយោបាយ ។ ថ្វីបើការវាយប្រយុទ្ធត្រូវតែយកមកប្រើជាចាំបាច់នោះ តែបនខ្មែរក្រហមត្រូវតែប្រមូលផ្តុំគំនិតវាលើផ្នែកនយោបាយ ( ចូចចំរៀងពួកវាច្រើនច្រៀងថា នយោបាយរួមផ្សំអាវុធ ប្រសើមោះមុតរបស់អង្គការ ) ដើម្បីឈានទៅរកគោលដៅរបស់វានោះ ។ ហេតុដូច្នេះហើយ ទោះបីជាទីក្រុងវ៉ាស៊ិនតោនបានដកការគាំទ្រនយោបាយចេញពីពួកខ្មែរក្រហម ដើម្បីធ្វើការចរចាជាមួយវៀតណាម ក្នុងការចៀសវាងកុំឲ្យខ្មែរក្រហមមកយកអំណាចវិញក៏ដោយ ក៏វាគ្មានអ្វីប្រែប្រួលផ្លាស់ប្តូរសោះឡើយ ។

ក្នុងពិធីបើកវគ្គរៀនសូត្រនោះ ប៉ុល-ពតបានចំណាយពេញមួយថ្ងៃក្នុងការសិក្សាវែកញែកពីនយោបាយ និងមែកធាងសង្គមវណ្ណៈនៃចលនាតស៊ូត្រីភាគីដែលរួមជាមួយពួកមិនមែនកុម្មុយនិស្ត ។ ប៉ុល-ពតបានបង្រៀនថា ការដែលខ្មែរក្រហមព្រមចូលរួមជាមួយពួកមិនមែនកុម្មុយនិស្ត ក្នុងគោលដៅប្រមូលយកនូវការគាំទ្រនយោបាយពីរាស្ត្រខ្មែរក្នុងស្រុក និងការគាំទ្រផ្លូវទូតពីអន្តរជាតិ ថ្វីបើមានការប្រែប្រួលគោលជំហរនយោបាយខ្លះដោយពួកបដិវត្តន៍ជួបប្រទះជាមួយពួកចក្រពត្តិនិងសក្តិភូមិក៏ដោយ ។ តែទោះជាយ៉ាងណាក៏ដោយ ប៉ុល-ពតបានព្រមានក្រើនរំលឹកពួកសិស្សវាថា ឲ្យរក្សានូវសភាពដើម ( Their true nature) ជានិច្ចហើយរស់នៅដោយទន្ទេញជាប់ជានិច្ចថា « នយោបាយបានផ្លាស់ប្តូរ តែពួកយើងនៅតែមានចិត្តគំនិតដដែល » (The politics have changed but the spirit remains the same ) ។

ថែមពីលើនេះទៀត ប៉ុល-ពតបានធានាដល់ពួកមេកង មេគណដឹកនាំវាថា ៖ « ថ្វីបើប៉ុស្តិ៍សំខាន់ៗខាងការទូតត្រូវពួកមិនមែនកុម្មុយនិស្តកាន់កាប់ក៏ដោយក៏ពួកខ្មែរក្រហមនៅតែជាកម្លាំងទ័ពដ៏ខ្លាំងជាងគេក្នុងចលនាតស៊ូចំរុះ ៖ សម្តេចសីហនុ ជាប្រធានតែគ្មានអំណាច ប្រៀបដូចសំបកក្រូចអីចឹង ឯពួកយើងវិញជាក្លែបផ្លែក្រូចនោះ ។ សីហនុនិងពិភពលោកខាងក្រៅមិនមានទិដ្ឋភាពដូច្នេះទេ ប៉ុន្តែសមមិត្តទាំងអស់គ្នាមិនត្រូវសង្ស័យសោះឡើយថា គឺពួកយើងនេះហើយ ដែលមាននាទីជាមេដឹកនាំពិតៗក្នុងការវាយប្រយុទ្ធរំដោះជាតិនេះ » ។

ក្នុងការបើកវគ្គសិក្សារៀនសូត្រនេះ ប៉ុល-ពតបានសួរដល់សិស្សជាគណដឹកនាំខ្មែរក្រហមថា ៖ « តើយើងត្រូវធ្វើយ៉ាងណាដើម្បីឲ្យប្រជាជនគាំទ្រយើង ? » ។ ពួកគណមេកងជាច្រើនបានឆ្លើយតបថា « ឲ្យលើកយកអំពើពុករលួយរបស់ក្រុមមិនមែនកុម្មុយនិស្តមកនិយាយ ហើយបង្ហាញពីសកម្មភាពស្នេហាជាតិរបស់ពួកខ្មែរក្រហម ។ ខ្លះទៀតលើកអំពីបញ្ហាសេដ្ឋកិច្ច ថាត្រូវរៀបចំឲ្យប្រជាជនបង្កបង្កើនផលស្រូវឲ្យបានច្រើន » ជាដើម តែប៉ុល-ពតនៅតែមិនពេញចិត្តលើចម្លើយទាំងនោះ ។ ពេលនោះមានមេកងវ៉ានៅជួរក្រោយម្នាក់លើកដៃឆ្លើយថា ៖ « យើងត្រូវដាក់ខ្លួនឲ្យទាបស្មើនឹងប្រជាជនដែលក្រីក្រជាងគេ នោះបន្ទាប់មកប្រជាជនក៏នឹងមកផ្តុំគាំទ្រពួកយើងនិងស្រឡាញ់ពួកយើង » ។ ប៉ុល-ពតបានឆ្លើយយ៉ាងពេញចិត្តថា « ត្រូវ ! ត្រូវណាស់ ! » ។

នៅក្នុងថ្នាក់វគ្គរៀនសូត្រនេះ ប៉ុល-ពតបានថ្កោលទោសពួកភ្នាក់ងាររៀតណាម (ក្បាលយួនខ្លួនខ្មែរ) ថាបានធ្វើវិទ្ធង្សនាដល់បដិវត្តន៍ ជាភាគច្រើនក្នុងការសម្លាប់រង្គាល ។ ប៉ុល-ពតបានសារភាពថា ៖ « ការដែលអង្គការបញ្ជាឲ្យសម្លាប់ពួកអ្នកនយោបាយ និងមេបញ្ជាការកងទ័ពសាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧៥នោះ « ព្រោះពួកគេប្រទ្បាក់ជោគជាំដោយគំនិតចក្រពត្តិ», ហើយប៉ុល-ពតបានរំលឹកពីមេដឹកនាំខ្មែរក្រហមក្មេងៗ ដែលបានអនុវត្តទ្រឹស្តីបដិវត្តន៍ដាច់ខាតពេក និងព្រមានឈប់ឲ្យធ្វើកំហុសដដែលនោះទៀត ។

នៅពេលបញ្ចប់បីទវគ្គរៀនសូត្រនោះ ប៉ុល-ពតបានថ្លែងសុន្ទកថាដែលធ្វើឲ្យពួកសិស្សគណា បញ្ជាការ វរសេនា... ស្រក់ទឹកភ្នែកនិងសំដែងការប្តេជ្ញាចិត្តតស៊ូប្រយុទ្ធរហូតដំណក់ឈាមចុងក្រោយបង្អស់ ដូចអ្នកនិពន្ធបានលើកសំដីនោះមកសរសេរត្រង់ទំព័រ២០០ថា ៖ « ខ្ញុំមានសេចក្តីសោកស្តាយណាស់ ដោយសមមិត្តទាំងអស់មិនទាន់យល់ឲ្យបានដល់ជំរៅ ។ ខ្ញុំសោកស្តាយណាស់ដែលក្រុមតស៊ូដទៃទៀតនឹងកាន់តែមានកម្លាំង ។ ទោះបីខ្ញុំកាន់តែចាស់ និងត្រូវចូលនិវត្តន៍ក៏ដោយ ក៏ខ្ញុំត្រូវតែខំប្រឹងឲ្យអស់សមត្ថភាពដើម្បីកសាងសមមិត្ត ។ កុំមើលងាយខ្លួនថា សមមិត្តទៅមិនរួច តែត្រូវប្រុងប្រយ័ត្នជានិច្ចចំពោះភាពតោះតើយនិងលាក់ការជានិច្ច » ។...

តើក្រុមដែលតាំងខ្លួនជាខ្មែរសេរីការ ស្រឡាញ់សេរីភាព យុត្តិធម៌...នោះមានការប្តេជ្ញាតាំងចិត្តឲ្យបានមួយភាគនៃក្រុមឃាតករនេះទេ ? ។

តាមសំដីហួត-អួនហេង នៅក្រចេះ សព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រនិញ៉ាបាននិយាយថា « ឈ្មោះឆន (ឬតាយក្ស), នៅកំពង់ចាមសម័យយួនយកស្រុកខ្មែរ បានត្រូវគេចោទប្តឹងយួនថាជាខ្មែរក្រហម ។ គាត់កំពុងតែដេកអង្រឹងក្រោមផ្ទះ ស្រាប់តែមានពួកទាហានយួនមួយក្រុមចុះពីរថយន្តដើរសំដៅមករកគាត់ៗឃើញដូច្នោះក៏នឹកថាយួនច្បាស់ជាមករកចាប់គាត់ជាមិនខាន ក៏កំសៀកខ្លួនគេចទៅក្រោយផ្ទះ ទាហានយួនក៏ដេញចាប់បណ្តោយ ។ ឈ្មោះឆនឬតាយក្សបានរត់ចូលព្រៃទៅរស់នៅជាមួយពួកខ្មែរក្រហម ហើយបានធ្វើជាមេបញ្ជាការកងវរសេនា ។ គេហៅថា « តាឆន » (តាជាវណ្ណៈក្នុងជួរខ្មែរក្រហម) ។ ហួត-អួនហេងបានរំលឹកសំដីតាឆនថា ៖ « របបនេះនៅតែកាប់សម្លាប់ដដែល គឺគ្មានកែប្រែទាល់តែសោះ ព្រោះទ្រឹស្តីក្រហមដាច់ខាតបានចែងថា ត្រូវតែសម្លាប់ដើម្បីឲ្យមនុស្សខ្លាច និងគោរពតាមទិសដៅរបស់អង្គការកុម្មុយនិស្ត និងដើម្បីឲ្យបានកាន់អំណាចតទៅថ្ងៃមុខទៀត » ។

បើមានដំណោះស្រាយសន្តិភាពរួចនៅស្រុកខ្មែរ តែគ្មានការចាត់ចែងកាត់ទោសបនខ្មែរក្រហមទេនោះ ក្នុងរយៈពេលវែងនាអនាគត ក្នុងពេលដែលពួកអាជ្ញាធរខ្មែរម្នាក់ៗខំបួម ខំពុករលួយស្រង់ដើមនោះ បនខ្មែរក្រហមក៏នឹងប្រមូលបាននូវការគាំទ្រពីប្រជារាស្ត្រខ្មែរមកវិញ ហើយក្រសោបយកអំណាចមកវិញទៀតជាមិនខានតែក្នុងនាមខ្មែរស្អីមួយផ្សេងទៀត មិនមែនក្នុងនាម « ខ្មែរក្រហម » ដដែលនេះទេ។

❑ ❑

❑

# ជំពូកទី៧

## ~ យោបល់ ~

យើងម្នាក់ៗ ទាំងស្មេរបរទេស បស្ចឹមប្រទេស ព្រមទាំងប្រជារាស្ត្រខ្មែរទាំងអស់គ្នាបានមើលឃើញ និងចោទទៅលើតែក្រុមខ្មែរក្រហមបនប៉ុល-ពត, អៀង-សារី, ខៀវ-សំផន, នួន-ជាតែប៉ុណ្ណោះ ។ ពិតមែនហើយថា បនប៉ុល-ពតជាជនដៃដល់ឧក្រិដ្ឋ បាតដៃប្រឡាក់ឈាមរាស្ត្រខ្មែរបីលាននាក់ តែវាមានកត្តាអាថ៌កំបាំងមួយចំនួនធំ ដែលជាក្រុមខ្មែរគ្នាឯងក៏មាន ក្រុមបរទេសក៏មាន ដែលបានទូរបញ្ញា ( ដោយចំពោះនិងមិនចំពោះ Directly or indirectly ) បនប៉ុល-ពតឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មសម្លាប់រង្គាលជនជាតិខ្មែរគ្នាឯង ដោយពួកបរទេសនោះចាំឆ្លៀតឱកាសចំណេញ និងបឺទបាំងនូវឧក្រិដ្ឋកម្មនិងបំណងរបស់គេមកលើប្រទេសខ្មែរ និងជនជាតិខ្មែរយើង ។

តើបនប៉ុល-ពតចេញពីណាមក ? បរទេសណា ខ្មែរណាជាអ្នកបង្កើតផ្តុងផ្តើមបនឧក្រិដ្ឋជនអស់ទាំងនេះឡើងឲ្យសម្លាប់ខ្មែរ ? ឃួនជាអ្នកបង្កើតពួកខ្មែរក្រហម ។

ប៉ុល-ពតមានគំនិតស្អប់របបរាជានិយម តាំងតែពីគេយកបងស្រីបង្អស់របស់គាត់ទៅថ្វាយហ្លួងស៊ីសុវត្ថិ-មុនីវង្សធ្វើជាស្នំម្លេះ (១) ។ ថែមពីលើនេះទៅទៀតនោះសាឡុត-សរមានបំណងដ៏ធំធេងក្នុងការកសាងខ្លួនគេ កិត្តិយសផ្ទាល់ខ្លួនរបស់គេឲ្យល្បីល្បាញខ្ទរខ្ទារ ជាមេដឹកនាំខ្មែរដ៏ឆ្នើមម្នាក់ដូចជាឡេនីន, ម៉ៅ-សេទុង ឬដូចជាហូ-ជីមិញដោយដើរយកផ្លូវសង្គមនិយមកុម្មុយនិស្តបែបម៉ៅនិយមដាច់ខាត (Radi-cal ) ។

*(១) សូមជំរាបថា ខ្មែរជារាស្ត្រសាមញ្ញ លើកលែងតែនាម៉ឺនដែលផ្គាប់ស្តេចដើម្បីបុណ្យស័ក្តិចេញ មិនចង់ឲ្យកូនស្រីខ្លួន ទៅធ្វើជាស្នំស្តេចដែលមានប្រពន្ធរាប់មិនអស់នោះទេ ។ តាមការសម្ភាសន៍របស់សីហនុ ចុះក្នុងទស្សនាវដ្តី Playboy ឆ្នាំ១៩៨៧ ក្បាល៣៤ លេខ៥ សីហនុបាននិយាយថា ជីតារបស់ហ្លួងគឺទ្រង់មុនីវង្ស មានស្នំជាផ្លូវការចំនួន៦០ តែតាមការពិតរាប់រយ ព្រោះហ្លួងមានដំណាក់នៅពាសពេញស្រុកខ្មែរ គ្រាន់តែពីស្គន់ទៅកំពង់ធំ មានដំណាក់បី-បួនកន្លែងទៅហើយ ។ ដំណាក់មួយនៅអ្នករាំង ជិតផ្សាររំលងត្រូវគេលួចដុតចោល ។ ចៅហ្វាយខេត្តតែងទៅបង្ខំរាស្ត្រឲ្យយកកូនក្រមុំទៅថ្វាយហ្លួង ពេលដែលហ្លួងទៅសំណាក់លំហែនៅនឹងដំណាក់ណាមួយនោះ ។ បងស្រីបង្អស់របស់ប៉ុល-ពតម្នាក់ឈ្មោះឡុត-សារឿន ត្រូវគេបង្ខំឲ្យទៅធ្វើជាស្នំហ្លួងមុនីវង្សនៅនឹងដំណាក់អ្នករាំងនោះ ។*

ពេលបានទៅរៀននៅស្រុកបារាំង ប៉ុល-ពតក៏ចូលចិត្តស្រឡាញ់ងប់ងល់នឹងទ្រឹស្ដីកុម្មុយនិស្ត ហើយបានចូលរួមជាមួយបក្សកុម្មុយនិស្តហូ-ជីមិញតាំងពីឆ្នាំ១៩៤៩នោះមក ។ ពេលជននេះបានវិលត្រឡប់មកស្រុកខ្មែរវិញនាដើមឆ្នាំ១៩៥៣ នោះក៏នៅតែបន្តការទាក់ទងជាមួយបក្សកុម្មុយនិស្តយួនដដែល ដោយបានទៅចូលរួមក្នុងមូលដ្ឋានតំបន់កំពត ត្រាច ត្រួតត្រាដឹកនាំដោយអាចារ្យមៀន ឬសឺង-ង៉ុកមិញ គឺនៅចុងសង្គ្រាមឥណ្ឌូចិនលើកទី១ ដែលជិតតែនឹងចប់ទៅហើយនោះ ។ តាំងពីក្រោយការសំរេចរបស់សន្និសិទហ្សឺណែវឆ្នាំ១៩៥៤មក ដោយមានមេដឹកនាំហាណូយជួយចាត់ចែងសំរួលឲ្យ ប៉ុល-ពតបានធ្វើដំណើរទៅស្រុកចិនប៉េកាំងតាមរយៈយន្ត-ហោះហាណូយយ៉ាងស្ងាត់ៗជាច្រើនដង ។ តាំងតែពីបានជួបសន្ទនាជាមួយម៉ៅ-សេទុងមក ជននេះមានការកោតសរសើរនូវទ្រឹស្ដីរើរវាយរបស់លោកប្រធានម៉ៅដ៏មហិមារបស់ចិនជាខ្លាំង ជាពិសេសទ្រឹស្ដីចែងពី«មហាលោតផ្លោះ-មហាអស្ចារ្យ» និងទ្រឹស្ដីចែងពី «ការធ្វើបដិវត្តន៍វប្បធម៌រំលាយសង្គមចាស់សក្តិភូមិ» ចោល ។ ជននេះក៏ចាប់មានមហិច្ឆិតាលោភលន់និងមានបំណងតាំងខ្លួនឲ្យក្លាយទៅជាមេដឹកនាំខ្មែរដ៏មហាភ្លឺស្វាងមហាអស្ចារ្យម្នាក់ក្នុងការតស៊ូវណ្ណៈ កសាងរបបកុម្មុយនិស្តក្នុងស្រុកខ្មែរ ឲ្យបានដូចជាឡេនីន ឬម៉ៅ-សេទុង ឬក៏ហូ-ជីមិញឲ្យទាល់តែបាន ។ ហេតុនេះហើយទើបជននេះបានអប់រំខ្លួនគេឲ្យមានបេះដូងថ្ម ចិត្តរឹងដូចដែក សាហាវដូចខ្លាត្រូវរបួស ចំពោះអ្វីដែលមកពាំង មករាំងនូវគោលបំណងដ៏ធំធេងរបស់គេនោះ ជននេះត្រូវតែកំទេចចោលទាំងអស់ ។ ដោយសារចិត្តមានៈប្តូរផ្តាច់បែបយ៉ាងនេះហើយ ជននេះក៏បានក្លាយមកជាមនុស្សគ្មានមនោសញ្ចេតនា ជាពិសេសរវាងប្ដីប្រពន្ធ ដែលធ្វើឲ្យអ្នកគ្រូខៀវ-ប៉ុណ្ណារីក្លាយជាឆ្កួតវក់ក្នុងឆ្នាំ១៩៧៨ ហើយប៉ុល-ពតក៏យកប្រពន្ធមួយទៀតទៅ ។

ដើម្បីធ្វើសង្គមឲ្យបានជឿនលឿនក្លាយជាសង្គមនិយមពិតប្រាកដនោះ គេត្រូវតែធ្វើបដិវត្តមួយឲ្យខ្លាំងក្លា ពោលគឺត្រូវតែកំទេចឲ្យអស់ពួកសក្តិភូមិ វណ្ណៈអ្នកដឹកនាំជំនាន់របបចាស់ អ្នកទីក្រុង នាយទុន ជាពិសេសត្រូវសម្លាប់អ្នកចេះដឹងចោលមុនឲ្យអស់សិន ព្រោះតាមឱវាទរបស់ម៉ៅ-សេទុងថា ៖ បើទុកពួកអស់នេះឲ្យនៅរស់ ពួកនេះដែលចេះពិចារណារកហេតុផលច្រើន និងបង្កើតឲ្យមានគំនិត «សេរីនិយម» ប្រឆាំងតបជាមួយគំនិតសង្គមនិយមកុម្មុយនិស្តវិញជាមិនខាន ។ ឯគ្រឹះវប្បធម៌ជំ-នឿសាសនា សិល្បៈក្នុងរបបចាស់ ក៏ត្រូវតែបំផ្លាញចោលទាំងអស់ដែរ បើពុំនោះទេការធ្វើបដិវត្តន៍ឈានផ្លោះទៅរកសង្គមនិយមពិតប្រាកដនោះ នឹងមិនបានសំរេចជោគជ័យដល់គោលដៅសោះឡើយ ។ នេះហើយជាជំនឿផ្តាច់មុខរបស់បនប៉ុល-ពត ហើយជាបំណងរបស់មេដឹកនាំចិនដែរ ក្នុងការយកស្រុកខ្មែរធ្វើការពិសោធន៍ នូវ

ទ្រឹស្តីរបស់លោកប្រធានម៉ៅឌឹមហិមារបស់គេ ថាតើទ្រឹស្តីនោះអាចទទួលជោគជ័យឬទេ ? ។

ឯចំណែកមេដឹកនាំយួនវិញ បានយល់និងដឹងពីគំនិតរើរវាយរបស់លោកប្រធានម៉ៅឌឹមហិមាច្បាស់លាស់ណាស់ និងដឹងអំពីគោលបំណងរបស់ចិនប្រុងយកវៀតណាមដូចជាចិនបានរំលាយយកប្រទេសទីបេក្នុងឆ្នាំ១៩៥៩ដែរ ព្រោះយួនធ្លាប់បានភ្លក្សមេរៀនជូរចត់ក្រោមការត្រួតត្រារបស់អធិរាជចិនអស់ដប់មួយសតវត្សមកហើយ ។ មេដឹកនាំយួនបានស្តាប់គំនិតមេដឹកនាំចិនច្បាស់ណាស់ ។ គំនិតម៉ៅវាស៊ីគ្នា ត្រូវស្របគ្នានឹងគោលបំណងរបស់យួន ដែលគ្រោងយកស្រុកខ្មែរឲ្យបានក្នុងអនាគត ដើម្បីឲ្យប្រជារាស្ត្រយួនជាងហុកសិបលាននាក់អាចរស់បានស្រួល ។

គ្រោងការណ៍ទី១ដែលយួនខាងជើងបានអនុវត្តគឺ យកពួកខ្មែរវៀតមិញមកដាក់ឲ្យដឹកនាំប្រទេសខ្មែរបាំងមុខអន្តរជាតិមួយរយៈសិន រួចហើយសឹមធ្វើវៀតណាមូបនិយកម្មសន្សឹមៗ ដើម្បីទាញយកស្រុកខ្មែរធ្វើជារដ្ឋមួយក្នុងសហព័ន្ធឥណ្ឌូចិនដែលមានយួនជាមេដឹកនាំ ។ តែគ្រោងការណ៍នេះបានត្រូវប៉ុល-ពតដឹងជាមុន ហើយកំទេចចោលតាំងពីឆ្នាំ១៩៧២ គឺតាំងពីពេលសាឡុត-សរបានបំពុលសម្លាប់សឹងង៉ុកមិញម្ល៉េះ ។ ការកំទេចផែនការយួននេះ បានធ្វើជាបន្តបន្ទាប់មកទៀតរហូតដល់ឆ្នាំ១៩៧៤ ដូចជាការចាប់សម្លាប់ពួកពាយ័ព្យទិសក្រុមមូល-សម្បត្តិ នៅថ្ងៃទី១៨មិថុនា១៩៧៤ជាដើម ។

ផែនការទី១បានខូចអាសារបង់អស់ហើយ ដោយសារស្នាដៃប៉ុល-ពត ។ ហេតុនេះមេដឹកនាំយួនរង់ចាំមើលផែនការទី២ ដែលយួនបានធ្វើសម្របទៅនឹង «ទ្រឹស្តីម៉ៅ» គឺបំផុសបំផុលផ្ទៃក្នុងស្នូលដឹកនាំខ្មែរក្រហម ធ្វើឲ្យប៉ុល-ពតឆ្កួតវក់វីសម្លាប់លែងសំចៃដៃ សូម្បីតែសង្ស័យក៏ត្រូវតែយកទៅសម្លាប់ចោលដែរ និងរួមសម្លាប់ទាំងខ្មែរ១៧មេសា ឲ្យផុតពូជពួកសំណល់សង្គមចាស់តែម្តងក្នុងរវាងឆ្នាំ១៩៧៧ ។ ប៉ុល-ពតក៏ធ្លាក់ចូលទៅក្នុងអន្ទាក់ទី២របស់មេដឹកនាំយួន ដែលដេករិះគិតតែមធ្យោបាយយលស្រុកខ្មែរតាំងពីសម័យសីហនុមកម្ល៉េះ ។

ដោយឃើញខ្មែរងាកទៅរកចិន, សត្រូវយួន, យ៉ាងប្តូរផ្តាច់ មេដឹកនាំយួនក៏ទាក់ទងរុស្ស៊ីរកជំនួយយ៉ាងសន្ធឹកសន្ធាប់មកវាយខ្មែរប៉ុល-ពត ឲ្យខ្មែរព្រមចូលរួមធ្វើជាសហព័ន្ធ តាមគំនិតបក្សអន្តរជាតិ (ស្របតាមគំនិតយួន) ដែលឲ្យយួនបង្កើតចលនា «កុម្មុយនិស្តឥណ្ឌូចិន»ឡើងនៅឆ្នាំ១៩៣០ នាក្រុងហុងកុង ។ កាលនោះនៅមិនទាន់មានខ្មែរនិងលាវជាសមាជិកបក្សរបស់កុម្មុយនិស្តឥណ្ឌូចិននៅឡើយទេ ។

ការលាងសំអាតជំរះសង្គមាដោយអនុវត្តវិធីសម្លាប់រង្គាលប្រជារាស្ត្រខ្មែរ តាមទ្រឹស្តីរើរវាយរបស់លោកប្រធានម៉ៅឌឹមហិមានោះ គឺប៉ុល-ពតបានដើរចូលទៅក្នុង

អន្ទាក់ទី២របស់មេដឹកនាំយួន ដែលរង់ចាំឱកាសល្អនេះជាយូរមកហើយ ។ ស្រប ពេលនឹងសេចក្ដីអំពាវនាវរបស់លោកព្រឹទ្ធិសភាអាមេរិកាំង George McGovern បានសុំឲ្យគ្រប់ប្រទេសទាំងអស់ (ឆ្នាំ១៩៧៨) ដែលស្រឡាញ់សេរីភាពនិងយុត្តិធម៌ ឲ្យបញ្ជូនកងទ័ពទៅវាយរំលំរដ្ឋាភិបាលខ្មែរក្រហមនោះ មេដឹកនាំយួនក៏យកលេស នេះឯងលើកទ័ពគគ្រឹកគគ្រេង វាយលុកចូលស្រុកខ្មែរ ដោយប្រើរថក្រោះបាញ់មិន ឆេះរបស់រុស្ស៊ីនាំមុខ ដោយផ្សាយប្រាប់ពិភពលោកទាំងមូលថា « វៀតណាមចូល មករំដោះប្រជាជនខ្មែរពីស្ថាននរកលោកិយនៃរបបកាប់សម្លាប់សាសន៍ឯង អនុវត្ត ដោយបនប៉ុល-ពត » ។

តើវៀតណាមបានជួយរំដោះខ្មែរពីក្រុមឃាតករប៉ុល-ពតមែនឬ ?

មេដឹកនាំយួនឆ្លាតណាស់ក្នុងការផ្សព្វផ្សាយប្រាប់ពិភពលោកនេះ ដើម្បីលាក់ បាំងនូវផែនការឧក្រិដ្ឋនិងគំនិតអាក្រក់របស់យួនក្នុងការលេបប្រទេសខ្មែរ រួមបញ្ចូលធ្វើសហព័ន្ធឥណ្ឌូចិន តាមបណ្ដាំរបស់ហូ-ជីមិញ ។ មេដឹកនាំយួនប្រើវិធីរារាំងជានិច្ចនូវគ្រប់សន្និសិទអន្តរជាតិនានា ដែលលើកឡើងនូវការស្វែងរកសន្តិភាពដល់ ប្រទេសខ្មែរនិងប្រជារាស្ត្រខ្មែរ និងប្រើវិធីពន្យាពេលឲ្យវែងអន្លាយ ដើម្បីរៀបចំជា បណ្ដើរ នូវផែនការ «វៀតណាមូបនិយកម្ម» រហូតមតិពិភពលោកនិងរាស្ត្រខ្មែរទាំង អស់ សុខចិត្តទទួលយកនូវសភាពបែបសព្វថ្ងៃ នៃការឈ្លានពានរបស់វៀតណាម Status quo ដោយប្រើភាសានយោបាយបណ្ដើរៗថា « នយោបាយរបស់ប្រទេស ឥណ្ឌូចិនទាំងបីជាដើម » គឺក្នុងគោលដៅធ្វើសហព័ន្ធឥណ្ឌូចិននោះតែម្ដង ។

ប៉ុល-ពតនិងបក្សពួក ( អៀង-សារី, តាម៉ុក, នួន-ជា, សុន-សេន ) ជាអ្នកដៃ ដល់ ទោះជាមិនចំពោះក៏ដោយ ( Indirectly ), ឯមេដឹកនាំវៀតណាមជាអ្នកគ្រោង គំនិតរៀបចំផែនការ ខ្ញីដៃខ្មែរដើម្បីសម្លាប់បំផុតពូជសាសន៍ខ្មែរ តែម្ដង ។

ប៉ុល-ពតនិងបក្សពួក ( អៀង-សារី, តាម៉ុក, នួន-ជា, សុន-សេន ) ជាអ្នកដៃ ដល់ ទោះជាមិនចំពោះក៏ដោយ ( Indirectly ), ឯមេដឹកនាំវៀតណាមជាអ្នកគ្រោង គំនិតរៀបចំផែនការ ខ្ញីដៃខ្មែរដើម្បីសម្លាប់បំផុតពូជសាសន៍ខ្មែរ តែម្ដង ។ គំនិតការ អនុវត្តន៍សម្លាប់រង្គាលរបស់បនប៉ុល-ពត ដូចជាបានទទួលនូវប្រព័ន្ធទូរបញ្ជា ( Remote control's system ) ពីមេដឹកនាំក្រុងហាណូយអីចឹង ។ បើយួនមកជួយខ្មែរ ហេតុអ្វីក៏ចាំបាច់រង់ចាំរហូតប៉ុល-ពតអនុវត្តផែនការសម្លាប់រង្គាលរាស្ត្រខ្មែររំលាយ សង្គមខ្មែរខ្ទេចខ្ទី ទើបជាបានធ្វើជាមកជួយរំលាយបន្ថែមកុំឲ្យសល់ដានទៀត ?

សម្ដេចសីហនុជាអ្នករុញប្រជារាស្ត្រខ្មែរតាំងអស់ទៅចូលក្នុងរណ្ដៅមរណៈរប ស់ប៉ុល-ពត ដោយស្រែកបំពងអំពាវនាវពីក្រុងប៉េកាំង មកឲ្យកូនចៅទាំងអស់របស់ឪនាំគ្នារត់ចូលព្រៃ វាយកំចាត់ចក្រពត្តិអាមេរិកាំងនិងបរិវារក្បត់លន់-នល់, សិរិ-

មត: ទោះបីក្រោយបីយល់ស្គាល់យ៉ាងច្បាស់នូវគំនិតបនប៉ុល-ពត បន្ទាប់ពីសម្តេចសីហនុបានចូលទៅទស្សនាស្រុកខ្មែរក្នុងតំបន់រំដោះឆ្នាំ១៩៧៣ហើយក៏ដោយ ក៏សម្តេចសីហនុមិនបានឈប់ស្រែកអំពាវនាវបែបដដែលៗនេះ រុញរាស្ត្រខ្មែរទៅឲ្យប៉ុល-ពតវាយក្បាលនឹងត្បូងចប អារកសម្លាប់នឹងផាងត្នោតថែមទៀតឡើយ ។

កំហុសជាន់លើកំហុស ( ជួយយួនហាណូយ រួចចូលជាមួយខ្មែរក្រហមទៀត) សម្តេចសីហនុគ្មានបានដោះស្រាយបញ្ហាខ្មែរណាមួយ ក្រៅតែពីបង្កើតបញ្ហាថែមឡើងឡើយ ។ សីហនុជាអ្នកចិញ្ចឹមបំប៉នកម្លាំងខ្លាទាំងពីរឲ្យធំធាត់ ឆាប់ទំពារលេបជីវិតរាស្ត្រខ្មែរនិងស្រុកខ្មែរ ដោយសារតែកំហឹងចង់សងសឹកពួកបនលន់នល់-សិរិមត:តែប៉ុណ្ណោះ ។

តើប្រទេសខ្មែរនឹងត្រូវក្លាយជាចំប៉ាទី២ ក្នុងអនាគតឆាប់ៗខាងមុខនេះឬ ? តើកងទ័ពវៀតណាមនឹងចាកចេញពីស្រុកខ្មែរដោយស្រួលៗឬ ? ។

ហេតុការណ៍ទាំងអស់នេះគ្មានអ្នកណាអាចទស្សន៍ទាយត្រូវទាំងអស់បានឡើយ ! តើមេដឹកនាំយួនប្រើយុទ្ធវិធីបែបណាក្នុងការរំលាយប្រទេសខ្មែរនេះ ?

១- មេដឹកនាំយួនប្រើផែនការ «ពន្យាពេល» ឲ្យយូរ ធ្វើឲ្យមតិពិភពលោកធុញទ្រាន់ រហូតទាល់តែខ្មែរនៅក្នុងប្រទេសបាក់ផ្លត់គំនិតជោគជាំ អាចរស់នៅរួមគ្នាជាមួយយួន ក្រោមការត្រួតត្រារបស់យួន ហើយសុខចិត្តទទួលយកសញ្ជាតិជាជនជាតិឥណ្ឌូចិន ។

២- បញ្ចូលនិគមយួនឲ្យមកតាំងទីលំនៅជាងបីលាននាក់ហើយ លើតំបន់ដីមានជីរជាតិ តាមមាត់ទន្លេមេគង្គ នៅតំបន់សំបូរត្រី បឹងទន្លេសាប ហើយបង្ខំឲ្យរបបអាយ៉ងហេងសំរិន-ហ៊ុនសែន ព្រមទទួលស្គាល់ពួកនិគមយួនទាំងនោះថា ជាជាតិកម្ពុជា ក្នុងគោលដៅយកឈ្នះប្រសិនបើមានការបោះឆ្នោតនៅកម្ពុជា ដើម្បីរក្សារបបអាយ៉ងនេះឲ្យមានជីវិតរស់រហូតទៅ ។ ព្រោះបើរបបអាយ៉ងនេះរស់ ការចុះហត្ថលេខាទាំងអម្បាលមាណរបស់ហេង-សំរិន ក្នុងសន្ធិសញ្ញាប្រគល់ទឹកដីទៅឲ្យយួន នោះចាត់ទុកជាបានការ ហើយខ្មែរនឹងត្រូវបាត់បង់ទឹកដីក្នុងអនាគតនេះ បើគ្មានការប្រុងប្រៀបរៀបចំជើងព្រួលនយោបាយឲ្យបានដិតដល់ទេនោះ ។

ចំពោះនិគមយួនជិតពីរលាននាក់នេះ តើគណកម្មការអន្តរជាតិអាចចាត់វិធានការក្តៅបង្ខំឲ្យចាកចេញបីដែនដីខ្មែរកើតឬទេ ? កងទ័ពយួនដែលចាកចេញទៅនោះគឺគ្រាន់តែបកខោអាវទាហានចោល រួចស្លៀកពាក់ខោអាវស៊ីវិលត្រឡប់មករស់នៅក្នុងចំណោមនិគមយួនវិញតែប៉ុណ្ណោះ ។

៣- មេដឹកនាំយួនមានបំណងជំរុញបង្កាត់ពូជខ្មែរ-យួន ឲ្យមានកូនកាត់យួន-ខ្មែរកាន់តែច្រើន ចេះនិយាយភាសាខ្មែរ តែមានចិត្តគំនិតស្រឡាញ់ជាតិយួនជាង ។

នេះជាវិធីរំលាយជាតិខ្មែរដោយប្រើរយៈពេលវែង ហើយដែលយួនបានយកមកប្រើបានសំរេចជោគជ័យរួចហើយនៅចំប៉ា និងថ្មីៗនេះនៅកម្ពុជាក្រោម ។

ផែនការយុទ្ធបនិយកម្មនេះអាចសំរេចទៅបាន អាស្រ័យទៅលើស្ថានការណ៍វិវត្តន៍នៃប្រវត្តិសាស្ត្រពិភពលោកផង តែជាពិសេសនោះអាស្រ័យទៅលើស្មារតីប្រជារាស្ត្រខ្មែរគ្រប់ៗរូបតែម្តង ។ តើខ្មែរទាំងអស់សុខចិត្តឲ្យប្រទេសខ្មែរក្លាយទៅជាស្រុកយួនឬទេ ? ។

យួនគ្មានបំណងទាល់តែសោះក្នុងការចាកចេញពីប្រទេសខ្មែរដោយស្រួលៗ គ្មានការគាបសង្កត់ពីអន្តរជាតិ គ្មានការតស៊ូយ៉ាងប្តូរផ្តាច់របស់ខ្មែរក្នុងការវាយបណ្តេញយួនឲ្យចេញពីដែនដីខ្មែរនោះទេ ។ មេដឹកនាំខ្មែរគ្រប់និន្នាការបានយល់រួចអស់ហើយពីពិសោធន៍នយោបាយខុស ខ្វះការពិចារណារបស់គេ ក្នុងអតិតកាលកន្លងមកថ្មីៗនេះ ។

តើផ្លូវណាដែលអាចស្រោចស្រង់នូវការគង់វង់នៃប្រជាជាតិខ្មែរ អរិយធម៌ វប្បធម៌ខ្មែរ សិល្បៈនិងប្រទេសខ្មែរបាន ?

ផ្លូវសំរាប់ខ្មែររស់មានតែមួយគត់ គឺការរួបរួមគ្នាជាធ្លុងមួយ និងការលះបង់ពលិកម្មរបស់មេខ្មែរគ្រប់ៗរូប សំរាប់ប្រទេសនិងរាស្ត្រខ្មែរពិតៗ តែត្រូវប្រើរូបមន្តណាមួយដើម្បីសំរេចនូវគោលការនេះ ?

តើខ្មែរក្រហមអាចផ្លាស់ប្តូរចរិតកាចសាហាវឃោរឃៅ លះបង់គំនិតម៉ៅនិយមរើរវាយ ឈប់សម្លាប់ខ្មែរតទៅទៀតឬទេ ?

បែរមកក្រុមខ្មែរសេរីដែលតាំងខ្លួនថា ស្រឡាញ់សេរីភាព យុត្តិធម៌នោះវិញ គ្មានបន្ទាត់នយោបាយច្បាស់លាស់ កង់ទ័ពទាំងមេទាំងកូនគ្មានវិន័យ ឈ្លោះបាក់បែកគ្នា ប្រព្រឹត្តអំពើពុករលួយ រំលោភសិទ្ធិមនុស្ស... តើពួកគេកំពុងដើរទៅរកអ្វីឲ្យពិតប្រាកដ ? ឬមួយពួកគេនាំគ្នារៀបចំពង្រឹករបបរាជានិយមឡើងវិញទៀត ?

ពួកបនខ្មែរក្រហមបានយកទ្រឹស្តីកុម្មុយនិស្តម៉ៅនិយមមកធ្វើជាឧត្តមគតិ ផ្ទុយទៅវិញពួកមេដឹកនាំវៀតណាមយកទ្រឹស្តីកុម្មុយនិស្ត គ្រាន់តែជាមធ្យោបាយដើម្បីបង្រួបបង្រួមវៀតណាមខាងជើងនិងខាងត្បូង និងដើម្បីពង្រីកទឹកដី បង្កើតជាមហាណាចក្រយួនឥណ្ឌូចិនមួយ ។

ដូចអត្ថបទរបស់លោក Roger Normand បានបញ្ជាក់ពីបំណងនិងយុទ្ធវិធីរបស់ពួកខ្មែរក្រហមស្រាប់ ពួកវានៅតែប្រាថ្នាដណ្តើមអំណាចមកវិញដដែល តែនៅពេលនេះខ្មែរក្រហមមិនទាន់ជាគ្រោះថ្នាក់ដល់កម្ពុជាទេ ក្នុងរយៈវេលាខ្លីខាងមុខនេះ ។

គ្រោះថ្នាក់របស់ប្រទេសខ្មែរនៅពេលនេះ (១៩៩០) គឺវៀតណាមតែម្តង ដែលមានកម្លាំងខ្លាំងជាងបនប៉ុល-ពត ទាំងខាងវិស័យយោធា ទាំងយុទ្ធវិធី ជាពិសេសយុទ្ធវិធីវៀតណាមលើឆាកអន្តរជាតិតែម្តង ។ វៀតណាមបានបំផុសមតិអន្តរជាតិដោយរំលើកយកគ្រោះថ្នាក់របស់ខ្មែរក្រហមមកពាំង បំបិទនូវឧក្រិដ្ឋកម្មនិងបំណងខ្មៅរបស់វៀតណាម ក្នុងការលេបប្រទេសខ្មែរ ។

ដោយយកបនអាយ៉ងហេងសំរិន-ហ៊ុនសែន ឲ្យដើរតួបណ្តោះអាសន្ន ដើម្បីឲ្យមតិពិភពលោកទទួលស្គាល់នូវរបបបន្តុបកញ្ឆេះយួននេះ មេដឹកនាំយួនប្រើយុទ្ធវិធីគ្រប់យ៉ាងដើម្បីពន្យាពេលដោះស្រាយវិបត្តិខ្មែរឲ្យវែងអន្លាយ ទម្លាក់កំហុសទៅលើក្រុមខ្មែរទាំងបួន ថាមិនព្រមជានាគ្នា ( តែមេដឹកនាំយួនផ្តល់វិធីគ្រប់យ៉ាងឲ្យអាយ៉ងភ្នំពេញរកលេសដើម្បីកុំឲ្យមានសន្តិភាពនៅស្រុកខ្មែរ ) ស្របទៅនឹងចិត្តគំនិតមេខ្មែរទាំងនោះផងដែរ ដែលសឹងតែលែងរវល់ពីអាណានិគមយួន ផែនការយួនទូបនិយកម្ម ការឈ្លានពានរបស់យួន បែរមកប្រកាប់ប្រចាក់គ្នាឈ្លោះបង្កើតគណ-បក្សនយោបាយ គ្មានដឹងទិសតំបន់ ក្នុងវេលាដែលស្រុកទាំងមូលកំពុងស្ថិតនៅក្រោមការត្រួតត្រារបស់យួន ។

មួយទៀតឯហ៊ុន-សែនក៏នឹងត្រូវយួនដកដាក់ពួកអតីតខ្មែរវៀតមិញមកជំនួសវិញ ក្នុងអនាគតខ្លីខាងមុខនេះ បើប្រសិនមេដឹកនាំយួនមើលឃើញថា ហ៊ុន-សែនគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រយោជន៍ឲ្យយួនទេនោះ ដូចដែលយួនបានប្តូរដកមេដឹកនាំលាវទ្រង់សុផានុវង្ស ដាក់លាវវៀតមិញកៃសូន-ភុំវិហានដូច្នោះដែរ ។ ការនាំគ្នាបង្កើតគណបក្សនយោបាយក្នុងស្ថានភាពប្រទេសខ្មែរនៅជាកញ្ឆេះយួន គឺខ្មែរទាំងអស់គ្នាកំពុងតែដើរចូលទៅក្នុងកលឧបាយរបស់មេដឹកនាំយួនហើយ ។ មេដឹកនាំយួននឹងប្រើវិធីដដែលៗ គឺបំបែកកម្លាំងឲ្យខ្សោយ «បំបែកដើម្បីត្រួតត្រា » ( **Diviser pour règner** ) ។

មេដឹកនាំយួនធ្វើយ៉ាងណាដើម្បីឲ្យអន្តរជាតិជឿថា «យួនពុំបានលូកដៃក្នុងរឿងផ្ទៃក្នុងខ្មែរទេ គឺពួកខ្មែរគ្នាឯងដែលប្រឈ្លោះដណ្តើមអំណាចគ្នា» ហើយធ្វើឲ្យអន្តរជាតិគេឈឺក្បាល គេលែងរវីរវល់នឹងរឿងខ្មែរតទៅទៀត ។

ជាងដប់ឆ្នាំដែលពិភពលោក ជាពិសេសសហរដ្ឋអាមេរិក បានធ្វើសម្ពាធសេដ្ឋកិច្ចនិងទូតជាមួយវៀតណាម តើក្រុមប្រទេសទាំងអស់នោះមានការខាតបង់គិតជាលុយអស់ប៉ុន្មានកោដិដុល្លារ ? តើគេបានប្រយោជន៍អ្វីតទៅទៀតក្នុងការបន្តធ្វើសម្ពាធទៅលើវៀតណាមនេះ តើប្រទេសខ្មែរមានប្រយោជន៍ប៉ុណ្ណាទៅ ក្នុងការប៉ះប៉ូវសេដ្ឋកិច្ចនៃក្រុមប្រទេសអស់ទាំងនោះ ? ។

មេដឹកនាំយួនបានមើលឃើញក្រឡានេះតាំងពីដំបូងទីមកម្ល៉េះ តែបែរមកមេដឹក

នាំខ្មែរនៅតែមានគំនិតផ្ដេកផ្ដួលលើអន្តរជាតិ១០០ភាគរយ ដោយលែងគិតជួយខ្លួនឯងសោះតែម្ដង គេគិតតែពីធ្វើយ៉ាងណាក្រសោបអំណាចឲ្យបាន ។ នេះហើយជាចំណុចខ្សោយរបស់មេដឹកនាំខ្មែរ ដែលក្លាយទៅជាបំរើនយោបាយខ្មាំងជាតិខ្មែរទៅវិញ ។

សម្ដេចសីហនុមិនបានបោះបង់ចោលពួកខ្មែរក្រហមសោះឡើយ ព្រោះទ្រង់យល់ឃើញថា មានតែយោធាខ្មែរក្រហមទេ ទើបមានលទ្ធភាពអាចវាយកំចាត់កងទ័ពយួនឈ្លានពានចេញពីស្រុកខ្មែរបាន ។ ឯបនខ្មែរក្រហមហ៊ុន-សែន/ហេង-សំរិនវិញ នៅតែត្រូវការកងទ័ពយួនឲ្យតាំងនៅក្នុងស្រុកខ្មែរដដែល ដើម្បីការពាររបបអាយ៉ងនេះឲ្យរស់នៅ ដោយព្រមឲ្យយួនប្រមូលយកភោគសម្បត្តិខ្មែរ ស្រូវ ត្រី ឈើត្បូងរាល់ថ្ងៃ ។

★ ទោះជាខំបដិសេធថា «មិនបំរើយួន» ក៏ដោយ តែការកាប់សម្លាប់រង្គាលប្រជារាស្ត្រខ្មែរជាងបីលាននាក់នោះ តើបនប៉ុល-ពតបានធ្វើការឲ្យនរណា ?

★ ទោះជាខំបដិសេធ «មិនបំរើយួន» ក៏ដោយ តែការអនុញ្ញាតឲ្យកងទ័ពយួនមកតាំងនៅលើដែនដីខ្មែរ ការជួយផ្ដល់អង្ករ ជួយដឹកនាំសាស្ត្រាវុធទៅឲ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ការជួយជញ្ជូនទ័ពយួនដែលចុះកប៉ាល់នៅកំពង់ផែកំពង់សោម ទៅដាក់នៅជាយដែនខ្មែរ-យួន តើនេះឬជាការជួយបញ្ចៀសសង្គ្រាមនៅកម្ពុជាដើម្បី«កម្ពុជាកោះសន្តិភាព» នៅសម័យសម្ដេចសីហនុនោះ ?

★ ទោះជាខំបដិសេធងា «មិនកញ្ជះយួន មិនអាយ៉ងយួន» ក៏ដោយ តែការចុះហត្ថលេខាឲ្យទ័ពយួននៅលើទឹកដីខ្មែរ២៥ឆ្នាំ ចុះហត្ថលេខាលើសន្ធិសញ្ញាកាត់បន្ថយព្រំដែនផ្ដល់ដីទៅយួន តាំងពីព្រំរួមបីប្រទេសរហូតដល់មាត់សមុទ្រ ការធ្វើតាមនូវគ្រប់មធ្យោបាយរបស់យួន ដើម្បីពន្យាពេលកុំឲ្យមានសន្តិភាពនៅកម្ពុជា តើទាំងអស់នេះមិនមែនជាអំពើរបស់ស្ដេចសាមលរាជហេង-សំរិន/ហ៊ុន-សែន កំពុងបំរើយួន ជាអាយ៉ងយួនទេឬ ?

★ ទោជាខំស្រែកបំពងថា «ស្អប់អាចោរយួនឈ្លានពាន»យ៉ាងណាក៏ដោយ តែការខំប្រកាប់ប្រចាក់គ្នាឯងផ្ទៃក្នុងព្រោះតែលុយកាក់ អំណាចនោះ តើពួកក្រុមខ្មែរសេរី ដែលថាស្រឡាញ់សេរីភាពនោះ កំពុងតែធ្វើការបំរើនរណា ? នរណាចំណេញ ? ខ្មែរចំណេញ ឬក៏យួនចំណេញ ?

ក្នុងសង្គ្រាមឥណ្ឌូចិនទាំងបីលើក ប្រទេសដែលចូលរួមក្នុងសង្គ្រាមនេះ គ្មានចំណេញបន្តិចសោះ ឯវៀតណាមវិញចំណេញកប់ក្ដោងទាំងបីលើក យកបានទាំងប្រទេសលាវ បានទាំងប្រទេសខ្មែរថែមទៀត ។

ការអកុសលមួយទៀតគឺខ្មែរគ្មានមេដឹកនាំ ដែលគិតជាតិគិតរាស្ត្រសោះ មានតែមេក្ដោបអំណាចផ្ដាច់ការ ។